ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ការពង្រីកវិសាលភាពនៃការកែច្នៃសំណល់រឹង

# នៅក្នុងក្រុងបាត់ដំបង



ក្រុងបាត់ដំបង

GGGI

# ការពង្រីកវិសាលភាពនៃការកែច្នៃសំណល់រឹង
# នៅក្នុងក្រុងបាត់ដំបង

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះ ត្រូវបានរៀបចំឡើងដោយវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល ( GGGI ) ប្រចាំប្រទេសកម្ពុជា និងសរសេរដោយ ធារ៉ា មីឆែលស៍ ( Terra Michaels ), ជ្យូសែលីន រ៉ាវ៉ាហ្ស ( Josselin Ravaz ) និង ពិសិដ្ឋ សែនសម្រស់ មកពី ហ្គ្រេត ( GRET ) ដោយមានការផ្តល់ធាតុចូល និងការត្រួតពិនិត្យពី ខារ៉ូលីន កាសៃ ឌីស្ស ( Karolien Casaer-Diez ), ជើរ៉ូម ហ្វាគ្រី ( Jerome Fakhry ) និង ដូណូវ៉ាន ស្តូរេយ៍ ( Donovan Storey ) មកពី GGGI ។


រួមគ្នាថែរក្សាបរិស្ថាន
ធ្វើក្រុងឱ្យស្រស់បំព្រង
ធនាគារ ANZ Royal

# អារម្ភកថារបស់អភិបាលក្រុង

ការកែលម្អការគ្រប់គ្រងសំណល់រឹង គឺជាអាទិភាពខ្ពស់មួយសម្រាប់ក្រុងបាត់ដំបង ដូចដែលត្រូវបានដាក់ចេញនៅក្នុងបញ្ជីសកម្មភាពជាអាទិភាព ក្នុងសេចក្តីព្រាងផែនការយុទ្ធសាស្ត្រស្តីពីទីក្រុងប្រកបដោយចីរភាព សម្រាប់ក្រុងចំនួន ៧។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទីក្រុងរបស់យើងសម្រេចបាននូវការរីកចម្រើនធំៗក្នុងការឆ្លើយតបចំពោះបញ្ហាគ្រប់គ្រងសំណល់រឹង និងបានចូលរួមក្នុងគំនិតផ្តួចផ្តើមជាច្រើន ដូចដែលបានសង្ខេបក្នុងរបាយការណ៍នេះ។ បច្ចុប្បន្ននេះ ក្រុងរបស់យើងមានជម្រើសមួយចំនួនសម្រាប់គ្រប់គ្រងសំណល់រឹងដែលអាចយកមកធ្វើការកែច្នៃបាន ដូចជា សំណល់ប្លាស្ទិក និងសំណល់សរីរាង្គជាដើម។ យើងមានមជ្ឈមណ្ឌលញែកសំរាមដើម្បីធ្វើការកែច្នៃសំណល់រឹងឡើងវិញ ដែលទើបតែសាងសង់រួច ត្រៀមនឹងដាក់ឱ្យដំណើរការ ហើយយើងក៏មានគោលបំណងសាងសង់ទីលានចាក់សំរាមថ្មី ដែលប្រសើរជាងមុន ក្នុងឆ្នាំខាងមុខផងដែរ។ ជាការពិត ការរីកចម្រើននៃវិស័យក្រៅប្រព័ន្ធក៏រួមចំណែកយ៉ាងធំធេងដល់ការទាញយកធនធាន ដែលអាចកែច្នៃបានយកមកធ្វើការកែច្នៃនៅក្នុងទីក្រុងនេះផងដែរ។

ទោះជាយ៉ាងណាក្តី ការកែលម្អបន្ថែមទៀតចាំបាច់ត្រូវតែមាន ព្រោះថាការចោលសំរាម និងការដុតសំរាមនៅទីលានដែលចំហ នៅតែកើតមានឡើងក្នុងទ្រង់ទ្រាយធំ រួមទាំងនៅក្នុងទីលានចាក់សំរាមដែលមានស្រាប់នេះផងដែរ។ ផ្អែកតាមសមិទ្ធផលដែលសម្រេចបានកន្លងមក និងដើម្បីបន្តដោះស្រាយបញ្ហានាពេលបច្ចុប្បន្ននេះ រដ្ឋបាលក្រុងស្វាគមន៍ចំពោះការសិក្សា ដែលផ្តោតលើការកែលម្អការកែច្នៃសំណល់នេះ។ ដូចដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍នេះ ដើម្បីឱ្យប្រព័ន្ធគ្រប់គ្រងសំណល់រឹងកាន់តែមានប្រសិទ្ធភាព ការញែកសំណល់រឹងនៅនឹងប្រភពដើម មានសារៈសំខាន់យ៉ាងខ្លាំង។ ការធ្វើបែបនេះ ធ្វើឱ្យគេអាចកែច្នៃសំណល់រឹងក្នុងបរិមាណកាន់តែច្រើនជាងមុន និងអាចញែកសំណល់រឹងដែលអាចយកទៅកែច្នៃបានចេញពីសំណលស្ងួត។ ការដុតសំរាមដោយចំហ និងការចោលសំរាមពាសវាលពាសកាល ត្រូវមានការទប់ស្កាត់ឱ្យបានត្រឹមត្រូវ តាមរយៈការអនុវត្តអនុក្រឹត្យលេខ ១១៣។ គំនិតផ្តួចផ្តើមទាំងនេះ មិនត្រឹមតែជួយឱ្យបរិស្ថាន សុខភាពសាធារណៈ និងសោភណភាពទីក្រុងរបស់យើងកាន់តែមានភាពល្អប្រសើរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតនូវឱកាសសេដ្ឋកិច្ច និងការងារផងដែរ។ ការបង្កើនបរិមាណ និងគុណភាពជីកំប៉ុសក៏ផ្តល់លទ្ធភាពឱ្យកសិកររបស់យើងអាចធ្វើកសិកម្មកាន់តែមានចីរភាព ព្រោះពួកគេអាចកាត់បន្ថយការប្រើប្រាស់ជីគីមីនាំចូលបាន។

ដើម្បីសម្រេចគោលដៅនេះ ប្រជាពលរដ្ឋគ្រប់រូបត្រូវតែចូលរួម។ ដូច្នេះ ការបង្កើនការយល់ដឹង និងការអប់រំ មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីធ្វើយ៉ាងណាឱ្យគ្រប់គ្នាបានយល់ដឹងពីការទទួលខុសត្រូវ និងកាតព្វកិច្ចរបស់ខ្លួន ជាពិសេសពាក់ព័ន្ធនឹងការអនុវត្តតាមអនុក្រឹត្យលេខ ១១៣។ ទិដ្ឋភាពដ៏សំខាន់មួយទៀតនោះ គឺការកាត់បន្ថយបរិមាណសំណល់រឹងឱ្យបាននៅតិចបំផុត។ ពេលដែលប្រទេសកម្ពុជាមានការអភិវឌ្ឍ ហើយប្រាក់ឈ្នួលកំពុងមានការកើនឡើង ការប្រើប្រាស់ក៏កំពុងមានការកើនឡើងផងដែរ។ នេះមានន័យថា មានការបង្កើនសំណល់រឹងកាន់តែច្រើន ឧទាហរណ៍ ដូចជា ពពួកវត្ថុដែលអាចប្រើប្រាស់បានតែ ១ ដងធ្វើពីប្លាស្ទិក និងស្នោជាដើម។ អនុក្រឹត្យលេខ ១៦៨ បញ្ជូនសារអំពីការកាត់បន្ថយការប្រើប្រាស់វត្ថុធ្វើពីប្លាស្ទិកដែលប្រើបានតែ ១ ដង។ ត្រូវមានការរៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយ ដើម្បីលើកទឹកចិត្តឱ្យមានការប្រើប្រាស់ធនធានដ៏មានតម្លៃរបស់យើង ឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។

ខ្ញុំទន្ទឹងរង់ចាំដំណាក់កាលអនុវត្តន៍ និងបន្តចូលរួមសហការជាមួយនឹង ក.ជ.អ.ច ជីជីជីអាយ និងតួអង្គដទៃទៀតក្នុងវិស័យគ្រប់គ្រងសំណល់រឹង។



**លោក ផេង សិទ្ធី**
**អភិបាល ក្រុងបាត់ដំបង**

# អក្សរកាត់

| | |
|---|---|
| **ADB** | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **BPP** | សហគ្រាសប្លាស្ទិកបាត់ដំបង (ឬហៅថា កន្លែងកែច្នៃប្លាស្ទិក) |
| **CINTRI** | ក្រុមហ៊ុន ស៊ីន ទ្រី ខូអិលធីឌីបាត់ដំបង |
| **COMPED** | អង្គការកែច្នៃសំរាម និង ការសិក្សានៅកម្ពុជា (មជ្ឈមណ្ឌលកែច្នៃជីកំប៉ុស) |
| **Et Chay** | អ្នកប្រមូលសំរាមក្រៅផ្លូវការ (អេត ចាយ) |
| **GGGI** | វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (ជីជីជីអាយ) |
| **HDPE** | ប្លាស្ទិកប៉ូលីអេទីឡែនមានដង់ស៊ីតេខ្ពស់ |
| **IGES** | វិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានសកល |
| **Leap Lim** | ក្រុមហ៊ុន លៀប លឹម ផ្តល់សេវាកម្មប្រមូលសំរាមក្នុងក្រុងបាត់ដំបង |
| **MEF** | ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **MOE** | ក្រសួងបរិស្ថាន |
| **MOI** | ក្រសួងមហាផ្ទៃ |
| **MOP** | ក្រសួងផែនការ |
| **MPWT** | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| **MRF** | មជ្ឈមណ្ឌលញែកសំរាម |
| **PDOE** | មន្ទីរបរិស្ថានខេត្ត |
| **PDRD** | មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត |
| **PPE** | ប្លាស្ទិកប៉ូលីផេនីឡែនអេទែរ |
| **RGC** | រាជរដ្ឋាភិបាលកម្ពុជា |
| **SWM** | ការគ្រប់គ្រងសំណល់រឹង |
| **UNIDO** | អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម |

# មាតិកា


សេចក្តីថ្លែងអំណរគុណ ii
អារម្ភកថារបស់អភិបាលក្រុង iv
អក្សរកាត់ vii
មាតិកា vi
អត្ថបទសង្ខេប viii

## ១. សេចក្តីផ្តើម ១

១.១. សាវតារគម្រោង និងគោលបំណង ១
១.១.១. សាវតារគម្រោង ១
១.១.២. គោលបំណង ១
១.២. វិធីសាស្រ្ត ២
១.២. ១. ការប្រជុំ និងការសម្ភាសជាមួយភាគីពាក់ព័ន្ធ ៣
១.២. ២. ការចុះពិនិត្យដល់ទីកន្លែងដើម្បីស្វែងយល់ពីផ្នែកសំរាម ៣
១.២. ៣. ការពិភាក្សាបន្ថែមដើម្បីស្វែងយល់ពីទីផ្សារសំណល់រឹងដែលបានកែច្នៃ ៤
១.២. ៤. សិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ៥
១.៣. ដែនកំណត់ និងឧបសគ្គនៃគម្រោង ៥
១.៣. ១. ទិន្នន័យសេដ្ឋកិច្ច-សង្គម ៥
១.៣. ២. ទិន្នន័យបច្ចេកទេស និងសេដ្ឋកិច្ចពីមជ្ឈមណ្ឌលកែច្នៃសំណល់រឹង ៥

## ២. ការពិនិត្យរបាយការណ៍ដែលធ្លាប់សិក្សា និងការប្រមូលទិន្នន័យ ៧

២.១. ក្រុងបាត់ដំបង ៧
២.២. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ៨
២.៣. គម្រោងផ្សេងៗពាក់ព័ន្ធនឹងសំណល់រឹងក្រុងបាត់ដំបង ១៣
២.៤. ការស្វែងយល់ពីវិស័យគ្រប់គ្រងសំណល់រឹងក្នុងខេត្តបាត់ដំបង ១៨
២.៤.១. អភិបាលកិច្ច ១៨
២.៤.២. ការបង្កើតសំរាម ២២
២.៤.៣. ការទុកដាក់ ប្រមូល និងការញែក ២៦
២.៤.៤. ការកែច្នៃ និងការបោះចោល ៣៥
២.៥. មេរៀនល្អៗពីគម្រោងសំរាមនៅលើពិភពលោក ៤០
២.៦. ការវិភាគភាពខ្លាំង ភាពខ្សោយ ឱកាស កត្តាគំរាមកំហែង និងការផ្តល់អនុសាសន៍ ៤៣
២.៦.១. អភិបាលកិច្ច ៤៣
២.៦.២. ការទុកដាក់ និងការញែក ៤៥
២.៦.៣. ការប្រមូលសំរាម ៤៦

២.៦.៤. កន្លែងកែច្នៃ និងបោះចោល ៤៧
២.៦.៥. ជ្រើសរើសតំបន់ធ្វើយុទ្ធនាការ ៤៨
២.៦.៦. មេរៀនបន្ថែមទៀតដែលបានអនុវត្តទូទាំងប្រទេសស្តីពីការគ្រប់គ្រងសំណល់រឹងក្នុងក្របខណ្ឌវិមជ្ឈការ ៤៩
២.៦.៧. សេចក្តីសន្និដ្ឋាន ៥២

**៣. ការរៀបចំប្រព័ន្ធកែច្នៃសំណល់រឹងក្នុងក្រុងបាត់ដំបង ៥៥**

៣.១. ការបង្កើតប្រព័ន្ធកែច្នៃសំរាមដែលមានប្រសិទ្ធភាព ៥៥
៣.២. អភិបាលកិច្ច ៥៦
៣.៣. ការស្តុកទុក និង ការញែក ៥៩
៣.៤. ការប្រមូល ៦២
៣.៥. យុទ្ធនាការផ្សព្វផ្សាយ ៦៤
៣.៤.១. ដំណាក់កាលទី ១៖ ផ្សារ ៦៤
៣.៤.២. ដំណាក់កាលទី ២៖ សង្កាត់ស្វាយប៉ោ ៧៦
៣.៥. អនុសាសន៍រយៈពេលវែង ៨២

**៤. ការធ្វើឲ្យប្រសើរឡើង អាជីវកម្មកែច្នៃសំណល់រឹងក្នុងក្រុងបាត់ដំបង ៨៩**

៤.១. អង្គការ ខមភីដ (COMPED) ៨៩
៤.៤.១. អនុសាសន៍ ៩៣
៤.៤.២. សេចក្តីសន្និដ្ឋាន ៩៧
៤.២. សហគ្រាសប្លាស្ទិកបាត់ដំបង ៩៨
៤.២. ១. ការវិភាគទីផ្សារ ៩៨
៤.២. ២. អនុសាសន៍ ៩៩
៤.២. ៣. សេចក្តីសន្និដ្ឋាន ១០២
៤.៣. មជ្ឈមណ្ឌលញែកសំរាម ១០២
៤.៣. ១. ជម្រើសទី ១៖ ចាប់ផ្តើមប្រតិបត្តិការឱ្យបានឆាប់រហ័ស ១០២
៤.៣. ២. ជម្រើសទី ២៖ ដើរតួជាស្តង់អេតចាយ ១០៣
៤.៣. ៣. ជម្រើសទី ៣៖ លក់ថង់ប្លាស្ទិកស្អាតសម្រាប់សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង ១០៣
៤.៣. ៤. ជម្រើសទី ៤៖ ការកែច្នៃស្មោ ១០៣
៤.៣. ៥. ជម្រើសទី ៥៖ ដំឡើងទៅជាកន្លែងកែច្នៃមួយកម្រិតទៀត ឬខ្សែសង្វាក់ញែកពេញលេញ ១០៤
ឧបសម្ព័ន្ធ ១ ១០៥

# អត្ថបទសង្ខេប

ក.ជ.អ.ច និង វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល បានធ្វើការងារក្នុងខេត្តបាត់ដំបង និងបានជ្រើសរើសក្រុងផ្សេងៗទៀត ដើម្បីអភិវឌ្ឍផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងប្រកបដោយចីរភាព។ ក្រោមការអនុវត្តកិច្ចការងារនេះ ក្រុងបានកំណត់ចក្ខុវិស័យ និង កំណត់កម្មវត្ថុសម្រាប់ការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព។ គម្រោងអាទិភាពត្រូវបានកំណត់ឡើង។ ក្រុងនីមួយៗបានជ្រើសរើសគម្រោងអភិវឌ្ឍន៍ទីក្រុងប្រកបដោយចីរភាពចំនួន១០។ ការអន្តរាគមន៍មួយក្នុងចំណោមការអន្តរាគមន៍ជាច្រើន ដែលកំណត់អាទិភាពដោយក្រុងបាត់ដំបង គឺពង្រីកវិសាលភាពនៃការកែច្នៃសំណល់រឹងក្នុងក្រុងឲ្យមានទំហំធំជាងមុន។

ដើម្បីគាំទ្រកិច្ចការងារនេះ ក.ជ.អ.ច និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល បានធ្វើការជាមួយក្រុងដើម្បីបង្កើតនូវជម្រើសលម្អិតជាច្រើនក្នុងការបង្កើតខ្សែសង្វាក់ផលិតកម្មដែលអាចទុកចិត្តបានសម្រាប់សំណល់រឹងដែលអាចកែច្នៃឡើងវិញបាន (រួមមាន ការញែក ការប្រមូល ការដឹកជញ្ជូន សំណល់រឹងនិងការលក់ផលិតផលដែលបានកែច្នៃរួច) ដោយផ្ដោតជាចម្បងលើសំណល់ប្លាស្ទិក និងសំណល់សរីរាង្គ។ ក្រោមការគាំទ្រដោយទីប្រឹក្សាហ្គ្រេត ( GRET ) ស្ថាប័នទាំង៣បានបង្កើតនូវជម្រើសផ្សេងៗ ដែលមានលក្ខណៈជាក់លាក់ ដែលអាចធ្វើទៅបានអមជាមួយនឹងការកំណត់តម្លៃជាស្រេច សម្រាប់ការអនុវត្ត។ របាយការណ៍នេះឆ្លុះបញ្ចាំងពីការវិភាគស្ថានភាពគ្រប់គ្រងសំណល់រឹងក្នុងក្រុង និងមានអនុសាសន៍ដែលបានស្នើឡើងជាផ្នែកមួយនៃគម្រោងនេះ ដើម្បីដោះស្រាយបញ្ហាជាក់ស្ដែង។ ក្រោយការបោះពុម្ពផ្សាយរបាយការណ៍នេះ វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល និងក.ជ.អ.ច ព្រមទាំងរដ្ឋបាលក្រុងបាត់ដំបង នឹងធ្វើការរួមគ្នា ក្នុងការអនុវត្តអនុសាសន៍ដែលបានលើកឡើង។

ផ្នែកទីមួយនៃរបាយការណ៍នេះ ផ្តល់ព័ត៌មានទូទៅអំពីគម្រោង ព្រមទាំងវិធីសាស្ត្រ និងបញ្ហាប្រឈមមួយចំនួន។ ផ្នែកទីពីរ ផ្តល់ការវិភាគដែលមានលក្ខណៈទូលំទូលាយអំពីស្ថានភាពបច្ចុប្បន្ន។ ផ្នែកនេះ បង្ហាញទិន្នន័យជាច្រើនអំពីស្ថានភាពសំណល់រឹងក្នុងក្រុងបាត់ដំបង បន្ទាប់មកទិដ្ឋភាពទូទៅនៃបរិបទនៃបទប្បញ្ញត្តិថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ព្រមទាំងទិដ្ឋភាពទូទៅនៃគម្រោងគ្រប់គ្រងសំណល់ផ្សេងៗទៀតដែលមានក្នុងក្រុងបាត់ដំបង។ ផ្នែកនេះ ក៏មានរាប់បញ្ចូលទាំងការដកស្រង់បទពិសោធន៍ថ្នាក់អន្តរជាតិដែលអាចយកជាគំរូបាន និងផ្តល់ការវិភាគលើភាពខ្លាំង ភាពខ្សោយ ឱកាស និងកត្តាគំរាមកំហែងចំពោះការគ្រប់គ្រងសំណល់រឹង ក្នុងក្រុងបាត់ដំបង ដោយមានភ្ជាប់អនុសាសន៍អមជាមួយការវិភាគនេះផងដែរ។ ផ្នែកទីបីនៃរបាយការណ៍នេះ និយាយអំពីវិធីសាស្ត្រដែលអាចអនុវត្តបានជាជំហានៗ សម្រាប់អនុវត្តន៍អនុសាសន៍ដែលដាក់ស្នើឡើង។ បន្ទាប់មក ផ្នែកទីបួន ផ្តល់ព័ត៌មានទូទៅនៃធុរកិច្ចកែច្នៃសំណល់រឹងក្នុងស្រុក និងទិសដៅដែលអាចពង្រឹងការអនុវត្តនេះឲ្យបានជោគជ័យ។ គ្រប់ផ្នែកទាំងអស់ដែលបានរៀបរាប់ខាងលើ មានព័ត៌មានមួយចំនួនដែលត្រូវបានដកចេញដើម្បីរក្សាជាការសម្ងាត់។

ជារួម របាយការណ៍នេះធ្វើឡើងសម្រាប់ ក.ជ.អ.ច និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល ជាមួយដៃគូគម្រោងផ្សេងទៀត យកជាមូលដ្ឋានក្នុងការគាំទ្ររដ្ឋបាលក្រុង និងធុរកិច្ចក្នុងតំបន់ ដើម្បីអនុវត្តតាមអនុសាសន៍ដែលបានលើកឡើង និងដំណើរការសាកល្បងគម្រោងញែកសំណល់រឹង។



# ១. សេចក្តីផ្តើម

## ១.១. សាវតារគម្រោង និងគោលបំណង

### ១. ១.១. សាវតារគម្រោង

ក្នុងរយៈពេលប្រាំឆ្នាំកន្លងទៅនេះ ប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿនបំផុតនៅអាស៊ីអាគ្នេយ៍ ដោយមានកំណើនផលិតផលក្នុងស្រុកសរុប (GDP) ប្រចាំឆ្នាំជាមធ្យម ៧%។ ការកើនឡើងនៃសំណល់រឹង និងបញ្ហាប្រឈមនានាដែលជាប់ទាក់ទងនឹងការគ្រប់គ្រងសំណល់រឹង គឺជាការលំបាកមួយក្នុងចំណោមការលំបាកជាច្រើន ដែលជាលទ្ធផលនៃកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងកំណើននៃការប្រើប្រាស់ជាបន្តបន្ទាប់នេះ។ បរិមាណសំណល់រឹងនៅទីប្រជុំជនបានកើនឡើងយ៉ាងខ្លាំងរហូតដល់ជាង ៤ លានតោនក្នុងមួយឆ្នាំ នៅទូទាំងប្រទេស ដែលប្រហែល ៣៧% ត្រូវបានយកទៅចាក់ចោលនៅទីលានចាក់សំរាម ១២% ត្រូវកែច្នៃឡើងវិញ និង ៥១% ត្រូវបានបោះចោល ឬដុតដោយខុសច្បាប់ បើទោះបីជាមានច្បាប់ហាមឃាត់ក៏ដោយ។ បរិមាណសំរាមដែលចាក់ចោលនៅទីលានចាក់សំរាម បានកើនឡើងជាបន្តបន្ទាប់ពី ៣១៧,៥៥០ តោន/ឆ្នាំ នៅឆ្នាំ២០០៤ ដល់ ១.៥០៣,៧២៣ លានតោន/ឆ្នាំ នៅឆ្នាំ២០១៧ និងកំពុងបន្តកើនឡើង។ ការកើនឡើងយ៉ាងខ្លាំងនៃការចោលសំណល់ រឹងគួបផ្សំនឹងការអនុវត្តការគ្រប់គ្រងសំណល់រឹងមិនបានល្អ (រួមមានការស្តុកទុក ការប្រមូល ដឹកជញ្ជូន និងការចាក់សំរាមនៅទីលានចាក់សំរាម) ព្រមទាំងកង្វះការចូលរួមពីសហគមន៍ បង្កនូវបញ្ហាប្រឈមធ្ងន់ធ្ងរជាច្រើនសម្រាប់ទីក្រុង។

ក្រុងបាត់ដំបង មានប្រជាជនរស់នៅប្រមាណ ១៦០.០០០នាក់ បានប្រឈមនឹងបញ្ហាជាច្រើនរួមមានការចោលសំរាមដោយមិនមានការគ្រប់គ្រងត្រឹមត្រូវ ឬចោលពាសវាលពាសកាល និងការដុត ក៏ដូចជាកង្វះខាតក្នុងការញែក ព្រមទាំងការរៀបចំផែនការប្រមូល។ ជាការកត់សម្គាល់ បរិមាណសំណល់សរីរាង្គយ៉ាងច្រើនត្រូវបានបង្កើតឡើងបានបង្កជាបញ្ហា (មានប្រមាណពី ៥០-៧០% នៃសំរាមទីក្រុង ) និងផ្តល់នូវឱកាសសម្រាប់ការអភិវឌ្ឍផលិតផលពីធនធានដែលទាញយកពីសំរាម។ បន្ថែមពីនេះទៀត ការចោលសំណល់ប្លាស្ទិក (ប្រហែល ១០ % នៃសំណល់ ដោយជាមធ្យមប្រជាជនកម្ពុជារស់នៅទីក្រុងក្នុងប្រទេសកម្ពុជា ប្រើថង់ប្លាស្ទិកប្រមាណ ២.០០០ ថង់ ក្នុងមួយឆ្នាំ ) បង្កជាបញ្ហាសុខភាពសាធារណៈ និងបរិស្ថាន ក៏ប៉ុន្តែវាក៏បានផ្តល់មកវិញនូវសក្តានុពលក្នុងការប្រមូល និងកែច្នៃឡើងវិញផងដែរ។

ខណៈពេលដែលរដ្ឋបាលក្រុងមានប្រតិបត្តិករផ្តល់សេវាកម្មប្រមូលសំរាមពីរ មានការប្រមូលសំរាមក្រៅផ្លូវការ និងកន្លែងកែច្នៃសំណល់រឹងគួរឱ្យកត់សម្គាល់មួយចំនួន ដែលតម្រូវឱ្យមានការរៀបចំ និងបង្កើនប្រសិទ្ធភាពដល់វិស័យទាំងមូល។

### ១.១.២. កម្មវត្ថុ

**កម្មវត្ថុនៃរបាយការណ៍នេះគឺ**

- ដើម្បីផ្តល់អនុសាសន៍សម្រាប់ការបង្កើតប្រព័ន្ធកែច្នៃសំណល់រឹងប្រកបដោយប្រសិទ្ធភាពមួយនៅក្នុងក្រុងបាត់ដំបង
- ដើម្បីរចនាគំរូធុរកិច្ចដែលមានភាពប្រសើរជាងមុនសម្រាប់មជ្ឈមណ្ឌលកែច្នៃសំណល់ដែលមានស្រាប់
- ដើម្បីរចនាការអនុវត្តសាកល្បងការញែកសំណល់រឹងនៅនឹងប្រភព ការប្រមូល និងការដឹកជញ្ជូនសំណល់រឹងដែលអាចកែច្នៃឡើងវិញដែលមានលក្ខណៈទ្រង់ទ្រាយធំ (សម្រាប់ សង្កាត់មួយ)

ខណៈដែលរបាយការណ៍នេះផ្តោតលើការញែកសំណល់រឹងនៅនឹងប្រភព និងការកែច្នៃឡើងវិញ ការកាត់បន្ថយសំណល់រឹងក៏មានសារៈសំខាន់ខ្លាំងដែរក្នុងការធ្វើឱ្យស្ថានភាពសំណល់រឹងនៅទីក្រុងនេះមានភាពប្រសើរឡើង ជាឧទាហរណ៍ ការកាត់បន្ថយ សំរាមទីក្រុង ការប្រើប្រាស់សម្ភារៈប្រើបានតែមួយដង រួមមាន ថង់និងកំប៉ុងប្លាស្ទិក ព្រមទាំងប្រអប់ស្នោ។ ដោយហេតុថារបាយការណ៍នេះមិនបានកំណត់ដំណោះស្រាយនៃជំហានដ៏សំខាន់នេះ ការកាត់បន្ថយសំរាមនឹងត្រូវបានដាក់បញ្ចូលទៅក្នុងដំណាក់កាលអនុវត្តន៍ ជាពិសេសនោះគឺអំឡុងពេលធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹង។

## ១.២. វិធីសាស្ត្រ

វិធីសាស្ត្ររួមសម្រាប់គម្រោងនេះ ត្រូវបានបង្ហាញនៅក្នុងរូបភាពខាងក្រោម។ ក្នុងផ្នែកទី ២៖ វិវេចនាឯកសារដែលមានស្រាប់និងការប្រមូលទិន្នន័យ សមាសធាតុនៃប្រព័ន្ធកែច្នៃសំណល់រឹងនាពេលបច្ចុប្បន្ន ត្រូវបានបង្ហាញចាប់ពីការបង្កើតរហូតដល់ការប្រមូលយកទៅចោលនិង ការកែច្នៃឡើងវិញ បន្ទាប់មកគឺការវិភាគចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងកត្តាគំរាមកំហែង (SWOT) ដើម្បីបង្កើតអនុសាសន៍។ អនុសាសន៍ ជាមួយនឹងផែនការការងារជាក់លាក់ នឹងបានរៀបរាប់លម្អិតបន្ថែមទៀត "ក្នុងផ្នែកទី ៣៖ ការរៀបចំប្រព័ន្ធកែច្នៃសំណល់រឹង ក្នុងក្រុងបាត់ដំបង" ដែលរួមមានទាំងផ្នែកកែច្នៃសំណល់រឹង និងការអនុវត្តសាកល្បងការញែកសំរាម ដោយហេតុថាផ្នែកទាំងពីរនេះមានការពាក់ព័ន្ធ និងបំពេញគ្នាទៅវិញទៅមក។ និយាយជារួម វិធីសាស្ត្រវិភាគធ្វើឡើង ដើម្បីផ្តល់អនុសាសន៍សាមញ្ញ និងតម្លៃសមរម្យ ដែលអាចរៀបចំ និងអនុវត្តន៍ទៅបានក្នុងរយៈពេលខ្លី តែទោះបីជាយ៉ាងនេះក្តីក៏មានផ្នែកមួយ ផ្តោតលើការងាររយៈពេលវែងផងដែរ។

ផ្នែកទី ៤៖ ការធ្វើឱ្យធុរកិច្ចកែច្នៃសំណល់រឹងកាន់តែប្រសើរឡើងក្នុងក្រុងបាត់ដំបង ផ្តល់ការវិភាគធុរកិច្ចអមជាមួយនឹងអនុសាសន៍ម្រាប់ការធ្វើឱ្យប្រសើរឡើងនូវកន្លែងកែច្នៃសំណល់រឹងចំនួនពីរ និងការពិភាក្សាអំពីសកម្មភាពសំខាន់ៗ សម្រាប់មជ្ឈមណ្ឌលញែកសំណល់ថ្មីមួយកន្លែង។ ផ្នែករងជាច្រើនទៀត ផ្តោតលើកន្លែងកែច្នៃសំណល់ពីរកន្លែង (អង្គការ ខមភីដ (COMPED) និងសហគ្រាសផលិតផលប្លាស្ទិកបាត់ដំបង ដែលកែច្នៃថង់ប្លាស្ទិក) រួមមានទាំងការវិភាគផ្នែកហិរញ្ញវត្ថុ ជាមួយនឹងការផ្តល់អនុសាសន៍ពីអ្នកជំនាញការផ្នែកគ្រប់គ្រងសំណល់រឹង រាប់បញ្ចូលទាំងទម្រង់គំនិតសន្និដ្ឋាន និងសេចក្តីលម្អិតទៅតាមផ្នែកនីមួយៗ។

ជាចុងក្រោយ ការចូលរួមរបស់ភាគីពាក់ព័ន្ធគឺជាធាតុមួយដ៏សំខាន់ដើម្បីធានាថាលទ្ធផលដែលទទួលបានសមស្របសម្រាប់វិស័យនេះ និងឆ្លើយតបទៅនឹងតម្រូវការរបស់តួអង្គសំខាន់ៗ។ ផ្នែករងខាងក្រោមនេះពិពណ៌នាពី ការប្រមូលទិន្នន័យ និងការចូលរួមរបស់ភាគីពាក់ព័ន្ធ ដែលបានធ្វើឡើងក្នុងការសម្របសម្រួលការអនុវត្តគម្រោង។

រូបភាពទី ១៖ វិធីសាស្ត្រក្នុងការសិក្សាគម្រោងជារួម



### ១.២.១. ការប្រជុំ និងការសម្ភាសជាមួយភាគីពាក់ព័ន្ធ

ទីប្រឹក្សាបច្ចេកទេស បានធ្វើការប្រជុំ និងធ្វើការសម្ភាសជាច្រើនលើកជាមួយភាគីពាក់ព័ន្ធសំខាន់ៗក្នុងវិស័យគ្រប់គ្រងសំណល់រឹង ដើម្បីស្វែងយល់អំពីប្រព័ន្ធកែច្នៃសំណល់រឹង និងគំរូធុរកិច្ចដែលមានស្រាប់ សមត្ថភាព ព្រមទាំងវិធីសាស្ត្រអនុវត្តរបស់ពួកគេ។ កិច្ចការនេះ រួមមានការស្វែងយល់អំពីខ្សែសង្វាក់ផលិតកម្ម ដូចជាជំហាននៃដំណើរការកែច្នៃផលិតផលពីសំណល់រឹង ការប្រើប្រាស់ផលិតផលដែលបានកែច្នៃឡើងវិញ ឬដែលទាញយកធនធានពីសំណល់រឹងនៅមជ្ឈមណ្ឌលកែច្នៃសំរាម និង តម្រូវការទីផ្សារ។

រូបភាពខាងក្រោមបង្ហាញអំពីភាគីពាក់ព័ន្ធសំខាន់ៗក្នុងវិស័យគ្រប់គ្រង និងប្រមូលសំណល់រឹង ក្នុងក្រុងបាត់ដំបង ដែលផ្នែកទាំងអស់នេះត្រូវបានពិពណ៌នាលម្អិតបន្ថែមទៀតនៅពេលក្រោយក្នុងរបាយការណ៍។ ឧបសម្ព័ន្ធ ១ ផ្តល់នូវបញ្ជីប្រជុំដែលបានធ្វើឡើងក្នុងអំឡុងពេលសិក្សា។

បន្ថែមលើភាគីពាក់ព័ន្ធសំខាន់ៗដែលបានរៀបរាប់ខាងលើ ទីប្រឹក្សាបច្ចេកទេស និងGGGI បានសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយអង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO) ដោយបានផ្តល់ការដំឡើងគ្រឿងបរិក្ខារដល់ទីតាំងកែច្នៃសំណល់រឹង និងបានធ្វើយុទ្ធនាការផ្សព្វផ្សាយនៅក្រុងបាត់ដំបង។ GGGI និង UNIDO បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នានៅខែកុម្ភៈឆ្នាំ២០១៩ ដើម្បីសម្រួលដល់កិច្ចខិតខំប្រឹងប្រែងនេះ។

### ១.២.២. ការចុះពិនិត្យដល់ទីកន្លែងដើម្បីស្វែងយល់ពីផ្នែកសំរាម

ទីប្រឹក្សាបច្ចេកទេសបានកំណត់ក្រុមសំខាន់ៗមួយចំនួនដែលមានសកម្មភាព ឬមានចំណាប់អារម្មណ៍ក្នុងវិស័យគ្រប់គ្រងសំណលរឹងនៅក្នុងក្រុងបាត់ដំបង ហើយបានចុះពិនិត្យដល់ទីកន្លែងចាប់ពីថ្ងៃទី២៩ ខែមករា ដល់ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៩ ។ អង្គការសង្គមស៊ីវិលមួយចំនួនត្រូវបានដាក់បញ្ចូល ដើម្បីស្វែងយល់បន្ថែមអំពីឆន្ទៈរបស់ប្រជាជនទូទៅក្នុងការបែងចែកសំណល់រឹង និងបង់ថ្លៃសេវាកម្មប្រមូលសំរាម។ ឧបសម្ព័ន្ធ ៣ ផ្តល់នូវបញ្ជីលម្អិតនៃភាគីពាក់ព័ន្ធ វិធីសាស្ត្រដែលប្រើប្រាស់ក្នុងការប្រមូលទិន្នន័យ និងចំនួនសំណាកនៃក្រុមនីមួយៗ។

រូបភាពទី ២៖ ភាគីពាក់ព័ន្ធសំខាន់ៗក្នុងវិស័យគ្រប់គ្រង និងប្រមូលសំរាម



### រូបភាពទី ៣៖ ការពិភាក្សាជាក្រុមនិងសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធដើម្បីប្រមូលទិន្នន័យ

| | |
|---|---|
| ស្តង់អេតចាយ (សម្ភាសន៍) → | • ស្តង់ធំមួយដែលនាំចេញទៅប្រទេសជិតខាង<br>• ស្តង់ទំហំមធ្យមមួយ<br>• ស្តង់ទំហំតូចពីរ |
| ផ្សារ (សម្ភាសន៍) → | • ប្រធានផ្សារចំនួន ៥ នាក់<br>• អ្នកប្រមូលសំរាមនៅផ្សារចំនួន ៥នាក់<br>• សេវាប្រមូលសំរាមក្នុងផ្សារជាលក្ខណៈឯកជន |
| អេតចាយ (ពិភាក្សាក្រុម/សម្ភាសន៍) → | • ការពិភាក្សាក្រុមចំនួន ១ ជាមួយនឹងអ្នកប្រមូលសំរាមក្រៅផ្លូវការនៅទីលានចាក់សំរាម<br>• ការសម្ភាសជាមួយអ្នកប្រមូលសំរាមក្រៅផ្លូវការចំនួន ៨នាក់<br>• ការសម្ភាសជាមួយអ្នកប្រមូលសំរាមក្រៅផ្លូវការចំនួន ១០នាក់ |
| ចៅសង្កាត់ (សម្ភាសន៍) → | • ទាំង ១០សង្កាត់ |
| អង្គការសង្គមស៊ីវិលផ្សេងៗ (ពិភាក្សាក្រុម) → | • ប្រជាជនជាស្ត្រីតាមបណ្តាញអង្គការបន្ទាយស្រ្តី<br>• យុវជនចំនួន ៤នាក់ពីបណ្តាញយុវជនខេត្តបាត់ដំបង |
| ការប្រជុំ/សម្ភាសន៍ផ្សេងៗ → | • អង្គការ Bareebo and Kleine Hilfsaktion - កសិដ្ឋានសរីរាង្គក្បែរក្រុង<br>• មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង<br>• Plastic Free ខេត្តបាត់ដំបង |

## ១.២. ៣. ការពិភាក្សាបន្ថែមដើម្បីស្វែងយល់ពីទីផ្សារសំណល់រឹងដែលបានកែច្នៃ

បទសម្ភាសន៍ និងការពិភាក្សាជាច្រើនត្រូវបានធ្វើឡើង ដើម្បីស្វែងយល់អំពីតម្រូវការផលិតផលដែលបានកែច្នៃពីសំណល់រឹង នៅក្រៅក្រុងបាត់ដំបង រួមទាំងតម្រូវការសក្តានុពលនៅកម្ពុជាទាំងគ្រាប់ជ័រប្លាស្ទិក និងផលិតផលប្លាស្ទិកចុងក្រោយ និងការចាប់អារម្មណ៍ចំពោះដីកំប៉ុស។ ការប្រជុំមួយចំនួនត្រូវបានធ្វើឡើងនៅសាលារាជធានីភ្នំពេញ ហើយខ្លះទៀតធ្វើឡើងតាមរយៈអ៊ីម៉ែលនិង/ឬទូរសព្ទ។ បញ្ជីលម្អិតនៃការទំនាក់ទំនង កាលបរិច្ឆេទ និងប្រធានបទត្រូវបានដាក់បញ្ចូលក្នុងឧបសម្ព័ន្ធ ១។

- សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យម (FASMEC) – កំណត់ទីផ្សារអាជីវកម្មកែច្នៃសំណល់រឹង
- ហ្គោហ្គ្រីនខេមបូឌា (GoGreen Cambodia) – កម្មវិធីទូរស័ព្ទដែលបានប្រើប្រាស់ក្នុងរាជធានីភ្នំពេញសម្រាប់ការប្រមូលសំរាម
- សមាគមកសិកម្មសរីរាង្គកម្ពុជា (COrAA)– សក្តានុពលសម្រាប់កសិដ្ឋានសរីរាង្គ
- ខេអេអែស (KAS) – ធ្លាប់បានធ្វើការសិក្សាពីមុនមកលើការញែក និងការប្រមូលសំរាមក្នុងក្រុងបាត់ដំបង
- កាវ៉ាក់ (CAVAC) – គម្រោងផ្នែកកសិកម្មដែលមានបណ្តាញសម្រាប់ការធ្វើកសិដ្ឋានសរីរាង្គ
- អេអាយអឹមអែស (AIMS) – អនុវត្តគម្រោងអភិវឌ្ឍន៍ខ្សែសង្វាក់ផ្គត់ផ្គង់ផ្នែកកសិកម្ម
- ក្រុមហ៊ុនហ្គ្រីនមូវខនសាលធីង ( Green Move Consulting ) – ផ្តល់ព័ត៌មានអំពីការប្រមូលធនធានមកវិញពីសំរាមសម្រាប់សហគ្រាសធុនតូច និងមធ្យម ( SMEs ) ក្នុងក្រុងបាត់ដំបង

### ១.២.៤. សិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ

សិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធត្រូវបានធ្វើឡើង នៅថ្ងៃទី ២ ខែឧសភា ឆ្នាំ២០១៩ ដើម្បីបង្ហាញ និងពិភាក្សាអំពីលទ្ធផលបឋម។ ភាគីពាក់ព័ន្ធសំខាន់ៗទាំងអស់ ក្នុងវិស័យនេះត្រូវបានអញ្ជើញឱ្យចូលរួមក្នុងការពិភាក្សា ហើយអង្គការយូនីដូត្រូវបានអញ្ជើញឱ្យធ្វើបទបង្ហាញពីការងារដែលពួកគាត់កំពុងធ្វើដំណាលគ្នា នៅក្នុងក្រុងបាត់ដំបង។

ទីប្រឹក្សាបច្ចេកទេស បានបង្ហាញពីកម្មវត្ថុរបស់គម្រោង ការរកឃើញសំខាន់ៗ មេរៀនដែលទទួលបានពីគម្រោងគ្រប់គ្រងសំណល់រឹងពីទីក្រុងដទៃទៀតជុំវិញពិភពលោក និងអនុសាសន៍បឋមសម្រាប់កែលម្អការគ្រប់គ្រងសំណល់រឹងនៅក្រុងបាត់ដំបង។ កិច្ចពិភាក្សាមួយ ត្រូវបានរៀបចំឡើង ដើម្បីទទួលបាននូវមតិយោបល់ពីអ្នកចូលរួម ដែលមានបែងចែកជា ៤ក្រុម ៖ ភាគីពាក់ព័ន្ធមកពីស្ថាប័នរដ្ឋាភិបាល ចៅសង្កាត់ ប្រធានគ្រប់គ្រងផ្សារ និងអង្គភាពប្រមូលសំរាម។ ការយល់ដឹងកាន់តែស៊ីជម្រៅ និងអនុសាសន៍ដែលទទួលបានពីសិក្ខាសាលា មានដាក់បញ្ចូលនៅក្នុងរបាយការណ៍នេះទាំងអស់។

## ១.៣. ដែនកំណត់ និងឧបសគ្គនៃគម្រោង

### ១.៣.១. ទិន្នន័យសេដ្ឋកិច្ច-សង្គម

ដើម្បីយល់ឱ្យបានច្បាស់ពីសក្តានុពលនៃការ ចាប់អារម្មណ៍របស់អ្នកប្រើប្រាស់ក្នុងការញែកសំណល់រឹង និងដើម្បីប៉ាន់ប្រមាណ/កំណត់បរិមាណខ្សែសង្វាក់ផលិតកម្មឱ្យបានគ្រប់ជ្រុងជ្រោយ ការស្ទង់មតិលើព័ត៌មានសេដ្ឋកិច្ច-សង្គម និង ឆន្ទៈក្នុងការបង់ប្រាក់ឱ្យបានល្អិតល្អន់ ពិតជាមានភាពចាំបាច់។ ទោះជាយ៉ាងនេះក៏ដោយ ទីប្រឹក្សាបច្ចេកទេស មិនបានធ្វើការស្ទង់មតិសេដ្ឋកិច្ច-សង្គមពេញលេញទេ មានតែការស្ទង់មតិទីផ្សារលើក្រុម ឬអង្គភាពមួយចំនួនដែលបានជ្រើសរើសប៉ុណ្ណោះ។

ទិន្នន័យសេដ្ឋកិច្ច-សង្គមមួយចំនួនត្រូវបានកំណត់នៅក្នុងរបាយការណ៍របស់ស៊ីឌីអាយអេ ( CDIA ) ដែលបានធ្វើកាលពីឆ្នាំ២០១៧ ហើយទីប្រឹក្សាបច្ចេកទេសបានប្រើប្រាស់ទិន្នន័យដើមដែលប្រមូលបានក្នុងកំឡុងឆ្នាំ២០១៧ តាមរយៈការស្ទង់មតិខ្លីមួយ ដើម្បីស្វែងយល់ពីការយល់ឃើញរបស់សាធារណៈជនទៅលើសកម្មភាពផ្សេងៗពាក់ព័ន្ធនឹងទឹកកខ្វក់ និងសំណល់រឹងនៃគម្រោងទន្លេសាប ២ របស់អេឌីប៊ី ( ADB Tonle Sap II )។ ទោះយ៉ាងណាក៏ដោយសំណុំទិន្នន័យទាំងពីរមានលក្ខណៈទូទៅ មិនមានព័ត៌មានគ្រប់គ្រាន់ដើម្បីស្វែងយល់អំពីតម្រូវការ និងឆន្ទៈប្រជាជនឱ្យបានទូលំទូលាយនោះទេ។

ដើម្បីថ្លឹងថ្លែងលើបញ្ហានេះ ទីប្រឹក្សាបច្ចេកទេសបានសម្ភាសន៍ជាមួយអ្នកទិញអេតចាយ (អ្នកប្រមូលសំរាមក្រៅផ្លូវការ) និងអង្គការសង្គមស៊ីវិលមួយចំនួន។ សរុបមក ទិន្នន័យនេះបានផ្តល់នូវការយល់ដឹងជាទូទៅអំពីតម្រូវការ និងកង្វល់របស់អ្នកបង្កើតសំណល់រឹង ឬ សំរាមនៅទូទាំងក្រុង ក៏ប៉ុន្តែ វានៅតែមានចំណុចខ្វះខាតក្នុងការស្វែងយល់ ដូចជាសារ និងឧបករណ៍ដែលល្អបំផុតសម្រាប់ធ្វើទីផ្សារ ឬគំនិតជាក់លាក់ និងច្បាស់លាស់ស្តីពីការជំរុញលើកទឹកចិត្តដល់ការញែកសំណល់រឹងតាមផ្ទះ។

### ១.៣.២. ទិន្នន័យបច្ចេកទេស និងសេដ្ឋកិច្ចពីមជ្ឈមណ្ឌលកែច្នៃសំណល់រឹង

ទីប្រឹក្សាបច្ចេកទេសទទួលបាននូវព័ត៌មានបច្ចេកទេស និងសេដ្ឋកិច្ចស្ទើរទាំងស្រុងតាមរយៈវិធីសាស្ត្រដែលបានរៀបរាប់ខាងលើ ដោយមានការជ្រោមជ្រែងពី GGGI និងពីអាជ្ញាធរមូលដ្ឋាន។ ទោះយ៉ាងណាក៏ដោយទិន្នន័យរសើបមួយចំនួន ដូចជា ព័ត៌មានហិរញ្ញវត្ថុលម្អិតរបស់វិស័យឯកជន (ជាពិសេស សហគ្រាសប្លាស្ទិកបាត់ដំបង (BPP) ក្រុមហ៊ុន ស៊ីន ទ្រី ក្រុមហ៊ុន លៀប លឹម និងអង្គការ ខមភីដ ( COMPED)) រួមមានដូចជា ព័ត៌មានអំពីចំណាយប្រតិបត្តិការ និងចំណាយវិនិយោគសម្រាប់ការទិញវត្ថុធាតុដើម ធនធានមនុស្ស ប្រេងសាំង អគ្គិសនី ទឹក ។ល។

មិនត្រូវបានផ្តល់ជូននោះទេ។ ដូច្នេះ ថ្លៃចំណុចខ្លះ ចាំបាច់ឱ្យយើងធ្វើការសន្មតដោយចៀសពុំរួច។ លើសពីនេះទៀត ព័ត៌មានដែលរសើប និងគំរូធុរកិច្ចសម្រាប់ក្រុមហ៊ុនកែច្នៃសំណល់រឹងនោះ ត្រូវបានលុបចេញពីរបាយការណ៍នេះ ដើម្បីឱ្យរបាយការណ៍នេះអាចចេញផ្សាយបាន។

# ២. វិធីទេចនាឯកសារដែលមានស្រាប់ និងការប្រមូលទិន្នន័យ

## ២.១. ក្រុងបាត់ដំបង

ក្រុងបាត់ដំបង ជាក្រុងធំលំដាប់ទីបីនៅកម្ពុជាដែលមានទីតាំងស្ថិតនៅភាគខាងលិចនៃប្រទេស មានចម្ងាយប្រហែល ១០០ គីឡូម៉ែត្រពីប្រទេសថៃ។ ទីក្រុងនេះមានប្រជាជនរស់នៅប្រមាណ ១៦០.០០០ នាក់ និងមានសង្កាត់ចំនួន ១០។ វិស័យកសិកម្មគ្របដណ្តប់តំបន់ជនបទដែលនៅក្បែរៗក្រុង ថ្វីបើរដ្ឋបាលក្រុងនេះគាំទ្រឱ្យមានកំណើនសណ្ឋាគារ ភោជនីយដ្ឋាន ផ្ទះសំណាក់ និងឧស្សាហកម្ម សិប្បកម្មខ្នាតតូចមួយចំនួន ដែលភាគច្រើនសម្រាប់បម្រើឲ្យវិស័យទេសចរណ៍ក៏ដោយ។

ដូចគ្នានឹងសាលាក្រុងដទៃទៀតនៅក្នុងប្រទេសកម្ពុជាដែរ ក្រុងបាត់ដំបងប្រឈមមុខនឹងបញ្ហាជាច្រើនពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម រួមមានការចោលសំរាមដោយមិនមានការគ្រប់គ្រងត្រឹមត្រូវ និងការដុត ក៏ដូចជាកង្វះខាតក្នុងការរៀបចំ និងការរៀបចំផែនការប្រមូលសំរាម។ រដ្ឋបាលក្រុងបាត់ដំបងទទួលខុសត្រូវក្នុងការគ្រប់គ្រងសេវាកម្មប្រមូលសំរាម ហើយមន្ទីរបរិស្ថានខេត្ត (ក្រោមឱវាទក្រសួងបរិស្ថាន) ទទួលខុសត្រូវចំពោះបទប្បញ្ញត្តិ និងផ្តល់ការណែនាំផ្នែកបច្ចេកទេស។ ច្បាប់ និងបទប្បញ្ញត្តិដែលគ្រប់គ្រងអង្គភាពនីមួយៗ និងការគ្រប់គ្រងសំរាមត្រូវបានពិពណ៌នានៅក្នុងផ្នែករងខាងក្រោម។

រូបភាពទី ៤៖ ផែនទីក្រុងបាត់ដំបង[1]




[1] អាយជីអីអែស (IGES), វិធីសាសន៍វិធីគ្រប់គ្រងសំណល់រឹងដោយមានការចូលរួមសម្រាប់ការកាត់បន្ថយបម្រែបម្រួលអាកាសធាតុ៖ ករណីក្រុងបាត់ដំបង, (ខែមិថុនា ឆ្នាំ២០១៨) ទំព័រទី ២

## ២.២. ច្បាប់ និងបទប្បញ្ញត្តិ

### អនុក្រឹត្យលេខ១១៣ អនក្រ បក ស្តីពីការគ្រប់គ្រងសំណល់រឹងទីប្រជុំជន

អនុក្រឹត្យនេះត្រូវបានអនុម័តកាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ដោយអនុវត្តទៅលើការញែក ទុកដាក់ សម្អាត ប្រមូល ដឹកជញ្ជូន កែច្នៃ និងការគ្រប់គ្រងសំណល់រឹង និងទីលានចាក់សំរាម នៅក្នុងប្រទេសកម្ពុជា។

### តួនាទីរបស់ស្ថាប័ន

ជាសេនាធិការនៃរាជរដ្ឋាភិបាលកម្ពុជា ក្រសួងចំនួន ២ និងរដ្ឋបាលក្រោមឱវាទរបស់ក្រសួងសាមី ទទួលខុសត្រូវលើការងារគ្រប់គ្រងសំណល់រឹង។

### វិធានការគ្រប់គ្រង

- អ្នកបង្កើតសំរាម ត្រូវតែញែក វេចខ្ចប់ ទុកដាក់ និងបញ្ចេញសំរាមរបស់ពួកគេ ហើយត្រូវបង់ថ្លៃសេវាប្រមូលប្រសិនមានការកំណត់។
- ការបោះចោល និងដុតសំរាម នៅតាមដងផ្លូវ ទីសាធារណៈ ទីវាល តាមប្រព័ន្ធលូទឹក ក្នុងប្រព័ន្ធទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជនត្រូវបានហាមឃាត់ដាច់ខាត។
- ប្រធាន ឬម្ចាស់ទីតាំងអាជីវកម្មនានា ត្រូវតែដាក់ធុងសំរាមឱ្យបានគ្រប់គ្រាន់ និងផ្តល់សេវាកម្មចាំបាច់ផ្សេងៗ។
- កំណត់ការផាកពិន័យសម្រាប់ភាគីពាក់ព័ន្ធគ្រប់មជ្ឈដ្ឋាន និងសកម្មភាពដែលមិនអនុលោមតាមការកំណត់នានាដូចមានចែងក្នុងតារាង ១។

រូបភាពទី ៥៖ តួនាទី របស់ស្ថាប័ននៅក្នុងអនុក្រឹត្យលេខ ១១៣[២]

| | | |
|---|---|---|
| **ក្រសួងមហាផ្ទៃ**<br>គាំទ្រទៅដល់ដំណើរការរបស់អង្គភាពគ្រប់គ្រង | រដ្ឋបាលខេត្ត | រៀបចំលិខិតបទដ្ឋានគតិយុត្តដែលចាំបាច់គាំទ្រដល់រដ្ឋបាលក្រុងក្នុងការរៀបចំផែនការសកម្មភាព ផែនការថវិកា និងការបង្កើតសេវាកម្ម អនុម័តលើការជ្រើសរើស និងការប្រើប្រាស់ទីលានចាក់សំរាម |
| | រដ្ឋបាលក្រុង | គ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន ទាំងស្រុងក្នុងតំបន់ដែនសមត្ថកិច្ចរបស់ខ្លួន មានសិទ្ធធ្វើប្រតិភូកម្មមុខងារទៅថ្នាក់ឃុំ និងចែករំលែកសេវាកម្មជាមួយក្រុងដែលនៅជាប់គ្នានឹងវិស័យឯកជន (ដោយមានកិច្ចសន្យាតិចជាង ១០ឆ្នាំ) អាចប្រមូលថ្លៃសេវាសម្រាប់បម្រើដល់ការគ្រប់គ្រងសំណល់រឹងត្រូវផ្តល់ធុងសំរាម និងសេវាកម្មឱ្យបានគ្រប់គ្រងតាមទីកន្លែងសាធារណៈនានា អនុម័តសកម្មភាពកែច្នៃ ឬការប្រើប្រាស់សំរាម |
| **ក្រសួងបរិស្ថាន**<br>រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត មគ្គុទ្ទេសបច្ចេកទេស ផ្តល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់សាលាក្រុង | មន្ទីរខេត្ត | ផ្តល់ការណែនាំផ្នែកបច្ចេកទេសដល់សាលាក្រុងសហការក្នុងការរៀបចំផែនការ និងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងជំរុញការអប់រំដល់ប្រជាជន អនុម័តការជ្រើសរើសនិងការប្រើប្រាស់ទីលាន |

[២] ការបកប្រែភាសាអង់គ្លេសនៅក្នុងឯកសារច្បាប់ខ្មែរ យើញមានប្រើពាក្យ “សំរាម Garbage” ឆ្លាស់គ្នានឹងពាក្យថា “សំណល់រឹង Waste” បាន។

### តារាងទី ១៖ សកម្មភាពល្មើស ឬសកម្មភាពមិនអនុវត្តតាមការកំណត់ និងការពិន័យអន្តរការណ៍

| ល.រ | សកម្មភាពល្មើស ឬសកម្មភាពមិនអនុវត្តតាមការកំណត់ | ការពិន័យអន្តរការណ៍[៣] |
|---|---|---|
| ១ | ការវេញ្ចក និងការវេចខ្ចប់សំរាមមិនបានត្រឹមត្រូវ | ពី ១០.០០០ ទៅ ២០០.០០០ រៀល |
| ២ | យកសំរាមទៅដាក់នៅតាមដងផ្លូវ/ទីសាធារណៈខុសម៉ោងអនុញ្ញាត | ពី ២០.០០០ ទៅ ៤០០.០០០ រៀល |
| ៣ | មិនបង់ថ្លៃប្រមូល ដឹកជញ្ជូន និងទីលានចាក់សំរាម | ទ្វេដងនៃថ្លៃសេវាប្រចាំខែ |
| ៤ | ការបោះចោលសំរាម | ពី ២០.០០០ ទៅ ៤០០.០០០ រៀល |
| ៥ | ការដុតសំរាម | ពី ៥០.០០០ ទៅ ១.០០០.០០០ រៀល |
| ៦ | ការទុកដាក់សំរាមមិនបានត្រឹមត្រូវរបស់ម្ចាស់កម្មវិធីដែលបានបង្កើតនៅក្នុងកម្មវិធីរបស់ខ្លួន | ពី ២០០.០០០ ទៅ ២.០០០.០០០ រៀល |
| ៧ | មិនមានធុងសំរាម និងសេវាចាំបាច់ផ្សេងៗគ្រប់គ្រាន់ក្នុងធុរកិច្ចរបស់ខ្លួន | ៤០០.០០០ រៀល |
| ៨ | ការទុកដាក់ សំរាម ពីសំណល់សំណង់មិនបានត្រឹមត្រូវ | ពី ៤០០.០០០ ទៅ ៨០០.០០០ រៀល |
| ៩ | ការធ្វើសេវាប្រមូលសំណល់កក់ដោយមិនមានលិខិតអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន | ពី ៤០០.០០០ ទៅ ១.០០០.០០០ រៀល |
| ១០ | ការទុកដាក់ និងវេចខ្ចប់សំណល់រឹង លាយឡំជាមួយនឹងសំណល់គ្រោះថ្នាក់ | ពី ៥០០.០០០ ទៅ ១.០០០.០០០ រៀល |

## ប្រកាសអន្តរក្រសួង លេខ ៨៦៨២ ប្រ.ក ស្តីពីការពិន័យលើការគ្រប់គ្រងសំរាម

ប្រកាសអន្តរក្រសួង លេខ ៨៦៨២ ប្រ.ក ចេញដោយក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៩ ដើម្បីគ្រប់គ្រង និងប្រើប្រាស់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍ ចំពោះបទល្មើសដូចមានចែងក្នុងអនុក្រឹត្យលេខ ១១៣។ ប្រកាសនេះដាក់ចេញនូវយន្តការដើម្បីបែងចែកថវិកាដែលទទួលបានតាមរយៈការពិន័យ។ ប្រកាសនេះ ផ្តល់អំណាចទៅដល់រដ្ឋបាលក្រុង និងស្រុក ដើម្បីបង្កើតក្រុមការងារអន្តរកាលមួយ ដើម្បីចូលរួមអនុវត្តប្រកាសរួមនេះ។

## ដីកាស្តីពីការគ្រប់គ្រងសំណល់រឹង[៤]

ដីកានេះបានចេញផ្សាយកាលពីថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ដោយអភិបាលខេត្តបាត់ដំបង សម្រាប់ខេត្តបាត់ដំបង ដោយមានការគាំទ្រពីខេអេអែស (KAS) ចូលរួមជាមួយមេឃុំ ចៅសង្កាត់ និងមន្ទីរពាក់ព័ន្ធ។ ដីកានេះរួមមាន ២៦ ប្រការ ដោយអនុលោមទៅតាមអនុក្រឹត្យលេខ ១១៣ ប៉ុន្តែមិនមានផែនការសកម្មភាពច្បាស់លាស់នោះទេ។ ដីកានេះបានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- ធ្វើឱ្យក្រុងបាត់ដំបងក្លាយជាក្រុងបៃតង
- ពង្រឹងការអនុវត្តតួនាទី និងភារកិច្ចប្រកបដោយប្រសិទ្ធភាព

[៣] 1 USD = ៤,១០០ រៀល
[៤] ខ្លឹមសារដីកាត្រូវបានផ្តល់ដោយខេអេអែស (KAS)

ក្នុងការគ្រប់គ្រងសំណល់រឹង
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាជនក្នុងការគ្រប់គ្រងសំណល់រឹង
- កំណត់តម្លៃការប្រមូល និងដឹកជញ្ជូនសំរាមប្រកបដោយតម្លាភាព ស្របទៅនឹងស្ថានភាពបច្ចុប្បន្ននៅក្រុងបាត់ដំបង
- អនុវត្តគោលការណ៍ស្រីអ៊ែរ (៣R)៖ កាត់បន្ថយ ប្រើប្រាស់ឡើងវិញ កែច្នៃឡើងវិញ
- អ្នកបង្កើត ឬម្ចាស់សំរាម អាចដាក់ពាក្យសុំការលើកលែងកាតព្វកិច្ចក្នុងការបង្កើតសំរាមក្នុងករណីដែលគាត់អះអាងបានថាគាត់អាចកែច្នៃឡើងវិញបានតាមស្តង់ដារសុវត្ថិភាព និងបរិស្ថានដែលបានត្រួតពិនិត្យ និងបញ្ជាក់ដោយមន្ទីរបរិស្ថានដោយលើកសំណើការលើកលែងនេះជូនសាលាក្រុង។
- ម្ចាស់លំនៅឋានត្រូវតែសហការជាមួយអ្នកផ្តល់សេវាក្នុងការសម្អាតកន្លែងមានសំរាម
- ប្រសិនបើគ្មានផ្លូវចូលទៅដល់ ម្ចាស់លំនៅឋានត្រូវប្រើទីតាំងប្រមូលសាធារណៈណាមួយដើម្បីដាក់សំរាម

### សារាចរអន្តរក្រសួងលេខ ១០៧០ ស្តីពីការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រង សំណល់រឹងទីប្រជុំជន

ចេញដោយក្រសួងបរិស្ថាន និងក្រសួងមហាផ្ទៃ កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ឯកសារនេះបានបញ្ជាក់អំពីតួនាទីរបស់ក្រសួងពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរបរិស្ថានដើម្បីធានានូវការអនុវត្តអនុក្រឹត្យលេខ ១១៣។

#### ថ្នាក់ជាតិ៖

ក្រសួងបរិស្ថាន និងក្រសួងមហាផ្ទៃ ត្រូវសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបង្កើតក្រុមការងារអន្តរក្រសួង ក្នុងការអនុវត្តការធ្វើវិមជ្ឈការនៃការគ្រប់គ្រងសំណល់រឹងទៅថ្នាក់ស្រុក/ក្រុង។ ក្រុមការងារនេះ មានទំនួលខុសត្រូវដូចតទៅ៖

- ផ្សព្វផ្សាយខ្លឹមសារអនុក្រឹត្យ
- រៀបចំបទប្បញ្ញត្តិ និងឯកសារបទដ្ឋានបច្ចេកទេសផ្សេងៗ
- សិក្សា ប្រមូលទិន្នន័យ និងរៀបចំផែនសម្រាប់ការផ្ទេរ និងការអនុវត្តសកម្មភាព
- តាមដាន វាយតម្លៃ និងរៀបចំសិក្ខាសាលាដើម្បីឆ្លុះបញ្ចាំងនូវអ្វីបានធ្វើ និងមេរៀនដែលបានទទួល
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារ និងបញ្ហាប្រឈមនានាជូនដល់រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរាជរដ្ឋាភិបាល។

#### រដ្ឋបាលខេត្ត៖

- ផ្សព្វផ្សាយខ្លឹមសារអនុក្រឹត្យទៅដល់ភាគីពាក់ព័ន្ធ
- ប្រគល់សកម្មភាពគ្រប់គ្រងសំណល់រឹងជូនស្រុកឬក្រុង
- ធ្វើការជាមួយភាគីពាក់ព័ន្ធដើម្បីពិនិត្យកែសម្រួលកិច្ចសន្យា
- ណែនាំ សម្របសម្រួល និងជួយជំរុញក្រុងឬស្រុកក្នុងការរៀបចំផែនការ
- ជំរុញ និងគាំទ្រដល់ក្រុង/ស្រុក ដើម្បីពិនិត្យមើលស្ថានភាពទីលានចាក់សំរាមបច្ចុប្បន្ន និងស្វែងរកទីតាំងសម្រាប់ទីលានចាក់សំរាមថ្មី
- តាមដាន និងវាយតម្លៃការអនុវត្តការគ្រប់គ្រងសំណល់រឹង។

#### រដ្ឋបាលស្រុក/ក្រុង

- ផ្សព្វផ្សាយខ្លឹមសារអនុក្រឹត្យទៅដល់ភាគីពាក់ព័ន្ធ
- ពិនិត្យលទ្ធភាពវិមជ្ឈការការគ្រប់គ្រងសំណល់រឹង
- ពិនិត្យកិច្ចសន្យាដែលមានស្រាប់ និងធ្វើការជាមួយភាគីពាក់ព័ន្ធដើម្បីពិនិត្យកែសម្រួលកិច្ចសន្យាតាមការចាំបាច់
- ប្រសិនបើមិនទាន់មានសេវាកម្មគ្រប់គ្រងសំណល់រឹងទេ ចូរធ្វើការរៀបចំ
- សិក្សាពីបច្ចុប្បន្នភាពការគ្រប់គ្រងសំណល់រឹង ដូចជាប្រភេទ និងបរិមាណ សំណល់រឹងដែលបានបង្កើត
- រៀបចំផែនការ និងវិធានការនានា ដើម្បីចូលរួមលើកកម្ពស់ការកាត់បន្ថយបរិមាណសំរាម និងការបោះចោល
- លើកកម្ពស់ការយល់ដឹងរបស់ប្រជាជនលើការញែកសំរាមនៅប្រភព ការវេចខ្ចប់ និងការបោះចោល
- ផ្តល់ធុងសាធារណៈឱ្យបានគ្រប់គ្រាន់ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការប្រមូល និងដឹកជញ្ជូនសំរាម
- ធ្វើការជាមួយអ្នកពាក់ព័ន្ធនានា ដើម្បីពិនិត្យមើលស្ថានភាពទីលានចាក់សំរាមបច្ចុប្បន្ន និងស្វែងរកទីតាំងសម្រាប់ទីលានចាក់សំរាមថ្មី។

#### ឃុំ/សង្កាត់៖

- ផ្សព្វផ្សាយខ្លឹមសារអនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្តិ និងឯកសារបទដ្ឋានបច្ចេកទេសផ្សេងៗទៅដល់ប្រជាជន

និងភាគីពាក់ព័ន្ធ។

- មន្ទីរបរិស្ថានខេត្ត៖
- ផ្សព្វផ្សាយខ្លឹមសារ អនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្តិ និងឯកសារបទដ្ឋានបច្ចេកទេសផ្សេងៗទៅដល់បុគ្គលិកក្រោមឱវាទ
- សហការជាមួយភាគីពាក់ព័ន្ធនានា ដើម្បីផ្សព្វផ្សាយខ្លឹមសារអនុក្រឹត្យលិខិតបទដ្ឋានគតិយុត្តិ និងឯកសារបទដ្ឋានបច្ចេកទេសផ្សេងៗប្រកបដោយប្រសិទ្ធភាពទៅដល់ប្រជាជន និងភាគីពាក់ព័ន្ធ
- ចូលរួមក្នុងការរៀបចំកិច្ចសន្យា
- ចូលរួមក្នុងការត្រួតពិនិត្យកន្លែងចាក់សំរាមបច្ចុប្បន្ន និងលទ្ធភាពនៃការកែច្នៃសំរាម
- ធ្វើការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំផែនការក្នុងការគ្រប់គ្រងសំរាម
- ចូលរួមក្នុងការសិក្សា និងពិគ្រោះយោបល់លើការស្វែងរកទីតាំងទីលានចាក់សំរាមថ្មី
- ធ្វើការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន
- ជំរុញការអនុវត្តអនុក្រឹត្យលេខ ១១៣។

### ប្រកាសលេខ ១៩៥៖ តម្លៃសេវាអតិបរមានៃសំរាមសំណល់រឹងនៅទីប្រជុំជន

បានចេញផ្សាយកាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ដោយក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកាសនេះរួមមាន ៩ មាត្រា សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិធ្វើការកំណត់នូវតម្លៃសេវាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ តម្លៃសេវាបូកបញ្ចូលនូវការសម្អាត ការប្រមូល និងការដឹកជញ្ជូនសំរាមសំណល់រឹងទីប្រជុំជន ក៏ដូចជាទីលានចាក់សំរាម។ គេធ្វើការបែងចែកនូវម្ចាស់សំរាមជា ១៥ប្រភេទ (ពិនិត្យក្នុងតារាង ២) និងបែងចែកទីតាំងជា ៣៖ ភ្នំពេញ ក្រុង និងស្រុក។ តម្លៃសេវាមានកម្រិតខ្ពស់បន្តិចសម្រាប់រាជធានីភ្នំពេញ ខណៈដែលតម្លៃមានកម្រិតទាបនៅថ្នាក់ស្រុក។ កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៩ តម្លៃសេវាប្រមូលសំរាមថ្មី ដោយអនុលោមទៅតាមប្រកាសនេះ ត្រូវបានចេញផ្សាយជាសាធារណៈក្នុងរាជធានីភ្នំពេញ ដោយកំណត់យកកាលបរិច្ឆេទសុពលភាពចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩។

តារាងខាងក្រោមបង្ហាញពីតម្លៃសេវាអតិបរមាសម្រាប់ក្រុង ដែលស៊ីសង្វាក់គ្នានឹងការសិក្សានេះ។

តារាងទី ២៖ តម្លៃសេវាអតិបរមាសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងនៅទីប្រជុំជន

| ល.រ | ប្រភេទនៃម្ចាស់សំរាម | តម្លៃសេវាប្រមូលសំរាមអតិបរមាក្នុងក្រុង(រៀល/ខែ) |
|---|---|---|
| ១ | លំនៅឋាន | ចាប់ពី ៦.៤០០ ទៅ ៥៧.២០០ |
| ២ | ទីតាំងអាជីវកម្ម/ហាង | ចាប់ពី ៥០.៤០០ ទៅ ១១៤.៤០០ |
| ៣ | សណ្ឋាគារ/ផ្ទះសំណាក់ (រាប់ចំនួនបន្ទប់) | ចាប់ពី ៩.៦០០ ទៅ ៣៣.៦០០ |
| ៤ | ទីកម្សាន្ត | ចាប់ពី ២៤២.៨០០ ទៅ ៦.២៦៧.២០០ |
| ៥ | មជ្ឈមណ្ឌលពាណិជ្ជកម្ម/ម៉ាត/ផ្សារ (គិតជា ម²) | ចាប់ពី ១.៦០០ ទៅ ២.៨០០ |
| ៦ | មន្ទីរពេទ្យ/មណ្ឌលសុខភាព/គ្លីនិក (រាប់ចំនួនគ្រែ) | ចាប់ពី ១២.៨០០ ទៅ ១៩.២០០ |
| ៧ | ស្ថាប័នអប់រំឯកជន/មិនមែនរដ្ឋាភិបាល | ចាប់ពី ១៥១.៦០០ ទៅ ១.៣៥៩.២០០ |
| ៨ | ស្ថាប័នអប់រំសាធារណៈ | ៣៤៨.០០០ |

| ល.រ | ប្រភេទនៃម្ចាស់សំរាម | តម្លៃសេវាប្រមូលសំរាមអតិបរមាក្នុងក្រុង(រៀល/ខែ) |
|---|---|---|
| ៩ | ក្រុមហ៊ុនឯកជន | ចាប់ពី ១៤០.០០០ ទៅ ៧៥៩.២០០ |
| ១០ | ស្ថានីយប្រេងឥន្ធនៈ | ចាប់ពី ១៣៣.៦០០ ទៅ ៣២៣.៦០០ |
| ១១ | ទីតាំងស្តុក/ដឹកជញ្ជូនទំនិញ (គិតជា ម២) | ចាប់ពី ៨០០ ទៅ ៤,៤០០ |
| ១២ | ឧស្សាហកម្ម/សិប្បកម្ម | ចាប់ពី ១៩៦.០០០ ទៅ ១.៩៥៨.៤០០ |
| ១៣ | ស្ថានទូត/ស្ថានកុងសុល/អង្គការមិនមែនរដ្ឋាភិបាល | ៣៩២.០០០ |
| ១៤ | ស្ថាប័នសាធារណៈ | ១០៤.០០០ |
| ១៥ | ផ្សេងៗ | ប្រែប្រួល |

### អនុក្រឹត្យលេខ ១៦៨ ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក

បានចេញផ្សាយកាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ អនុក្រឹត្យនេះរួមមាន ៣២មាត្រា ដោយរឹតបន្តឹងលើការនាំចូល ផលិត ចែកចាយ ប្រើប្រាស់ និងការកែច្នៃថង់ប្លាស្ទិកក្នុងប្រទេសកម្ពុជា។ គោលបំណងនៃអនុក្រឹត្យនេះ គឺដើម្បីកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកមានដៃយួរ និងជំរុញការប្រើប្រាស់វត្ថុជំនួសថង់ដែលមិនប៉ះពាល់បរិស្ថាន។ ក្នុងអនុក្រឹត្យនេះដែរ មានកំណត់ឱ្យទិញថង់ប្លាស្ទិកក្នុងផ្សារទំនើប (បើចង់ប្រើវា)។ បន្ថែមពីនេះទៀត ចាប់ពីពេលនេះទៅ ថង់ប្លាស្ទិកក្នុងកំរាស់ណាមួយត្រូវបានហាមឃាត់មិនឱ្យធ្វើការនាំចូល និងផលិត ខណៈដែលការអនុគ្រោះពន្ធនឹងត្រូវបានផ្តល់ជូនសម្រាប់ការនាំចូល និងការផលិតថង់ដែលងាយពុកផុយ។

### តួនាទី របស់ស្ថាប័ន

ក្រៅពីក្រសួងទាំងពីរដែលពាក់ព័ន្ធនឹងសកម្មភាពគ្រប់គ្រងសំរាម (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍ បានចូលរួមក្នុងការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងថង់ប្លាស្ទិកនេះដែរ។

រូបភាពទី ៦៖ តួនាទី របស់ស្ថាប័នក្រោមអនុក្រឹត្យលេខ ១៦៨

| | | | |
|---|---|---|---|
| **ក្រសួងបរិស្ថាន** | ដឹកនាំការរៀបចំគោលនយោបាយយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តិផ្តល់ជំនាញបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិជំរុញការអនុវត្តអនុក្រឹត្យឯកភាពការអនុគ្រោះពន្ធ VAT លើការកែច្នៃ និងការផលិតសម្ភារៈនានាអំពីសំណល់ថង់ប្លាស្ទិក | **មន្ទីរបរិស្ថានខេត្ត** | គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងសំណល់ថង់ប្លាស្ទិក |
| **ក្រសួងមហាផ្ទៃ** | សហការ និងសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ | **រដ្ឋបាលខេត្ត** | គាំទ្រ សម្របសម្រួល និងដឹកនាំក្នុងការអនុវត្តសម្មភាពដែលទាក់ទងនឹងការកាត់បន្ថយថង់ប្លាស្ទិក និងលើកទឹកចិត្តការកែច្នៃ អាចធ្វើប្រតិភូកម្មមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិ |

| | |
|---|---|
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | កំណត់អត្រាការប្រមូលពន្ធ អាករ និងនីតិវិធីចាំបាច់ផ្សេងទៀតដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពកត់ត្រាទិន្នន័យការនាំចូលថង់ប្លាស្ទិកប្រចាំឆ្នាំ ដើម្បីបញ្ជូនមកក្រសួងបរិស្ថានធ្វើការវាយតម្លៃត្រួតពិនិត្យលើការអនុវត្តអាករលើសម្ភារៈវេចខ្ចប់ដែលផលិតពីវត្ថុធាតុងាយពុកផុយត្រួតពិនិត្យលើការអនុវត្តអាករលើការកែច្នៃ និងការផលិតសម្ភារៈនានាអំពីសំណល់ថង់ប្លាស្ទិក |
| ក្រសួងទេសចរណ៍ | បញ្ចូលនូវសូចនាករប្រសិទ្ធភាពទុកដាក់សំណល់ថង់ប្លាស្ទិកក្នុងការវាយតម្លៃសោភណភាពក្រុងស្អាតសម្របសម្រួលក្នុងការលើកកម្ពស់ការអប់រំស្តីពីថង់ប្លាស្ទិក |

### វិធានការគ្រប់គ្រង

- ពលរដ្ឋមានកាតព្វកិច្ចចូលរួមកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក
- អាជីវកម្ម ឬអ្នកផ្តល់សេវាកម្ម ត្រូវបានលើកទឹកចិត្តឱ្យកាត់បន្ថយចំនួនថង់ប្លាស្ទិកដែលផ្តល់ទៅឱ្យអតិថិជន
- ផ្សារទំនើប និងមជ្ឈមណ្ឌលពាណិជ្ជកម្មត្រូវតែគិតថ្លៃលើការប្រើប្រាស់ថង់ប្លាស្ទិក
- ថង់ប្លាស្ទិកដែលនាំចូលត្រូវមានទំហំទៅតាមបទដ្ឋានកំណត់
- ការពិពណ៌នាអំពីការផាកពិន័យចំពោះការល្មើស៖
    - ការចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរ
    - ការផ្អាកអាជីវកម្មជាបណ្តោះអាសន្ន
    - ការផ្អាក និងការដកហូតការអនុញ្ញាតក្នុងការនាំចូល ឬការផលិតក្នុងស្រុក
    - ការពិន័យ

## ២.៣. គម្រោងផ្សេងៗពាក់ព័ន្ធនឹងសំណល់រឹងក្នុងក្រុងបាត់ដំបង

ក្រៅពីគម្រោងនេះ មានតួអង្គជាច្រើនដែលមានគម្រោងពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម ទាំងទើបនឹងរៀបចំថ្មីៗ ទាំងបានរៀបចំហើយ ឬកំពុងដំណើរការនៅក្រុងបាត់ដំបង ឬដែលមានការងារក្នុងការរួមចំណែកដល់សកម្មភាពគ្រប់គ្រងសំណល់រឹងនៅក្នុងក្រុង។

### អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO)

អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO) កំពុងផ្តល់ការគាំទ្រទៅដល់ក្រុមហ៊ុន ស៊ីន ទ្រី, សហគ្រាសប្លាស្ទិកបាត់ដំបង (BPP) អង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា ( COMPED ) ដើម្បីធ្វើឲ្យគ្រឿងបរិក្ខារ និងការញែកសំណល់រឹងនៅនឹងប្រភពរបស់ពួកគេ កាន់តែប្រសើរឡើង។ ទំហំការងារ និងរយៈពេលការងាររបស់ពួកគេមានដូចខាងក្រោម[៩]៖

១. ជួយក្រុមហ៊ុន ស៊ីន ទ្រី និង លៀប លឹម ក្នុងការប្រមូលសំរាមស្ងួតសម្រាប់ញែកនៅមជ្ឈមណ្ឌលញែកសំរាម

ក. រៀបចំ និងអនុវត្តន៍យុទ្ធនាការលើកកម្ពស់ការយល់ដឹងនៅតាមសាលារៀន

- ពីខែមករា ដល់ខែមីនា ឆ្នាំ២០១៩

២. ជួយបំពាក់គ្រឿងបរិក្ខារដល់សហគ្រាសប្លាស្ទិកបាត់ដំបង (BPP) ឱ្យបានប្រសើរជាងមុន ដើម្បីអាចផលិតថង់ប្លាស្ទិក និងប្រភេទប្លាស្ទិកផ្សេងៗទៀតឱ្យកាន់តែមានប្រសិទ្ធភាព

ខ. ផ្តល់ជូននូវឧបករណ៍ចំនួន ៤ គ្រឿងសម្រាប់ខ្សែសង្វាក់ផលិតកម្មថ្មី៖ ម៉ាស៊ីនកិនមួយ ម៉ាស៊ីនលាងមួយ ម៉ាស៊ីនសម្ងួតប្រព័ន្ធគ្រប់គ្រងទឹកកខ្វក់ និងម៉ាស៊ីនបំប្លែងជាគ្រាប់ជ័រ

- ធ្វើលទ្ធកម្មទិញឧបករណ៍ក្នុងខែតុលា ឆ្នាំ២០១៩ ហើយនឹងដំឡើងក្នុងខែមេសា ឆ្នាំ២០២០

[៩] យោងតាមការពិភាក្សា និងការអ៊ីមែលជាច្រើនជាមួយទីប្រឹក្សាបច្ចេកទេស និងបុគ្គលិករបស់ UNIDO ។ ពេលវេលាត្រូវបានគេប៉ាន់ស្មាន និងមិនមានលក្ខណៈរឹងមាំទេ។

៣. ជួយបំពាក់គ្រឿងបរិក្ខារដល់អង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា (COMPED) ឱ្យបានប្រសើរជាងមុន

ក. ផ្ដល់ជូននូវម៉ាស៊ីនចំនួន ៣គ្រឿង៖ ម៉ាស៊ីនកាត់ចិញ្ច្រាំមួយគ្រឿង ម៉ាស៊ីនចូកច្របល់មួយគ្រឿង និងម៉ាស៊ីនរែងមួយគ្រឿង

- ធ្វើលទ្ធកម្មទិញឧបករណ៍ក្នុងខែមេសា ឆ្នាំ២០១៩ ហើយដំឡើងក្នុងខែសីហា ឆ្នាំ២០១៩

ខ. ផ្ដល់ជូននូវការសាងសង់គ្រឹះបេតុង និងដំបូល

- សាងសង់ដើម ឆ្នាំ២០២០

GGGI និង UNIDO បានរៀបចំនូវកិច្ចព្រមព្រៀងសហប្រតិបត្តិការបច្ចេកទេសមួយ សម្រាប់ឱ្យគម្រោងទាំងពីរមានកិច្ចសហការកាន់តែជិតស្និតក្នុងកំឡុងពេលអនុវត្តគម្រោង។

## វិទ្យាស្ថានយុទ្ធសាស្រ្តបរិស្ថានសកល (IGES)

វិទ្យាស្ថានយុទ្ធសាស្រ្តបរិស្ថានសកល(IGES) ដែលធ្លាប់បានធ្វើការជាមួយ អង្គការកែច្នៃសំរាម និង ការសិក្សានៅកម្ពុជា (COMPED) បានអនុវត្តការសាកល្បងការញែក និងការប្រមូលសំរាមនៅខេត្តបាត់ដំបង។ គម្រោងដំបូងបានចាប់ផ្ដើមក្នុងឆ្នាំ២០១១ ជាមួយគំនិតផ្ដួចផ្ដើមក្នុងការគ្រប់គ្រងសំរាមនៅតាមសហគមន៍ ដោយមានគំនិតបើកការរៀបចំផែនការគ្រប់គ្រងសំរាម ការសម្រេចចិត្ត ការអនុវត្ត និងការតាមដានជូនដល់ភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងវិស័យនេះ។ គំនិតផ្ដួចផ្ដើមនេះត្រូវបានពង្រីកនៅក្នុងឆ្នាំ២០១៤ ដែលនាំឱ្យមានការសិក្សាអំពីសារធាតុបំពុលបរិយាកាសដែលមានរយៈពេលខ្លី និងផែនការការងារពាក់ព័ន្ធ ដោយត្រូវបានបញ្ចប់នៅក្នុងឆ្នាំ២០១៧។

ពេញមួយគម្រោងនេះ សិក្ខាសាលាសាធារណៈជាច្រើនត្រូវបានធ្វើឡើង ដើម្បីប្រមូលមតិយោបល់។ មតិយោបល់ដែលបានដាក់ក្នុងរបាយការណ៍នេះ បានបង្ហាញយ៉ាងច្បាស់អំពីការចាប់អារម្មណ៍និងការចូលរួមពីសាធារណជន។ លើសពីនេះទៀត វាស្ដែងឱ្យឃើញថាភាគីពាក់ព័ន្ធសំខាន់ៗទាំងអស់បានចូលរួមនៅក្នុងការរៀបចំផែនការ និងការអនុវត្តការងារ រួមមានទាំងរដ្ឋបាលក្រុង មន្ទីរបរិស្ថានខេត្ត ក្រុមហ៊ុន ស៊ីន ទ្រី អង្គការ ខមភីដ និងសង្កាត់ជាច្រើន។ អនុសាសន៍ដ៏គួរឱ្យចាប់អារម្មណ៍មួយ បានលើកឡើងថាគួរមានការដាក់ធុងសំរាមសរីរាង្គបន្ថែមភ្ជាប់នឹងឡានសំរាមដែលមានស្រាប់ ដើម្បីងាយស្រួលក្នុងការប្រមូល និងញែកសំរាម ទោះបីជាយ៉ាងនេះក្ដី មិនមានភាពច្បាស់លាស់ទេថា តើរឿងនេះបានចាប់ផ្ដើមអនុវត្តហើយឬនៅនោះទេ។ ផែនការការងារក្នុងការគ្រប់គ្រងសំណល់រឹង និងការសាកល្បង ត្រូវបានអនុវត្តដោយមានការសម្របសម្រួលជាមួយក្រុមការងារ[៦]។ ទោះបីយ៉ាងនេះក្ដី យើងសង្កេតឃើញថា ការធ្វើយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈមានរយៈពេលមិនគ្រប់គ្រាន់ឡើយ (ឧទាហរណ៍ការធ្វើតែពីរបីថ្ងៃ ដែលមានរយៈពេលខ្លី)[៧]។ វាក៏ហាក់ដូចជាមិនមានការតាមដាន និងការវាយតម្លៃច្បាស់លាស់ណាមួយ ដើម្បីកំណត់ប្រសិទ្ធភាពនៃយុទ្ធនាការ និងអនុវត្តសមាសភាគនៃគម្រោងផ្សេងទៀតនោះដែរ[៦]។

សមាសភាគមួយនៃគម្រោងនេះ គឺផ្ដោតលើការញែកសំរាមនៅក្នុងផ្សារចំនួន ៣ ប៉ុន្តែវាទទួលបានជោគជ័យតែនៅផ្សារបឹងឈូកប៉ុណ្ណោះ។ សំរាមដែលបានញែក ត្រូវបានគេសម្រេចយកទៅដាក់នៅអង្គការកែច្នៃសំរាម និង ការសិក្សានៅកម្ពុជា (COMPED) ហើយ វិទ្យាស្ថានយុទ្ធសាស្រ្តបរិស្ថានសកល (IGES) បានសម្របសម្រួលក្នុងការចរចាររវាងភាគីខាងផ្សារ និង ក្រុមហ៊ុន ស៊ីន ទ្រី ដើម្បីឱ្យទីផ្សារអាចទទួលបានការបញ្ចុះតម្លៃសម្រាប់ការបង្វែរសំរាមនេះ។ ជាការសន្និដ្ឋាននោះគឺថា ភាគីខាងផ្សារគ្រាន់តែបង់ថ្លៃសេវាទីលានចាក់សំរាម ដែលហេតុនេះបានធ្វើឱ្យពួកគេអាចមានលទ្ធភាពទិញឡានដឹកសំរាមទុកប្រមូលសំរាមដោយខ្លួនឯង។ ទោះជាយ៉ាងនេះក្ដី ដោយហេតុថាថ្លៃសេវាទីលានចាក់សំរាមនៅមានកម្រិតខ្ពស់នៅឡើយ ទើបវាមិនបានផ្ដល់ការលើកទឹកចិត្តក្នុងការញែកសំរាមនោះទេ។

[៦] អាយជីអីអែស/ខមភីដ (IGES/COMPED), *របាយការណ៍ចុងក្រោយស្ដីអំពីផែនការការងារសម្រាប់កាត់បន្ថយកត្តាបំពុលអាកាសជាតុរយៈពេលខ្លី*, (ខែ កុម្ភៈ ឆ្នាំ ២០១៧)។
[៧] យោងតាមការពិភាក្សា និងការអ៊ីមែលជាច្រើនជាមួយទីប្រឹក្សាបច្ចេកទេស និងបុគ្គលិករបស់យូនីដូ។ ពេលវេលាត្រូវបានគេប៉ាន់ស្មាន និងមិនមានលក្ខណៈរឹងមាំទេ។
[៨] UNESCAP/WASTE CONCERN, ឱ្យតម្លៃសំណល់រឹង, វិរូបកម្មទីក្រុង, ឆ្នាំ២០១៥

## ធនាគារពិភពលោក[៧]

នៅខែមិថុនា ឆ្នាំ២០១៩ ធនាគារពិភពលោកបានរៀបចំសិក្ខាសាលាមួយ ដើម្បីបង្ហាញ និងពិភាក្សាអំពីគម្រោងគ្រប់គ្រងសំណល់រឹងដែលខ្លួនគ្រោងនឹងអនុវត្ត។ គម្រោងនេះ រួមមានសមាសភាគផ្នែកច្បាប់ គោលនយោបាយនិងការពង្រឹងសមត្ថភាពថ្នាក់ជាតិ និងការអនុវត្តសាកល្បងនៅក្នុងក្រុងចំនួន ៣។ ធនាគារពិភពលោកពិចារណាក្នុងការជួយដល់ការកែសម្រួលអនុក្រឹត្យលេខ ១១៣ ដើម្បីកែសម្រួលតួនាទី របស់ភាគីពាក់ព័ន្ធ រួមមានប្រព័ន្ធទិន្នន័យគោល និងប្រព័ន្ធរបាយការណ៍ និងកំណត់សំណាកគំរូសំរាម និងនីតិវិធីក្នុងការវិភាគ និងការងារមួយចំនួនទៀត។ គោលនយោបាយថ្មី អាចជួយដោះស្រាយបញ្ហាប្លាស្ទិក ( រាប់បញ្ចូលទាំងលទ្ធភាពហាមប្រាមវត្ថុប្រើប្រាស់តែម្តងហើយបោះចោល ) និងការវេចខ្ចប់សំណល់។ ការកសាងសមត្ថភាព និងគោលការណ៍ណែនាំផ្សេងៗទៀត រួមមានការស្រង់ថ្លៃដើមទម្រង់គំរូសម្រាប់ធ្វើកិច្ចសន្យា ជួយដល់ការត្រួតពិនិត្យ និងការពង្រឹងផ្នែកបរិស្ថាន និងការណែនាំក្នុងការរៀបចំ និងប្រតិបត្តិការរបស់ទីលានចាក់សំរាម។

## គណៈកម្មាធិការសេដ្ឋកិច្ចសង្គមប្រចាំអាស៊ីប៉ាស៊ីហ្វិចរបស់អង្គការសហប្រជាជាតិ ( UNESCAP )[៨]

ក្នុងឆ្នាំ២០១២ យូអិនអេស្កេព ( UNESCAP ) ក្នុងភាពជាដៃគូជាមួយ អង្គការ ខមភីដ ( COMPED ) បានអនុវត្តកម្មវិធីលើកកម្ពស់ការយល់ដឹងស្តីពីការបែងចែកប្រភេទដែលជាផ្នែកមួយនៃកម្មវិធីប្រែក្លាយសំរាមមកជាធនធាន នៃគម្រោងកាត់បន្ថយភាពក្រីក្រ និងការគ្រប់គ្រងសំណល់រឹងប្រកបដោយចីរភាពក្នុងបណ្តាទី រួមខេត្ត និងក្រុងតូចៗក្នុងអាស៊ីប៉ាស៊ីហ្វិក ដែលបានទទួលហិរញ្ញប្បទានពីមូលនិធិប៊ិល និងមេលីនដា ហ្គេតស៍ ( Bill & Melinda Gates) ចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥។ កម្មវិធីលើកកម្ពស់ការយល់ដឹងនេះ ផ្តោតលើផ្សារចំនួន ៣ នៅក្នុងក្រុងបាត់ដំបង គឺផ្សារណាត់/ផ្សារធំ ផ្សារថ្មី និងផ្សារបឹងឈូក។ អ្នកលក់តាមផ្លូវ កម្មករ និងសមាជិកសមាគមក៏ដូចជាគ្រួសារមួយចំនួន ត្រូវបានគេកំណត់គោលដៅក្នុងការញែកសំរាមនៅនឹងប្រភព។

ការអនុវត្តនៅផ្សារបឹងឈូក បានបង្ហាញពីភាពជោគជ័យធំមួយ ដោយមានអ្នកលក់តាមផ្លូវចំនួន ៣៥% បានធ្វើការញែកសំរាមរបស់ខ្លួនក្នុងរយៈពេលមួយឆ្នាំ។ ទាំងអ្នកសម្អាតផ្សារ និងក្រុមហ៊ុន ស៊ីន ទ្រី បានប្រមូលសំរាមដែលបានញែកហើយនោះ។ ទោះយ៉ាងណា ផ្សារពីរផ្សេងទៀតត្រូវបានគេរាយការណ៍ថាមិនសូវទទួលបានជោគជ័យប៉ុន្មានទេ ដោយសារហេតុផលមួយចំនួន។ ហេតុផលទីមួយ ការគ្រប់គ្រងទីផ្សារ និងអ្នកសម្អាតផ្សារ ( អ្នកសម្អាតផ្សារមានចំនួនតិចតួចពេក ) មិនបានសហការដែលជាហេតុបណ្តាលឱ្យមានការទុកដាក់សំរាមឡូកឡំគ្នាវិញ។ លើសពីនេះទៀត មិនមានការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុដល់អ្នកលក់តាមផ្លូវសម្រាប់ការញែកសំរាម ហើយធុងសំរាមក៏មានមិនគ្រប់គ្រាន់ដើម្បីឱ្យអ្នកចោលសំរាមញែកសំរាមនោះដែរ។ គម្រោងនេះគូសបញ្ជាក់ឱ្យឃើញពីកម្រិតប្តេជ្ញាចិត្តច្បាស់លាស់ពីអ្នកគ្រប់គ្រងផ្សារ និងអ្នកសម្អាតផ្សារ ហើយយុទ្ធនាការលើកកម្ពស់ការយល់ដឹងមិនអាចផ្តោតតែទៅលើអ្នកលក់តាមផ្លូវតែម្យ៉ាងប៉ុណ្ណោះទេ។

## ធនាគារអភិវឌ្ឍអាស៊ី ( ADB )

ធនាគារអភិវឌ្ឍន៍អាស៊ី មានគម្រោងកំពុងដំណើរការចំនួន ២ នៅខេត្តបាត់ដំបង៖ ការអភិវឌ្ឍន៍មជ្ឈមណ្ឌលញែកសំរាម ក្រោមគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងរបៀងភាគខាងត្បូង និងការអភិវឌ្ឍទីលានចាក់សំរាមថ្មីក្រោមគម្រោងអាងទន្លេសាប។

ទំហំការងារដំបូងនៃការអភិវឌ្ឍន៍មជ្ឈមណ្ឌលញែកសំរាម គឺដើម្បីសាងសង់មជ្ឈមណ្ឌលញែក សំណល់រឹងក្នុងកម្រិតអតិបរមាចំនួន ៨ តោន ដោយមានឧបករណ៍ញែកចំនួន ៨ ក្នុងមួយវេន ៨ ម៉ោង។ លទ្ធផលសិក្សាសមិទ្ធិលទ្ធភាព ស្នើឱ្យមានគ្រឿងចក្របូកចំនួន ១ ម៉ាស៊ីនកៀបចំនួន ១ ជញ្ជីងថ្លឹងចំនួន ៣ ធុងប៉ូលីទីលីនដែលមានដង់ស៊ីតេខ្ពស់ ( HDPE ) ចំនួន ៨ ធុង និងម៉ាស៊ីនភ្លើងចំនួន ១ គ្រឿង។ គម្រោងនេះត្រូវបានអនុវត្តន៍ដោយមានកិច្ចសហប្រតិបត្តិការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន និងការសម្របសម្រួលជាមួយសាលាក្រុងបាត់ដំបង។ ការសិក្សានេះ ក៏បានស្នើឱ្យមានការកសាងសមត្ថភាពមន្ត្រីដែរ។ នៅខែធ្នូ ឆ្នាំ២០១៨ ធនាគារអភិវឌ្ឍន៍អាស៊ីបានជូនដំណឹងដល់អ្នកនិពន្ធអំពីបេសកកម្មវិវេចន៍ពាក់កណ្តាលអាណត្តិនៃគម្រោងដែលបានអនុវត្ត។ ការកសាងសមត្ថភាពលើប្រតិបត្តិការ

### រូបភាពទី ៧៖ ទីតាំងទីលានថ្មីដែលបានស្នើឡើងក្នុងគម្រោង ADB




និងការថែទាំកន្លែងទាញយកធនធាន ត្រូវបានគ្រោងធ្វើសម្រាប់មន្ត្រីសាលាក្រុង និងប្រតិបត្តិករឯកជន ប៉ុន្តែមិនបានកំណត់ពេលវេលាជាក់លាក់នៅឡើយទេ។ ជាមួយគ្នានេះដែរ មិនមានផែនការបន្ទាន់ ឬថវិកា ដើម្បីដំឡើងឧបករណ៍ញែកនៅមជ្ឈមណ្ឌលញែកសំរាមនោះទេ។

គម្រោងអាងទន្លេសាបកំពុងត្រួតពិនិត្យលើការជ្រើសរើស និងរៀបចំទីតាំងទីលានចាក់សំរាមថ្មី ដែលត្រូវបានស្នើឡើងឱ្យស្ថិតនៅចម្ងាយប្រមាណ ២១ គីឡូម៉ែត្រ ខាងត្បូងក្រុងបាត់ដំបង។ គម្រោងនេះគ្រោងនឹងដំណើរការនៅឆ្នាំ២០២២ ជាមួយនឹងអាយុកាលប្រើប្រាស់លើសពី ៣០ ឆ្នាំ និងមានបរិមាណប្រហែល ៣ លានម៉ែត្រគូប។ បច្ចុប្បន្នវាស្ថិតនៅក្នុងដំណាក់កាលរៀបចំភ្ជាប់ជាមួយនឹងជម្រើសសំណើចំនួន ៣។ ជម្រើសមួយដែលបង្ហាញក្នុងរូបភាពទី ៧ គឺជាជម្រើសដែលល្អបំផុត ប៉ុន្តែមិនទាន់មានការសម្រេចជ្រើសរើសនៅឡើយទេ។

### Konrad-Adenauer-Stiftung (KAS)

ខេអេអែស (KAS) គឺជាក្រុមអ្នកផ្តល់យោបល់មួយរបស់អាល្លឺម៉ង់ដែលបានធ្វើការជាមួយសង្កាត់ និងសាលាខេត្តក្នុងខេត្តបាត់ដំបង ដើម្បីអភិវឌ្ឍដីកា ឬបទប្បញ្ញត្តិមូលដ្ឋានសម្រាប់ការគ្រប់គ្រងសំណល់រឹងនៅថ្នាក់ឃុំក្នុងខេត្តបាត់ដំបង (បានពិពណ៌នានៅក្នុងផ្នែកច្បាប់ និងបទប្បញ្ញត្តិ៖ ដីកាស្តីពីការគ្រប់គ្រងសំណល់រឹង)។ គម្រោងនេះត្រូវបានអនុវត្តនៅឆ្នាំ២០១៦ និងឆ្នាំ២០១៧ ដោយបានសម្រេចលទ្ធផលជាសេចក្តីព្រាងបទប្បញ្ញត្តិដែលត្រូវបានអនុម័តជាផ្លូវការដោយអភិបាលខេត្តក្នុងឆ្នាំ២០១៨[៩]។

ខាងក្រោមនេះគឺជាអ្វីត្រូវបានណែនាំឱ្យអនុវត្តរហូតដល់ឆ្នាំ ២០៣០ ដើម្បីកែលម្អការគ្រប់គ្រងសំរាមប្រកបដោយប្រសិទ្ធភាព។

រូបភាពទី ៨៖ អនុសាសន៍របស់ KAS រហូតដល់ឆ្នាំ២០៣០[១០]

| ការត្រួតពិនិត្យទៅលើការគ្រប់គ្រងកាកសំណល់រឹង | ការអនុវត្តដោយម៉ឺងម៉ាត់ | ការលើកកំពស់ការយល់ដឹង និងការគ្រប់គ្រងជាសាធារណៈ |
|---|---|---|
| • ការប្រមូលកម្រៃដោយសាលាក្រុង<br>• ការបង្កើតថវិការផ្ទាល់ខ្លួន<br>• ការពង្រឹងនូវសមត្ថភាពរបស់សាលាក្រុង<br>• កិច្ចសន្យារយៈពេលខ្លីជាមួយអ្នកផ្តល់សេវាកម្ម ឬការដេញថ្លៃជាលក្ខណៈអន្តរជាតិ<br>• ការត្រួតពិនិត្យ<br>• ការប្រមូល និងវិភាគទិន្នន័យ | • វិធានការត្រជាក់៖ ការបង្កើនការយល់ដឹង និងការអប់រំ<br>• វិធានការត្រជាក់៖ ការលើកទឹកចិត្តសម្រាប់ការអនុវត្តបានល្អ<br>• វិធានការក្តៅ៖ ការអនុវត្តច្បាប់<br>• វិធានការក្តៅ៖ ការផ្តន្ទាទោសចំពោះការរំលោភបំពានលើដីកា | • យុទ្ធសាស្ត្រទំនាក់ទំនង<br>• AIDA និង KISS<br>• ឯកអគ្គរដ្ឋទូតសុច្ឆន្ទៈទីក្រុងបៃតង<br>• វិស័យសាធារណៈគ្មានការប្រើប្រាស់ប្លាស្ទិក<br>• រង្វាន់វិស័យសាធារណៈគ្មានការប្រើប្រាស់ប្លាស្ទិក<br>• ទីក្រុងស្អាត<br>• កិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាល<br>• គេហទំព័រការសំអាត អនាម័យនៅក្នុងកម្ពុជា (អាចរកបាននៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧) |

## ហ្គោហ្គ្រីន ខែមបូឌា ( GoGreen Cambodia )[១១]

ហ្គោហ្គ្រីន ខែមបូឌា ( GoGreen Cambodia ) គឺជាក្រុមអ្នកស្ម័គ្រចិត្តមួយមានមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា ដែលជាផ្នែកមួយនៃអ៊ីនស្តែដដ៍ អាស៊ីខាងត្បូង( inSTEDD South Asia ) ដែលបានជំរុញការអភិវឌ្ឍកម្មវិធីទូរស័ព្ទអេនដ្រយ ( Android ) ជាសាធារណៈដោយឥតគិតថ្លៃ សម្រាប់រាយការណ៍អំពីបញ្ហាគ្រប់គ្រងសំរាម។

## ចលនាជុំឥដ្ឋបៃតង

គម្រោង ចលនាជុំឥដ្ឋបៃតង ត្រូវបានបង្កើតឡើងដោយក្រុមយុវជនប្រកបដោយភាពច្នៃប្រតិដ្ឋតាមរយៈកម្មវិធីគំនិតផ្តួចផ្តើមអ្នកដឹកនាំអាស៊ីអាគ្នេយ៍ ( YSEALI ) និងបានបញ្ចប់នៅខែមករា ឆ្នាំ២០១៩។ គោលបំណងចម្បង គឺប្រើប្រាស់សំណល់ប្លាស្ទិកឡើងវិញដោយបង្កើតទៅជាជុំឥដ្ឋអេកូតាមរយៈការកម្ទេចប្លាស្ទិកស្ងួតតូចៗទៅក្នុងដបប្លាស្ទិក។ សកម្មភាពទាំងនោះ រួមមាន (១) កិច្ចសហការជាមួយសាលារៀនចំនួន ២ នៅខេត្តបាត់ដំបង

រូបភាពទី ៩៖ កម្មវិធីហ្គោហ្គ្រីន ខែមបូឌា ( GoGreen Cambodia )




https://play.google.com/store/apps/details?id=org.insteddilabsea.gogreen&hl=en

[១០] KAS, Deika on Solid waste management: A Case of Participatory Legislative Drafting at the Commune Level, ឆ្នាំ២០១៧, ទំព័រទី១៨
[១១] ព័ត៌មានពីការពិភាក្សាជាមួយបុគ្គលិក GoGreen Camboddia និង តាមរយៈទំព័រFacebookរបស់GoGreen Cambodia

ដើម្បីប្រមូលសំរាមប្លាស្ទិកស្ងួតហើយបង្កើតជាឥដ្ឋ (២) ជំរុញកសិករសរីរាង្គឱ្យប្រើប្រាស់ដុំឥដ្ឋប្លាស្ទិក (ឧទាហរណ៍ សាងសង់បរិក្ខារដាក់ដីកំប៉ុសនៅតាមខ្នងផ្ទះ) និងគៀងគរយុវជននៅតាមកសិដ្ឋានសរីរាង្គ។ ក្រុមនេះ មានបណ្តាញយុវជនយ៉ាងរឹងមាំនៅខេត្តបាត់ដំបង។

### កម្ពុជាគ្មានថង់ប្លាស្ទិក (Plastic Free Cambodia)

កម្ពុជាគ្មានថង់ប្លាស្ទិក គឺជាអង្គភាពអ្នកស្ម័គ្រចិត្តដែលផ្តោតលើការប្រើប្រាស់សម្ភារៈផ្សេងជំនួសឲ្យប្លាស្ទិក។ សកម្មភាពនានានៅខេត្តបាត់ដំបងរួមមាន៖ (១) សិក្ខាសាលាស្តីពីការកាត់បន្ថយកាកសំណល់ប្លាស្ទិក (២) ការចូលរួមសម្អាតក្នុងអំឡុងពេលព្រឹត្តិការណ៍ពិសេសៗ ដូចជាពិធីបុណ្យអុំទូក និង (៣) ផ្សព្វផ្សាយការលើកកម្ពស់ការចូលរួមក្នុង យុទ្ធនាការខែកក្កដាគ្មានថង់ប្លាស្ទិក (Plastic Free July)។

### សមាគមហ្វ្លេមីស្ហ (Flemish) សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងជំនួយបច្ចេកទេស(VVOB)

វីវីអូប៊ី (VVOB) គឺជាអង្គការបែលហ្សិកដែលផ្តោតលើការអប់រំដើម្បីការអភិវឌ្ឍ។ ផ្អែកលើការប្រជុំជាមួយបុគ្គលិករបស់ស្ថាប័ននេះ នាំឱ្យយើងយល់ដឹងអំពីគោលបំណងនៃកម្មវិធីនេះធ្វើឡើងដើម្បីលើកកម្ពស់សាលារៀនអេកូ និងគ្មានប្លាស្ទិក។ កម្មវិធីនេះនឹងមានរយៈពេលរហូតដល់ឆ្នាំ២០២១។ វីវីអូប៊ី កំពុងផ្តោតគោលដៅលើសកម្មភាពសាលាអេកូ និងគ្មានប្លាស្ទិកនេះនៅតាមសាលារៀនចំនួន ២០ ដែលក្នុងនោះមានសាលាបឋមសិក្សាចំនួន ១១ និងវិទ្យាល័យចំនួន ៩។ គិតត្រឹមដើមឆ្នាំ២០១៩ វីវីអូប៊ី បានធ្វើការជាមួយសាលារៀនចំនួន១០។ សកម្មភាពចម្បងរបស់ពួកគេរួមមាន៖ (១) ផ្តល់ធុងសំរាម (ចំនួនពី ២ ទៅ ១០ ដោយផ្អែកលើតម្រូវការរបស់សាលារៀន) ដែលត្រូវបានរៀបចំសម្រាប់ប្រភេទសំរាមផ្សេងៗគ្នា និង (២) អប់រំនាយកសាលា គ្រូ និងសិស្សអំពីការបែងចែកសំរាមឱ្យបានត្រឹមត្រូវ។

### ផែនដីមួយមហាសាគរមួយ

សហការជាមួយអង្គការខេមកីឌ មូលនិធិផែនដីមួយមហាសាគរមួយរបស់អាល្លឺម៉ង់ បានគាំទ្រសកម្មភាពចូលរួមសម្អាតនៅដងស្ទឹងសង្កែក្នុងខេត្តបាត់ដំបង ដោយផ្តល់ទូក និងឧបករណ៍ផ្សេងទៀតទៅឱ្យអង្គការខេមកីឌ ដើម្បីប្រមូលសំរាមក្នុងទឹក។

## ២.៤. ការស្វែងយល់ពីវិស័យគ្រប់គ្រងសំណល់រឹងក្នុងក្រុងបាត់ដំបង

ផ្តើមពីការធ្វើវិវេចនារបាយការណ៍ដែលធ្លាប់សិក្សា កិច្ចប្រជុំ និងការសម្ភាស ស្ថានភាពបច្ចុប្បន្ននៃខ្សែសង្វាក់ផលិតកម្ម និងតួអង្គពាក់ព័ន្ធត្រូវបានពិពណ៌នានៅក្នុងផ្នែករងខាងក្រោម។ ទីមួយ ការគ្រប់គ្រងត្រូវបានដោះស្រាយអមដោយទិដ្ឋភាពទូទៅនៃលំហូរសំរាមដូចដែលបានបង្ហាញក្នុងរូបភាពទី ១០ ពីការបង្កើតដល់ការទុកដាក់ ការប្រមូល និងការញែក រហូតទៅដល់ការកែច្នៃ និងការបោះចោល។ ចុងបញ្ចប់មេរៀនដែលទទួលបានពីគម្រោងអន្តរជាតិផ្សេងៗទៀត ត្រូវបានបង្ហាញ ដើម្បីជាការជំរុញចិត្តបន្ថែម។ រូបភាពទី ១១ ក៏បង្ហាញផែនទីក្រុងបាត់ដំបង ដែលបានបង្ហាញពីសេវាកម្មសំខាន់ៗ និងតួអង្គដែលត្រូវមានវត្តមាន។

### ២.៤.១. អភិបាលកិច្ច

ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងទេសចរណ៍ ព្រមទាំងអង្គភាពក្រោមឱវាទ គឺជាតួអង្គគ្រប់គ្រងសំខាន់ៗ (រូបភាពទី ១២ខាងក្រោម)។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានផ្តល់ធនធានហិរញ្ញវត្ថុ សម្រាប់សេវាកម្មគ្រប់គ្រងសំណល់រឹង មិនបានបង្ហាញនៅក្នុងរូបភាពខាងក្រោមទេ។ សាលាក្រុងដែលស្ថិតនៅក្រោមឱវាទក្រសួងមហាផ្ទៃ មានការទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ការអនុវត្តគម្រោងនេះ ដូច្នេះត្រូវបានបង្ហាញមុនគេ។

### សាលាក្រុងបាត់ដំបង៖ អ្នកគ្រប់គ្រងសេវាសំរាមផ្សេងៗ

សាលាក្រុងបាត់ដំបង មានបុគ្គលិកបច្ចេកទេសចំនួន ៤នាក់ នៅក្រោមការិយាល័យរៀបចំសោភ័ណភាព និងគ្រប់គ្រងកាកសំណល់ក្រុង ដែលធ្វើការលើសកម្មភាពគ្រប់គ្រងសំណល់រឹង។ ស្របតាមអនុក្រឹត្យលេខ ១១៣ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់ថវិកាជាតិសម្រាប់សេវាអនាម័យបរិស្ថាន ដោយក្នុងនោះក្រុងបាត់ដំបងទទួលបាន ៨៧.០០០ ដុល្លារអាមេរិច ក្នុងឆ្នាំ២០១៥ និងប្រហែល ១៤០.០០០ ដុល្លារអាមេរិច ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ ។

ដូចដែលបានកំណត់ដោយគោលនយោបាយ រដ្ឋបាលក្រុងទទួលបន្ទុកគ្រប់គ្រង និងអនុវត្តសេវាកម្មប្រមូលសំរាម (រួមទាំងការដាក់ធុងសំរាមនៅតាមទីសាធារណៈ) ប៉ុន្តែមិនប្រមូលថ្លៃ

## រូបភាពទី ១០៖ -ដ្យាក្រាមលំហូរកាកសំណល់រឹងបច្ចុប្បន្នរបស់ក្រុងបាត់ដំបង

### សង្ខេបស្ថានភាពលំហូរសំណល់ដែលមានក្នុងក្រុងបាត់ដំបង: ស្ថានភាពបច្ចុប្បន្ន
### បរិមាណសំណល់សរុបប្រហែល 130 តោន ក្នុងមួយថ្ងៃ








## រូបភាពទី ១១៖ -ផែនទីនៃការគ្រប់គ្រងសំណល់រឹង នៅតំបន់ដែលមានសេវាកម្ម ប្រមូល និង ភាគីពាក់ព័ន្ធសំខាន់ៗ




## រូបភាពទី ១២៖ តួអង្គគ្រប់គ្រងសំខាន់ៗ



ប្រមូលសំរាមឡើយ ដែលភារកិច្ចនេះ ត្រូវបានកំណត់ដោយច្បាប់។ ផ្ទុយទៅវិញរដ្ឋបាលក្រុងបានចុះកិច្ចសន្យាជាមួយអ្នកប្រមូលពីរ គឺក្រុមហ៊ុនស៊ីន ទ្រី ដែលបានប្រមូលសំរាម (និងថ្លៃសេវាពាក់ព័ន្ធ) ក្នុងឃុំចំនួន ៨ ចាប់តាំងពីឆ្នាំ២០១០ និងក្រុមហ៊ុនលៀប លឹម ដែលត្រូវបានឧបត្ថម្ភធនដោយថវិកាសាលាក្រុង ដើម្បីផ្តល់សេវាជូនដល់ឃុំចំនួន ២ និងទីសាធារណៈចាប់តាំងពីឆ្នាំ២០១៥។ កិច្ចសន្យារយៈពេល ១០ឆ្នាំ របស់ក្រុមហ៊ុនស៊ីន ទ្រី នឹងត្រូវបន្តជាថ្មី នៅឆ២០២០ ហើយកិច្ចសន្យារបស់ក្រុមហ៊ុនលៀប លឹម ត្រូវបានបន្តជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ២០១៩ នេះតទៅ ដោយថវិកាក្រុងទាំងអស់ (ប្រហែល ១៤៣.០០០ ដុល្លារអាមេរិច ក្នុងឆ្នាំ ២០១៩) ត្រូវបានបែងចែកទុកសម្រាប់សេវាកម្មដែលផ្តល់ដោយរដ្ឋបាលក្រុង។ ទាក់ទងនឹងសេវាកម្មកែច្នៃ និងការបោះចោល សាលាក្រុងជាម្ចាស់ទីតាំងមជ្ឈមណ្ឌលញែកសំរាម(MRF) ដែលការសាងសង់ត្រូវបានផ្តល់មូលថវិកាដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ទីក្រុងបានផ្តល់សិទ្ធិឱ្យ ក្រុមហ៊ុនលៀប លឹម ក្នុងការគ្រប់គ្រងកន្លែងនោះ ទោះបីមិនទាន់មានកិច្ចសន្យាផ្លូវការជាលាយលក្ខណ៍អក្សរណាមួយក៏ដោយ។ រដ្ឋបាលសាលាក្រុងមិនមានថវិកាដើម្បីចំណាយលើប្រតិបត្តិការនៅកន្លែងនេះទេ។ លើសពីនេះសាលាក្រុងបានផ្តល់ដីមួយហិកតាដល់ ក្រុមហ៊ុនស៊ីន ទ្រី សម្រាប់កន្លែងចាក់សំរាមបច្ចុប្បន្ន និងដីមួយហិកតាដល់ខមភីដ សម្រាប់កន្លែងកែច្នៃដីកំប៉ុស។ ផែនទី ក្នុងរូបភាពទី ១១ បង្ហាញពីទីតាំងនៃអង្គភាពទាំងនេះ និងឃុំដែលបម្រើការដោយក្រុមហ៊ុនស៊ីន ទ្រី និងក្រុមហ៊ុនលៀប លឹម។

រដ្ឋបាលសាលាក្រុងក៏ទទួលខុសត្រូវក្នុងការលើកកម្ពស់ការយល់ដឹង និងការញែកសំរាម ហើយមានគោលបំណងរៀបចំការប្រកួតប្រជែងថ្នាក់ភូមិ សម្រាប់សកម្មភាពលើកកម្ពស់បរិស្ថាន ប៉ុន្តែមកទល់ពេលនេះ មិនទាន់មានផែនការយុទ្ធសាស្ត្រណាមួយត្រូវបានបង្កើតឡើង ដើម្បីសម្របសម្រួលសកម្មភាព និងការអនុវត្តជាមួយឃុំនានាឡើយ។ បញ្ហានេះត្រូវបានគូសបញ្ជាក់ នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធកាលពីថ្ងៃទី ២ ខែឧសភា ឆ្នាំ២០១៩ នៅពេលដែលសាលាក្រុងបានឯកភាពលើភាពចាំបាច់នៃកិច្ចការនេះ និងបានបង្ហាញផែនការដើម្បីផ្ទេរតួនាទីទៅកម្រិតឃុំនេះ។ លោកចៅសង្កាត់ក៏បានសម្តែងនូវឆន្ទៈនិងចំណាប់អារម្មណ៍ខ្ពស់ក្នុងការកែលម្អការគ្រប់គ្រងសំណល់រឹង។ ជាចុងក្រោយទោះបីជាអនុក្រឹត្យលេខ ១១៣ ចែងអំពីគោលការណ៍ណែនាំ និងការផាកពិន័យ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ទីក្រុងក៏ដោយ ក៏មិនទាន់មានសកម្មភាពអនុវត្ត ដោយសាលាក្រុងនៅឡើយទេ។

## មន្ទីរបរិស្ថានខេត្តបាត់ដំបងៈ អ្នកផ្តល់យោបល់ និងអ្នកអនុវត្តន៍

ការិយាល័យការពារបរិស្ថាន នៃមន្ទីរបរិស្ថានខេត្តមានបុគ្គលិក ចំនួន ៣ នាក់ និងថវិកាប្រហែល ៧៥០ ទៅ ១០០០ ដុល្លារអាមេរិច ក្នុងមួយឆ្នាំ ។ ដូចដែលបានកំណត់នៅក្នុងគោលនយោបាយពាក់ព័ន្ធ មន្ទីរបរិស្ថានខេត្តបាត់ដំបង ត្រូវសហការលើការធ្វើផែនការ និងការអនុវត្តច្បាប់ និងយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈ ក៏ដូចជាផ្តល់ការណែនាំបច្ចេកទេសដល់សាលាក្រុង និងគាំទ្រដល់ការគ្រប់គ្រងសំណល់ថង់ប្លាស្ទិក។ ដោយសហការជាមួយសាលាក្រុង មន្ទីរបរិស្ថានខេត្តក៏ទទួលខុសត្រូវផងដែរក្នុងការអនុវត្តការពិន័យចំពោះការមិនគោរពច្បាប់។ ទោះយ៉ាងណាក៏ដោយ យើងមើលឃើញថានាបច្ចុប្បន្ននេះមន្ទីរបរិស្ថានខេត្តមិនទាន់បានអនុវត្តវិធានការស្តីពីការល្មើសណាមួយនៅឡើយទេ។

បន្ថែមលើសពីនេះទៀត មន្ទីរបរិស្ថានខេត្តបាត់ដំបងត្រូវផ្តល់វិញ្ញាបនបត្រញែកសំណល់រឹងបរិស្ថានដល់អង្គភាពនានា ទោះបីយ៉ាងណាក៏ដោយរហូតមកដល់ពេលនេះ ផ្តល់វិញ្ញាបនបត្រជូនបានដល់តែភោជនីយដ្ឋាន និងសហគ្រាសខ្នាតតូច និងមធ្យមមួយចំនួនប៉ុណ្ណោះ។ មន្ទីរបរិស្ថានខេត្តបានបញ្ជាក់ជូនផងដែរថា អង្គភាពប្រភេទផ្សេងទៀតដែលប្រហែលជាសំដៅដល់វិស័យ ក្រៅផ្លូវការ ក៏អាចមានសិទ្ធិទទួលបានការទទួលស្គាល់នេះផងដែរ។

## រដ្ឋបាលខេត្តបាត់ដំបង

ទោះបីសាលាក្រុងបាត់ដំបងជាអ្នកអនុវត្តសេវាកម្មគ្រប់គ្រងសំណល់រឹងដ៏សំខាន់ក៏ដោយ ក៏រដ្ឋបាលខេត្តមានទំនួលខុសត្រូវមួយចំនួនស្របតាមអនុក្រឹត្យលេខ ១១៣ និង ១៦៨។ ទំនួលខុសត្រូវទី ១ គឺការគាំទ្រដល់សាលាក្រុងក្នុងការរៀបផែនការថវិកា និងផែនការសកម្មភាព ក៏ដូចជាការបង្កើតសេវាកម្ម។ ទំនួលខុសត្រូវទី ២ គឺការដឹកនាំការអនុវត្តសកម្មភាពទាក់ទងនឹង

ការកាត់បន្ថយថង់ប្លាស្ទិក (រួមទាំងការកែច្នៃឡើងវិញ) យ៉ាងណាមិញការទទួលខុសត្រូវទាំងនេះអាចត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះយ៉ាងណាក្តី រហូតមកដល់ពេលនេះរដ្ឋបាលសាលាខេត្តបានត្រឹមតែចូលរួមក្នុងសកម្មភាពកែច្នៃសំណល់រឹងរបស់យូនីដូប៉ុណ្ណោះ។ ថ្វីបើដូច្នោះមែនក៏ដោយ ក៏រដ្ឋបាលសាលាខេត្ត នៅតែជាតួអង្គសំខាន់ដែលមានសិទ្ធិសម្រេច នៅក្នុងការបង្កើតផែនការ និងគោលនយោបាយគ្រប់គ្រងសំណល់រឹង។

## ក្រសួងបរិស្ថាន

ក្រសួងបរិស្ថាន មានការទទួលខុសត្រូវច្រើននៅថ្នាក់ជាតិ ប៉ុន្តែអ្វីដែលគួរឱ្យចាប់អារម្មណ៍នោះ គឺការអនុវត្ត និងផែនការអនុវត្តន៍[១៧] នៃអនុក្រឹត្យលេខ ១៦៨ ស្តីពីថង់ប្លាស្ទិក។ មជ្ឈមណ្ឌលធុរកិច្ចធំៗ និងផ្សារទំនើបត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយនាយកដ្ឋានគ្រប់គ្រងសំណល់រឹងថា ធុរកិច្ចទាំងនេះត្រូវគិតថ្លៃសម្រាប់ការប្រើប្រាស់ថង់ប្លាស្ទិកនៅកន្លែងរបស់ខ្លួន។ អ្នកតំណាងនៅក្រសួងក៏បានឱ្យដឹងថាផ្សារតូច និងម៉ាតមួយចំនួនបានដាក់កំហិតឱ្យមានការគិតថ្លៃនេះ។ នាយកដ្ឋានគ្រោងនឹងពង្រីកការអនុវត្តនេះទៅផ្សារក្នុងមូលដ្ឋានចន្លោះ ឆ្នាំ២០២០ និងឆ្នាំ២០២២។

នាយកដ្ឋានគ្រប់គ្រងសំណល់រឹង បានចាប់ផ្តើមរៀបចំអនុក្រឹត្យស្តីពីការគ្រប់គ្រងសម្ភារៈវិចខ្ចប់ចំណីអាហារ រួមមានកំប៉ុងប្លាស្ទិក បំពង់បឺត និងប្រអប់ស្នោ។ វាជារឿងសំខាន់ ព្រោះវាផ្តោតសំខាន់ទៅលើវត្ថុដែលមិនអាចកែច្នៃឡើងវិញបាន ដែលវិស័យសំរាមក្រៅផ្លូវការមិនអាចមានលទ្ធភាពប្រមូលយកបាន។ គេមិនទាន់ច្បាស់ថា តើអនុក្រឹត្យនេះនឹងត្រូវបានបញ្ចប់ ហើយអនុវត្តនៅពេលណា ឬមានខចែងយ៉ាងណាខ្លះនៅឡើយទេ។

នាយកដ្ឋានអប់រំបរិស្ថាន អនុវត្តផែនការ និងការអនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈ។ ក្នុងអំឡុងពេលសម្ភាសន៍នៅខែមីនា ឆ្នាំ២០១៩ នាយកដ្ឋានបានផ្តល់ព័ត៌មានអំពីយុទ្ធនាការនាពេលខាងមុខ ដែលបានបង្កើតដើម្បីផ្សាយនៅតាមវិទ្យុ ទូរទស្សន៍ និងកាសែត បូកទាំងផ្ទាំងប៉ាណូ បណ្ណផ្សព្វផ្សាយ បណ្ណប្រកាស និងផ្ទាំងស្ទិកឃើរបិទ(រូបសញ្ញាឬអក្សរអប់រំសម្រាប់បិទលើយានយន្ត)។ ទោះយ៉ាងណាក៏ដោយវាហាក់ដូចជាព្រឹត្តិការណ៍ទាំងនេះដំណើរការតែក្នុងរយៈពេលខ្លីប៉ុណ្ណោះ ហើយក៏គ្មានការត្រួតពិនិត្យណាមួយដែរ (កាលពីពេលមុនក៏មិនមានដែរ) ដើម្បីកំណត់ពីលទ្ធផលនៃព្រឹត្តិការណ៍ទាំងនេះ។

## ក្រសួងទេសចរណ៍

ទោះបីជាក្រសួងទេសចរណ៍នៅមិនទាន់ត្រូវបានលើកយកមកពិភាក្សាក្នុងការអនុវត្តសកម្មភាពគ្រប់គ្រងសំណល់រឹងនៅឡើយក្តី ក៏ក្រសួងនេះ សាកសមនឹងរាប់បញ្ចូលក្នុងសកម្មភាពនេះ ដោយមានហេតុផលច្រើន។ ហេតុផលទីមួយ វិស័យទេសចរណ៍ជារឿយៗមានឥទ្ធិពលយ៉ាងខ្លាំងដល់តម្រូវការសេវាកម្មសាធារណៈ (ដូចជានៅសៀមរាបដែលមានតម្រូវការគ្រប់គ្រងសំរាមកាន់តែច្រើន ដោយសារបរិមាណភ្ញៀវទេសចរចូលទស្សនាតំបន់អង្គរមានចំនួនច្រើន)។ ហេតុផលទីពីរ ក្រសួងទេសចរណ៍ មានទំនួលខុសត្រូវក្នុងការគ្រប់គ្រងសំរាមថង់ប្លាស្ទិកក្នុងអនុក្រឹត្យលេខ១៦៨ រួមទាំងការសហការក្នុងការលើកកម្ពស់ការអប់រំស្តីពីថង់ប្លាស្ទិក។ ក្រសួងទេសចរណ៍ ក៏បានបញ្ចូលការគ្រប់គ្រងសំរាមថង់ប្លាស្ទិកធ្វើជាសូចនាករមួយនៅក្នុងការវាយតម្លៃពានរង្វាន់ទីក្រុងស្អាតដែលត្រូវគ្រប់គ្រង និងផ្តល់ជូនដោយក្រសួងនេះផ្ទាល់។

## ២.៤..២. ការបង្កើតសំរាម

ប្រជាជនក្នុងក្រុងបាត់ដំបងមានចំនួនប្រមាណ ១៦ម៉ឺននាក់។ ការប៉ាន់ស្មានបរិមាណសំរាម ដែលបានបង្កើតក្នុងមួយថ្ងៃកាលពីមុន មានចាប់ពី ៨៧ ទៅ ១៣០ តោន/ថ្ងៃ[១៣] ។ ទោះបីបរិមាណនេះ ខុសគ្នាតាមរដូវក៏ដោយ ក៏របាយការណ៍ថ្មីៗនេះ (ពីឆ្នាំ ២០១៧) ប៉ាន់ស្មានថាបរិមាណសំរាមកើនឡើងកាន់តែខ្ពស់រហូតដល់ ១៣០តោន/ថ្ងៃ។ ក្រោមការសិក្សានេះ ទីប្រឹក្សាបច្ចេកទេស បានប៉ាន់ប្រមាណថា ការផលិតសំរាមអាចនឹងកើនខ្ពស់ជាងនេះ។ ដូច្នេះ របាយការណ៍នេះ កំណត់យកបរិមាណសំរាម ១៣០ តោន/ថ្ងៃ។

## សារតារនៃអ្នកបង្កើតសំរាម

ផ្អែកលើមូលដ្ឋានទិន្នន័យឃុំសង្កាត់ឆ្នាំ២០១៦ សាលាក្រុងបាត់ដំបងមានសង្កាត់ចំនួន ១០ គ្រួសារចំនួន ២៩.៧២០ គ្រួសារ និងមានប្រជាជនចំនួន ១៦១.០៧២នាក់ (សូមមើលតារាងខាងក្រោម)។ ស្វាយប៉ោជាទីប្រជុំឃុំដែលភាគច្រើនមានស្ថាប័នសាធារណៈ និងឯកជននៅទីនោះ។ តារាងទី ៣ បង្ហាញពីប្រភេទធុរកិច្ចនៅក្រុងបាត់ដំបង។

## តារាងទី ៣៖ ព័ត៌មានប្រជាសាស្ត្រ និងចំនួនធុរកិច្ចនៅក្រុងបាត់ដំបង[១៤]

| សង្កាត់ | ចំនួនគ្រួសារ | ចំនួនប្រជាជន | ចំនួនផ្សារទំនើប | ចំនួនផ្សារ | ចំនួនផ្សារតូចៗ [១៥] | ចំនួនផ្សារព្រឹក | ចំនួនភោជនីយដ្ឋាន | ចំនួនគ្លីនិកសុខភាព | ចំនួនសណ្ឋាគារ | ចំនួនផ្ទះសំណាក់ | ចំនួនស្ថាប័នមីក្រូហិរញ្ញវត្ថុ | ចំនួនស្ថាប័នធនាគារ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំការសំរោង | ៣,៧៥៥ | ២០,៩៤២ | ០ | ០ | ២ | ០ | ១ | ២ | ០ | ៥ | ០ | ០ |
| ក្តួលដូនទាវ | ២,៣២៥ | ១០,៥៣៦ | ០ | ០ | ១ | ០ | ១ | ០ | ០ | ០ | ០ | ០ |
| អូរចារ | ៣,០៤១ | ១៨,២២២ | ១ | ១ | ០ | ០ | ០ | ០ | ១ | ៦ | ២ | ១ |
| អូរម៉ាល់ | ២,៧៧៥ | ១២,៥៨៣ | ០ | ០ | ១ | ០ | ០ | ០ | ០ | ០ | ១ | ០ |
| ព្រែកព្រះស្តេច | ២,៥៦១ | ១៤,១០១ | ០ | ១ | ០ | ០ | ២ | ១ | ១ | ២១ | ៣ | ១ |
| រតនៈ | ២,៩៩៧ | ១៦,៥៥៤ | ០ | ០ | ១ | ០ | ៧ | ២ | ១៨ | ១៦ | ៦ | ១ |
| ស្លាកែត | ១,៣៧៨ | ៨,៨៤៧ | ០ | ០ | ១ | ០ | ៥ | ០ | ១ | ៣ | ០ | ០ |
| ស្វាយប៉ោ[១៦] | ៣,៤៤០ | ២១,៧៩៩ | ១ | ៣ | ០ | ១ | ៩ | ១០ | ១៩ | ៣៤ | ៤ | ១០ |
| ទួលតាឯក | ៤,០៥៤ | ១៩,២០៦ | ០ | ០ | ២ | ០ | ១ | ៣ | ១ | ៤ | ០ | ០ |
| វត្តគរ | ៣,៣៩៤ | ១៨,២៨២ | ០ | ០ | ០ | ០ | ៨ | ១ | ០ | ៧ | ០ | ០ |
| សរុប | ២៩,៧២០ | ១៦១,០៧២ | ២ | ៥ | ៨ | ១ | ៣៤ | ១៩ | ៤១ | ៩៦ | ១៦ | ១៣ |

[១២] ប្រជុំជាមួយអនុប្រធាននាយកដ្ឋានគ្រប់គ្រងសំណល់រឹងនៃក្រសួងបរិស្ថាន

[១៣] ការប៉ាន់ប្រមាណទាបដែលបានព្យាករនៅក្នុងរបាយការណ៍គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធបរិស្ថានទីក្រុង របស់ស៊ីឌីអាយអេ ( CDIA ) ក្នុងខែសីហា ឆ្នាំ២០១០ ក្នុងឧបសម្ព័ន្ធទី ២ និងការប៉ាន់ប្រមាណខ្ពស់គឺបានមកពីផែនការការងារឆ្នាំ២០១៧ សម្រាប់ការកាត់បន្ថយការបំពុលអាកាសជាតុក្នុងរយៈពេលខ្លី របស់អាយជីអ៊ីអែស/ខាំផេដ ( IGES/COMPED ) ។ ប្រភពផ្សេងទៀតប៉ាន់ស្មានបរិមាណសរុបរវាងតួលេខទាំងពីរនេះ ។

[១៤] ទិន្នន័យមូលដ្ឋានឃុំសង្កាត់នៃក្រសួងមហាផ្ទៃឆ្នាំ២០១៦ និងទិន្នន័យកែសម្រួលលើចំនួនផ្សារផ្អែកលើបទសម្ភាសន៍ជាមួយមេឃុំ

[១៥] ផ្សារតូចៗត្រូវបានគេចាត់ទុកថាជាផ្សារដែលមិនបើកពេញមួយថ្ងៃ (បើកតែពេលព្រឹក និងពេលរសៀលប៉ុណ្ណោះ)

[១៦] ទីប្រជុំឃុំនៃក្រុង

យោងតាមទិន្នន័យដែលប្រមូលបានក្នុងឆ្នាំ២០១៧ ប្រជាជនប្រហែល ៧៤% ចង់បានវិក្កយបត្រដោយឡែកសម្រាប់ថ្លៃសេវាប្រមូលសំណល់រឹង ជាជាងដាក់ចូលជាមួយវិក្កយបត្រទឹក ឬអគ្គិសនី។ ជាមធ្យម ការស្ទង់មតិនេះក៏បានចង្អុលបង្ហាញថា មានគ្រួសារដែលមានឆន្ទៈចំណាយប្រហែល ២ដុល្លារក្នុងមួយខែសម្រាប់សេវាកម្មការគ្រប់គ្រងសំណល់រឹងដែលមានភាពល្អប្រសើរ[១៧]។ ចំនួននេះ តិច ឬច្រើន មានភាពស្របទៅតាមច្បាប់ដែលកំណត់កម្រិតថ្លៃសេវាសម្រាប់ការប្រមូលសំរាមនៅតាមខ្នងផ្ទះចន្លោះពី ១,៦ ទៅ ១៤ ដុល្លារប៉ុណ្ណោះ អាស្រ័យទៅលើទំហំ និងប្រភេទខ្នងផ្ទះ។

## ទម្លាប់របស់ម្ចាស់សំរាម

សម្រាប់ខ្នងផ្ទះ និងធុរកិច្ច សេវាប្រមូលតាមផ្ទះត្រូវបានផ្តល់ដោយការប្រមូលជាផ្លូវការ ទោះយ៉ាងណាក៏ដោយតំបន់ខ្លះមិនអាចចូលទៅដល់នោះទេ។ នៅតាមផ្សារ អ្នកលក់ដាក់សំរាមក្នុងថង់ប្លាស្ទិក ឬបោះចោលទៅលើដី ដើម្បីឱ្យអ្នកសម្អាតផ្សាររើស។ ការពិភាក្សាបានបង្ហាញថា មូលហេតុនៃការបរាជ័យក្នុងការញែកសំរាមកាលពីមុននោះ គឺដោយសារតែអ្នកបង្កើតសំរាមសង្កេតឃើញអ្នកប្រមូលសំរាមជាអ្នកដាក់សំរាមឡូកឡំគ្នាទៅវិញទេ។ ដូច្នេះពួកគាត់ក៏គិតថាការញែកសំរាមខាតតែពេល។ លើសពីនេះទៀត បទសម្ភាសន៍ជាមួយអ្នកលក់នៅតាមផ្សារបានបង្ហាញថាពួកគេដឹងថានៅក្នុងប្រទេសផ្សេងទៀត (ឧទាហរណ៍ប្រទេសថៃ) ទីផ្សារត្រូវបានរក្សាភាពស្អាតបាត ព្រោះប្រជាពលរដ្ឋនៅទីនោះដឹងថាពួកគេនឹងត្រូវពិន័យបើគេចោលសំរាមគ្មានសណ្តាប់ធ្នាប់[១៨]។ ចម្លើយទាំងនេះបង្ហាញថា ទាំងការធ្វើឱ្យប្រសើរឡើងនៃសកម្មភាពប្រមូល និងការពង្រឹងការអនុវត្ត គឺជាផ្នែកសំខាន់នៃការអភិវឌ្ឍវិស័យគ្រប់គ្រងសំណល់រឹងនៅប្រទេសកម្ពុជា ។ វាក៏បង្ហាញថា ការប្រាស្រ័យទាក់ទងឱ្យដល់បុគ្គលពាក់ព័ន្ធនៅមូលដ្ឋានស្តីពីរបៀបញែកសំរាមគឺជារឿងសំខាន់ ដើម្បីឱ្យម្ចាស់សំរាម អាចយល់ពីមូលហេតុចាំបាច់ត្រូវតែញែកសំរាម។

លើសពីនេះទៅទៀត ការសិក្សាមួយដែលធ្វើឡើងសម្រាប់គម្រោង អេស៊ា (SWITCH Asia) ក្នុងឆ្នាំ២០១៥ ពាក់ព័ន្ធនឹង ទ្រីហ្គើ១៧ (17triggers) ស្តីពីអាកប្បកិរិយាជុំវិញការកាត់បន្ថយសំណល់ថង់ប្លាស្ទិក បានកត់សម្គាល់ពីការពិតគួរឱ្យចាប់អារម្មណ៍មួយចំនួនរបស់អ្នកបង្កើតសំរាម[១៩]។ ការសិក្សានោះបានរកឃើញថា មានការយល់ដឹងខ្ពស់ពីផលប៉ះពាល់សុខភាព និងបរិស្ថានចេញពីការគ្រប់គ្រងសំរាមមិនបានត្រឹមត្រូវ (ការដុតសំរាម ការចោលសំរាម) ដោយអ្នកប្រើប្រាស់ ៩៧% បង្ហាញពីបញ្ហាផ្លូវដង្ហើមបណ្តាលពីការដុតសំរាម។ ចំណុចមួយទៀតដែលគួរឱ្យចាប់អារម្មណ៍ផងដែរនោះ គឺនិស្សិតមានការយល់ដឹងខ្ពស់បំផុតពីផលប៉ះពាល់ ហើយនិស្សិតខ្លួនឯងហ្នឹងក៏ទំនងជាភាគរយខ្ពស់បំផុតក្នុងការចោលសំរាម។ លើសពីលើនេះទៀតបុគ្គលម្នាក់ៗក៏ទំនងជាអ្នកចោលសំរាមច្រើនជាងគ្រួសារអ្នកស្រុកទៅទៀត។

ទាក់ទងតែនឹងថង់ប្លាស្ទិក គ្រាន់តែខាងអាជីវករនៅផ្សារបង្កើតសំរាមថង់ប្លាស្ទិកប្រមាណ ៥០% នៃថង់ប្លាស្ទិកទាំងអស់។ អាជីវករផ្សារបានសម្តែងការមិនសប្បាយចិត្តចំពោះការសុំឱ្យអ្នកទិញដាក់ឥវ៉ាន់ចូលគ្នាក្នុងថង់តែមួយ ហើយក៏មិនចង់ឱ្យគេយល់ថាពួកគាត់ជាមនុស្សកំណាញ់។

មូលហេតុដែលបង្ហាញពីការមិនចូលរួមធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម មានដូចខាងក្រោម:

- វាជាបញ្ហារបស់អ្នកដទៃ
- វាជាការងាររបស់អ្នកដទៃ
- ធុងសំរាមមិនដែលឃើញមាននៅកន្លែងដែលត្រូវការទេ
- ថង់ប្លាស្ទិកងាយស្រួលកាន់តាមម៉ូតូ
- បុគ្គលម្នាក់ៗគេមិនចង់រើសសំរាម ព្រោះគេមិនចង់ពាក់ព័ន្ធថាខ្លួនជាអ្នករើសសំរាមទេ ព្រោះជារូបភាពដែលខ្លួនគិតថាអាក្រក់មើល។

[១៧] ទិន្នន័យស្ទង់មតិសេដ្ឋកិច្ច-សង្គមដែលប្រមូលបាននៅចុងឆ្នាំ២០១៧ នៃគម្រោងទន្លេសាប ២ របស់ ADB

[១៨] ការពិភាក្សា ការប្រមូលទិន្នន័យ

[១៩] 17 Triggers Reducing Plastic Bag Waste in Major Cities of Cambodia Behavior Change Communication Campaign Market Research Report ខែវិច្ឆិកា ឆ្នាំ២០០៩

ការសិក្សាក៏បានលើកឡើងដែរថា ព្រះសង្ឃប្រហែលជាអាចមានឥទ្ធិពលច្រើនទៅលើ ការយល់ឃើញរបស់មនុស្សចាស់ ប៉ុន្តែតារាល្បីៗទំនងជាមានឥទ្ធិពលលើយុវជនច្រើនជាង។ លើសពីនេះទៀត ផ្សារពិតជាចង់ឱ្យមានការគេផ្សព្វផ្សាយ និងចូលរួមក្នុងយុទ្ធនាការដើម្បីលើកកម្ពស់ការគ្រប់គ្រងសំរាម ទោះបីអ្នកលក់មានទម្លាប់អនុវត្តន៍ដែលពិបាកកែក៏ដោយ។

សរុបមក វាពិតជាការលំបាកណាស់ក្នុងការបញ្ច្រាបនូវទម្លាប់ថ្មី ប្រសិនបើបុគ្គលម្នាក់ៗមិនយកចិត្តទុកដាក់ចំពោះបញ្ហានេះ។ ការចូលរួមយូរអង្វែង គឺចាំបាច់ដើម្បីអភិវឌ្ឍទម្លាប់ថ្មី។ ការសិក្សាចិត្តវិទ្យាមួយកាលពីឆ្នាំ២០០៩ [២០] សន្និដ្ឋានថា មនុស្សម្នាក់ត្រូវចំណាយពេលជាមធ្យមប្រមាណ ៦៦ថ្ងៃ ដើម្បីបង្កើតទម្លាប់ថ្មី តែវាអាស្រ័យទៅតាមអធ្យាស្រ័យរបស់បុគ្គល ពីមនុស្សម្នាក់ទៅមនុស្សម្នាក់។ ចំណុចនេះគួរត្រូវយកមកពិចារណានៅពេលបង្កើតការសាកល្បង និងផែនការអនុវត្តរយៈពេលវែង។

## សមាសភាពសំណល់

សំរាមរហូតដល់ ៨០ភាគរយ[២១] ត្រូវបានប៉ាន់ប្រមាណថាមានសារធាតុសរីរាង្គ ដែលភាគច្រើនជាកាកសំណល់អាហារដែលបានមកពីតាមផ្ទះ និងតាមផ្សារ (រួមបញ្ចូលគ្នាបានប្រមាណជា ៩៥% នៃសំណល់អាហារសរុប)។ ទោះយ៉ាងណាក្តី ប្រភពមានភាពខុសគ្នាខ្លាំង ដោយការសិក្សារបស់អាយជីអ៊ីអែស/ខមភីដ (IGES/COMPED)[២២] បានប៉ាន់ស្មានថា មានតែសំណល់អាហារ តែ ៦១តោនប៉ុណ្ណោះ ដែលត្រូវបានបង្កើតមួយថ្ងៃ ដែលស្មើនឹង៤៧% នៃសំណល់រឹងសរុបដែលបានប៉ាន់ស្មានថាមាន ១៣០ តោន/ថ្ងៃ។ ដោយមានភាពខុសគ្នាធំនេះ សមាសភាព នៃសំណល់រឹងត្រូវបានបង្ហាញត្រួសៗនៅក្នុងរូបភាពខាងក្រោមដោយផ្អែកលើសមាសភាពជាមធ្យមនៃសរីរាង្គ ៧០% សំណល់ផ្សេងៗ ៣០% និងភាគរយទាក់ទងផ្សេងទៀតសម្រាប់សមាសភាគរង។

រូបភាព ១៣៖ ការប៉ាន់ប្រមាណត្រួសៗនៃសមាសធាតុសំណល់ក្នុងក្រុងបាត់ដំបង[២៣]




[២០] របៀបនៃការបង្កើតទម្លាប់៖ Modelling habit for formation in the real world, Pillippa Lally et all, European Journal of Social Psychology, ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩

[២១] ការប៉ាន់ស្មានពីប្រភពមួយចំនួន តាមរយៈការកំណត់សំគាត់របស់ UNIDO និង វេបសាយរបស់ COMPED (https://comped-cam.org/wastesurvey.php ) អាចប្រើបាន ខែ ធ្នូ ឆ្នាំ២០១៨

[២២] IGES/COMPED, Work Plan for Mitigating Short-Lived Climate Pollutants Final Report ខែកុម្ភៈ ឆ្នាំ២០១៧

[២៣] Food waste estimates: IGES/COMPED 2017. Other estimates: average from UNIDO's notes and the COMPED វេបសាយ (https://comped-cam.org/wastesurvey.php).

### ២.៤.៣. ការទុកដាក់ ប្រមូល និងការញែកសំណល់រឹង

អ្នកបង្កើតសំរាមភាគច្រើនមិនធ្វើការញែក និងទុកដាក់សំរាមទាំងអស់ទេ។ ទោះយ៉ាងណាក៏ដោយ វាគួរឱ្យកត់សម្គាល់ដែរថា ៨៨% នៃគ្រួសារទាំងអស់បានញែកសំរាមដែលអាចយកទៅកែច្នៃឡើងវិញ ដើម្បីលក់ទៅឱ្យអេតចាយ ដោយទទួលបានប្រាក់ចំណូលជាមធ្យមប្រហែល ២ ដុល្លារក្នុងមួយគ្រួសារក្នុងមួយខែ ដែលរបស់ទាំងនោះជាទូទៅគឺកំប៉ុងអាលុយមីញ៉ូម[២៤]។ គេក៏ដឹងដែរថា គ្រួសារប្រហែល ៦០% ផ្ទុកសំរាមចោលក្នុងថង់ប្លាស្ទិក និងប្រមាណ ១៥% ចោលសំរាមនៅក្នុងធុង ហើយនៅសល់ប៉ុន្មានទៀត ប្រើមធ្យោបាយផ្សេងៗ ឬគ្មានការទុកដាក់សំរាមទាល់តែសោះ។ ក្រៅពីនេះ គ្រួសារខ្លះធ្វើជីកំប៉ុសសំណល់រឹងរបស់ខ្លួន។

គួរកត់សម្គាល់ថាប្រាក់ចំណូល ២ដុល្លារអាមេរិកក្នុងមួយខែ បានពីការលក់របស់ដែលអាចកែច្នៃទៅអេតចាយ គឺស្មើទៅនឹងថ្លៃបង់សេវា ដែលគ្រួសារមធ្យមពេញចិត្តនឹងបង់ និងស្ថិតក្នុងចន្លោះថ្លៃប្រមូលដែលបានអនុញ្ញាតដូចមានចែងក្នុងច្បាប់។ ដូច្នេះវាមានន័យថាការប្រមូលសំរាមមិនចោទសម្រាប់គ្រួសារតូចៗទេ[២៥]។

#### ការផ្តល់ឲ្យធុងសំរាមសាធារណៈ

ក្រុមហ៊ុនសេវាកម្មប្រមូលសំរាមឯកជនទាំង ២ គឺទទួលខុសត្រូវក្នុងការផ្គត់ផ្គង់ធុងសំរាមសាធារណៈ៖

- ក្រុមហ៊ុន ស៊ីន ទ្រី ៖ ផ្អែកលើការប្រជុំជាមួយប្រធានសាខាក្រុមហ៊ុនស៊ីន ទ្រី ខេត្តបាត់ដំបង ក្រុមហ៊ុនស៊ីនទ្រីផ្តល់ធុងសំរាមសាធារណៈចំនួន ៤៥ (ធុង ៣០ មានចំណុះ ១៤០លីត្រ និងធុង ១៥ មានចំណុះ ២៤០លីត្រ) ដោយដាក់ពង្រាយនៅតាមសួនច្បារសាធារណៈមួយចំនួន។ ប្រធានគ្រប់គ្រងក៏បានបញ្ជាក់ដែរថា មានធុងស្តុកសំរាមនៅផ្សារ ចំនួន ៩កន្លែង។ ដោយឡែក ធុងស្តុកសំរាមមួយនៅផ្សារជ្រៃក្នុងស្រុកថ្មគោលក្បែរនោះ និងមួយទៀតយកទៅរក្សាទុកនៅយានដ្ឋានក្រុមហ៊ុនស៊ីន ទ្រី ដើម្បីថែទាំបណ្តោះអាសន្ន។ លើសពីនេះទៀត ដូចដែលបានសង្កេតឃើញនៅក្នុងបទសម្ភាសន៍នៅតាមផ្សារថា មិនឃើញមានធុងស្តុកសំរាមមួយដែលត្រូវមាននោះ នៅផ្សារបឹងឈូកទេ។ ហេតុដូច្នេះហើយបច្ចុប្បន្ននេះមានតែធុងស្តុកសំរាមចំនួន ៦ ប៉ុណ្ណោះ ដែលត្រូវបានប្រើប្រាស់សម្រាប់ការស្តុកសំរាម នៅផ្សារភ្នពុយមានចំនួន ២ និងមានមួយៗនៅផ្សារណាត់/ផ្សារធំ/ផ្សារកណ្តាល/ផ្សារលើ/បុរីរចេក និងផ្សារវត្តតាមឹម (បង្ហាញក្នុងរូបភាពទី ១៤)។
- ក្រុមហ៊ុនលៀប លឹម៖ យោងតាមវិសាលភាពរបស់សាលាក្រុងដែលបានកំណត់ការងាររបស់ក្រុមហ៊ុនលៀប លឹម នៅឆ្នាំ២០១៨ និងបានផ្ទៀងផ្ទាត់ជាមួយម្ចាស់ក្រុមហ៊ុនបានឱ្យដឹងថា មានធុងសំរាមចំនួន ១៥០ធុង (ធុង ១០០ មានចំណុះ ៦០លីត្រ និងធុង ៥០ ទៀត មានចំណុះ ២៤០ លីត្រ)។ រដ្ឋបាលក្រុងបានអំពាវនាវឱ្យដាក់ធុងសំរាមទាំងនេះនៅតាមសួនច្បារសាធារណៈ សាលារៀនមួយចំនួន និងវត្តមួយចំនួន នៅសង្កាត់កណ្តាលចំនួន ៣ គឺសង្កាត់ស្វាយប៉ោ សង្កាត់រតនៈ និងសង្កាត់ព្រែកព្រះស្តេច។ គេកត់សម្គាល់ឃើញថាធុងខ្លះត្រូវបានគេលួច ឬខូច។ មានការប៉ាន់ស្មានក្នុងកំឡុងពេលប្រមូលទិន្នន័យថា ប្រហែល ៥០ ភាគរយនៃធុងសំរាម (ប្រហែល ១០០ធុង) នៅសល់ហើយភាគច្រើននៅតាមសួនច្បារសាធារណៈ ដូចមានបង្ហាញក្នុងរូបភាពទី ១៤។

[២៤] ទិន្នន័យស្ទង់មតិសេដ្ឋកិច្ច-សង្គមដែលប្រមូលបាននៅចុងឆ្នាំ២០១៧ នៃគម្រោងទន្លេសាប ២ របស់ ធនាគារអភិវឌ្ឍអាស៊ី

[២៥] IGES/COMPED, Work Plan for Mitigating Short-Lived Climate Pollutants Final Report, ខែកុម្ភៈ ឆ្នាំ២០១៧

## រូបភាពទី ១៤៖ ផែនទី នៃទីតាំងស្តុកសំណល់រឹងជាសាធារណៈក្នុងក្រុងបាត់ដំបង




### ការប្រើប្រាស់ធុងសំរាម និងធុងដាំស្វ៊ែរ

គួរកត់សម្គាល់ថា កង្វះការរៀបចំ និងលើកកម្ពស់របស់ធុងស្តុកសំរាមមិនបានជួយសម្រួលដល់ការប្រើប្រាស់ទេ។ គេរកឃើញនៅផ្សារភ្ជុំយថា អ្នកសម្អាតមិនបានប្រើធុងសំរាមទេ (បើទោះបីធុងនៅទំនេរមិនទាន់ពេញក៏ដោយ) ហើយបន្តបោះចោលសំណល់រឹង (ភាគច្រើនជាសំណល់សរីរាង្គ) នៅលើដីក្បែរផ្សារ (សូមមើលរូបថតក្នុងរូបភាពទី ១៥)។

ជាពិសេសនៅតាមផ្សារ គឺមិនមានកន្លែងស្តុកសំរាមនៅខាងក្នុងផ្សារទេ ដូច្នេះវាត្រូវបានបោះចោលនៅលើដីដើម្បីឱ្យអ្នកសម្អាតមកប្រមូលយក។ នៅខាងក្រៅផ្សារ មានធុងសំរាម (ផ្សារមួយ មានធុងសំរាមចំនួនពីរ) ដែលផ្តល់ដោយក្រុមហ៊ុនស៊ីន ទ្រី ដែលមិនគ្រប់គ្រាន់សម្រាប់ការញែកសំណល់រឹង បណ្តាលឱ្យមានគំនរសំរាមហួសប្រមាណនៅជុំវិញធុងស្តុកសំរាម។ លើសពីនេះទៀតនោះ

## រូបភាពទី ១៥៖ រូបភាពពីផ្សារភ្ជុំយ







គឺបញ្ហាអ្នកជិតខាងយកសំរាមមកបោះចោល នៅក្នុងធុងទាំងនេះដែរ ជាងការប្រើប្រាស់សេវាកម្មប្រមូលតាមដងផ្លូវ។

- មានតែសង្កាត់ស្វាយប៉ោប៉ុណ្ណោះដែលមានធុងស្តុកសាធារណៈ។
- ផ្សារណាត់/ផ្សារធំ/ផ្សារកណ្តាល តាមផ្សារនីមួយៗមានធុងស្តុកសំរាមតែមួយ ដែលជាលទ្ធផលមានគំនរសំរាមនៅជុំវិញនោះ ហើយតម្រូវឱ្យក្រុមហ៊ុនស៊ីន ទ្រី ចំណាយពេលច្រើនក្នុងការប្រមូល។
- ផ្សារថ្មីមានតែការចាក់សំរាមចំហ (ផ្ទាល់ដី)។
- ផ្សារភ្លើពុយមានធុងស្តុកសំរាមពីរ ប៉ុន្តែមិនបានញែករវាងកាកសំណល់ស្ងួត និងសើមឡើយ។ ម៉្យាងទៀតអ្នកសម្អាតពេលខ្លះមិនដាក់សំណល់រឹងចូលក្នុងធុងសូម្បីតែពេលដែលវាមិនពេញក៏ដោយ ដោយសារតែកម្ពស់របស់ធុងនោះ។

## ការប្រមូល

សេវាកម្មប្រមូលត្រូវបានបែងចែកជាពីរប្រភេទធំៗគឺ៖

- **ការប្រមូលផ្លូវការ៖** រួមមានក្រុមហ៊ុនស៊ីន ទ្រី សម្រាប់សង្កាត់ចំនួន ៨ ក្រុមហ៊ុនលៀប លឹម សម្រាប់សង្កាត់ចំនួន ២ និងសេវាប្រមូលដោយខ្លួនឯងសម្រាប់ផ្សារបឹកឈូក។
- **ការប្រមូលក្រៅផ្លូវការ៖** ហៅថា "អេតចាយ" រួមមាន៖ ការប្រមូលបុគ្គលម្នាក់ៗ ការប្រមូលដោយអេតចាយខ្នាតតូច/មធ្យម និងអេតចាយខ្នាតធំ។

អ្នកប្រមូលតូចៗផ្សេងទៀតមិនត្រូវបានអង្កេតស៊ីជម្រៅនៅក្នុងការសិក្សានេះរួមមាន កសិករដែលប្រមូលកំទេចកំទីសំណល់អាហារ សម្រាប់ចិញ្ចឹមសត្វចិញ្ចឹម ធ្វើជីកំប៉ុសលក្ខណៈគ្រួសារ និងសំរាមមិនមានការគ្រប់គ្រង ឬដុត។ ចំនួនប៉ាន់ស្មាននៃសំណល់រឹងដែលប្រមូលដោយអ្នកប្រមូលទាំងអស់ដែលបានរាយខាងលើត្រូវបានបង្ហាញនៅក្នុងរូបភាពទី ១៦។

រូបភាពទី ១៦៖ ការប៉ាន់ស្មានសំណល់រឹងដែលប្រមូលបាន[២៦]




[២៦] ប្រភពត្រូវបានពិភាក្សាក្នុងផ្នែកខាងក្រោម។ បរិមាណសំណល់រឹងនៃក្រុមហ៊ុន ស៊ីន ទ្រី យោងតាមគម្រោងទន្លេសាប២របស់ធនាគារអភិវឌ្ឍន៍អាស៊ី ប្រមាណ១០ តោនក្នុងមួយថ្ងៃ តែវាអាចតិចជាងនេះ ដែលនេះនឹងបង្កើន បរិមាណសំរាមដែលមិនដឹងឬមិនអាចគ្រប់គ្រងបាន។

## អ្នកប្រមូលសំរាមក្រុមហ៊ុនស៊ីនទ្រី

ក្រុមហ៊ុនស៊ីន ទ្រីបានធ្វើប្រតិបត្តិការនៅខេត្តបាត់ដំបងតាំងពីឆ្នាំ២០១០ ដោយមានកិច្ចសន្យា ១០ឆ្នាំ ជាមួយរដ្ឋបាលក្រុងបាត់ដំបង ដើម្បីផ្តល់សេវាកម្មនៅក្នុងទីក្រុងរហូតដល់ឆ្នាំ២០២០។ យោងតាមកិច្ចសន្យា ក្រុមហ៊ុនស៊ីន ទ្រី គឺត្រូវប្រមូលសំរាមនៅឃុំទាំង ១០ និងទីសាធារណៈនានា ដោយឡែកឃុំពីរក្នុងចំណោមឃុំទាំងដប់នេះត្រូវបានធ្វើកិច្ចសន្យា ឱ្យផ្តល់សេវាដោយក្រុមហ៊ុនលៀប លឹម។ ផែនទីនៃតំបន់សេវាកម្មរបស់ក្រុមហ៊ុនស៊ីន ទ្រី និងចំនួនដងនៃការប្រមូលត្រូវបានបង្ហាញនៅក្នុងរូបភាពទី ១៧ ។ កិច្ចសន្យាត្រូវបានធ្វើបច្ចុប្បន្នភាពនៅឆ្នាំ២០១៧ និងឈានដល់ការបន្តជាថ្មីនៅឆ្នាំ២០២០។

ផ្អែកលើផ្លូវប្រមូល និងកាលវិភាគ និងការសម្ភាសជាលក្ខណៈបុគ្គល និងការពិភាក្សាជាក្រុមជាមួយអ្នករើសសំរាមក្រៅផ្លូវការនៅទីលានចាក់សំរាម ចំនួនសំរាមត្រូវបានប្រមូលរហូតដល់ ១០២ តោន ក្នុងមួយថ្ងៃ (ដែលស្មើនឹង ៧៨% នៃសំណល់សរុបថ្វីបើមានការប៉ាន់ប្រមាណថា យ៉ាងហោចណាស់ សំណល់រឹង ៨% ទៀត បានមកពីក្រៅក្រុងបាត់ដំបងក៏ដោយ) ដូចដែលមានពណ៌នាក្នុងតារាងទី ៤។ ដើម្បីប្រៀបធៀបជាមួយប្រភពផ្សេងទៀត ការសិក្សាសមិទ្ធិលទ្ធភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី បានកត់សម្គាល់ថា ការប៉ាន់ស្មានការប្រមូលសំរាមរបស់ក្រុមហ៊ុនស៊ីន ទ្រី មានចំនួនពី ១៤០ ទៅ ១៤៨ តោន ក្នុងមួយថ្ងៃ ហើយសាលាក្រុងបាត់ដំបងបានរាយការណ៍ថាការប្រមូលរបស់ក្រុមហ៊ុនស៊ីន ទ្រី មានចំនួនប្រមាណ ៨០ តោន ក្នុងមួយថ្ងៃ[២៧]។ កង្វះការកុងសង់ស៊ីសគ្នាក្នុងការកំណត់អត្រាថ្លៃប្រមូលក៏ត្រូវបានកត់សម្គាល់នៅក្នុងរបាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីដែរ ដែលមានការប៉ាន់ប្រមាណបន្ថែមទៀតថា អត្រានៃការប្រមូល ១០០ តោន ក្នុងមួយថ្ងៃ គឺជាការប៉ាន់ស្មានសមហេតុផល បើមើលជាក់ស្តែងផ្អែកតាមចំនួនឡានដឹក និងចម្ងាយទៅទីលានចាក់សំរាម ផ្តល់នូវប្រសិទ្ធភាពនៃការប្រមូលផ្តុំប្រហែល ៧៦% នៃសំណល់រឹងសរុប។

កង្វះទិន្នន័យដែលអាចទុកចិត្តបាន បង្ហាញពីភាពទន់ខ្សោយនៃប្រព័ន្ធត្រួតពិនិត្យ និងសមត្ថភាពរបស់សាលាក្រុង ដើម្បីគ្រប់គ្រងការអនុវត្តកិច្ចសន្យាប្រកបដោយប្រសិទ្ធភាព។ បញ្ហានេះគួរតែត្រូវបានដោះស្រាយដោយបញ្ចូលខចែង ជាក់លាក់មួយចំនួននៅក្នុងកិច្ចសន្យាថ្មីដែលផ្តល់ភារកិច្ចបន្ថែមទៀតដល់ក្រុមហ៊ុនស៊ីន ទ្រី ទាក់ទងនឹងការធ្វើរបាយការណ៍ និងតម្លាភាព។

ជារួម ក្រុមហ៊ុនស៊ីន ទ្រី ខេត្តបាត់ដំបងមានបុគ្គលិក ៧២នាក់ រថយន្ត ១៧គ្រឿង និងឧបករណ៍មួយចំនួនទៀតដូចមានចែងក្នុងឧបសម្ព័ន្ធ៦ ដើម្បីដំណើរការសេវាកម្មរបស់ខ្លួននៅខេត្តបាត់ដំបង។ ថ្លៃសេវាប្រមូលជាទូទៅខុសគ្នាពី ០.៥ ដុល្លារទៅ ៥០ ដុល្លារសម្រាប់គ្រួសារ និងអាជីវកម្មដូចដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ៤ ដោយថ្លៃតាមផ្សារប្រហែល ១៥០ ដុល្លារទៅ ២៣០ ដុល្លារក្នុងមួយខែ[២៨]។ គេប៉ាន់ប្រមាណថាប្រហែលមួយភាគបួននៃគ្រួសារសរុបទាំងអស់នៅក្នុងទីក្រុងនេះ បង់ថ្លៃសេវាកម្មប្រមូលសំរាម។

ត្បិតថាមាន ប្រហែល ៧០ ភាគរយនៃសំរាមដែលបានបង្កើតត្រូវបានប្រមូល តែក៏មានតំបន់ជាច្រើនត្រូវបានគេរាយការណ៍ថា សេវាកម្មនៅមានកម្រិត ឬគ្មានការផ្តល់សេវា ទោះបីជាស្ថិតនៅក្នុងតំបន់សេវាកម្មរបស់ក្រុមហ៊ុនស៊ីន ទ្រី ក៏ដោយ។ ឧទាហរណ៍តំបន់នានានៃឃុំតេនៈមិនដែលឃើញមានសេវាកម្មប្រមូលសំរាមទេ ហើយតំបន់ក្បែរស្ថានីយ៍រថភ្លើងក៏មានសេវាកម្មអន់ដែរ។

[២៧] IGES, Participatory Waste Management Approach for Climate Change Mitigation: The Case of Battambang City, ខែមិថុនា ឆ្នាំ២០១៨

[២៨] ប៉ាន់ស្មានតាមរយៈការសម្ភាសជាមួយអេត ចាយ នៅទីលានលើចំនួនឡានដឹកដែលដឹកសំរាមចូលរៀងរាល់ថ្ងៃ

## តារាងទី ៤៖ បរិមាណប៉ាន់ស្មាននៃសំរាមដែលប្រមូលដោយក្រុមហ៊ុនស៊ីន ទ្រី[២៩]

| ប្រភេទឡានដឹក | ចំនួនឡាន | ចំនួនដងក្នុងការប្រមូលក្នុងមួយថ្ងៃ | បរិមាណប៉ាន់ស្មាននៃសំរាមក្នុងមួយឡាន (តោន) | បរិមាណប៉ាន់ស្មានសំរាមដែលបានប្រមូល (តោន/សប្តាហ៍) | បរិមាណប៉ាន់ស្មានសំរាមដែលបានប្រមូលក្នុងមួយថ្ងៃ (តោន/ថ្ងៃ) |
|---|---|---|---|---|---|
| រថយន្តកៀប - ៥តោន | ៥ | - ថ្ងៃច័ន្ទដល់ថ្ងៃសៅរ៍៖ ៣ដង<br>- ថ្ងៃអាទិត្យ៖ ២ដង | ៥ | ៥០០ | ៧១ |
| រថយន្តកៀប - ១១តោន | ២ | - ១ដង ជារៀងរាល់ថ្ងៃ | ១១ | ១៥៤ | ២២ |
| រថយន្តកៀបសម្រាប់ផ្សារ - ៤តោន | ១ | - ថ្ងៃច័ន្ទដល់ថ្ងៃសៅរ៍៖ ៣ដង<br>- ថ្ងៃអាទិត្យ៖ ២ដង | ៣ | ៦០ | ៩ |
| សរុប | | | | ៧១៤ | ១០២ |

### អ្នកប្រមូលសំរាម លៀប លឹម និងប្រតិបត្តិករបរិក្ខារញែកសំណល់រឹង

ក្រុមហ៊ុនលៀប លឹម ត្រូវបានជ្រើសរើសតាមរយៈការដេញថ្លៃក្នុងឆ្នាំ២០១៥ ដើម្បីផ្តល់សេវាកម្មប្រមូលសំរាមនៅសង្កាត់ចំនួន ២ និងសកម្មភាពអនាម័យបរិស្ថានផ្សេងទៀតនៅទូទាំងក្រុង។ ចាប់តាំងពីពេលនោះមកកិច្ចសន្យានេះត្រូវបានបន្តជារៀងរាល់ឆ្នាំ រហូតដល់ឆ្នាំ២០២០។ លើសពីនេះទៀតសាលាក្រុងបានស្នើសុំឱ្យក្រុមហ៊ុនលៀប លឹម ដំណើរការកន្លែងទាញយកធនធាននៅជិតកន្លែងចាក់សំរាម ទោះបីជាភារកិច្ចនេះមិនត្រូវបានចែងជាផ្លូវការនៅក្នុងកិច្ចព្រមព្រៀងក៏ដោយ។ សកម្មភាពលម្អិតដែលបានព្រមព្រៀងជាមួយសាលាក្រុងរួមមាន៖ ការប្រមូលសំរាមដោយឡាននៅឃុំចំនួន ២ ការប្រមូលសំរាមដោយកង់នៅតំបន់ដែលបានកំណត់ចំនួន ១៤ នៃឃុំទាំងអស់ ការសម្អាតនិងប្រមូលសំរាមនៅតាមទីសាធារណៈចំនួន ១០ កន្លែង ការកាត់តម្រឹមដើមឈើនិងការកាត់ស្មៅនៅតាមទីសាធារណៈចំនួន ៣ កន្លែង ការអប់រំ និងសកម្មភាពលើកកម្ពស់ការយល់ដឹងផ្សេងៗ (រួមទាំងការទិញធុងសំរាមចំនួន ២០០ ដែលមានទំហំខុសៗគ្នា និងថង់ប្លាស្ទិកធំៗ ជាង ២០០០ សម្រាប់ការប្រើប្រាស់ជាសាធារណៈ និងព្រឹត្តិការណ៍សំខាន់ៗ) និងសកម្មភាពបន្ទាប់បន្សំពាក់ព័ន្ធនឹងទឹកកខ្វក់។ សាលាក្រុងបានផ្តល់ថវិកាចំនួន ៥៨១លានរៀល (ប្រហែល ១៤៥.០០០ ដុល្លារអាមេរិក) ដល់ក្រុមហ៊ុនលៀប លឹម សម្រាប់សេវាកម្មទាំងនេះក្នុងឆ្នាំ២០១៨ និង ៥៧៥ លានរៀល (ប្រហែល ១៤៣.០០០ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៩ ។ ចំនួននេះត្រូវនឹងចំនួនទឹកប្រាក់ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្តល់ជូនដល់សាលាក្រុង (១៤០.០០០ ដុល្លារអាមេរិក) ។ ។

[២៩] ប៉ាន់ស្មានតាមរយៈការសម្ភាសជាមួយអេត ចាយ នៅទីលានលើចំនួនឡានដឹកដែលដឹកសំណល់រឹងចូលរៀងរាល់ថ្ងៃ

ផែនទីនៃតំបន់សេវារបស់ក្រុមហ៊ុនលៀប លឹម និងក្រុមហ៊ុនស៊ីន ទ្រី និងចំនួនដងនៃការប្រមូលត្រូវបានបង្ហាញនៅក្នុងរូបភាពទី ១៧ ។

ការសិក្សាសមិទ្ធិលទ្ធភាពស្តីពីកន្លែងទាញយកធនធានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី បានប៉ាន់ស្មានថាសំរាមចំនួន ១០ តោនក្នុងមួយថ្ងៃត្រូវបានប្រមូល[៣០] ដោយក្រុមហ៊ុនលៀប លឹម យ៉ាងណាមិញម្ចាស់ក្រុមហ៊ុនប៉ាន់ស្មានថាមានសំរាមតែប្រហែល ៤ តោនក្នុងមួយថ្ងៃប៉ុណ្ណោះ ដែលត្រូវបានគេយកទៅទីលានចាក់សំរាម។

ទោះយ៉ាងណាក៏ដោយ ផ្អែកលើទំហំ និងចំនួនឡានប្រមូលសំរាមដូចដែលបានរបាយការណ៍ដោយក្រុមហ៊ុនលៀប លឹម គេបានប៉ាន់ស្មានថា មានសំរាមប្រមាណតែ ២ តោនប៉ុណ្ណោះដែលត្រូវបានប្រមូលក្នុងមួយថ្ងៃដូចមានបង្ហាញក្នុងតារាងទី ៥ ។

លើសពីនេះទៀត ក្រុមហ៊ុនលៀប លឹម កំពុងផ្តល់សេវាកម្មប្រមូលសំរាមនៅសង្កាត់ចំនួន ២ ដែលមិនស្ថិតក្រោមទំនួលខុសត្រូវរបស់សាលាក្រុង។

## តារាងទី ៥៖ បរិមាណប៉ាន់ស្មាននៃសំរាមដែលប្រមូលដោយក្រុមហ៊ុនលៀប លឹម

| ទំហំឡាន (ម៣) | ដង់ស៊ីតេសំរាម (តោន/ម៣) | ភាពញឹកញាប់ និងកាលវិភាគ | ចំនួនសំរាមពីចំនួនឡានក្នុងមួយអាទិត្យ | បរិមាណប៉ាន់ស្មាននៃសំរាមដែលបានប្រមូល (តោន/សប្តាហ៍) | បរិមាណប៉ាន់ស្មាននៃសំរាមដែលបានប្រមូល (តោន/ថ្ងៃ) |
|---|---|---|---|---|---|
| ៦ | ០.៣ | ម្តងក្នុងមួយសប្តាហ៍ (អាទិត្យ ច័ន្ទ និងអង្គារ | ៧ | ១២.៦ | ២ |

## រូបភាពទី ១៧៖ ផែនទី និង ផ្លូវប្រមូលសំណល់រឹងក្នុងនៃតំបន់សេវាកម្ម ក្រុមហ៊ុន ស៊ីន ទ្រី និង លៀប លឹម ក្រុងបាត់ដំបង




**កំណត់សម្គាល់៖**

- ទំហំឡាននៃក្រុមហ៊ុន ស៊ីន ទ្រី៖ បន្ទាត់ដិត សំដៅឡានដឹក ទំហំ ១១តោន និង បន្ទាត់ដាច់ដាច់ សំដៅឡានទំហំ៥តោន
- កាលវិភាគនៃសេវាកម្មប្រមូល **ពណ៌ខៀវ** សំដៅការប្រមូលរាល់ថ្ងៃ **ពណ៌ទឹកក្រូច** សំដៅការប្រមូលថ្ងៃច័ន្ទ ថ្ងៃពុធ ថ្ងៃសុក្រ **ពណ៌លឿង** សំដៅការប្រមូល២ថ្ងៃម្តង ពណ៌ខ្មៅ សំដៅការប្រមូលថ្ងៃអង្គារ ថ្ងៃព្រហស្បតិ៍ ថ្ងៃសៅរ៍
- **បន្ទាត់ពណ៌ក្រហម** សំដៅតំបន់ដែលស្ទួនគ្នារវាងក្រុមហ៊ុន ស៊ីន ទ្រី និង ក្រុមហ៊ុន លៀប លឹម

[៣០] SCE/Gret/Group Huit, ADB Tonle Sap Basin Feasibility Study ខែមីនា ២០១៨ ទំព័រ ១៦០

## អ្នកប្រមូលសំរាមឯកជនតាមផ្សារ

ផ្សារបឹងឈូកមានសេវាកម្មប្រមូលសំរាមឯកជនផ្ទាល់ខ្លួន ដែលប្រតិបត្តិការបីដងក្នុងមួយថ្ងៃ (ប្រហែលម៉ោង ៥ ព្រឹក ម៉ោង ២ រសៀល និងម៉ោង ៥ ល្ងាច) ដូចដែលមានក្នុងគម្រោងអាយជីអ៊ីអែស (IGES)។ អ្នកប្រមូលសំរាមឯកជនទាំងនោះមានឡានដឹកសំរាម ៣តោន ចំនួន ២គ្រឿង និងមានបុគ្គលិកប្រហែល ១២ នាក់ដែលបានយកចិត្តទុកដាក់ចំពោះសេវាកម្មនេះ។ ផ្សារនៅតែបង់លុយឱ្យក្រុមហ៊ុនស៊ីន ទ្រី សម្រាប់សេវាទីលានចាក់សំរាម ដែលមានតម្លៃប្រហែល ២០០ ដុល្លារក្នុងមួយខែ ដូចដែលបានបញ្ជាក់ដោយក្រុមហ៊ុនស៊ីន ទ្រី។ អ្នកគ្រប់គ្រងផ្សារបានសង្កត់ធ្ងន់ថា សេវាកម្មនេះប្រមូលសំរាមសរុបចំនួន ១០តោនក្នុងមួយថ្ងៃ ដែលមានបរិមាណខ្ពស់ជាងបរិមាណប៉ាន់ស្មានសំណល់រឹងដែលបានបង្កើតនៅផ្សារនេះ។

## ការប្រមូលក្រៅផ្លូវការ៖ អេតចាយ

វិស័យប្រមូលក្រៅផ្លូវការ គឺជាចរន្តប្រមូលយ៉ាងសកម្មសម្រាប់ការកែច្នៃឡើងវិញនៅក្នុងប្រទេសកម្ពុជាដែលប្រមូលបានប្រហែល ១០-១៥% នៃសំណល់រឹងដែលបានបង្កើតនៅក្នុងក្រុងបាត់ដំបង។ លំហូរនៃសកម្មភាពប្រមូលក្រៅផ្លូវការត្រូវបានបង្ហាញនៅក្នុងរូបភាពទី ១៨ ដោយផ្នែកនេះផ្តោតលើអ្នកប្រមូលទិញជាជាងផ្តោតលើស្តង់អេតចាយ ដោយសារពួកគេផ្តល់សេវាកម្មប្រមូលតាមផ្ទះ។

ចំនួននៃអ្នកប្រមូលក្រៅផ្លូវការនីមួយៗមិនត្រូវបានគេស្គាល់ជាទូទៅទេ។ តាមរយៈការប្រមូលព័ត៌មានពីអ្នកពាក់ព័ន្ធផ្សេងៗ គេអាចសន្និដ្ឋានថាមានអ្នករើសអេតចាយប្រហែលពី ៥០ ទៅ ៦០នាក់នៅទីលានចាក់សំរាម (៥០ភាគរយជាស្ត្រី និង ៣០ភាគរយជាកុមារអាយុប្រហែល ៨ ទៅ ១២ឆ្នាំ ) ហើយមានអ្នករើសអេតចាយប្រហែល ១៥០ ទៅ ២០០នាក់នៅក្នុងទីក្រុង (យ៉ាងណាមិញអាចមានច្រើនជាងនេះ)។ តាមរយៈបទសម្ភាសន៍ គេប៉ាន់ប្រមាណថាប្រភេទទាំងពីរចំណាយពេលពី ៦ ទៅ ៨ម៉ោងក្នុងមួយថ្ងៃធ្វើការ និងអាចរកចំណូលបានប្រហែល ៣០ ទៅ ៥០ដុល្លារអាមេរិកក្នុងមួយសប្តាហ៍ ដែលអាចប្រហែលនឹងប្រាក់ឈ្នួលអប្បបរមា១៨២ ដុល្លារក្នុងមួយខែនៅឆ្នាំ២០១៩ ក្នុងឧស្សាហកម្មកាត់ដេរ។

តារាងទី ៦៖ បរិមាណប៉ាន់ស្មាននៃសំរាមដែលប្រមូលដោយផ្សារបឹងឈូក

| ទំហំឡាន (តោន) | បរិមាណប៉ាន់ស្មាននៃសំរាមក្នុងមួយឡាន (តោន) | បរិមាណសំរាមអាស្រ័យលើចំនួនឡានក្នុងមួយថ្ងៃ | បរិមាណប៉ាន់ស្មាននៃសំរាមដែលបានប្រមូល (តោន/ថ្ងៃ) |
|---|---|---|---|
| ៣ | ២ | ៥ | ១០ |

រូបភាពទី ១៨៖ លំហូរនៃការប្រមូលក្រៅផ្លូវការ



ទាក់ទងនឹងស្តង់អេតចាយ មានប្រហែល ២០ ស្តង់តូច និងមធ្យម ហើយមានស្តង់អេយចាតធំចំនួន ២កន្លែងនៅខេត្តបាត់ដំបង។ ជាធម្មតា ស្តង់អេតចាយតូច/មធ្យមទទួលបានប្រាក់ចំណេញ គម្លាតពី ១០% ទៅ ១៥%។

ក្រៅពីទីលានចាក់សំរាម អ្នកប្រមូលអេតចាយ នៅរាយប៉ាយ និងពិបាកដឹងពីទីតាំងណាស់។ ទោះយ៉ាងណាក៏ដោយមានទីតាំងគួរឱ្យកត់សម្គាល់ចំនួនពីរដែលអ្នកប្រមូលក្រៅផ្លូវការបានប្រមូលផ្តុំ ដូចបានបង្ហាញនៅក្នុងរូបភាពទី ១៩។ ទីតាំងទី ១ គឺនៅក្បែរមន្ទីរពេទ្យបង្អែកខេត្តបាត់ដំបងក្នុងភូមិព្រែកមហាទេពដែលនៅជាប់នឹងស្តង់អេតចាយតូចមួយ និងទី ២ ស្ថិតនៅតាមបណ្តោយដងស្ទឹងសង្កែនៅជិតនាគសន្តិភាព។

តាមការប៉ាន់ស្មាន បរិមាណសំរាមដែលប្រមូលបានពីវិស័យក្រៅផ្លូវការក្នុងខេត្តបាត់ដំបងតាមរយៈស្តង់អេតចាយមានរហូតដល់ ១៧តោនក្នុងមួយថ្ងៃ (ដូចបង្ហាញក្នុងតារាងទី ៧ បង្ហាញពីប្រភេទនៃសំរាម តម្លៃ និងបរិមាណដែលប្រមូលបានតាមកម្រិតរៀងៗខ្លួន។ ជាទូទៅស្ថានភាពហាក់ដូចជាកាន់តែប្រសើរសម្រាប់អេតចាយនៅក្នុងក្រុង។ លក្ខខណ្ឌការងារ និងគុណភាពនៃសំរាមកាន់តែមានភាពប្រសើរឡើង ដែលផ្តល់នូវតម្លៃខ្ពស់ជាងមុន។ អេតចាយនៅទីលានចាក់សំរាមផ្ទុយទៅវិញ មានជម្រើសទីពីរសម្រាប់សម្ភារៈដែលអាចកែច្នៃឡើងវិញបាន។ ទោះយ៉ាងណាក៏ដោយ ចំណុចនេះ នាំឱ្យពួកគេផ្តោតលើថង់ប្លាស្ទិក ដោយសារតាមខ្នងផ្ទះនីមួយៗ និង/ឬ អេតចាយនៅក្នុងទីក្រុង មិនអាច ឬមិនចង់ខ្វាយខ្វល់នឹងរឿងថង់ប្លាស្ទិកនេះប៉ុន្មានទេ។

## រូបភាព ១៩៖ ទីតាំងខ្លះៗនៃអ្នកប្រមូលសំរាមក្រៅផ្លូវការក្នុងក្រុងបាត់ដំបង



តារាងទី ៧) គេប៉ាន់ប្រមាណថា សំរាមពី ២ ទៅ ២,៥ តោនមានប្រភពពីអ្នករើសអេតចាយនៅទីលានចាក់សំរាម និងពី៥ ទៅ ៧ តោនគឺមកពីអ្នករើសអេតចាយក្នុងក្រុង (ជួនកាលវាអាចឡើងដល់ ១០ តោន ឬលើសនេះ) ហើយនៅសល់ប៉ុន្មានទៀតត្រូវបានសន្មតថាមានប្រភពមកពីតាមខ្នងផ្ទះ ឧស្សាហកម្ម ឬពីខាងក្រៅក្រុង។

តារាងទី ៧ បង្ហាញពីប្រភេទសំណល់រឹង តម្លៃ និងបរិមាណសំណល់រឹងដែលប្រមូលបានតាមកម្រិតនីមួយៗនៃការប្រមូលក្រៅផ្លូវការ។

## តារាងទី ៧៖ តម្លៃ និងបរិមាណនៃវត្ថុដែលអាចកែច្នៃឡើងវិញ បង់ថ្លៃដោយអ្នកប្រមូលទៅស្តង់អេតចាយខ្នាតតូច និងមធ្យម

| សំណល់រឹងដែលអាចកែច្នៃ | តម្លៃ[៣១] (ដុល្លារ/គ.ក) | សំណល់រឹងដែលប្រមូលបានពីអ្នករើសអេតចាយនៅទីលានចាក់សំរាម (គ.ក/ថ្ងៃ) | សំណល់រឹងដែលប្រមូលបានពីអ្នករើសអេតចាយនៅក្នុងក្រុង (គ.ក/ថ្ងៃ) | សំណល់រឹងដែលបានប្រមូលក្នុងមួយស្តង់អេតចាយ (គ.ក/ថ្ងៃ) |
|---|---|---|---|---|
| កំប៉ុងអាលុយមីញ៉ូម | ១.០០ | ០.៩ | ០.៩ | ៨២.៥ |
| កម្ទេចកម្ទីអាលុយមីញ៉ូម | ០.៦៣ | ០.៤ | ០.៧ | ១០.៥ |
| PET ដូចជាដបទឹកសុទ្ធ | ០.២៥ | ៥.១ | ៦.៤ | ១០៧.៥ |
| ប្លាស្ទិកលាយគ្នា (HDPE, PP, and LDPE) | ០.២០ | ៦.៩ | ៤.២ | ៧០.០ |
| ភីវីស៊ី (PVC) | ០.០៥ | ០.០ | ០.០ | ២០.០ |
| ថង់ប្លាស្ទិក | ០.០៨ | ១២.៤ | ០.០ | ០.០ |
| ដែក១ (រឹងជាង) | ០.២០ | ១.៨ | ២.៤ | ១៣៥.០ |
| ដែក២ (ទន់ជាង) | ០.១៥ | ១.៦ | ១.៨ | ៧០.០ |
| ស័ង្កសី ដូចជាកំប៉ុងទឹកដោះគោ | ០.១០ | ៤.២ | ២.៦ | ៨២.៥ |
| កែវ | ០.០៦ | ៣.៧ | ៣.០ | ១០.០ |
| ក្រដាសកេស | ០.០៨ | ៣.១ | ១២.១ | ២៦០.០ |
| ទង់ដែង | ៤.១៣ | ០.១ | ០.១ | ២.០ |
| សំណល់រឹងជាមធ្យមដែលប្រមូលបានក្នុងម្នាក់ក្នុងមួយថ្ងៃ | | ៤០ | ៣៤ | ៨៥០ |
| ចំនួនប៉ាន់ស្មាននៃអ្នករើសអេតចាយ | | ៥០ ទៅ ៦០ | ១៥០ ទៅ ២០០ | ២០ (តូច/មធ្យម) |
| សំណល់រឹងដែលប្រមូលបានសរុបក្នុងមួយថ្ងៃ | | ប្រហែល ២ ទៅ ២.៥ តោន | ប្រហែល ៥ ទៅ ៧ តោន | ប្រហែល ១៧ តោន |

[៣១] តម្លៃនេះជាតម្លៃនៅតាមស្តង់អេតចាយតូច មធ្យម ទៅអ្នកប្រមូលយកមកលក់។ តម្លៃដែលអ្នកប្រមូលទិញពីតាមផ្ទះទាបជាងនេះ១០%។ នៅពេលដែលស្តង់អេតចាយតូច មធ្យម ទៅស្តង់ធំ តម្លៃខ្ពស់ជាងនេះ ១៥%។ តម្លៃនាំចេញមិនត្រូវបានដឹងទេ។

គួរកត់សម្គាល់ដែរថា ស្តង់អេតចាយមួយចំនួនមិនទិញ និងលក់ថង់ប្លាស្ទិក ដែលត្រូវបានប្រមូលដោយអ្នករើសអេតចាយនៅទីលានចាក់សំរាមទេ ដោយសារហេតុផលមួយចំនួន៖

- អ្នករើសអេតចាយមួយចំនួននៅក្នុងក្រុងមិនដឹងថាថង់ប្លាស្ទិកត្រូវបានទិញដោយ សហគ្រាសប្លាស្ទិកបាត់ដំបង (BPP) សម្រាប់ការកែច្នៃឡើងវិញទេ។
- ពួកគេខ្លះដឹងថាអាចលក់ថង់ប្លាស្ទិកបាន ប៉ុន្តែពួកគេមិនចង់ប្រមូលទេ ពីព្រោះវាមានតម្លៃទាប (ត្រឹមតែ ៣០០ ទៅ ៥០០ រៀល/គីឡូក្រាម) ហើយវាត្រូវការពេលវេលា និងទីកន្លែងដើម្បីប្រមូល និងទុកដាក់។

សរុបមក វិស័យសំណល់រឹងគួរតែជួយជំរុញឱ្យមានការបង្កើនតម្លៃវត្ថុសំណល់ ដែលអ្នករើសអេតចាយប្រមូលបានឱ្យមានតម្លៃខ្ពស់ ជាជាងឱ្យក្រុមហ៊ុនស៊ីន ទ្រី ឬលាភលីម ព្រោះពួកគេខំដើរប្រមូលតាមផ្ទះ ដែលពួកគេចំណាយលើសំរាមដែលអាចកែច្នៃឡើងវិញក្នុងតម្លៃខ្ពស់។ ការញែកសំរាមនឹងជួយឱ្យមានការកែច្នៃឡើងវិញបានកាន់តែច្រើន ដើម្បីទាញយកសំណល់ទាំងនោះមកប្រើឡើងវិញ ព្រោះការញែកសំរាមរួចស្រេចដូច្នេះងាយស្រួលញែកវត្ថុយកមកកែច្នៃ។ ព្រោះហេតុដូច្នេះហើយ យុទ្ធនាការបង្កើតទំនាក់ទំនងគ្នារវាងតួអង្គពាក់ព័ន្ធ គួរតែគូសបញ្ជាក់ការទាញយកនូវផលជានពីសំរាមកែច្នៃ ប្រាប់ទៅអ្នករើសអេតចាយ និងបញ្ជូនកាកសំណល់សរីរាង្គទៅឱ្យអង្គការខមភីដ (COMPED)។ លើសពីនេះទៀត ពួកគេគួរបង្កើតប្រព័ន្ធប្រមូលវត្ថុដែលអាចកែច្នៃឡើងវិញបាន សម្រាប់អ្នករើសអេតចាយ (ជំនួសឱ្យការរើសច្របល់គ្នា ហើយណាមួយវារញ៉េរញ៉ៃផង)។

គួរកត់សម្គាល់ថា ការឱ្យក្រុមអេតចាយចូលរួមការងារនេះ មិនជាងាយស្រួលពេកទេ ព្រោះពួកគេគ្មានអង្គការកណ្តាល ហើយនៅរាយប៉ាយពេញទីក្រុង។ ទោះយ៉ាងណាក៏ដោយ វាចាំបាច់ក្នុងការដោះស្រាយបញ្ហាសុខភាព និងអនាម័យ ការញែកសំណល់អនាម័យសាធារណៈជាដើម ក៏ដូចជាស្វែងយល់ពីបញ្ហាប្រឈម និងឱកាសផ្សេងៗរបស់ពួកគេ។ ក្នុងសិក្ខាសាលាពិគ្រោះយោបល់រវាងភាគីពាក់ព័ន្ធមួយ ចៅសង្កាត់យល់ព្រមសម្របសម្រួលជាមួយក្រុមអេតចាយ ដែលនេះគឺជាឱកាសដែលពួកគេអាចចូលរួមក្នុងយុទ្ធនាការនេះបាន។ ហេតុដូច្នេះ ពួកគេគួរតែត្រូវបាន ចាត់ទុកថាជាចំណុចគន្លឹះសម្រាប់រួមគ្នាធ្វើការងារនេះឱ្យបានកាន់តែល្អជាងនេះថែមទៀត។

## ២.៤.៤. ការកែច្នៃ និងការបោះចោល

### សហគ្រាសប្លាស្ទិកបាត់ដំបង[៣២]៖ អ្នកកែច្នៃប្លាស្ទិក

សហគ្រាសប្លាស្ទិកបាត់ដំបង (ហៅម្យ៉ាងទៀតថាផលិតផលប្លាស្ទិកបាត់ដំបង) មានអាយុកាល ៣ ឆ្នាំ ដោយផលិតតែគ្រាប់ប្លាស្ទិកសម្រាប់កែច្នៃពីថង់ប្លាស្ទិក។ ផលិតផលប្លាស្ទិកបាត់ដំបង ទទួលទិញថង់ប្លាស្ទិកពីអេតចាយដែលបានពីទីលានចាក់សំរាមខេត្តបាត់ដំបង និងខេត្តសៀមរាប ទោះបីយ៉ាងណាប្រភពពីខេត្តសៀមរាបមានតម្រូវជាងដោយសារ ថង់ទាំងនោះមានទំហំធំជាង។ ប្រភពផ្សេងទៀតរួមមាន ប្រជាជន និងស្តង់អេតចាយក្នុងខេត្តបន្ទាយមានជ័យ។ ផលិតផលប្លាស្ទិកបាត់ដំបងចំណាយប្រាក់ពី ២០០ ទៅ ៨០០ រៀលក្នុង ១ គីឡូក្រាម អាស្រ័យលើភាពស្អាត និងថា តើវាអាចប្រើប្រាស់បានឬអត់ (លម្អិតបន្ថែមទៀតនៅក្នុងរូបភាពទី ២០)។

សមត្ថភាពផលិតរបស់សហគ្រាសនេះ មានបរិមាណ ១,៨តោនក្នុងមួយថ្ងៃ (ប្រហែល ៤៥តោនក្នុងមួយខែ) ប្រសិនបើសិប្បកម្មនេះដំណើរការបាន ២៤ម៉ោង។ ប៉ុន្តែបច្ចុប្បន្នវាផលិតបានប្រហែល ២៥-៣០តោនប៉ុណ្ណោះ ក្នុងមួយខែ។ ប្រាក់ខែអប្បបរមាសម្រាប់បុគ្គលិក ៣៥នាក់ គឺ ១៥០ដុល្លារក្នុងមួយខែ។ បញ្ហាប្រឈមមួយគឺថាមុខតំណែងខ្លះមានចំណូលខ្ពស់ (ដូចជាមុខតំណែងដែលតម្រូវឱ្យកាត់ដេថង់ប្លាស្ទិក) ប៉ុន្តែតួនាទីផ្សេងទៀតមិនបានទទួលចំណូលខ្ពស់ទេ។

យ៉ាងណាមិញ បញ្ជីឧបករណ៍សម្រាប់ផលិតផលប្លាស្ទិកបាត់ដំបងមិនទាន់ត្រូវបានបញ្ចប់ក្នុងការសិក្សានេះក៏ដោយ យូនីដូគ្រោងនឹងបង្កើនសមត្ថភាពប្រព័ន្ធផលិតកម្មរបស់សិប្បកម្មដល់ ៤ ទៅ ៥ តោនក្នុងមួយថ្ងៃ (១០០-១២៥តោន ក្នុងមួយខែ) ដោយផ្តល់ជូននូវ៖

- ម៉ាស៊ីនកិន និងគ្រឿងបន្លាស់
- ម៉ាស៊ីនលាងសម្អាត (នៅដំណាក់កាលទីពីរ/ទីបីរួមមានការលាងស្បោង) និងគ្រឿងបន្លាស់
- ម៉ាស៊ីនសម្ងួត និងគ្រឿងបន្លាស់
- ម៉ាស៊ីនបង្កើតជាគ្រាប់តូចៗ

[៣២] ក្រុមហ៊ុនជាទូទៅត្រូវបានគេស្គាល់ថាជាផលិតផលប្លាស្ទិកបាត់ដំបង គឺត្រូវបានចុះបញ្ជីផ្លូវការថាជា“ សិប្បកម្មកែច្នៃប្លាស្ទិក”។

ផលិតផលប្លាស្ទិកបាត់ដំបងបានលក់គ្រាប់ប្លាស្ទិករបស់ខ្លួនទៅឱ្យប្រទេសថៃ។ ការចំណាយដោយបូកសរុបនឹងការដឹកជញ្ជូន ថ្លៃសេវាព្រំដែន កម្លាំងពលកម្ម និងពន្ធនាំចូលជាទូទៅ ផលិតផលប្លាស្ទិកបាត់ដំបងចំណាយ ២៦.១០០បាត (ប្រហែល ៨៣០ ដុល្លារ) ដើម្បីនាំចេញគ្រាប់ប្លាស្ទិកចំនួន ១២.៥ តោនបាន។ គេសន្មតថាការដំឡើងសមត្ថភាពដែលនឹងផ្តល់ជូនដោយ យូនីដូ នឹងធ្វើឱ្យគ្រាប់ប្លាស្ទិកមានគុណភាពល្អជាងមុន ធ្វើឱ្យគេងាយនឹងចូលមកទាក់ទងផលិតករនេះបាន និងកាត់បន្ថយឈ្មួញកណ្តាលបរទេស។

ផលិតផលប្លាស្ទិកបាត់ដំបងបានបើកដំណើរការជាថ្មីនៅខែសីហា ឆ្នាំ២០១៩ ក្រោមឈ្មោះថ្មី "សិប្បកម្មកែច្នៃប្លាស្ទិក" នៅភូមិតាពូងជើង ឃុំតាពូង ស្រុកថ្មគោល ខេត្តបាត់ដំបង ។ សហគ្រាសនេះបានដំឡើងសមត្ថភាពខ្សែសង្វាក់ផលិតកម្មរបស់ខ្លួន ហើយ ឥឡូវនេះ សហគ្រាសក៏កំពុងផលិតថង់ប្លាស្ទិកដែលមានសាច់ស្វិត ព្រមទាំងនាំចេញគ្រាប់ប្លាស្ទិកទៅប្រទេសថៃផងដែរ។

ជាទ្រឹស្តី បន្ទាប់ពីការដំឡើងសមត្ថភាពទទួលបានពីយូនីដូ សហគ្រាសនឹងមានសមត្ថភាពថ្មី ពោលគឺខ្លួនអាចផលិតប្រភេទប្លាស្ទិកប្រភេទផ្សេងទៀតបាន។ តែទោះយ៉ាងនេះក្តី ក៏សហគ្រាសនេះនៅចង់បន្តផ្តោតលើថង់ប្លាស្ទិកទន់ជាង ជាពិសេសប្រភេទប្លាស្ទិកសម្រាប់ប្រើក្នុងវិស័យឧស្សាហកម្ម។

សិប្បកម្មកែច្នៃប្លាស្ទិកនេះ កំពុងមានវត្តមានក្នុងទីផ្សារ (ដែលមិនមានអ្នកប្រកួតប្រជែងនៅក្នុងតំបន់នេះ ) ដែលបណ្តាលឱ្យសហគ្រាសនេះ អាចត្រួតត្រាតម្លៃទីផ្សារបាន។ សហគ្រាសក៏បានលើកឡើងថា ខ្លួនមិនចង់ប្រកួតប្រជែង និងលូកលាន់ក្នុងបណ្តាញផ្គត់ផ្គង់ដែលពាក់ព័ន្ធនឹងអេតចាយ និងស្តង់អេតចាយទេ ហើយគាត់ក៏មិនមានលំហូរសាច់ប្រាក់ ដើម្បីបង់ថ្លៃខ្ពស់សម្រាប់អេចឌីភីអ៊ី (HDPE) និងអិលឌីភីអ៊ី (LDPE) ដែរ។ ដំណើរការនៃការកែច្នៃអេចឌីភីអ៊ី គឺដូចគ្នានឹងអិលឌីភីអ៊ីដែរ ប៉ុន្តែវាត្រូវការសីតុណ្ហភាពខ្ពស់ជាងនេះ។ វាអាចលាយបញ្ចូលគ្នាទាំងពីរក្នុងកំឡុងពេលដំណើរការកែច្នៃ។

រូបភាពទី ២០៖ ខ្សែសង្វាក់ផលិតកម្មនាពេលបច្ចុប្បន្នរបស់សិប្បកម្មកែច្នៃប្លាស្ទិក



## អង្គការខមភីដៈ កន្លែងធ្វើជីកំប៉ុស

អង្គការខមភីដ (COMPED) គឺជាអង្គការក្រៅរដ្ឋាភិបាលមួយដែលដំណើរការកន្លែងធ្វើជីកំប៉ុសជាប់នឹងដីទីលានចាក់សំរាម (មួយហិកតា) ដែលត្រូវបានផ្ដល់ដោយសាលាក្រុង។ បច្ចុប្បន្នខមភីដ ទទួលបានសំណល់ចម្រុះប្រហែល ៤ ទៅ ៦តោនក្នុងមួយថ្ងៃដែលប្រមូលដោយក្រុមហ៊ុនស៊ីន ទ្រី ពីផ្សារពួកុយ ដែលជាទីផ្សារលក់ដុំនៅកណ្ដាលក្រុង។ សំណល់នេះត្រូវបានបំបែកដោយខមភីដនៅនឹងកន្លែង ដែលឱ្យ លទ្ធផលជាសំណល់សរីរាង្គមានប្រយោជន៍ប្រហែល ២តោនកន្លះ (៥០ ភាគរយ) ។ ទោះយ៉ាងណាក៏ដោយសំណល់ភាគច្រើនដែលបានមកដោយផ្ទាល់ពីអ្នកលក់ (នៅខាងក្នុងទីផ្សារ) មិនសូវប្រេបល់គ្នាទេ (រូបភាពទី ២១)។ ដូច្នេះការណ៍នេះបង្ហាញឱ្យឃើញច្បាស់ណាស់ថា តាមពិតសំណល់មិនមែនច្របល់ឡូកឡំគ្នានៅឯផ្សារឯណោះទេ តែគឺត្រូវបានច្របល់ឡូកឡំគ្នាក្នុងកំឡុងពេលសម្អាតផ្សារ និងប្រមូលសំរាមនេះតែម្ដង។ ដោយសារតែបញ្ហានេះ អង្គការខមភីដ ត្រូវជួលបុគ្គលិកដើម្បីញែកសំរាមដែលបានមកពីក្រុមហ៊ុនស៊ីន ទ្រី ដែលធ្វើឱ្យកើនថ្លៃដើមផលិតកម្ម និងកាត់បន្ថយតម្លៃប្រកួតប្រជែងរបស់ជីកំប៉ុស។ សំណល់ចម្រុះក៏អាចបង្កគ្រោះថ្នាក់ដល់គុណភាពនៃផលិតផលសម្រេចផងដែរ។ សម្ភារៈសរីរាង្គអាចត្រូវបានបំពុលដោយកាកសំណល់គីមីក្នុងកំឡុងពេលដឹកជញ្ជូន។

រូបភាពទី ២១៖ ឧទាហរណ៍នៃសំណល់នៅផ្សារភ្ជួពុយ








ខមភីដរាយការណ៍ថា ប្រតិបត្តិការជីកំប៉ុសបច្ចុប្បន្នមិនផ្ដល់ប្រាក់ចំណេញទេ ហើយត្រូវបានទ្រទ្រង់ដោយប្រាក់ចំណូលផ្សេងទៀតពីសកម្មភាពពិគ្រោះយោបល់របស់អង្គការ។

យូរៗម្ដង ក្រុមហ៊ុនលៀប លឹម ក៏ដឹកសំណល់សរីរាង្គដែលសំបូរទៅដោយកាបូនរហូតដល់ ១០តោនក្នុងមួយខែ (កំណាត់ឈើដែលផ្នែកខ្លះលក់ជាអុស) ទោះយ៉ាងណាក៏ដោយខមភីដ មិនមានមធ្យោបាយសម្រាប់បំបែកសំណល់នេះទៅជាបំណែកតូចៗដែលចាំបាច់ ដើម្បីទទួលបានបរិមាណកាបូនសមាមាត្រអាស៊ូតទេ។ បញ្ហាប្រឈម គឺមានការប្រកួតប្រជែងសម្រាប់វត្ថុធាតុដើមទាំងនេះ (រោងចក្រស៊ីម៉ង់ត៍និងឥដ្ឋ និងការប្រើប្រាស់នៅតាមគ្រួសារដូចជាវត្ថុធាតុដើមសម្រាប់ដុតជាដើម)។

សមត្ថភាពអតិបរមាត្រូវបានគេប៉ាន់ប្រមាណថា យ៉ាងហោចក៏សហគ្រាសអាចទទួលយកសំណល់សរីរាង្គប្រមាណ ៨-១០តោន/ថ្ងៃបាន។ រោងបេតុងបច្ចុប្បន្នសម្រាប់ធ្វើជីកំប៉ុសមានទំហំប្រហែល ៤០០-៥០០ ម៉ែត្រការ៉េ ប៉ុន្តែគំនរបច្ចុប្បន្នខ្ពស់ពេកមិនមានបុគ្គលិកគ្រប់គ្រាន់ក្នុងការបង្កើនប្រតិបត្តិការទេ ហើយការបង្កើនគំនរថ្មីក៏ថ្លៃដែរ។ ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការ និងលទ្ធផលអង្គការយូនីដូគ្រោងនឹងផ្ដល់នូវឧបករណ៍ដូចខាងក្រោម៖

- ឧបករណ៍ចិញ្ច្រាំដោយដៃខ្នាតតូច សម្រាប់សំណល់សម្បូរបរិមាណកាបូនច្រើនដូចជាសំបកដូង ឬកំណាត់ឈើ
- ម៉ាស៊ីនបង្វិលដើម្បីច្របល់គំនរជីកំប៉ុសកាន់តែមានប្រសិទ្ធភាព
- ឧបករណ៍ញែក
- បង្កើនផ្ទៃដីគ្របដណ្ដប់ដល់ ៦០០ ម៉ែត្រការ៉េ (បច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលដេញថ្លៃ) ។

គេប៉ាន់ប្រមាណថា ក្រោយពេលទទួលបានការដំឡើងសមត្ថភាពនេះ បរិក្ខារនេះអាចកើនសមត្ថភាពទទួលសំណល់ពី ១០-១២ តោនក្នុងមួយថ្ងៃនៅចុងឆ្នាំ២០១៩។

## រូបភាពទី ២២៖ ខ្សែសង្វាក់ផ្គត់ផ្គង់បច្ចុប្បន្នរបស់ COMPED



## មជ្ឈមណ្ឌលញែកសំរាម( MRF )

ការសាងសង់កន្លែងញែកសំណល់( MRF ) ត្រូវបានបញ្ចប់ជាស្ថាពរនៅខែតុលា ឆ្នាំ២០១៨។ វាត្រូវបានគេរៀបចំឡើងដែលអាចទទួលបាន ៨ តោនក្នុងមួយថ្ងៃ ទោះជាយ៉ាងណាក៏ដោយ ប្រតិបត្តិការនេះនៅមានកម្រិត បើតាមការសង្កេតឃើញច្រើនដងចាប់ពីខែធ្នូ ឆ្នាំ២០១៨ រហូតដល់ខែមិថុនា ឆ្នាំ២០១៩។ ក្រុមហ៊ុនលៀប លឹម ដឹកសំណល់មកម្តងក្នុងមួយអាទិត្យដើម្បីញែក ហើយជួលអ្នករើសអេតចាយដែលនៅទីលានចាក់សំរាមក្បែរនោះ ដើម្បីញែកសំរាមដោយដៃ។ បច្ចុប្បន្នមានតែបុគ្គលពីរនាក់ប៉ុណ្ណោះដែលធ្វើការនៅកន្លែងនោះ ទោះបីអេតចាយត្រូវបានជួលជាថ្នូរនឹងការប្រមូលសំរាម និងថង់ប្លាស្ទិកដែលអាចកែច្នៃឡើងវិញបាន ( ២០០៛/គីឡូក្រាម )។ បុគ្គលផ្សេងទៀតត្រូវបានជួលម្តងម្កាល ទោះជាយ៉ាងណាក៏ដោយពួកគេរាយការណ៍ថា ពួកគេរកប្រាក់បានច្រើនជាងពីការរើសនៅទីលានចាក់សំរាម ដូច្នេះការងារនេះគេមិនសូវចាប់អារម្មណ៍ទេ។ ក្រោមគម្រោងមជ្ឈមណ្ឌលញែកសំរាមរបស់ ADB បុគ្គលិកនឹងទទួលបានការបណ្តុះបណ្តាលទាំងផ្នែកគ្រប់គ្រង និងការញែកសំរាម។

និយាយជារួមសម្រាប់មជ្ឈមណ្ឌលញែកសំរាម ដើម្បីដំណើរការបាន វាចាំបាច់ត្រូវមានការសម្របសម្រួលល្អប្រសើរជាងមុនរវាងក្រុមហ៊ុនស៊ីន ទ្រី ក្រុមហ៊ុនលៀប លឹម និងអេតចាយ។ អាជ្ញាធរមូលដ្ឋានត្រូវផ្តួចផ្តើមគំនិត និងរៀបចំកិច្ចសហប្រតិបត្តិការរវាងក្រុមហ៊ុនស៊ីន ទ្រី និងក្រុមហ៊ុនលៀប លឹម ដោយប្រុងប្រយ័ត្ន ដើម្បីកែលម្អសេវាកម្មប្រមូលសំរាម រៀបដំណើរការរបស់មជ្ឈមណ្ឌលញែកសំរាម ឱ្យកាន់តែប្រសើរឡើង និងធានាបាននូវទំនាក់ទំនងល្អជាមួយភាគីពាក់ព័ន្ធ (រួមទាំងអេតចាយ )។ ប្រសិនបើពួកគេមិនចូលរួមទេ បរិមាណសំរាមបញ្ជូនទៅមជ្ឈមណ្ឌលញែកសំរាម នៅតែមានកម្រិតចំពោះសមត្ថភាពប្រមូលរបស់ក្រុមហ៊ុនលៀប លឹម ហើយវិស័យគ្រប់គ្រងសំណល់រឹងទាំងមូលអាចរងផលប៉ះពាល់។

កន្លែងញែកសំណល់រឹងមើលទៅទំនងជាអាចធ្វើប្រតិបត្តិការបានប្រកបដោយនិរន្តរភាព (តាមទស្សនៈទានផ្នែកហិរញ្ញវត្ថុ) ប្រសិនបើវាទទួលបានប្រាក់ចំណូលបន្ថែមសម្រាប់សេវាកម្មកែច្នៃ ( ឧទាហរណ៍ តម្លៃក្នុងមួយតោន )។ បើមិនដូច្នោះទេ ប្រាក់ចំណូលបានមកពីវត្ថុធាតុដែលអាចកែច្នៃឡើងវិញនោះនឹងមិនគ្រប់គ្រាន់សម្រាប់ចំណាយលើប្រតិបត្តិការទេ។ បច្ចុប្បន្ននេះ សម្ភារៈដែលមានតម្លៃបំផុត ត្រូវបានប្រមូលដោយអេតចាយផ្ទាល់ពីអ្នកបង្កើតសំរាមនៅក្នុងក្រុង (ដោយមិនចាំបាច់ញែកសំរាមតាមផ្ទះ )។ វាមានសារៈសំខាន់ណាស់ក្នុងរក្សាឱ្យបាន សេវាកម្មប្រមូលតាមផ្ទះនេះ។ ដូច្នេះ បរិក្ខារញែកយកវត្ថុសំណល់ នឹងទទួលបានតែវត្ថុសំណល់ដែលមានតម្លៃទាបប៉ុណ្ណោះ។

## ទីលានចាក់សំរាម

ទីលានចាក់សំរាមបច្ចុប្បន្នដំណើរការដោយ ក្រុមហ៊ុន ស៊ីន ទ្រី ជាកន្លែងចាក់សំរាមលក្ខណៈចំហដោយគ្មានការគ្រប់គ្រងបរិស្ថាន។ វាបានដំណើរការអស់រយៈពេលប្រហែល ១៥ឆ្នាំ មកហើយ ដែលមានទីតាំងស្ថិតនៅចម្ងាយ ៤គីឡូម៉ែត្រខាងជើងក្រុង។ ទីលាននេះ ត្រូវបានគេប៉ាន់ស្មានថានឹងពេញអស់ នៅចន្លោះឆ្នាំ ២០២០ និង២០២៥ ។ សំរាមមិនត្រូវបានបង្ហាប់ ឬយកដីគ្របទេ ហើយវាត្រូវបានគេប៉ាន់ស្មានថា ៨០% នៃសំរាម ត្រូវបានដុតនៅនឹងកន្លែង[៣៣] ដែលបណ្តាលឱ្យមានការព្រួយបារម្ភដល់សុខភាពសាធារណៈ។ ទីតាំងនេះមិនមានផែនការប្រតិបត្តិការ ឬការគ្រប់គ្រងទេ ហើយពិបាកក្នុងការធ្វើដំណើរក្នុងរដូវវស្សាដោយសារផ្លូវថ្នល់ជាផ្លូវដី។ នេះមានន័យថា សំរាមត្រូវបានគេបោះចោលនៅលើផ្លូវចូលក្នុងកំឡុងពេលរដូវវស្សាហើយបានឈូសឆាយនៅដើមរដូវប្រាំង។

ដីនេះជាកម្មសិទ្ធិមួយផ្នែករបស់ក្រុមហ៊ុនស៊ីន ទ្រី ( ៦ ហិកតា ) និងមួយផ្នែកទៀតរបស់ក្រុង ( ១ ហិកតា )។ យោងតាមកិច្ចសន្យាជាមួយសាលាក្រុង ស៊ីន ទ្រី ត្រូវប្រគល់ដីជាទីលានចាក់សំរាមទៅឱ្យសាលាក្រុងវិញ នៅពេលដែលទីលាននោះមានសំរាមពេញ។

ថ្មីៗនេះ លៀប លឹមក៏បានបើកកន្លែងចាក់សំរាមថ្មីមួយដែរ ដែលដំណើរការជាកន្លែងចាក់សំរាមលក្ខណៈចំហ ជំនួសទីលានចាក់សំរាមរបស់ស៊ីន ទ្រី។ វាមានទីតាំងនៅភូមិអូរមុន្នី ឃុំអន្លង់វិល ខេត្តបាត់ដំបង។ គម្រោងទន្លេសាបរបស់ធនាគារអភិវឌ្ឍន៍អាស៊ី បានស្នើឱ្យកន្លែងចាក់សំរាមថ្មីស្ថិតនៅចម្ងាយប្រមាណ

[៣៣] SCE/Gret/Group Huit, ADB Tonle Sap Basin Feasibility Study, March 2018, page 163

២១ គីឡូម៉ែត្រភាគខាងត្បូងពីទីក្រុង។ ការបិទកន្លែងចាក់សំរាម ដែលមានស្រាប់អាចជះឥទ្ធិពលយ៉ាងខ្លាំងដល់មជ្ឈមណ្ឌល ញែកសំរាម អេតចាយ និងខមភីជ។ នៅពេលនោះនឹងមិនមាន សំរាមត្រូវបញ្ជូនទៅទីតាំងនោះទៀតទេ ដូច្នេះហើយខមភីជ កន្លែង ទាញយកធនធាន និងអេតចាយ ត្រូវត្រៀមលក្ខណៈសម្រាប់ផល ប៉ះពាល់ដែលអាចកើតមាននេះ។ ទោះយ៉ាងណាក៏ដោយវាទំនង ជាដោយសារតែមជ្ឈមណ្ឌលញែកសំរាម និងមានចម្ងាយតែប្រាំគី ឡូម៉ែត្រប៉ុណ្ណោះ ផ្ទុយពីទីលានថ្មីដែលមានចម្ងាយ ២១ គម ដូច នេះវាមានអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុសម្រាប់ស៊ីន ទ្រី ដើម្បីនាំ យកសំរាមទៅទីតាំងដដែលនេះសិន។

## ២.៥. មេរៀនល្អៗពីគម្រោងគ្រប់គ្រងសំរាម នៅលើពិភពលោក

យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹងនៅក្នុងទីក្រុងចំនួន ៤ ដែលត្រូវ បានទទួលស្គាល់ជាអន្តរជាតិ ថាមានការគ្រប់គ្រងសំរាមបានល្អ ត្រូវបានយកមកពិនិត្យ ដើម្បីទាញយកមេរៀនល្អៗសម្រាប់យក មកអនុវត្តនៅក្រុងបាត់ដំបង។

### ក្រុងពិស្ណុលោក ប្រទេសថៃ[៣៤]

ក្រុងពិស្ណុលោកប្រើ វិធីសាស្ត្រយកសហគមន៍ជាគោល ដោយ ផ្តោតសំខាន់លើការបណ្តុះបណ្តាល ដើម្បីអប់រំបុគ្គលិកក្រុង ផ្សារ សហគមន៍ សាលារៀន និងសណ្ឋាគារស្តីពីសំរាម និងបម្រែបម្រួល អាកាសធាតុ។ អ្នកស្ម័គ្រចិត្តការពារបរិស្ថាននៅតាមសហគមន៍ ត្រូវបានបណ្តុះបណ្តាល ដើម្បីបង្កើនការយល់ដឹង និងអាចត្រូវបាន ដំឡើងឋានៈជាកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល។ ព្រឹត្តិការណ៍ បង្កើនការយល់ដឹងជាសាធារណៈជាច្រើនដំហាន ត្រូវបានរៀបចំ ឡើង រួមមាន យុទ្ធនាការ សិក្ខាសាលា និងសកម្មភាពតាមផ្ទះ។ ការបណ្តុះបណ្តាលមានប្រធានបទជាក់លាក់មួយចំនួន រួមមាន វត្ថុធាតុសំណល់រឹងដែលអាចកែច្នៃឡើងវិញបាន និងតម្លៃរបស់វា ការប្រើប្រាស់ធុងសំរាមតាមគ្រួសារ ការធ្វើជីកំប៉ុស ថ្លៃសេវាកម្ម ប្រមូលសំរាមផ្លូវការ និងគោលការណ៍បង់ប្រាក់សម្រាបអ្នកបំពុល។

វិស័យក្រៅផ្លូវការដែលសកម្មខ្លាំងណាស់មិនទទួលបានការលើក ទឹកចិត្តដោយផ្ទាល់ពីរដ្ឋាភិបាលទេ ប៉ុន្តែផ្ទុយទៅវិញត្រូវបានគាំទ្រ ដោយការបណ្តុះបណ្តាល ធនាគារសំរាម និងត្រូវបានគេទទួល ស្គាល់ថាជាតួអង្គសំខាន់សម្រាប់ការពារបរិស្ថាន។

ចំពោះជំនួយជាធាតុចូលពីថ្នាក់ក្រុង ជាធម្មតា សាលាក្រុងចេញ លិខិត "ស្នើសុំកិច្ចសហប្រតិបត្តិការ" សម្រាប់ការអនុវត្តច្បាប់ជា ជាងការផាកពិន័យ ប៉ុន្តែខាងសាលាក្រុងក៏អាចចេញលិខិតពិន័យ ផងដែរ។ ក្រុងនេះក៏កំពុងបន្តពង្រីក និងធ្វើពិពិធកម្មមជ្ឈមណ្ឌល ប្រព្រឹត្តិកម្មការគ្រប់គ្រងសំណល់រឹង ដើម្បីជួយសម្រួលដល់ចរន្ត សំរាម។ ចាប់ពីឆ្នាំ១៩៩៩ ទីក្រុងនេះ បានទទួលការគាំទ្រអស់ រយៈពេល ៧ឆ្នាំ ពីរដ្ឋាភិបាលអាល្លឺម៉ង់ ដើម្បីអភិវឌ្ឍ និងអនុវត្តកម្ម វិធីគ្រប់គ្រងសំណល់រឹងដែលមានភាពប្រសើរជាងមុន។

នៅឆ្នាំ២០១៣ ប្រហែល២០% នៃសំរាមទីក្រុងត្រូវបានកែលម្អ ភាគច្រើនដោយវិស័យក្រៅផ្លូវការ។ ខាងក្រោមនេះ មានរំលេច ចំណុចសំខាន់ដែលនាំគម្រោងគ្រប់គ្រងសំរាមនៅទីក្រុងនេះ ទទួលបានជោគជ័យ៖

- ប្រព័ន្ធគ្រប់គ្រងដែលយកសហគមន៍ជាគោល ដែលមាន លក្ខណៈគ្រប់ជ្រុងជ្រោយ ដោយមានការតែងតាំងអ្នក ស្ម័គ្រចិត្តដែលមានតួនាទី ជាក់លាក់ និងការបណ្តុះបណ្តាល/ ការលើកកម្ពស់ការយល់ដឹងច្បាស់លាស់ ជាច្រើន ដំណាក់កាល។
- វិស័យក្រៅផ្លូវការសកម្មមួយ ដែលត្រូវបានលើកកម្ពស់ ប៉ុន្តែ មិនត្រូវបានលើកទឹកចិត្តដោយផ្ទាល់ទេ។
- ការអនុវត្តដោយគ្មានការពិន័យ។
- ជំនួយបច្ចេកទេសរយៈពេលវែង ដើម្បីបង្កើតផែនការគ្រប់គ្រង សំណល់រឹងឱ្យបានគ្រប់ជ្រុងជ្រោយ
- មានការចូលរួមយ៉ាងសកម្មពីសំណាក់អាជ្ញាធរមូលដ្ឋាន។
- យុទ្ធនាការលើកកម្ពស់ការយល់ដឹង និងទំនាក់ទំនង រយៈពេលវែង។

[៣៤] Climate and Clean Air Coalition Municipal Solid Waste Initiative, Solid waste management City Profile: Phitsanulok Municipality, Thailand, 2014. Sarintip Tantanee and Suthi Hantrakul, Municipal Waste Management Challenges of Urbanization: Lesson Learned from Phitsanulok, Thailand ខែមករា ឆ្នាំ២០១៩

## ក្រុងស៊ូរ៉ាបាយ៉ា ប្រទេសឥណ្ឌូនេស៊ី [៣៥]

ស៊ូរ៉ាបាយ៉ាផ្តោតលើ វិធីសាស្ត្រពង្រឹងសិទ្ធិអំណាចដល់សហគមន៍ តាមរយៈការគាំទ្រដល់យុទ្ធនាការសង្គមនីយកម្ម/ការប្រឹក្សាយោបល់ ដែលផ្តោតលើ អ័របី (៣Rs) ការបង្កើតអ្នកសម្របសម្រួល និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងអង្គការបរិស្ថានក្រៅរដ្ឋាភិបាល។ មានការចែកចាយធុងសំរាម ដាក់ធុងជីកំប៉ុស និងរទេះសំរាមឥតគិតថ្លៃ និងកន្លែងសម្អាតសំរាមចម្រុះ រួមទាំងធនធានសំរាម និងកន្លែងធ្វើជីកំប៉ុស។ ដើម្បីជាការយល់ដឹង ខេត្តនីមួយៗនៃប្រទេសឥណ្ឌូនេស៊ីជ្រើសរើស "ឯកអគ្គរដ្ឋទូតសុច្ចន្ទៈអនាម័យ" ជារៀងរាល់ឆ្នាំ ហើយទីក្រុងនេះរៀបចំការប្រកួតប្រជែងដែលសហគមន៍នីមួយៗ ត្រូវបានវិនិច្ឆ័យដោយចំនួនដើមឈើដែលបានដាំ និងសោភណភាពនៃការដាំដើមឈើ។ តួអង្គទាំងអស់ (សាធារណៈ ឯកជន និងអង្គការមិនស្វែករកប្រាក់ចំណេញ)ចូលរួមក្នុងយុទ្ធនាការលើកកម្ពស់ការយល់ដឹង ហើយរដ្ឋាភិបាលជួលបុគ្គលិកពេញម៉ោងដើម្បីជានាទូរដំណើរការកម្មវិធីនេះ។

ប្រហែល ១/៦ នៃសំរាមទីក្រុងបានប្រែមុខមាត់ជាមួយនឹងការគ្រប់គ្រងសំណល់រឹងដែលមានភាពល្អប្រសើរ។ ខាងក្រោមនេះ មានរំលេចចំណុចសំខាន់ដែលនាំគម្រោងគ្រប់គ្រងសំរាមនៅទីក្រុងនេះ ទទួលបានជោគជ័យ៖

- ការប្រកួតប្រជែងផ្តល់នូវការលើកទឹកចិត្តជាថវិកា និងបានបង្កើតមោទនភាពនៅក្នុងសហគមន៍។
- វិធីសាស្ត្រ "រួមគ្នាពីក្រោមឡើងលើនិងពីលើចុះក្រោម" បានបង្ហាញថា ការកាត់បន្ថយ និងការញែកសំរាមអាចទទួលបានជោគជ័យ និងមានចីរភាពនៅទូទាំងក្រុងដោយមានការគាំទ្រពីគ្រប់តួអង្គទាំងអស់។
- ការកសាងសមត្ថភាពសម្រាប់អ្នកពាក់ព័ន្ធទាំងអស់បានបង្ហាញពីការផ្តល់នូវអត្ថប្រយោជន៍ដល់វិស័យទាំងមូល។

## ក្រុងឡាពីនតាណា ប្រទេសឈីលី[៣៦]

នៅទីក្រុងឡាពីនតាណា សំណល់បន្លែបង្កើតបានជាចរន្តសំណល់ធំជាងគេ (៥៥%) ដូច្នេះសាលាក្រុងបានសម្រេចចិត្តផ្តោតលើសំណល់សរីរាង្គ និងការធ្វើជីកំប៉ុស។ រដ្ឋាភិបាលបានចំណាយពេល និងធនធាន ដើម្បីកំណត់អត្តសញ្ញាណតួអង្គពាក់ព័ន្ធ និងការធ្វើផែនការដែលជាលទ្ធផលកំណត់គោលដៅការក្នុងការញែកសំរាមតាមផ្សារ និងការផ្តល់ធុងសំរាមតាមផ្ទះ ដើម្បីញែកសំណល់បន្លែ ដោយមានប្រកពសំណល់ពីរទៀតនឹងត្រូវបានប្រមូលនៅថ្ងៃបន្ទាប់។ រដ្ឋាភិបាលក៏មានយុទ្ធនាការមួយដែលកំពុងបន្តធ្វើពីផ្ទះមួយទៅផ្ទះមួយ ដើម្បីលើកកម្ពស់ការយល់ដឹងដោយជួលបុគ្គលដែលមានចំណេះដឹងផ្នែកបរិស្ថាន។ កន្លែងធ្វើជីកំប៉ុស (ដែលប្រហែល ១/៣ ជាការចិញ្ចឹមជន្លេន) ត្រូវបានពង្រីកជាបណ្តើរៗ ជាមួយនឹងការផ្តល់ថវិកាជាជំហ៊ានៗ។ វាក៏មានទីតាំងយុទ្ធសាស្ត្រផងដែរ គឺនៅជិតក្រុងជាងទីលានចាក់សំរាម ដូច្នេះវាជួយសន្សំការចំណាយលើការប្រមូលរបស់ក្រុមហ៊ុនដោយបង្វែរសំណល់រឹង ដែលអាចនឹងចាក់ទៅទីលានចាក់សំរាម។ ប្រជាពលរដ្ឋទទួលបានការលើកទឹកចិត្តក្នុងទម្រង់ជាការផ្តល់ជីកំប៉ុសឥតគិតថ្លៃ និងទទួលបានកន្លែងសាធារណៈដែលមានភាពប្រសើរ ដូចជាសួន ការថែទាំក្លឹបកីឡាជាដើម។ តាមការប៉ាន់ស្មាន មានប្រហែលតែ ២៨% នៃគ្រួសារទាំងអស់ប៉ុណ្ណោះ ដែលញែកសំរាមរបស់ពួកគេ ទោះបីជារដ្ឋបាលក្រុងបានធ្វើយុទ្ធនាការជាច្រើនសម្រាប់ប្រជាជនភាគច្រើនក៏ដោយ។ រដ្ឋបាលក្រុងនឹងបន្តធ្វើយុទ្ធនាការដើម្បីដោះស្រាយបញ្ហានេះ។

ក្នុងចំណោមថវិកាសម្រាប់ការគ្រប់គ្រងបរិស្ថាន និងសំរាម ប្រហែល ៤០% ត្រូវបានចំណាយសម្រាប់ការប្រមូលសំរាមទីក្រុង (រួមទាំងសេវាកម្មសាធារណៈ និងការសម្អាតនៅតាមទីផ្សារ) ៣៦% លើការបោះចោលសំរាមទីក្រុង MSW ២% លើការអប់រំ ១% លើប្រតិបត្តិការ និងថែទាំកន្លែងធ្វើជីកំប៉ុស និង ១៧% លើកម្មវិធីបរិស្ថានផ្សេងទៀត (កម្មវិធីឃុំស្អាត ឧបករណ៍ការពារ ។ល។)។

ប្រមាណជា ២០% នៃសំរាមទីក្រុងសរុបត្រូវបានគេយកមកធ្វើជីកំប៉ុស។ មូលហេតុនៃភាពជោគជ័យមានដូចខាងក្រោម៖

- ផ្តោតលើចរន្តការទាញយកធនធនពីសំរាម ដែលរួមចំណែកធំជាងគេ
- បន្តកម្មវិធីអប់រំជាមួយនឹងការលើកទឹកចិត្តជាសាធារណៈតាមផ្ទះ

---

[៣៥] IGES and UNEP, Planning and Implementation of Integrated Solid waste management Strategies at Local Level: The Case of Surabaya City ខែឧសភា ឆ្នាំ២០១៧

[៣៦] Cecilia Allen, La Pintana, Chile: Prioritizing the Recovery of Vegetable Waste, ខែមិថុនា ឆ្នាំ២០១២

- កំណត់គោលដៅសំណល់សរីរាង្គពីផ្សារ និងគាំទ្រចំណាយសម្អាតផ្សារ
- បន្តផ្តល់នូវឱកាសសម្រាប់កម្មវិធីអប់រំ និងបរិស្ថាន
- ការបោះចោលសំរាមទីក្រុង គឺជាការចំណាយដ៏ច្រើនរបស់ក្រុង ដូច្នេះសាលាក្រុងមានឆន្ទៈក្នុងការគាំទ្រការធ្វើជីកំប៉ុសដើម្បីកាត់បន្ថយការចំណាយ។

## ក្រុងម៉ុមបៃ ប្រទេសឥណ្ឌា[៣៧]

ទីក្រុងម៉ុមបៃមានវិស័យសំរាមក្រៅផ្លូវការដែលរីកចម្រើន ហើយដោយសារទីក្រុងធំខ្លាំង ដូច្នេះការរៀបចំផែនការពង្រីកមានភាពស្មុគស្មាញណាស់។ ព្រោះហេតុដូច្នេះ វិធីវិមជ្ឈការអនុញ្ញាតឱ្យមានភាពបត់បែន និងកែតម្រូវបាន។ និគមនីមួយៗទទួលខុសត្រូវក្នុងការប្រមូលសំរាមផ្ទាល់ខ្លួនដោយមានចំណុចប្រមូលរួម និងការប្រមូលតាមផ្ទះ។ វិស័យក្រៅផ្លូវការដែលប្រទេសឥណ្ឌាបាននិងកំពុងឆ្ពោះទៅរកការបង្កើតជាផ្លូវការមួយរយៈកន្លងមកការប្រមូល និងការសម្អាតសំរាម បានទទួលប្រាក់ចំណូលពីថ្លៃសេវាប្រមូល និងលក់ផលិតផលកែច្នៃឡើងវិញ។ អង្គការក្នុងស្រុកផ្តល់នូវកម្មវិធីបណ្តុះបណ្តាលសម្រាប់វិស័យក្រៅផ្លូវការរួមមានការចរចារកិច្ចសន្យា ការធ្វើជីកំប៉ុស ការរៀបចំប្រកបដោយភាពសហការ ការញែក និងការដោះស្រាយបញ្ហាសំរាមជាដើម និងការរៀបចំកិច្ចសន្យាសម្រាប់សេវាកម្មប្រមូលសំរាម។ ជីវៈឧស្ម័នគឺជាបច្ចេកវិទ្យាជីកំប៉ុសទទួលបានការចាប់អារម្មណ៍ ព្រោះវាអាចត្រូវបានអនុវត្តត្រឹមកម្រិតមូលដ្ឋានដែលមានទំហំជីតូចហើយមិនមានក្លិនទេ។

ទោះបីការអនុវត្តវិធានការវិមជ្ឈការត្រូវការពេលយូរក៏ដោយ ក៏សាលាក្រុងទទួលបានអត្ថប្រយោជន៍តាមរយៈការសន្សំលុយពីការបង្វែរសំរាមនេះដែរ។ ចំណុចសំខាន់ៗទាក់ទងនឹងភាពជោគជ័យរបស់កម្មវិធីនេះគឺ៖

- ការគាំទ្រ ការលើកកម្ពស់ និងការរៀបចំវិស័យក្រៅផ្លូវការ
- អនុញ្ញាតឱ្យថ្នាក់និគមនៅក្នុងទីក្រុងនីមួយៗអនុវត្តនូវអ្វីដែលល្អបំផុតសម្រាប់ពួកគេ
- កំណត់នូវចំណុចប្រមូលសំរាមរួមនៅក្នុងសហគមន៍ និងថ្លៃសេវាសម្រាប់សេវាកម្មប្រមូល

## មេរៀនល្អៗ

និយាយជារួម មានមេរៀនល្អៗសំខាន់ៗ និងយុទ្ធសាស្ត្រច្នៃប្រឌិតមួយចំនួន ដែលទទួលបានពីករណីសិក្សាពីទីក្រុងគំរូទាំងបួននេះ ដែលអាចមានប្រយោជន៍យកមកអនុវត្តក្នុងក្រុងបាត់ដំបង ដូចដែលមានបង្ហាញក្នុងរូបភាពខាងក្រោម៖

**គន្លឹះជោគជ័យ៖**

- ជំនួយបច្ចេកទេសរយៈពេលវែង
- យុទ្ធនាការលើកកម្ពស់ការយល់ដឹង និងទំនាក់ទំនងរយៈពេលវែង
- ការចូលរួមយ៉ាងពេញទំហឹងពីអាជ្ញាធរមូលដ្ឋាន
- កម្មវិធីបណ្តុះបណ្តាល និងការអនុវត្តរយៈពេលវែង
- ការពង្រីក និងធ្វើពិពិធកម្មកន្លែងសម្អាត
- វិធីវិមជ្ឈការ ឬវិធីសាស្ត្រយកសហគមន៍ជាគោល
- កិច្ចសហប្រតិបត្តិការចម្រុះគ្រប់តួអង្គសម្រាប់ការយល់ដឹងជាសាធារណៈ
- ពង្រីកវិស័យក្រៅផ្លូវការដែលបានលើកកម្ពស់ និងបណ្តុះបណ្តាល

**យុទ្ធសាស្ត្រគួរឱ្យចាប់អារម្មណ៍៖**

- កម្រមានការចេញការពិន័យណាស់ តែច្រើនតែមានចេញលិខិត "សំណើសុំកិច្ចសហការ"
- ការជ្រើសរើស "ឯកអគ្គរដ្ឋទូតសុច្ឆន្ទៈអនាម័យ" តាមខេត្ត ឬ អ្នកការពារបរិស្ថានស្ម័គ្រចិត្តនៅតាមសហគមន៍ដើម្បីបង្កើនការយល់ដឹង
- ការប្រកួតប្រជែងសហគមន៍ស្អាត ដោយផ្តែកលើការដាំដើមឈើ និងសោភណភាព

## ២.៦. ការវិភាគ ភាពខ្លាំង ភាពខ្សោយ ឱកាស ការគំរាមកំហែង និងការផ្តល់អនុសាសន៍

សមាសធាតុមុននៃផ្នែកទី ២៖ "វិវេចនារបាយការណ៍ដែលមានស្រាប់ និងការប្រមូលទិន្នន័យ" បានផ្តល់ការយល់ដឹងអំពីទិដ្ឋភាពទូទៅនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ និងការយល់ដឹងអំពីវិស័យគ្រប់គ្រងសំណល់រឹង ( ពីការគ្រប់គ្រង និងការបង្កើតតាមរយៈការកែច្នៃ និងការបោះចោល ) នៅក្នុងក្រុងបាត់ដំបង ។ វាក៏បានបង្ហាញពីគម្រោងផ្សេងទៀតដែលផ្តោតលើវិស័យនេះ និងបទពិសោធន៍ជោគជ័យពីទីក្រុងនានានៅលើពិភពលោក ។ ការវិភាគខាងក្រោមបង្ហាញពីចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែងដែលឈានទៅដល់ការផ្តល់អនុសាសន៍ សម្រាប់ការកែលម្អវិស័យគ្រប់គ្រងសំរាមរឹងនេះ ។

### ២.៦.១. អភិបាលកិច្ច

| ភាពខ្លាំង | ភាពខ្សោយ | ឱកាស | ការគំរាមកំហែង |
|---|---|---|---|
| • មានគោលនយោបាយមួយចំនួនដែលកំណត់ការគ្រប់គ្រង និងការអនុវត្តសកម្មភាពគ្រប់គ្រងសំណល់រឹង ។<br>• អនុក្រឹត្យលេខ ១១៣ ចែងយ៉ាងច្បាស់អំពីការពិន័យចំពោះការល្មើសអាស្រ័យតាមប្រភេទសកម្មភាព (រាប់បញ្ចូលទាំងការដុត និងការចោលសំរាម ) ។<br>• បច្ចុប្បន្នសាលាក្រុងកំពុងគាំទ្រសេវាកម្មសាធារណៈតាមវិធីផ្សេងៗ ។ | • មានការសម្របសម្រួលតិចតួចនៅក្នុងចំណោមភាគីពាក់ព័ន្ធជាច្រើនដែលកំពុងអនុវត្តគំនិតផ្តួចផ្តើមការគ្រប់គ្រងសំណល់រឹង ។<br>• មានការចូលរួមតិចតួចពីសង្កាត់ និងភូមិទៅលសំណល់រឹង ។<br>• ច្បាប់នៃការល្មើសមិនត្រូវបានអនុវត្តទេ ។<br>• មិនមានការត្រួតពិនិត្យសកម្មភាពគ្រប់គ្រងសំណល់រឹង ។ | • សាលាក្រុងមានថវិកាប្រមាណ ១៤៣,០០០ ដុល្លារជារៀងរាល់ឆ្នាំសម្រាប់សកម្មភាពគ្រប់គ្រងសំរាម និងទឹកកខ្វក់ ។<br>• អនុក្រឹត្យលេខ ១១៣ ផ្តល់សិទ្ធិដល់ក្រុងដើម្បីធ្វើប្រតិភូកម្មដល់ឃុំ/សង្កាត់ ។<br>• ឃុំ/សង្កាត់មានការទឹកចិត្តចំពោះការចូលរួមក្នុងការគ្រប់គ្រងសំរាម ។<br>• មានកម្មវិធីត្រួតពិនិត្យប៉ុន្តែត្រូវការធ្វើបច្ចុប្បន្នភាព ។<br>• ការអនុវត្តជាមួយនឹងការដាក់ឱ្យមានការព្រមានបានទទួលជោគជ័យនៅក្នុងប្រទេសដទៃទៀត ។ | • មិនមានផែនការអនុវត្តជាក់ស្តែងនៅក្នុងអនុក្រឹត្យលេខ ១១៣ - ថាតើអ្នកណាគួរអ្នកប្រមូល អ្នកណាគួរជាអ្នកផាកពិន័យ គ្រប់គ្រងប្រាក់ចំណូលដោយរបៀបណា ។ ល ។<br>• ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនទទួលស្គាល់កិច្ចសន្យាក្រុងដែលធ្វើឱ្យមានការលំបាកក្នុងការអនុវត្ត ។<br>• ប្រហែលជាមិនមានភាពប្រសើរឡើងនៅក្នុងវិស័យនេះទេបើគ្មានជំនួយបច្ចេកទេស ។<br>• ការអនុវត្តច្បាប់ដែលមិនបានគ្រោងទុក និងគ្មានការចូលរួមជាសាធារណៈអាចបង្កើនការចោលសំរាមជាចំហ ឬដុត ។ |

៣៧ Virali Gokaldas, Mumbai, India: Waste Picker-Run Biogas Plants as a Decentralized Solution, June 2012 and Sarintip Tantanee and Suthi Hantrakul, Municipal Waste Management Challenges of Urbanization: Lesson Learned from Phitsanulok, Thailand, January 2019 should both references be here like this?

មូលដ្ឋានគ្រឹះនៃគោលនយោបាយ និងប្រតិភូកម្មអំណាចដល់អង្គភាពនានាសម្រាប់គ្រប់គ្រងសេវាកម្មគ្រប់គ្រងសំណល់រឹងនៅខេត្តបាត់ដំបង មានគ្រប់គ្រាន់ ដែលអាចធ្វើឱ្យវិស័យនេះដំណើរការតាមប្រក្រតីបាន។ ទោះយ៉ាងណាក្តី អនុសាសន៍ខាងក្រោមនឹងជួយធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ចនៃសេវាកម្មគ្រប់គ្រងសំណល់រឹងដោយផ្អែកលើការវិភាគភាពខ្លាំង ភាពខ្សោយ ឱកាស កត្តាគំរាមកំហែងខាងលើ។

**តម្រូវឱ្យមានការសម្របសម្រួលតាមវិស័យ ជាពិសេសទាក់ទងនឹងការចូលរួមពីសង្កាត់។**

ច្បាប់ អនុញ្ញាតច្បាស់លាស់ហើយថា ឱ្យមានការធ្វើប្រតិភូកម្ម និងត្រូវមានឆន្ទៈខ្ពស់ពីសង្កាត់ និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីឱ្យការសម្របសម្រួលមានភាពប្រសើរឡើង ប៉ុន្តែត្រូវមានវិធានការដើម្បីធ្វើកិច្ចការនេះបាន។ ខាងក្រោមនេះ គឺជាអនុសាសន៍ដែលបានផ្តល់ជូន ដើម្បីកែលម្អបញ្ហានេះ៖

- ត្រូវរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ដើម្បីបង្កើនការសម្របសម្រួល និងការជជែកសន្ទនា។ កិច្ចប្រជុំនេះគួរតែ រៀបចំឡើងដោយសាលាក្រុង។
- ការចាត់តាំងតំណាងសង្កាត់ ដោយផ្តោតខ្លាំងលើក្នុងការគ្រប់គ្រងសំណល់រឹង ដែលនឹងជួយសម្រួលដល់ការអនុវត្តឱ្យបានកាន់តែល្អប្រសើរនៅទូទាំងក្រុង។ ពួកគេត្រូវតែមាននូវទំហំការងារច្បាស់លាស់មួយដែលមានការឯកភាព និងទទួលស្គាល់ដោយសាលាក្រុង។
- ប្រព័ន្ធផ្សព្វផ្សាយសង្គមមានការពេញនិយមខ្លាំងនៅក្នុងប្រទេសកម្ពុជា ជាពិសេសហ្វេសប៊ុក និងតេលេក្រាម ដែលជាប្រភពមិនគិតថ្លៃ ហើយគួរតែត្រូវបានប្រើដើម្បីបង្កើនការជឿទុកចិត្តពីសាធារណៈ និងការសម្របសម្រួល។
- សាលាក្រុងគួរខិតខំប្រឹងប្រែង ដើម្បីគាំទ្រដល់ព្រឹត្តិការណ៍គ្រប់គ្រងសំណល់រឹងនានា ដែលរៀបចំដោយភាគីពាក់ព័ន្ធផ្សេងៗ ព្រោះវាបង្កើនការជឿទុកចិត្ត និងការចូលរួមរបស់សាធារណជន។
- សាលាក្រុងគួរចាត់បុគ្គលិកមួយរូប ដើម្បីគ្រប់គ្រងចំណុចដែលបានរៀបរាប់ខាងលើនេះ។

មិនមានការត្រួតពិនិត្យ និងការអនុវត្តសកម្មភាពល្មើសទេ។ ច្បាប់គួសបញ្ជាក់ពីសកម្មភាពល្មើស និងការផាកពិន័យ ប៉ុន្តែយន្តការគ្រប់គ្រង និងវិធានការមិនត្រូវបានកំណត់ច្បាស់លាស់នោះទេ។ ខាងក្រោមនេះ គឺជាអនុសាសន៍ដែលបានផ្តល់ជូនដើម្បីដោះស្រាយបញ្ហានេះ៖

- សាលាក្រុងគួរតែបង្កើតក្រុមត្រួតពិនិត្យដែលទទួលបន្ទុកលើការត្រួតពិនិត្យអ្នកផ្តល់សេវាកម្ម(ក្រុមហ៊ុនស៊ីន ទ្រី ក្រុមហ៊ុនលៀប លឹម និងភាគីពាក់ព័ន្ធដទៃទៀតដែលចូលរួមក្នុងវិស័យគ្រប់គ្រងសំណល់រឹង)។
- ផែនការអនុវត្ត គឺជាសមាសធាតុចាំបាច់នៃការគ្រប់គ្រងសំណល់រឹង ទោះយ៉ាងណាក្តីដោយសារតែខ្វះភាពច្បាស់លាស់ទាក់ទងនឹងតួនាទី និងទំនួលខុសត្រូវ ការអនុវត្តត្រូវបានណែនាំឱ្យធ្វើជាដំណាក់កាលៗជាមួយ នឹងប្រព័ន្ធផ្តល់ដំណឹងជាមុន។ ជាពិសេស ឧទាហរណ៍ពីក្រុមហ៊ុនពិស្ណុលោក (Phitsanulok) របស់ប្រទេសថៃបានបង្ហាញថា អង្គភាពនានាឆ្លើយតបទៅនឹង “សំណើរសុំកិច្ចសហការ” ដែលជាប្រភេទប្រព័ន្ធព្រមានមួយដែលកម្រនឹងឈានទៅដល់ការពិន័យណាស់។
- ដើម្បីអនុញ្ញាតឱ្យមានការពង្រឹងការអនុវត្ត វាក៏មានភាពចាំបាច់ដែរក្នុងការបង្កើតសូចនាករដែលមានប្រយោជន៍សម្រាប់ការត្រួតពិនិត្យផងដែរ។ ជាទស្សនៈ សូចនាករទាំងនេះត្រូវមានការព្រមព្រៀងលក្ខណៈថ្នាក់ជាតិ បើទោះបីជាការអនុវត្តសាកល្បងអាចត្រូវបានធ្វើនៅខេត្តបាត់ដំបងក៏ដោយ។
- កម្មវិធីគឺចាំបាច់ណាស់ដើម្បីបង្កើនប្រសិទ្ធភាពការតាមតាមរយៈកម្មវិធីទូរស័ព្ទដូចជា ហ្គោហ្គ្រីនខែមបូឌា (GoGreen Cambodia ) ជាដើម។ លើសពីនេះទៅទៀតមានតម្រូវការចាំបាច់សម្រាប់ពាក្យស្នើសុំដែលត្រូវបានប្រើប្រាស់ជាលក្ខណៈឯកជនដោយអង្គភាពរដ្ឋាភិបាលសម្រាប់ការតាមដាន។
- មន្ទីរបរិស្ថានខេត្តគួរតែចាត់តាំងបុគ្គលិកម្នាក់សម្រាប់សេវាកម្មអនុវត្ត និងត្រួតពិនិត្យ។

## ២.៦.២. ការទុកដាក់ និងការញែក

| ភាពខ្លាំង | ភាពខ្សោយ | ឱកាស | កត្តាគំរាមកំហែង |
| --- | --- | --- | --- |
| • សាលាក្រុងផ្តល់ធុងសំរាមសាធារណៈមួយចំនួន។<br>• សកម្មភាពញែកធ្លាប់មានរួចមកហើយ ហើយដោយសារវិស័យមិនផ្លូវការ បានផ្តល់សេវាកម្មដល់ផ្ទះសម្រាប់ការទាញយកធនធានពីវត្ថុដែលអាចកែច្នៃបាន។<br>• យុទ្ធនាការនានាមិនបានទទួលជោគជ័យខ្លាំងទេក្នុងការញែកសំណល់សរីរាង្គនាពេលកន្លងមក។ | • ធុងស្តុកសំរាមធំៗ កំពុងខ្វះនៅតាមផ្សារនិងតំបន់ដែលមិនផ្តល់សេវា។<br>• ខ្វះការរៀបចំដើម្បីសម្រួលដល់ការប្រើប្រាស់ធុងស្តុកសំរាម (ជាពិសេសតាមផ្សារ)<br>• ការយល់ដឹងអំពីបញ្ហាសំរាមនៅមានកម្រិតខ្ពស់ប៉ុន្តែប្រជាជនជ្រើសរើសមិនកែលម្អទំលាប់របស់ពួកគេ។<br>• យុទ្ធនាការកន្លងមកមានរយៈពេលខ្លីណាស់ហើយបានដកចេញនូវភាគីពាក់ព័ន្ធសំខាន់ៗដូចជាអ្នកគ្រប់គ្រងផ្សារជាដើម។<br>• សមាសធាតុជាច្រើននៃការគ្រប់គ្រងសំរាម ដូចជាចំណេះដឹងអំពីច្បាប់និងការយល់ដឹងអំពីសកម្មភាពកែឆ្នៃមិនត្រូវបានសាធារណជនយល់ច្បាស់នោះទេ។ | • មានថវិកាសាធារណៈសម្រាប់សកម្មភាពគ្រប់គ្រងសំណល់រឹង។<br>• កែលម្អសកម្មភាពទីផ្សារនិងការបណ្តុះបណ្តាល (រួមទាំងការបណ្តុះបណ្តាលគ្រូបង្គោល) បានបង្ហាញនូវជោគជ័យនៅកន្លែងផ្សេងទៀត។<br>• ផ្សារនិងអាជីវកម្មធំៗភាគច្រើនមានទីតាំងស្ថិតនៅកណ្តាលសង្កាត់ស្វាយប៉ោ ដូច្នេះវាសាកសមសម្រាប់សកម្មភាពចាប់ផ្តើម។<br>• ក្រុង (ជាពិសេសផ្សារ) បង្កើតនូវបរិមាណសំណល់សរីរាង្គយ៉ាងច្រើន ហើយមានកន្លែងធ្វើជាក់ដីកំប៉ុសស្រាប់ដែលត្រៀមដើម្បីទទួល។ | • បង្កើនធុងស្តុកសំរាមសាធារណៈអាចកាត់បន្ថយការបង់ប្រាក់សម្រាប់សេវាកម្មប្រមូលផ្លូវការ។<br>• ការមិនអើពើពីភាគីពាក់ព័ន្ធសំខាន់ៗ (ដូចជាអ្នកបោសសម្អាតផ្សារ) ពីដំណើរការរៀបចំផែនការ និងការបណ្តុះបណ្តាលធ្វើឱ្យមានគម្លាតចំណេះដឹងនិងការប្តេជ្ញាចិត្ត។<br>• ការផ្តល់ឧបករណ៍ព័ត៌មាននិងសេវាកម្មមិនគ្រប់គ្រាន់ដល់អ្នកបង្កើតសំរាមបង្កឱ្យទំលាប់ក្នុងការញែកសំរាមមិនបានល្អ<br>• កង្វះកិច្ចព្រមព្រៀងជាផ្លូវការអាចនាំឱ្យមានភាពបរាជ័យនៅក្នុងខ្សែសង្វាក់តម្លៃ។ |

ការគាំទ្រមួយចំនួនត្រូវបានផ្តល់ជូន ដោយការដាក់ធុងសំរាមសាធារណៈ និងការលើកកម្ពស់ការយល់ដឹងប៉ុន្តែជាទូទៅនៅមានកម្រិត និងគ្មានផែនការច្បាស់លាស់។ ការវិភាគភាពខ្លាំង ភាពខ្សោយ ឱកាស ការគំរាមកំហែង ខាងលើនាំឱ្យមានអនុសាសន៍ដូចខាងក្រោម។

មានតម្រូវការបង្កើនការដាកធុងសំរាម និងធុងស្តុកសំរាមសាធារណៈឱ្យចំតាមផែនការ។ ជាមួយនឹងចូលរួមពីតំណាងគ្រប់គ្រងសំណល់រឹងថ្នាក់សង្កាត់ ការកំណត់ទីតាំងសម្រាប់ដាក់ធុងអាចមានភាពងាយស្រួលជាងមុន ក៏ដូចជាអាចទាញយកមកវិញនូវថ្លៃសេវាប្រមូលដែរ។

- ធុងស្តុកសំរាមសាធារណៈត្រូវការជាចាំបាច់នៅតំបន់សង្កាត់ដែលមិនទាន់មានសេវាល្អ។ ដើម្បីកាត់បន្ថយការគំរាមកំហែងនៃការមិនបង់ប្រាក់សេវាសម្រាប់សេវាកម្មប្រមូលសំរាម សាលាក្រុងគួរតែផ្តលសិទ្ធិអនុញ្ញាតឱ្យទៅតំណាងគ្រប់គ្រងសំណល់រឹងថ្នាក់សង្កាត់ ដើម្បីប្រមូលថ្លៃសេវាប្រចាំខែដើម្បីបង់ទៅក្រុមហ៊ុនស៊ីន ទ្រី ជាពិសេសកន្លែងដែលដាក់ធុងស្តុកសំរាមសាធារណៈ។
- ការញែកសំរាមមានតិចតួចបំផុត ក្រៅពីវិស័យកែច្នៃកែច្នៃក្រៅផ្លូវការដែលកំពុងរីកចម្រើន។ ដើម្បីបង្កើនទម្លាប់នៃការញែកសំរាម ធុងសំរាមដោយឡែក និងទីលានចាក់សំរាមគួរតែត្រូវបានផ្តល់ និង/ឬបានបង្ហាញប្រាប់។

- វាពិតជាមានសារៈសំខាន់ណាស់ដែលភាគីពាក់ព័ន្ធដូចជាអ្នកគ្រប់គ្រងផ្សារ អ្នកបោសសម្អាត អ្នកប្រមូលនិងតំណាងសង្កាត់ មាននូវថាជាតុចូលអំពីទីតាំងដាក់ធុងសំរាម និងធុងស្តុកសំរាម ដើម្បីជានាថាវាអាចបំពេញនូវសេចក្តីត្រូវការ។

ការអប់រំ និងការលើកកម្ពស់ការយល់ដឹង ចាំបាច់ត្រូវតែជាការកិច្ចខិតខំប្រឹងប្រែងដែលមានរយៈពេលវែង និងមានឧបករណ៍ដែលល្អប្រសើរជាងមុន។ យុទ្ធនាការលើកកម្ពស់ការយល់ដឹងជាច្រើនត្រូវបានអនុវត្តនាពេលកន្លងមក ទោះបីជាវានាំឱ្យយើងសម្រេចបានការអនុវត្តការញែកសំរាមខ្លះមកហើយក៏ដោយ ក៏វាបានត្រឹមរយៈពេលខ្លីប៉ុណ្ណោះ។

- យុទ្ធនាការគួរតែត្រូវបានអនុវត្តឱ្យមានរយៈពេលវែងជាជាងគ្រាន់ធ្វើតែពីរបីថ្ងៃ។ មានការណែនាំឱ្យធ្វើរយៈពេល ៦០ ថ្ងៃ ដោយរៀបឱ្យមានលក្ខណៈជាព្រឹត្តិការណ៍ និងសកម្មភាពបណ្តុះបណ្តាលជាបន្តបន្ទាប់។ យុទ្ធនាការទាំងនេះក៏គួរតែរួមបញ្ចូលនូវសារក្នុងកាត់បន្ថយសំរាមផងដែរ ជាពិសេសនៅតាមផ្សារ និងសាលារៀន (ដោយការយកនូវកាបូប និងដបទឹកដែលអាចប្រើឡើងវិញបាន ។ល។)
- ព្រឹត្តិការណ៍បណ្តុះបណ្តាលគ្រូបង្គោល បង្កើនមូលដ្ឋានចំណេះដឹង ហើយដូច្នេះបរិមាណព័ត៌មានត្រូវបានផ្សព្វផ្សាយទូលំទូលាយ។ តំណាងសង្កាត់ សាលាក្រុង និងបុគ្គលិកមន្ទីរបរិស្ថានខេត្ត អ្នកស្ម័គ្រចិត្ត អ្នកគ្រប់គ្រងផ្សារ ។ល។ គឺជាបេក្ខជនដែលល្អបំផុតដើម្បីក្លាយជាគ្រូបង្គោល និងគួរតែទទួលបានវិញ្ញាបនបត្រសម្រាប់ការងារនេះ។
- សកម្មភាពនៃការអនុវត្ត ត្រូវតែកំណត់គោលដៅទៅកេអ្នកបង្កើតសំរាម អ្នកសម្អាត និងអ្នកប្រមូល ពីព្រោះវាជាចំណុចខ្សោយបំផុតនៅក្នុងប្រព័ន្ធ។ ជាពិសេសនេះរួមមានអ្នកសម្អាតតាមផ្សារ អ្នកលក់ដូរ អាជីវកម្ម បុគ្គលិកក្រុមហ៊ុនស៊ីន ទ្រី និងក្រុមហ៊ុនលៀប លឹម គ្រួសារជាដើម។
- ចំណេះដឹងទូទៅលើប្រធានបទសំខាន់ៗអាចត្រូវបានធ្វើឱ្យប្រសើរឡើង។ យុទ្ធនាការនេះគួរតែរួមបញ្ចូលនូវប្រធានបទជាច្រើនរួមមាន ការអនុវត្តច្បាប់ កន្លែងកែច្នៃ សារៈសំខាន់នៃអេតចាយ និងកន្លែងកែច្នៃផ្សេងទៀត ។ល។
- កិច្ចខិតខំប្រឹងប្រែងផ្នែកទីផ្សារនាពេលកន្លងមកនៅមានកម្រិតនៅឡើង ទាំងរយៈពេលអនុវត្ត និងភាពនៃការទទួលខុសត្រូវ។ វាច្បាស់ណាស់ថាសម្ភារៈ និងកិច្ចខិតខំប្រឹងប្រែងផ្នែកទីផ្សារអាចត្រូវបានកែលម្អឱ្យបានល្អប្រសើរជាង។

ការអនុវត្តក្នុងការទុកដាក់សំរាម និងការលើកកម្ពស់ការយល់ដឹងគួរតែស្ថិតនៅក្នុងដំណាក់កាលរៀបចំផែនការ ដោយផ្តោតលើចរន្តសំរាមជាក់លាក់មួយ។ ដោយសារតែមានអ្នកបង្កើតសំរាមច្រើន នៅទូទាំងក្រុង ការអនុវត្តការបង្កើនការទុកដាក់ និងការលើកកម្ពស់ការយល់ដឹងអាចត្រូវបានធ្វើឡើងនៅត្រឹមផ្នែកណាដែលអាចគ្រប់គ្រងបាន ដោយផ្តោតលើចរន្តសំរាមដែលអាចទាញយកធនធានបានច្រើនបំផុត។ ខាងក្រោមនេះគឺជាអ្វីដែលត្រូវបានណែនាំ៖

- ផ្សារគឺជាអ្នកបង្កើតធំជាងគេបំផុតនៅក្នុងក្រុង និងផលិតសំណល់សរីរាង្គ។ គេបានផ្តល់អនុសាសន៍ថាឱ្យកំណត់គោលដៅលើផ្សារធំបំផុតជាមុន និងពិសេសគឺសម្រាប់ការទាញយកធនធានពីសំណល់សរីរាង្គសម្រាប់កន្លែងធ្វើជីកំប៉ុស។
- ដោយសារសង្កាត់កណ្តាលមានប្រជាជនច្រើន និងមានចំនួនអាជីវកម្មច្រើន វាគួរតែជាអាទិភាពខ្ពស់បំផុតបន្ទាប់។

## ២.៦.៣. ការប្រមូលសំរាម

ខណៈពេលដែលវិស័យប្រមូលផ្លូវការ និងក្រៅផ្លូវការមានសកម្មភាពខ្លាំង ហើយអាជ្ញាធរពិតជាបានផ្តល់ការគាំទ្រ តែការសម្របសម្រួល ការបណ្តុះបណ្តាល និងការចូលរួមពីសាធារណជននៅមានភាពខ្វះខាតច្រើននៅឡើយ។ ការវិភាគភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង ខាងលើនាំឱ្យមានអនុសាសន៍ដូចខាងក្រោម៖

មធ្យោបាយល្អ និងលឿនបំផុត ដើម្បីគាំទ្រលើការញែកសំរាមដល់ផ្ទះ គឺដើម្បីលើកកម្ពស់ និងផ្តល់លទ្ធភាពបន្ថែមទៀតដល់វិស័យប្រមូលក្រៅផ្លូវការដែលសកម្ម។ អ្នកប្រមូលសំរាមតាមដងផ្លូវ និងតាមទីលានចាក់សំរាម ៨០% គឺជាស្ត្រី និងកុមារ ដូច្នេះការផ្តល់ការបណ្តុះបណ្តាល និងឧបករណ៍នឹងជួយឱ្យពួកគេអនុវត្តសេវាកម្មរបស់ពួកគេបានប្រសើរជាងមុនប្រកបដោយសុវត្ថិភាព។ អនុសាសន៍មួយចំនួន មានផ្តល់ជូនដូចខាងក្រោម៖

- ព្រឹត្តិការណ៍បណ្តុះបណ្តាលទៀងទាត់ត្រូវបានធ្វើឡើង ដើម្បីអប់រំអំពីបញ្ហាសុខភាព សេវាប្រមូលផ្លូវការ ការទុកដាក់សំរាម និងការអនុវត្តច្បាប់ ។ល។

- ការចូលរួម គឺជាការចាំបាច់ក្នុងការស្វែងយល់ពីបញ្ហាប្រឈមរបស់ពួកគេ និងស្វែងរកដំណោះស្រាយដើម្បីជួយក្នុងការទាញ

| ភាពខ្លាំង | ភាពខ្សោយ | ឱកាស | ការគំរាមកំហែង |
| --- | --- | --- | --- |
| • ប្រតិបត្តិករប្រមូលផ្លូវការកំពុងទាញយកធនធាននៃសំណល់ទីក្រុង។<br>• តំបន់សាធារណៈត្រូវបានថែទាំដោយធនឧបត្ថម្ភសាធារណៈ។<br>• វិស័យក្រៅផ្លូវកា រគឺជាអ្នកប្រមូលធំជាងគេទី ២ ដែលសកម្ម និងជាសំខាន់ក្នុងទាញយកធនធានពីវត្ថុដែលអាចកែច្នៃបាន | • សេវាកម្មប្រមូលជាផ្លូវការមិនមានភាពស៊ីសង្វាក់គ្នា និងមិនត្រូវបានផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅឡើយ។<br>• អ្នកបង្កើតសំរាមជាច្រើនមានទស្សនៈមិនល្អចំពោះសេវាកម្មប្រមូលផ្លូវការ។<br>• អ្នកបង្កើតសំរាមជាច្រើនមិនបង់ថ្លៃប្រមូលសំរាមទេ។<br>• អ្នកប្រមូលផ្លូវការចំណាយពេលវេលាច្រើនក្នុងការប្រមូលសំរាមតាមផ្សារដែលរាយប៉ាយមិននៅក្នុងធុងសំរាម។ | • មានថវិកាសាធារណៈគ្រប់គ្រាន់សម្រាប់សកម្មភាពសំណល់រឹង។<br>• អាជ្ញាធរសាធារណៈមានសិទ្ធិប្រមូលថ្លៃគ្រប់គ្រងសំណល់រឹង។<br>• បណ្តាញប្រមូលសំរាមក្រៅផ្លូវការគឺរឹងមាំ ហើយមានជាឧទាហរណ៍នៅក្នុងប្រទេសដទៃទៀតបានបង្ហាញថាការចូលរួមរបស់ពួកគេអាចនាំឱ្យខិតខំប្រឹងប្រែងក្នុងការទាញយកធនធានពីសំរាមកាន់តែបានច្រើនថែមទៀត។ | • ការខកខានមិនបានកត់សម្គាល់និងបញ្ចូលអ្នកប្រមូលសំរាមទាំងអស់ថាជាផ្នែកមួយនៃខ្សែសង្វាក់តម្លៃគ្រប់គ្រងសំណល់រឹង នាំឱ្យការទាញយកធនធានពីសំរាមមានកម្រិតទាប។<br>• កង្វះការសម្របសម្រួលនិងកិច្ចព្រមព្រៀងជាមួយអ្នកប្រមូលផ្លូវការនោះនៅពេលមានការប្រែប្រួលសកម្មភាពប្រមូលសំរាម គឺមានការគំរាមដល់និរន្តរភាពនៃសេវាកម្មទាំងនោះ។<br>• ការញែកសំរាមដែលបានប្រមូលតាមផ្ទះគឺជារឿយៗមិនទទួលបានជោគជ័យទេ។ |

យកធនធានពីសំរាមដែលមានការគ្រប់គ្រងច្បាស់លាស់និងបរិមានច្រើនជាងមុន។

អ្នកប្រមូលសំរាមផ្លូវការគួរតែបោះពុម្ព និងផ្សព្វផ្សាយសេវាកម្មរបស់ពួកគេហើយធ្វើបច្ចុប្បន្នភាពដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរ។ ការផ្តល់កាលវិភាគច្បាស់លាស់ និងសេវាកម្មជាក់លាក់អាចកែប្រែមុខមាត់ របស់ពួកក្នុងក្រសែភ្នែកសាធារណៈ ហើយអាចនឹងសូម្បីតែការទាញយកថ្លៃដើមមកវិញ។ ខាងក្រោមនេះត្រូវបានណែនាំជាពិសេស។

- បោះពុម្ពតារាងពេលវេលានៅលើវិក្កយបត្រប្រចាំខែ និងចែករំលែកជាមួយសាលាក្រុងដើម្បីធ្វើការផ្សព្វផ្សាយនៅលើបណ្តាញសង្គម។
- គេយល់ឃើញថា អ្នកប្រមូលផ្លូវការបានយល់ព្រមប្រមូលសំណល់រឹងដែលបានញែកហើយ។ នៅពេលចរចារលើសេវាកម្មបន្ថែម កាលវិភាគសេវាកម្មគួរតែត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លុះបញ្ចាំងពីកិច្ចព្រមព្រៀង (ដែលគួរធ្វើជាផ្លូវការ)។
- ការពិភាក្សាគួរតែត្រូវបានលើកឡើងថាតើតំណាងសង្កាត់អាចប្រមូល និងបង់ថ្លៃសេវាប្រមូលក្នុងនាមតំណាងតំបន់ដែលមិនទទួលបានសេវាបានឬទេ។

## ២.៦.៤. កន្លែងកែច្នៃ និងបោះចោល

កន្លែងកែច្នៃ និងបោះចោល ត្រូវបានវាយតម្លៃយ៉ាងលម្អិតបន្ថែមទៀតនៅក្នុងផ្នែកទី ៤៖ “ការធ្វើឱ្យប្រសើរឡើងអាជីវកម្មកែច្នៃក្នុងក្រុងបាត់ដំបង”។ ទោះយ៉ាងណាក៏ដោយចំណុចខាងក្រោមនេះបំពេញន័យឱ្យអនុសាសន៍ដែលបានផ្តល់រួចមកហើយនៅក្នុងការពិភាក្សាផ្នែករងនេះ។

ជាពិសេស ច្បាស់ណាស់ថាមានតម្រូវការដើម្បីពង្រឹងការយល់ដឹងឱ្យកាន់តែប្រសើរឡើងក្នុងចំណោមអេតចាយ និងអ្នកបង្កើតសំរាមការសម្របសម្រួលរវាងភាគីពាក់ព័ន្ធក្នុងវិស័យ និងការញែកសំរាមឱ្យបានល្អជាងមុន។ សម្រាប់គោលដៅរយៈពេលវែងការអភិវឌ្ឍទីលានចាក់សំរាមថ្មីប្រកបដោយស្តង់ដារបរិស្ថានត្រឹមត្រូវ គឺមានសារៈសំខាន់ណាស់។

### ២.៦.៥. ជ្រើសរើសតំបន់ធ្វើយុទ្ធនាការ

ទាក់ទងនឹងការជ្រើសរើសតំបន់យុទ្ធនាការ (សាកល្បង) ក្នុងសង្កាត់សម្រាប់ការសាកល្បងសកម្មភាពលើកកម្ពស់ការយល់ដឹង ពិតជាមានសារៈសំខាន់ណាស់ដើម្បីបង្ហាញពីសាវតារ និងសូចនាករសំខាន់ៗ។

| ភាពខ្លាំង | ភាពខ្សោយ | ឱកាស | កត្តាគំរាមកំហែង |
|---|---|---|---|
| • សិប្បកម្មកែច្នៃប្លាស្ទិកកែច្នៃថង់ប្លាស្ទិក ជាសេវាកម្មកែច្នៃដែលស្គង់អេតចាយមិនផ្តល់ឱ្យ។<br>• ខមភីដ (COMPED) ផ្តល់សេវាធ្វើជីកំប៉ុសដែលក្រុងផ្សេងទៀតនៅកម្ពុជាមានទាន់មាន។ | • អេតចាយមួយចំនួនក្រៅពីនៅទីលានចាក់សំរាមកំពុងប្រមូលថង់ប្លាស្ទិកសម្រាប់សិប្បកម្មកែច្នៃប្លាស្ទិក។<br>• សំណល់រឹងចម្រុះបច្ចុប្បន្នត្រូវបានបញ្ជូនទៅក្រុមហ៊ុន COMPED បណ្តាលឱ្យចំណាយលើប្រតិបត្តិការកាន់តែខ្ពស់។<br>• កន្លែងទាញយកឧស្ម័នកំពុងត្រូវបានប្រើប្រាស់។<br>• ថ្លៃដើមប្រតិបត្តិការខ្ពស់ជាងតម្លៃលក់ជីកំប៉ុស។<br>• មិនមានយន្តការ និងថវិកា (នៅថ្នាក់អាជ្ញាធរមូលដ្ឋាន) ដើម្បីបដិភាគហិរញ្ញវត្ថុដល់សកម្មភាពញែកសំរាម និងទាញយកឧស្ម័ន។ | • ប្រជាជនទូទៅ និងអេតចាយខ្លះហាក់មិនដឹងថាថង់ប្លាស្ទិចអាចយកទៅកែច្នៃបានទេ។<br>• ផ្សារបង្កើតនូវបរិមាណសំណល់សរីរាង្គយ៉ាងច្រើន។<br>• ប្រសិនបើទីលានចាក់សំរាមថ្មីត្រូវបានប្តូរទៅចម្ងាយ ១៥ គីឡូម៉ែត្រឆ្ងាយពីកន្លែងបច្ចុប្បន្ន នោះវានឹងបង្កើតឱកាសសម្រាប់អ្នកប្រមូលសំរាមដើម្បីសន្សំប្រាក់ដោយយកកាកសំណល់ទាំងនោះទៅ។ | • កង្វះការសម្របសម្រួលមុនពេលការបិទទីលានចាក់សំរាម អាចប៉ះពាល់ដល់ប្រតិបត្តិការរបស់ក្រុមហ៊ុនខមភីដ (COMPED) និងកន្លែងទាញយកឧស្ម័ន |

### គម្រោងសាកល្បងមុនៗក្នុងការញែកសំរាម ការប្រមូល និងការធ្វើជីកំប៉ុស

ផ្សារបឹងឈូកផ្សារថ្មី (១៣មករា) ផ្សារណាត់/ផ្សារធំ (ផ្សារកណ្តាល) និងផ្សារភូពុយធ្លាប់បានសហការជាមួយក្រុមហ៊ុន COMPED សម្រាប់ការញែកសំរាម ដឹកជញ្ជូន និងធ្វើជីកំប៉ុសពីសំណល់សរីរាង្គ។ ក្រុមហ៊ុនស៊ីន ទ្រី គឺទទួលបន្ទុកក្នុងការប្រមូល និងដឹកជញ្ជូនសំណល់សរីរាង្គទៅឱ្យអង្គការខាំផែដ។ លទ្ធផលបានបង្ហាញថាការសាកល្បងទទួលបានជោគជ័យក្នុងរយៈពេលខ្លី ប៉ុន្តែនៅទីបំផុតការញែកសំរាមបានបញ្ឈប់។ ទោះបីហាក់ដូចជាគ្មានការត្រួតពិនិត្យ និងវាយតម្លៃត្រូវបានធ្វើឡើងក៏ដោយ ក៏វាទំនងជាការសាកល្បងមិនបានជោគជ័យ ព្រោះវាមានរយៈពេលខ្លីពេក ដោយគ្មានការប្រាស្រ័យទាក់ទងគ្រប់គ្រាន់រវាងភាគីពាក់ព័ន្ធ (រួមទាំងអាជ្ញាធរមូលដ្ឋាន) និងកង្វះការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ។

បញ្ហាដំបូងពីរ គឺមែនទែនទៅងាយស្រួលក្នុងការកែតម្រូវបើមានការតាំងចិត្តមុតមាំ។ ការសាកល្បងអាចត្រូវបានពង្រីកដោយមានសកម្មភាពបន្ថែម ហើយភាគីពាក់ព័ន្ធបានចូលរួមតាំងពីដំបូង។ នេះគឺជាហេតុផលមួយក្នុងចំណោមហេតុផល ដែលមានការស្នើឱ្យបង្កើតកិច្ចព្រមព្រៀងជាមួយអ្នកគ្រប់គ្រងផ្សារ និងអ្នកប្រមូលផ្លូវការមុនពេលអនុវត្តយុទ្ធនាការណាមួយ ពីព្រោះការគាំទ្រ និងការយល់ដឹងរបស់ពួកគេគឺចាំបាច់ដើម្បីទទួលបានជោគជ័យ (ជាពិសេសជាមួយអ្នកប្រមូល ព្រោះការលាយឡំវិញនៃសំណល់រឹងក្នុងកំឡុងពេលប្រមូល រារាំងដល់ការញែកនៅនឹងប្រភព)។

ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ គឺមានការលំបាកជាងមុនក្នុងការដោះស្រាយបើគ្មានប្រភពមូលនិធិច្បាស់លាស់ ដែលជាផ្នែកនៃប្រព័ន្ធដែលមាន។ ខណៈពេលដែលមានករណីសិក្សាមួយពីគម្រោងអាយជីអ៊ីអែស ( IGES ) បានបង្ហាញពីការចរចាអំពីការសន្សំសំចៃ ដែលអាចធ្វើទៅបានទាក់ទងទៅនឹងសំណល់រឹងដែលត្រូវបានបង្វែរចេញពីទីលានចាក់សំរាម (ហើយធ្វើបានសម្រេចជាមួយផ្សារបឹងឈូក) វាកាន់តែមានភាពស្មុគស្មាញសម្រាប់ចំនួនអ្នកទទួលផលច្រើន។ ដូច្នេះវាទំនងជាពិបាក និងមានដំណើរការយូរជាងនេះជាមួយក្រុមហ៊ុនស៊ីន ទ្រី ហើយមិនត្រូវបានណែនាំឱ្យអនុវត្តភ្លាមៗនោះទេ ប៉ុន្តែគួរតែត្រូវបានពិចារណាសម្រាប់ការធ្វើផែនការរយៈពេលវែង។ ផ្ទុយទៅវិញ គេបានផ្តល់អនុសាសន៍ឱ្យលើកកម្ពស់ការប្រកួតប្រជែង មោទនភាព និងការទទួលស្គាល់ជាសាធារណៈក្នុងរយៈពេលខ្លី ដូចដែលបានឃើញនៅក្រុងស៊ូរ៉ាបាយ៉ា។

លើសពីនេះទៀតនៅពេលទម្លាប់របស់អ្នកបង្កើតសំរាម និងអ្នកប្រមូលសំរាមមានការលំបាកក្នុងការផ្លាស់ប្តូរណាស់ គេបានផ្តល់អនុសាសន៍ឱ្យមានយុទ្ធនាការរយៈពេលវែងជាមួយនឹងការអនុវត្តជាជំហាន  ដើម្បីរៀបចំផែនការបង្កើនធុងសំរាម និងធុងស្តុកសំរាម ក៏ដូចជាការធ្វើទីផ្សារ ការបណ្តុះបណ្តាល និងការលើកកម្ពស់ការយល់ដឹង។ គួរមានបុគ្គលិកពេញម៉ោងអនុវត្តសកម្មភាពទាំងនោះ ដើម្បីជានាទូវធ្វើការជាមួយអ្នកបង្កើតសំរាម ដើម្បីបង្កើនការយល់ដឹង និងឆ្លើយឆ្លងសំណួរ។

### តំបន់គោលដៅដែលទទួលបានការណែនាំសម្រាប់ធ្វើយុទ្ធនាការ

គេបានផ្តល់អនុសាសន៍ឱ្យអនុវត្តការសាកល្បងញែកសំរាមដោយផ្តោតលើការទាញយកធនធានពីសំណល់សរីរាង្គជាពីរជំហ៊ាន គឺទីមួយនៅផ្សារធំៗក្នុងមូលដ្ឋានចំនួន ៥ និងទី ពីរនៅកណ្តាលសង្កាត់ស្វាយប៉ោ។ មូលហេតុមានដូចខាងក្រោម៖

### សម្រាប់ផ្សារៈ

- ការបង្កើតសំណល់រឹងមានបរិមាណខ្ពស់ រហូតដល់ ២០% នៃសំណល់ទីក្រុងទាំងមូល) ដែលភាគច្រើនជាសំណល់សរីរាង្គ)
- ប្រព័ន្ធគ្រប់គ្រងសំណល់រឹងដែលមានស្រាប់ដូចជាអ្នកបោសសម្អាតផ្សា ការទុកដាក់ និងការប្រមូល
- គ្រួសារខ្លះយកសំណល់របស់ពួកគេទៅបោះចោលនៅផ្សារ ប៉ុន្តែបើមានចំណុចត្រួតពិនិត្យខ្លះៗនោះនឹងជួយធ្វើឱ្យប្រសើរឡើងនូវការត្រួតពិនិត្យ និងការអនុវត្ត (ហើយប្រហែលនឹងទទួលបានកម្រៃមកវិញ)
- សមាជិកសហគមន៍ជាច្រើនដើរទិញឥវ៉ាន់នៅផ្សារ ដូច្នេះយុទ្ធនាការតាមផ្សារនឹងកាន់តែទូលំទូលាយ
- អ្នករើសក្រៅផ្លូវការមកពីទូទាំងក្រុង មកប្រមូលសំរាមដែលអាចកែច្នៃឡើងវិញបាន ដែលនាំឱ្យមានការពង្រីកវិសាលភាពកាន់តែទូលាយ និងមធ្យោបាយដើម្បីសហការគ្នា។

### សម្រាប់សង្កាត់ស្វាយប៉ោះ

- សង្កាត់នេះមានប្រជាជនច្រើនជាងគេ និងមានអាជីវកម្មមួយចំនួនធំ
- មានផ្សារបីក្នុងចំណោមទីផ្សារធំជាងគេទាំង៥
- ជាកន្លែងដែលភ្ញៀវទេសចរជាតិ និងអន្តរជាតិចូលទស្សនាច្រើនជាងគេ
- មានស្ថាប័នឯកជន និងសាធារណៈ
- យុទ្ធនាការផ្សព្វផ្សាយពីមុនស្តីពីការគ្រប់គ្រង សំណល់រឹងនៅតាមទី ប្រជុំជនត្រូវបានធ្វើភាគច្រើននៅក្នុងសង្កាត់នេះជាពិសេសនៅតាមបណ្តោយផ្លូវលេខ១ លេខ២ និងលេខ៣។

## ២.៦.៦. មេរៀនបន្ថែមទៀតដែលបានអនុវត្តទូទាំងប្រទេសស្តីពីការគ្រប់គ្រងសំណល់រឹងក្នុងក្របខណ្ឌវិមជ្ឈការ

 ដោយបានចេញផ្សាយនៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៥ អនុក្រឹត្យលេខ១១៣ ស្តីពី"ការគ្រប់គ្រងសំរាម និងសំណល់រឹងទីក្រុង" បង្កើតតួនាទី  និងទំនួលខុសត្រូវនៅគ្រប់កម្រិតទាំងអស់នៃរដ្ឋាភិបាលក្នុងគោលបំណងធ្វើវិមជ្ឈការការទទួលខុសត្រូវក្នុងការគ្រប់គ្រងសំរាមដល់ថ្នាក់មូលដ្ឋាន។ អនុក្រឹត្យនេះក៏បង្ហាញពីតម្រូវការសម្រាប់ការញែកសំរាម ការទុកដាក់ ការសម្អាត ការប្រមូល ការដឹកជញ្ជូន ការកែច្នៃសំរាម និងការគ្រប់គ្រងទីលានចាក់សំរាម។ ការតម្រូវឱ្យបង់ថ្លៃសេវា និងការពិន័យចំពោះការល្មើសច្បាប់ ក៏មានចែងផងដែរ។ ដោយផ្អែកលើការវិភាគស្ថានភាពទូទៅនៅក្រុងបាត់ដំបង នាំឱ្យយើងអាចទាញចេញជាមេរៀនបន្ថែមមួយចំនួនទៀតសម្រាប់ការអនុវត្តអនុក្រឹត្យលេខ ១១៣។

## ការធ្វើប្រតិភូកម្មទៅថ្នាក់ឃុំ/សង្កាត់

គោលបំណងសំខាន់មួយនៃអនុក្រឹត្យ គឺធ្វើវិមជ្ឈការការទទួលខុសត្រូវក្នុងការគ្រប់គ្រងសំរាមទៅថ្នាក់ក្រោមជាតិ។ បញ្ហានេះនៅតែត្រូវអនុវត្តឱ្យបានយ៉ាងពេញលេញ។ ក្នុងករណីខេត្តបាត់ដំបង សាលាក្រុងត្រូវបានផ្តល់ការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម តែមិនមានការធ្វើប្រតិភូកម្មបន្តទៅដល់ថ្នាក់ឃុំសង្កាត់ទេ ទោះបីមានការចង់ចូលរួមពីថ្នាក់ឃុំ/សង្កាត់ក៏ដោយ។ ការធ្វើប្រតិភូកម្មទៅថ្នាក់ក្រោមទៀតនឹងមានប្រសិទ្ធភាពខ្លាំង សម្រាប់ការប្រាស្រ័យទាក់ទងព័ត៌មាន និងការអនុវត្តសកម្មភាពនៅថ្នាក់មូលដ្ឋាន។ ការកសាងសមត្ថភាពសម្រាប់ថ្នាក់ក្រោមជាតិក៏នៅមានការខ្វះខាត ហើយជាទូទៅមានការយល់ដឹងទាបអំពីបញ្ហាបច្ចេកទេស និងគោលនយោបាយ ដោយមានការបណ្តុះបណ្តាលតិចតួចប៉ុណ្ណោះ។

## កំណត់គោលដៅការលើកកម្ពស់ការយល់ដឹងដែលប្រសើរជាងមុន

ការងារសំខាន់ៗ កំពុងត្រូវបានធ្វើជាមួយនឹងយុទ្ធនាការអប់រំ ឧទាហរណ៍ធ្វើដោយនាយកដ្ឋានអប់រំបរិស្ថាន នៃក្រសួងបរិស្ថាន។ ទោះជាយ៉ាងណាក៏ដោយ យុទ្ធនាការទាំងនេះមានរយៈពេលខ្លី (ជាធម្មតាមួយថ្ងៃ) ហើយមានប្រសិទ្ធភាពតិចតួច។ ដើម្បីឱ្យសហគមន៍ផ្លាស់ប្តូរទម្លាប់ដែលរស់ស៊ាំយូរមកហើយ យុទ្ធនាការគួរតែត្រូវបានអនុវត្តក្នុងរយៈពេលវែងជាជាងគ្រាន់តែប្រើពេលពីរបីថ្ងៃ។ គេបានផ្តល់អនុសាសន៍ឱ្យមានដាក់គោលដៅរយៈពេល ៦០ថ្ងៃ ដោយមានព្រឹត្តិការណ៍ និងសកម្មភាពបណ្តុះបណ្តាលជាបន្តបន្ទាប់។ ជម្រើសមួយសម្រាប់រដ្ឋាភិបាលនោះគឺការផ្តោតការខិតខំប្រឹងប្រែងលើទីក្រុងណាមួយ ដោយធ្វើការជាមួយថ្នាក់ក្រោមជាតិ បន្ទាប់មកធ្វើការត្រួតពិនិត្យ និងវាយតម្លៃលើប្រសិទ្ធភាពនៃយុទ្ធនាការ ដើម្បីចម្លងទៅធ្វើនៅក្រុងផ្សេងទៀត។

អនុក្រឹត្យនេះមានលក្ខណៈប្រាកដប្រជា និងច្បាស់លាស់លើតម្រូវការសម្រាប់ការគ្រប់គ្រងសំណល់រឹង (ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបោះចោល)។ ទោះយ៉ាងណាក៏ដោយ ជាទូទៅមិនមានការទាក់ទងច្បាស់លាស់ជាមួយអ្នកបង្កើតសំរាមទេ (គ្រួសារ ហាង ភោជនីយដ្ឋានជាដើម)។ មនុស្សភាគច្រើនមិនបានដឹងទេថាការរក្សាសំណល់រឹងដែលអាចកែច្នៃ និងសំរាមផ្សេងៗញែកពីគ្នា គឺជាតម្រូវការស្របច្បាប់ ឬថាសំរាមត្រូវតែត្រូវវេចខ្ចប់ឱ្យបានត្រឹមត្រូវ។ ជាផ្នែកមួយនៃយុទ្ធនាការលើកកម្ពស់ការយល់ដឹង ឧបករណ៍ដាក់ស្តែងគួរតែត្រូវបានអនុវត្ត ហើយគោលការណ៍កាត់បន្ថយសំរាមគួរតែត្រូវបានដាក់បញ្ចូលផងដែរ។ ឧទាហរណ៍អគារផ្ទះល្វែង និងបុរីគួរតែត្រូវមានធុងសំរាមដាច់ដោយឡែក សម្រាប់ការប្រមូលផ្លូវការ ឬក៏អេតចាយអាចប្រមូលបាន។ ម្ចាស់លំនៅឋានគួរតែទទួលបានការអប់រំអំពីសំណល់រឹងណា ដែលអាចប្រមូលលក់ទៅឱ្យអេតចាយ (ឧទាហរណ៍ ខិត្តបណ្ណ និងបណ្ណប្រកាស) ហើយការងារដែលធ្វើដោយអ្នកប្រមូលក្រៅផ្លូវការទាំងនេះគួរតែត្រូវបានទទួលស្គាល់។ ជម្រើសមួយទៀតគឺត្រូវវេចខ្ចប់សំណល់រឹងកែច្នៃបាននៅក្នុងថង់ថ្លា ដើម្បីឱ្យអេតចាយមើលឃើញ កុំឱ្យពួកគេរវល់តែស្រាយគ្រប់ថង់ ដែលជាហេតុធ្វើឱ្យជ្រុះសំរាម។

## ផែនការគ្រប់គ្រង ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ

ថវិកាដែលបានផ្តល់ទៅសាលាក្រុងជាទូទៅមានកម្រិតទាប។ លើសពីនេះទៀត ក្រុងនានាមិនប្រើប្រាស់ថវិកានេះ ប្រកបដោយប្រសិទ្ធភាពទេ។ ក្នុងករណីខេត្តបាត់ដំបង ថវិកាប្រមាណ ១៤០.០០០ ដុល្លារអាមេរិក ត្រូវបានផ្តល់ឱ្យប្រតិបត្តិករឯកជនមួយដោយមានកិច្ចសន្យាធូរលុង និងមិនតម្រូវឱ្យមានការញធ្វើរបាយការណ៍។ ជាមួយនឹងថវិកាតិចតួច ការណែនាំអំពីរបៀបក្នុងការចំណាយនឹងធានាបាននូវការចាយលុយឱ្យសមនឹងថ្លៃចំណាយ។ រដ្ឋាភិបាលកណ្តាល និងថ្នាក់ក្រោមជាតិគួរតែឯកភាពគ្នាលើផែនការថវិកាលម្អិត ដែលត្រូវមានលទ្ធផលច្បាស់លាស់។ បញ្ជីអាទិភាពគួរតែត្រូវបានបង្កើតឡើង ភ្ជាប់នឹងផែនការសកម្មភាព និងថវិកាចំណាយលម្អិតទៅនឹងសកម្មភាពដែលបានជ្រើសរើស។ នៅពេលថវិកាត្រូវបានផ្តល់ទៅសាលាក្រុង ការធ្វើកិច្ចសន្យាប្រកបដោយតម្លាភាព ការធ្វើរបាយការណ៍ និងការត្រួតពិនិត្យ ចាំបាច់ត្រូវតែមាន។

## តម្រូវការក្នុងកិច្ចសន្យាប្រកបដោយភាពប្រាកដប្រជាច្បាស់លាស់សម្រាប់អ្នកផ្តល់សេវាឯកជន

ដោយសារកិច្ចការគ្រប់គ្រងសំរាមភាគច្រើនត្រូវបានផ្តល់ទៅឱ្យវិស័យឯកជន ដូចនេះសាលាក្រុងគួរតែមានភាពច្បាស់លាស់ជាងមុនលើតម្រូវការ និងកិច្ចសន្យា។ កិច្ចសន្យាដោយយកលទ្ធផលជាមូលដ្ឋានជាមួយអ្នកផ្តល់សេវាឯកជន គួរត្រូវបានយកមកប្រើប្រាស់។ ឧទាហរណ៍ក្រុងគួរតែធ្វើការជាមួយវិស័យឯកជន និងពិគ្រោះយោបល់ជាមួយប្រជាជន ដើម្បីបង្កើត និងទាក់ទងពីកាលវិភាគប្រមូល និងការងារសម្រាប់ដំណើរការ។ ប្រជាជននឹងដឹងថាពេលណាសំរាមនឹងត្រូវគេមកប្រមូល ដែលអាចជួយសម្រួលដល់ការប្រមូលសំរាម និងកែលម្អសោភណភាព

ក្រុង។ ធ្វើដូចនេះអាចឱ្យអ្នកបង្កើតសំរាមអាចគោរពតាមអនុក្រឹត្យ ដោយរក្សាទុកសំរាមនៅផ្ទះរហូតដល់ថ្ងៃប្រមូល។ អាជ្ញាធរក្រុងនៅតែប្រឈមនឹងការច្រឡំអនុក្រឹត្យទាក់ទងនឹងរឿងដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលស្គាល់ថាការសោលាក្នុងការធ្វើកិច្ចសន្យាទៅអ្នកផ្តល់សេវាគ្រប់គ្រងសំរាម។

## ការប្រកួតប្រជែង និងគណនេយ្យភាពជាងមុនពីវិស័យឯកជន

ការដំណើរការកិច្ចសន្យាប្រកបដោយតម្លាភាព និងការប្រកួតប្រជែងគឺត្រូវបានលើកទឹកចិត្ត។ ជាទូទៅមានតែប្រតិបត្តិករឯកជនមួយប៉ុណ្ណោះ ដែលទទួលខុសត្រូវក្នុងការប្រមូលសំរាមនៅក្នុងក្រុងមួយ (មានពីរនៅខេត្តបាត់ដំបង)។ ការធ្វើឱ្យមានការប្រកួតប្រជែងកាន់តែច្រើននៅក្នុងសេវាកម្មប្រមូលសំរាមជាមួយនឹងកិច្ចសន្យាដែលមានតម្លាភាព និងជាសាធារណៈដោយមានរយៈពេលកំណត់ (៥-១០ ឆ្នាំ) នឹងជួយធ្វើឱ្យសេវាកម្មកាន់តែប្រសើរឡើង។ អ្នកម៉ៅការប្រមូលសំរាមគួរត្រូវបានតាមដាន ដើម្បីធានាថាពួកគេប្រមូលសំរាមនៅគ្រប់តំបន់ដែលបានធ្វើកិច្ចសន្យា។ ករណីក្នុងខេត្តបាត់ដំបង តំបន់ទាំងមូលដូចជាឃុំរតនៈមិនមានសេវាអ្វីទាំងអស់។ ការដុតសំរាមដើម្បីបង្កើនទំហំទីលានចាក់សំរាមគួរតែត្រូវបានហាមឃាត់ ដូចមានចែងក្នុងអនុក្រឹត្យ។ បញ្ហានេះ គួរតែត្រូវបានដាក់បញ្ចូលក្នុងកិច្ចសន្យានាពេលអនាគត។

## ត្រួតពិនិត្យឱ្យបានទៀងទាត់ និងការពិន័យលើការដុត និងការចោលសំរាម

អនុក្រឹត្យនេះបញ្ជាក់យ៉ាងច្បាស់តម្រូវមិនឱ្យដុត ឬចោលសំរាម ហើយគេដឹងច្បាស់ណាស់អំពីផលប៉ះពាល់បរិស្ថាន និងសុខភាពសាធារណៈបណ្តាលមកពីសកម្មភាពទាំងនេះ។ ការដុតសំរាម និងការចោលសំរាមតែងតែមានតម្លៃថោកជាងការចោលត្រឹមត្រូវ ហើយតែងតែត្រូវបានគេសង្កេតឃើញមាននៅតាមទី ជនបទដែលគ្មានប្រព័ន្ធប្រមូលសំរាម។ នៅក្នុងតំបន់ទីក្រុង ការអនុវត្តន៍របៀវនេះនៅតែមាន បើទោះបីជាមានសេវាកម្មហើយ បើគ្មានការអប់រំ និងអន្តរាគមន៍ពីរដ្ឋាភិបាលទេរឿងនេះនឹងនៅតែបន្តកើតមាន។ ការត្រួតពិនិត្យរួមគ្នាឱ្យខ្លាំងជាងមុន ជាមួយការអប់រំប្រជាជនដោយគំរាមពិន័យ អាចមាននឹងប្រសិទ្ធភាព (សូមមើលផ្នែកការអនុវត្តច្បាប់) ។ យុទ្ធនាការជាវិជ្ជមានស្តីពីអត្ថប្រយោជន៍នៃការបញ្ឈប់សកម្មភាពទាំងនេះគួរតែអនុវត្ត។

នៅខេត្តបាត់ដំបងប្រជាជនជាច្រើននាំគ្នាបោះចោលសំរាមនៅផ្សារ។ វាគួរតែមានដាក់ស្លាកសញ្ញា និងបញ្ជាក់ថានេះជារឿងខុសច្បាប់ ហើយការផាកពិន័យអាចនឹងត្រូវបានអនុវត្ត។

ទោះបីជាការផាកពិន័យមិនត្រូវបានធ្វើក៏ដោយ “ការព្រមាន” ដែលប្រជាជនអាចត្រូវបានពិន័យ ឬ “ ស្នើសុំកិច្ចសហការ” អាចមានប្រសិទ្ធភាព ប្រសិនបើត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ដោយហេតុថា បច្ចុប្បន្ននេះប្រជាជនពេលខ្លះគាត់មិនទាំងដឹងថាពួកគាត់អាចនឹងត្រូវគេពិន័យនោះទេ។ ផែនការអនុវត្តច្បាប់ គួរតែត្រូវបានបង្កើតឡើងពីមួយថ្ងៃទៅមួយថ្ងៃ និងជាដំហានៗ ដោយចាប់ផ្តើមពីការត្រួតពិនិត្យដោយបុគ្គលិករបស់មន្ទីរបរិស្ថាន និងប្រព័ន្ធផ្តល់ព័ត៌មានជាមុន។

## ការបង់ថ្លៃសេវា

វាសំខាន់ណាស់ក្នុងការអនុវត្តអនុក្រឹត្យឱ្យបានត្រឹមត្រូវ។ ដោយសារភារកិច្ចគ្រប់គ្រងសំរាមភាគច្រើនត្រូវបានផ្តល់ទៅឱ្យវិស័យឯកជន អាជីវកម្មទាំងនេះចាំបាច់ត្រូវមានធនធានហិរញ្ញវត្ថុ។ នៅខេត្តបាត់ដំបងគេប៉ាន់ស្មានថា មានអ្នកបង្កើតសំរាមប្រមាណតែ ២៥% ប៉ុណ្ណោះដែលបង់ថ្លៃសេវាកម្មគ្រប់គ្រងសំរាម។ ខណៈពេលដែលមានហេតុផលជាច្រើនចំពោះបញ្ហានេះ (មិនមានថវិកា មិនសប្បាយចិត្តនឹងសេវាកម្ម ។ល។) វាពិបាកសម្រាប់ប្រតិបត្តិករឯកជនក្នុងការផ្តល់សេវាកម្មឱ្យបានល្អប្រសិនបើពួកគេមិនបានទទួលប្រាក់ខែ។ គួរកត់សម្គាល់ថានៅខេត្តបាត់ដំបង ៨៨%នៃប្រជាជនបានលក់របស់របរមួយចំនួនទៅឱ្យអេតចាយ។ គ្រួសារនីមួយៗរកប្រាក់ចំណូលបានជាមធ្យម ២ដុល្លារក្នុងមួយខែពីការលក់ទាំងនោះ ដែលស្ថិតក្នុងចន្លោះនៃថ្លៃប្រមូលដែលអនុញ្ញាតដូចមានចែងក្នុងច្បាប់។ ដូច្នេះ វាមានន័យថាការប្រមូលសំរាមមិនចោទសម្រាប់គ្រួសារតូចៗទេ។

គួរតែឱ្យមានយន្តការដែលមានប្រសិទ្ធភាពជាងមុន សម្រាប់ការប្រមូលថ្លៃឈ្នួល។ ឧទាហរណ៍ថ្លៃឈ្នួលអាចត្រូវបានប្រមូលដោយសាលាក្រុង ឬបញ្ចូលគ្នាជាមួយអគ្គិសនី (ដូចជានៅភ្នំពេញ) ឬវិក្កយបត្រទឹកនិងចែកបន្តទៅឱ្យអ្នកម៉ៅការប្រមូលប្រាក់ស្របទៅតាមគុណភាពនៃសេវាកម្មរបស់ពួកគេ។ ថវិកាមួយចំនួនក៏គួរតែត្រូវបានគេផ្តល់សម្រាប់ប្រតិបត្តិការ និងថែទាំទីលានចាក់សំរាម មិនមែនតែសម្រាប់ការប្រមូលប៉ុណ្ណោះទេ។ រដ្ឋបាលសង្កាត់ក៏អាចទទួលខុសត្រូវផងដែរចំពោះការប្រមូលថ្លៃសេវាពីគ្រួសារនៅតាមតំបន់ដែលប្រើប្រាស់ធុងស្តុកសំរាមសាធារណៈ។

### ២.៦.៧. សន្និដ្ឋាន

សរុបមក ក្រុងបាត់ដំបង នៅមានការខ្វះខាតផែនការទាក់ទងនឹងការគ្រប់គ្រងសំណល់រឹងនៅក្នុង ក្រុងនៅឡើយ។ ថ្វីបើមានកង្វះខាតបែបនេះក៏ដោយ ក៏មានការចាប់អារម្មណ៍ខ្ពស់ពីភាគីពាក់ព័ន្ធសំខាន់ៗ និងឱកាសជាច្រើនដើម្បីអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសំណល់រឹងប្រកបដោយជោគជ័យនៅក្នុងក្រុងនេះបានដែរ។ ជាមួយនឹងការរៀបចំផែនការដែលមានភាពល្អប្រសើរ និងការសម្របសម្រួលក្នុងរយៈពេលវែងតាមជំហានច្បាស់លាស់ ដើម្បីធ្វើការកែលម្អការគ្រប់គ្រង ការទុកដាក់ ការបណ្តុះបណ្តាល ការយល់ដឹង ការពង្រឹងច្បាប់ និងការប្រមូលសេវា នោះការគ្រប់គ្រងសំណល់រឹងដែលមានភាពល្អប្រសើរនឹងអាចសម្រេចទៅបានសម្រាប់ក្រុងបាត់ដំបង។

ផ្នែកទី ៣៖ ការរៀបចំប្រព័ន្ធកែច្នៃសំណល់រឹងក្នុងក្រុងបាត់ដំបង





# ៣. ការរៀបចំប្រព័ន្ធកែច្នៃសំណល់រឹងក្នុងក្រុងបាត់ដំបង

## ៣.១ ការបង្កើតប្រព័ន្ធកែច្នៃសំរាមដែលមានប្រសិទ្ធភាព

មកដល់ត្រង់ចំណុចនេះ របាយការណ៍នេះ បានប្រមូលផ្តុំព័ត៌មានដែលមានស្រាប់ក្នុងសាលាក្រុងទាំងមូល។ ក្នុងផ្នែកនេះ អនុសាសន៍ជាច្រើននឹងត្រូវបានលើកឡើងក្នុងគោលដៅធ្វើឲ្យប្រសើរឡើងប្រព័ន្ធគ្រប់គ្រងសំណល់រឹងក្នុងក្រុងបាត់ដំបង។ វិធីសាស្រ្តនេះរៀបចំប្រព័ន្ធគ្រប់គ្រងសំណល់រឹងធ្វើយ៉ាងណាកុំឲ្យមានការប្រែប្រួលខ្លាំងទៅលើលក្ខខណ្ឌ និង ថវិកាដែលមានស្រាប់ក្នុងសាលាក្រុងដើម្បីធានាឲ្យបានភាពងាយស្រួលក្នុងការអនុវត្តក្រោមជំនួយពីម្ចាស់ជំនួយខ្លះជាមួយនឹងការគាំទ្រផ្នែកបច្ចេកទេស ដើម្បីឲ្យការអនុវត្តគម្រោងអាចធ្វើទៅបាន។

ប្រព័ន្ធគ្រប់គ្រងសំណល់រឹងក្នុងសាលាក្រុងទាំងមូលដែលបានបង្ហាញក្នុងផ្នែកទីមួយ អាចប្រើប្រាស់ជាគំរូសម្រាប់បង្កើតយុទ្ធសាស្រ្តគ្រប់គ្រងសំណល់រឹងឲ្យមានភាពទូលំទូលាយជាងមុន។ ផ្នែកទីពីរ បានបកស្រាយយ៉ាងលម្អិតអំពីយុទ្ធនាការសាធារណៈនៃការគ្រប់គ្រងសំណល់រឹង ដែលមាន២ដំណាក់កាល ដែលក្នុងនោះផ្តោតសំខាន់លើការបង្កើនកន្លែងស្តុក ការធ្វើឲ្យប្រសើរឡើងសេវាកម្មប្រមូល និងការលើកកម្ពស់ការយល់ដឹង។ បន្ទាប់មកទៀតផ្នែកទីបី នឹងលើកយកសកម្មភាពលម្អិត នៃគម្រោងជំនួយការបច្ចេកទេសមកធ្វើការពិភាក្សា។ ជាចុងបញ្ចប់ ផ្នែកចុងក្រោយគូសបញ្ជាក់ពីការចំណាយលើការអនុវត្តសម្រាប់ផ្នែកទាំង៣ខាងលើ ដែលត្រូវបានបង្ហាញដោយយោងតាមការផ្តល់ជំនួយពីភាគីពាក់ព័ន្ធ។

ភាគីពាក់ព័ន្ធទាំងអស់យល់ស្របថា ការញែកសំណល់រឹងនៅនឹងប្រភព ជាចំណុចគន្លឹះក្នុងការធ្វើឲ្យប្រសើរឡើងការគ្រប់គ្រងសំណល់រឹងក្នុងក្រុងបាត់ដំបង។ ចំណុចគន្លឹះទាំងនេះ មានចំណុចសំខាន់ៗមួយចំនួន រួមមាន ការកែលម្អការគ្រប់គ្រងនិងការរៀបចំផែនការសកម្មភាព ការបង្កើនកន្លែងស្តុក និងការញែកសំណល់រឹងព្រមទាំងការកែលម្អសេវាកម្មប្រមូល។ រូបភាពទី ២៣ បង្ហាញសកម្មភាពដែលស្នើឡើងសម្រាប់អនុវត្តក្នុងរយៈពេល៣ឆ្នាំក្រោយក៏ប៉ុន្តែមានតែផែនការឆ្នាំទី ១ ប៉ុណ្ណោះ ដែលបានលើកមកបង្ហាញជាលម្អិត ដោយហេតុថាសមាសភាពតូចៗជាច្រើនមានភាពងាយស្រួលក្នុងការពង្រីកនាពេលអនាគត។

រូបភាពទី ២៣៖. សកម្មភាពនៃការគ្រប់គ្រងសំណល់រឹងដែលស្នើឡើងក្នុងក្រុងបាត់ដំបង




## ៣.២. អភិបាលកិច្ច

ដូចដែលបានពិភាក្សាក្នុងផ្នែកមុនៗ ការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ និងការចូលរួមពីសហគមន៍ គឺជាគន្លឹះដ៏សំខាន់ក្នុងការធ្វើឲ្យប្រសើរឡើងសេវាកម្មគ្រប់គ្រងសំណល់រឹង ។ លើសពីនេះទៅទៀត ការបង្កើនការខិតខំប្រឹងប្រែងក្នុងការតាមដានជាប្រចាំនិងការអនុវត្តច្បាប់នឹងជំរុញប្រជាពលរដ្ឋឲ្យកែប្រែទំលាប់របស់គាត់ឲ្យល្អជាងនេះ ។ អនុសាសន៍ដែលមានក្នុងផ្នែករងនេះមានគោលដៅគាំទ្រកិច្ចខិតខំប្រឹងប្រែងទាំងពីរដែលលើកឡើង ។

### អនុសាសន៍ ១៖ ការតាមដានសកម្មភាពគ្រប់គ្រងសំណល់រឹងផែនការពង្រឹងការអនុវត្តច្បាប់

- ដំណាក់កាលទី ១៖ បង្កើតផែនការអនុវត្តច្បាប់
  - បង្កើតផែនការអនុវត្តច្បាប់ អ្នកណាជាអ្នកត្រូវចុះអនុវត្ត? គួរចុះញឹកញាប់ប៉ុណ្ណា?
  - ផ្តល់អនុសាសន៍ក្នុងការអនុញ្ញាតឲ្យអ្នកតំណាងការងារគ្រប់គ្រងសំណល់រឹងប្រចាំសង្កាត់ធ្វើការរាយការណ៍ទៅមន្ទីរបរិស្ថានខេត្ត
  - ប្រើប្រាស់ប្រព័ន្ធព្រមាន - ព្រមាន២ដង បើនៅតែបន្តអនុវត្តទើបពិន័យ
  - អប់រំជាសាធារណៈអំពីការផាកពិន័យក្នុងការដុត និងចោលសំរាមពាសវាលពាសកាល ព្រមទាំងចែករំលែកព័ត៌មានថានឹងមានផែនការអនុវត្តការផាកពិន័យនាពេលអនាគត
  - ដាក់បញ្ចូលការបញ្ចុះតម្លៃសម្រាប់ជាការលើកទឹកចិត្តក្នុងការញែកសំណល់រឹង
- ដំណាក់កាលទី ២៖ សាកល្បងផែនការអនុវត្តច្បាប់
  - ចាប់ផ្តើមអនុវត្តច្បាប់ក្រោយពីធ្វើការអប់រំជាសាធារណៈបានទូលំទូលាយ

- អនុវត្តប្រព័ន្ធផ្តល់ព័ត៌មានជាមុន
- សង្កាត់ប្រមូលប្រាក់ពិន័យបន្ទាប់ពីមានការអនុម័តពីមន្ទីរបរិស្ថានខេត្ត

- ដំណាក់កាលទី ៣៖ ចុះអនុវត្តផែនការអនុវត្តច្បាប់
  - ធ្វើសិក្ខាសាលាជាមួយភាគីពាក់ព័ន្ធដើម្បីត្រួតពិនិត្យឡើងវិញ និង សម្រិតសម្រាំងផែនការ
  - ចុះផាកពិន័យ

## សូចនាករក្នុងការតាមដាន

វាពិតជាមានសារៈសំខាន់ណាស់ក្នុងការកំណត់ឲ្យបានច្បាស់លាស់នូវសូចនាករសំខាន់ៗសម្រាប់ធ្វើការតាមដាន។ ជាញឹកញាប់សូចនាករក្នុងការតាមដានមានច្រើនពេក តែមិនមានសារៈសំខាន់។ សូចនាករនៃការគ្រប់គ្រងសំណល់រឹងដែលគួរកំណត់រួមមាន៖

- បរិមាណសំណល់រឹងដែលបានប្រមូល (ចំនួនឡានដឹកសំរាមដែលចាក់នៅទីលាន)
- ភាពញឹកញាប់នៃការប្រមូល
- អ្នកជិតខាងដែលកេងចំណេញពីសេវាកម្មគ្រប់គ្រងសំណល់រឹងភាគរយក្នុងការប្រមូលថ្លៃសេវាកម្មគ្រប់គ្រងសំណល់រឹងបរិមាណនិងភាគរយនៃសំណល់រឹងដែលបានយកមកច្នៃជាដីកំប៉ុសដោយអង្គការ COMPED (ដើម្បីវាយតម្លៃគុណភាពនៃការញែកសំណល់រឹងនៅនឹងប្រភព)
- អត្រានៃការពេញចិត្តរបស់អ្នកប្រើប្រាស់ (ការស្ទង់មតិជាប្រចាំមួយ)
- បរិមាណសំណល់រឹងដែលបង្កើតដោយមនុស្សម្នាក់ក្នុងមួយថ្ងៃ

## កម្មវិធីតាមដាន

មានកម្មវិធី២ប្រភេទដែលមានសារៈសំខាន់សម្រាប់ការតាមដាន៖ មួយសម្រាប់សាធារណៈជនដើម្បីលើកទឹកចិត្តក្នុងការចូលរួមរបស់ប្រជាជនទូទៅ និង មួយទៀតសម្រាប់អាជ្ញាធរ។ កម្មវិធីទាំងនោះអនុញ្ញាតឲ្យយើងអាចប្រមូលសូចនាករ ពាក្យបណ្តឹង ឬការជោគជ័យ និងត្រួតពិនិត្យឡើងវិញ បានយ៉ាងឆាប់រហ័ស និងប្រកបដោយភាពងាយស្រួល។

បច្ចុប្បន្ននេះ កម្មវិធីហ្គោហ្គ្រីនខេមបូឌា ( GoGreen Cambodia ) អាចប្រើប្រាស់បានជាសាធារណៈក្នុងក្រុងបាត់ដំបង។ បើទោះបីជាសមត្ថភាពនៃកម្មវិធីនៅមានដែនកំណត់នាពេលនេះ (កម្មវិធីមានសមត្ថភាព៣មុខក្នុងការធ្វើរបាយការណ៍ ដូចជា តំបន់ដែលត្រូវការឲ្យមកយកសំណល់រឹង តំបន់ដែលមានសេវាកម្មល្អ និង តំបន់ដែលត្រូវការធុងសំរាមបន្ថែម) វាអាចប្រើប្រាស់បានសម្រាប់តាមដានបានភ្លាមៗ។ ជាពិសេស វាអាចប្រើប្រាស់បានក្នុងកំឡុងពេលធ្វើយុទ្ធនាការ ដោយប្រើប្រាស់រូបភាពទឹកមុខដូចជាទឹកមុខសប្បាយចិត្ត ដើម្បីបង្ហាញថា សំណល់រឹងត្រូវបានញែកត្រឹមត្រូវល្អ និង ទឹកមុខមិនសប្បាយចិត្តដើម្បីបង្ហាញថាសំណល់រឹងមិនបានញែក។ ព័ត៌មានអំពីធុងសំរាមអាចមានសារៈសំខាន់ផងដែរសម្រាប់សង្កាត់ និងអាជ្ញាធរ ដើម្បីយល់ថាតំបន់ណាខ្លះដែលកំពុងមានបញ្ហា។

បើទោះបីជាយ៉ាងនេះក៏ដោយ កម្មវិធីនេះត្រូវការកែលម្អឲ្យមានភាពល្អប្រសើរជាងនេះ ដើម្បីត្រួតពិនិត្យការតាមដានដែលបានធ្វើឡើង (ការធ្វើឲ្យប្រសើរឡើងការស្តុកទុកទិន្នន័យសម្រាប់អ្នកប្រើប្រាស់)។ បច្ចុប្បន្ននេះ កម្មវិធីហ្គោហ្គ្រីនខេមបូឌា ក៏កំពុងស្វែងរកទទួលជំនួយបន្ថែមសម្រាប់គោលបំណងនេះ និងមានចំណាប់អារម្មណ៍ក្នុងការសហការជាមួយអាជ្ញាធរ។ ការបង្កើតកម្មវិធីដូចគ្នានេះសម្រាប់ឲ្យអាជ្ញាធរធ្វើការប្រមូលទិន្នន័យតាមដានលម្អិត ក៏ជាជម្រើសអាចធ្វើទៅរួចមួយដែរ។

## ការតាមដានជាប្រចាំ

ដែលល្អបំផុត បុគ្គលិកម្នាក់ពីមន្ទីរបរិស្ថានខេត្ត គួរតែត្រូវបានចាត់តាំងក្នុងសកម្មភាពតាមដាន។ វាអាចមានសារៈសំខាន់ក្នុងការបង្កើនសកម្មភាពតាមដានបន្តិចម្តងៗ អមជាមួយនឹងការធ្វើយុទ្ធនាការផ្សព្វផ្សាយ ដូចច្នេះព័ត៌មាននៃផែនការចុះតាមដាននឹងបានផ្សព្វផ្សាយបានច្បាស់លាស់ជាសាធារណៈមុនពេលចាប់ផ្តើមសកម្មភាព។

- មន្ទីរបរិស្ថានខេត្ត គួរជួល និងបណ្តុះបណ្តាលបុគ្គលិកពេញម៉ោងនៅពេលដែលចាប់ផ្តើមអនុវត្តផែនការយុទ្ធនាការ
- បុគ្គលិកនេះគួរបន្តទុកជាបុគ្គលិកពេញម៉ោងបើទោះបីជាយុទ្ធនាការត្រូវបានបញ្ចប់
- បុគ្គលិកនេះ គួរមានតួនាទី ក្នុងការកត់ត្រា បញ្ហាប្រឈម និងព័ត៌មានផ្សេងៗទាក់ទងនឹងសកម្មភាពតាមដាន។
- បុគ្គលិកគួរប្រើប្រាស់កម្មវិធីហ្គោហ្គ្រីនខេមបូឌា ក្នុងការតាមដាន និង ស៊ើបអង្កេតលើការរាយការណ៍ពីសាធារណជន។

- សកម្មភាពនៅទីលានចាក់សំរាមគួរត្រូវបានតាមដានយ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍។
- សង្កាត់ទាំងអស់គួរត្រូវបានតាមដានយ៉ាងហោចណាស់ម្តងក្នុងមួយខែ។

## អនុសាសន៍ទី ២៖ ការបង្កើនការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ

### ការប្រជុំប្រចាំត្រីមាស

សកម្មភាពដែលមានសារៈសំខាន់ និងសាមញ្ញបំផុត ដែលបានស្នើឡើងគឺ កិច្ចប្រជុំប្រចាំត្រីមាស ដើម្បីបង្កើតទំនាក់ទំនងក្នុងចំណោមសហគមន៍ភាគីពាក់ព័ន្ធក្នុងការគ្រប់គ្រងសំណល់រឹងក្នុងក្រុងបាត់ដំបង។ ត្រូវបានបំផុសគំនិតដោយការប្រជុំប្រចាំខែរបស់ក្រុមការងារផ្នែកទឹកស្អាតនិងអនាម័យ(WATSAN) ដែលបានរៀបចំឡើងដោយក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងរាជធានីភ្នំពេញ ការប្រជុំក្នុងទម្រង់បែបនេះត្រូវបានស្នើឡើង៖

- អ្នកតំណាងប្រចាំសង្កាត់ ត្រូវបង្ហាញ ភាពជោគជ័យ បញ្ហាប្រឈម និង សំណើ សម្រាប់ធ្វើឲ្យការគ្រប់គ្រងសំណល់រឹងមានភាពប្រសើរឡើង
- បន្ទាប់មកទៀត ភាគីពាក់ព័ន្ធផ្សេងទៀត (អង្គការក្រៅរដ្ឋាភិបាល អ្នកប្រមូល និង អ្នកអនុវត្ត ។ល។) បង្ហាញត្រួសៗអំពីកម្មវិធី និងព្រឹត្តិការណ៍របស់ពួកគាត់ដែលគ្រោងនឹងធ្វើក្នុងពេលខាងមុខ ដើម្បីអាចបង្ហាញថា ពួកគាត់ត្រូវការគាំទ្រពីសាលាក្រុង ព្រមទាំង ស្វែងរកចំណុចណាខ្លះដែលអង្គការក្រៅរដ្ឋាភិបាល អាចគាំទ្រសាលាក្រុង និង សង្កាត់វិញ។
- ប្រសិនបើអាច ភាគីមួយ គួរបង្ហាញលម្អិតអំពីការសិក្សាថ្មីៗ និង លទ្ធផលពីការអនុវត្ត ជាដើម។ កិច្ចប្រជុំលើកទី ១ អាចប្រើប្រាស់ជាការបង្ហាញផែនការសម្រាប់ការអភិវឌ្ឍប្រព័ន្ធកែច្នៃសំណល់រឹងដែលមានភាពប្រសើរឡើង តែកិច្ចប្រជុំក្រោយៗអាចផ្លាស់ប្តូរវេនគ្នាក្នុងការធ្វើបទបង្ហាញលម្អិតបែបនេះ។
- គួរមានមួយផ្នែកនៃការប្រជុំជាការពិភាក្សាគ្នាដោយបើកចំហសម្រាប់សំនួរផ្សេងៗ និង ការចែករំលែកគំនិត ព្រមទាំងការព្រមព្រៀងគ្នាក្នុងការធ្វើសកម្មភាពជារួម។

### អ្នកតំណាងការគ្រប់គ្រងសំណល់រឹងប្រចាំសង្កាត់

លើសពីនេះទៅទៀត វាពិតជាមានសារៈសំខាន់ណាស់ក្នុងការធានាថាមានអ្នកតំណាងការគ្រប់គ្រងសំណល់រឹងប្រចាំសង្កាត់នៅរាល់ពេលទាំងអស់ ដើម្បីបង្កើនកិច្ចសន្ទនារវាង ម្ចាស់សំណល់រឹង និងអាជ្ញាធរ។ ពួកគាត់នឹងមានតួនាទី សំខាន់ក្នុងការចែករំលែកព័ត៌មានថ្មីៗ ក្នុងការគ្រប់គ្រងសំណល់រឹង ដូចជា សេវាកម្មប្រមូល ទីតាំងនៃធុងដាំស្ទូរ សេចក្តីប្រកាសថ្មីៗពីអាជ្ញាធរមូលដ្ឋាន ។ល។

ខាងក្រោមនេះជាវិសាលភាពការងារដែលបានស្នើឡើងសម្រាប់អ្នកតំណាងការគ្រប់គ្រងសំណល់រឹងប្រចាំសង្កាត់៖

- ចូលរួមក្នុងការប្រជុំប្រចាំត្រីមាសជាមួយសាលាក្រុង ហើយធ្វើការប្រជុំនៅសង្កាត់ភ្លាមៗក្រោយពីការប្រជុំប្រចាំត្រីមាសនេះ ដើម្បីចែករំលែកព័ត៌មាន។
- ជាសមាជិកនៃទំព័រហ្វេសប៊ុក (Facebook) ឬតេឡេក្រាំ (Telegram ) ដែលបានបង្កើតឡើងដោយសាលាក្រុង និងចែករំលែកសេចក្តីប្រកាស និងធ្វើបច្ចុប្បន្នភាពទៅកាន់សហគមន៍អំពីសកម្មភាពគ្រប់គ្រងសំណល់រឹង
- ចូលរួមផ្សព្វផ្សាយអនុក្រឹត្យលេខ ១១៣ ជាពិសេស តម្រូវការនៃការមិនបោះចោលពាសវាលពាសកាល និងដុតសំរាម ព្រមទាំងការបង់ថ្លៃសេវាប្រមូលសំរាមនៅពេលដែលសំរាមត្រូវបានប្រមូល។
- ចូលរួមក្នុងការអប់រំសហគមន៍លើការញែកសំណល់នៅនឹងប្រភព

វាជាការចាំបាច់ដែលសាលាក្រុងយល់ព្រម និងចាត់តាំងអ្នកតំណាងដូចដែលបានរៀបរាប់ខាងលើ ឲ្យបានច្បាស់លាស់ និងគួរមានកិច្ចប្រជុំផ្លូវការ និងមានការចុះហត្ថលេខាយល់ព្រម រវាងចៅសង្កាត់ និងអភិបាលនៃគណៈអភិបាលសាលាក្រុង។

### បណ្តាញសង្គម

វាមានភាពសាមញ្ញ និងមិនមានចំណាយថវិកាអ្វីសោះ ក្នុងការបង្កើត និងរក្សាទុកក្រុមបណ្តាញសង្គមជាមធ្យោបាយទំនាក់ទំនងសម្រាប់ភាគីពាក់ព័ន្ធក្នុងការចែករំលែកព័ត៌មាន។ គួរប្រើប្រាស់ ហ្វេសប៊ុក (Facebook) និងតេឡេក្រាំ (Telegram ) (បង្កើតជាក្រុមសម្រាប់ភាគីពាក់ព័ន្ធ និងទំព័រ

សម្រាប់សហគមន៍) ដោយសារបណ្តាញទាំងពីរនេះ ត្រូវបានប្រើប្រាស់ជាទូទៅក្នុងប្រទេសកម្ពុជា។

សកម្មភាពដែលស្នើឡើងសម្រាប់ការគ្រប់គ្រងបណ្តាញសង្គមមានដូចជា៖

- សាលាក្រុងគួរគ្រប់គ្រងគណនេយ្យបណ្តាញសង្គម និងគួរចាត់តាំងបុគ្គលិកម្នាក់ដើម្បីអនុវត្តការងារនេះ។
- គួរធ្វើបច្ចុប្បន្នភាពឲ្យបានទៀងទាត់ យ៉ាងហោចណាស់ពីរទៅបីដងក្នុងមួយសប្តាហ៍។
- សម្ភារៈទាំងអស់ដែលបានបង្កើត កំឡុងពេលធ្វើយុទ្ធនាការ (មើលផ្នែករងបន្ទាប់ទៀត) គួរត្រូវបានចែករំលែកឲ្យទៀងទាត់។
- គួរបង្កើតសញ្ញារួមមួយប្រកបដោយភាពច្នៃប្រតិដ្ឋ ដែលអាចប្រើប្រាស់នៅគ្រប់ព្រឹត្តិការណ៍ទាំងអស់
- គួរបង្ហាញពីសារៈប្រយោជន៍នៃការកែច្នៃសំណល់រឹង ការធ្វើជីកំប៉ុស និងចែករំលែកព័ត៌មានអំពីគោលនយោបាយដែលប៉ះពាល់ដល់ប្រជាជន ដូចជា ការអនុវត្តច្បាប់ជាដើម។

### បុគ្គលិកដែលបានចាត់តាំងសម្រាប់អន្តរកម្មភាគីពាក់ព័ន្ធនិងបណ្តាញសង្គម

សកម្មភាពដែលបានរៀបរាប់ខាងលើតម្រូវឲ្យមាន ការសម្របសម្រួលការធ្វើផែនការ អន្តរកម្ម និង ការធ្វើបច្ចុប្បន្នភាពសកម្មភាពថ្មីៗយ៉ាងច្រើន។ មានការអនុសាសន៍ថា សាលាក្រុងត្រូវចាត់តាំងបុគ្គលិកម្នាក់ ដើម្បីរៀបចំការប្រជុំប្រចាំត្រីមាស គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពបណ្តាញសង្គម និងទំនាក់ទំនងទៅវិញទៅមកជាមួយភាគីពាក់ព័ន្ធ (និងចូលរួមព្រឹត្តិការណ៍របស់ពួកគេ)។ ខាងសាលាក្រុងក៏ត្រូវចូលរួមយ៉ាងសកម្មក្នុងការធ្វើយុទ្ធនាការផ្សព្វផ្សាយ រួមមាន ការចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលការសិក្សាអំពីការធ្វើទីផ្សារការគ្រប់គ្រងសំណល់រឹង ផ្តល់ជំនួយក្នុងវគ្គបណ្តុះបណ្តាល និងធ្វើអន្តរកម្មជាមួយអ្នករើសអេតចាយ ព្រមទាំង ទំនាក់ទំនងជាមួយអ្នកគ្រប់គ្រងផ្សារ និង/ឬ អ្នកតំណាងការគ្រប់គ្រងសំណល់រឹងប្រចាំសង្កាត់។

## ៣.៣. ការស្តុកទុក និង ការញែក

មានកន្លែងស្តុកគ្រប់គ្រាន់ និងងាយស្រួលក្នុងការប្រើប្រាស់ អមជាមួយនឹងមានយុទ្ធសាស្ត្រផ្សព្វផ្សាយច្បាស់លាស់ អាចជួយជំរុញឲ្យមានការចូលរួមពីសាធារណៈជនក្នុងការញែកសំណល់រឹងបានកាន់តែច្រើន។ អនុសាសន៍ខាងក្រោមលើកឡើងសម្រាប់ជំរុញកិច្ចខិតខំប្រឹងប្រែងនេះ។ អនុសាសន៍ត្រូវបានរៀបរាប់ត្រួសៗក្នុងផ្នែករងខាងក្រោមនេះ តែនឹងពិភាក្សាលម្អិតក្នុងផ្នែករងបន្ទាប់ដែលមានចំណងជើងថា យុទ្ធនាការផ្សព្វផ្សាយ ទំព័រទី ៧៦។

### អនុសាសន៍ទី ៣៖ យុទ្ធនាការតាមដំណាក់កាល និង ការកំណត់សំណល់រឹងក្នុងការទាញយកមកប្រើប្រាស់ឡើងវិញ

យុទ្ធនាការតាមដំណាក់កាលត្រូវបានដាក់ស្នើឡើងឲ្យបង្កើនកន្លែងស្តុក និងសកម្មភាពនៃការញែកសំណាក់ក្នុងក្រុងបាត់ដំបង។ ចំណុចនេះគួរតែត្រូវតាមដាន និងកែសម្រួលដើម្បីឲ្យកាន់តែទទួលបានភាពជោគជ័យតាមដំណាក់កាលនីមួយៗនៃការអនុវត្ត។ លើសពីនេះទៅទៀត ការផ្តោតទៅលើ ការទាញយកសំណល់រឹងមកប្រើប្រាស់ឡើងវិញ (សំរាមសរីរាង្គ និងសំរាមស្ងួត ព្រមទាំងសំរាមដែលអាចកែច្នៃឡើងវិញបាន ។ល។) គួរត្រូវបានកែសម្រួលតាមប្រភេទសំណល់រឹងដែលបានបង្កើត និងធនធានដែលអាចទាញយកមកបានច្រើនបំផុត ។

### សំណល់រឹងផ្សារនិងសរីរាង្គ

គោលដៅដំបូងគេគឺផ្សារធំៗទាំង៥ ដោយសារតែផ្សារទាំងនេះបង្កើតសំណល់រឹងក្នុងបរិមាណច្រើន និងងាយស្រួលក្នុងការតាមដាន។ ផ្សារក៏ជាចំណុចប្រមូលផ្តុំនៃជីវិតនៅតាមទីក្រុង ហេតុនេះផ្សារអាចមានឥទ្ធិពលទៅកាន់ប្រជាពលរដ្ឋបានទូលំទូលាយ។ លើសពីនេះទៅទៀត ជាអនុសាសន៍ សំណល់សរីរាង្គជាសំណល់រឹងចម្បងដែលអាចទាញយកធនធានប្រើប្រាស់ឡើងវិញ ដោយសារតែសំណល់រឹងប្រភេទនេះមានបរិមាណច្រើន។ យុទ្ធសាស្ត្រផ្សព្វផ្សាយត្រូវបញ្ជាក់ឲ្យបានច្បាស់ថាសំណល់សរីរាង្គ គឺសម្រាប់អង្គការខមភីដ (COMPED) និងសន្មតថាសំណល់រឹងប្រភេទផ្សេងទៀតត្រូវដាក់ក្នុងធុងទី ២ ដែលអាចបន្តយកទៅមជ្ឈមណ្ឌលញែកសំរាម(MRF) បាន។

សំណល់ប្លាស្ទិកក៏អាចជាគោលដៅតាមទីតាំងដាក់លាក់នៃផ្សារ ដូចជា តំបន់ដែលលក់សំលៀកបំពាក់ ស្បែកជើង និង តុក្កតា ជាដើម។ តំបន់ទាំងនេះបង្កើតបានជាសំណល់ប្លាស្ទិកដែលលាយជាមួយនឹងម្ហូបអាហារ (ពីអាហារថ្ងៃត្រង់និងអាហារសំរន់) និងទឹកពីភេសជ្ជៈ។

ដើម្បីលើកទឹកចិត្តលើសកម្មភាពញែក គេបានផ្តល់អនុសាសន៍ក្នុងការធ្វើឲ្យយុទ្ធនាការឲ្យកាន់តែមានការប្រកួតប្រជែង គឺការផ្តល់ពានរង្វាន់លើសកម្មភាពញែកសំណល់រឹងដែលជោគជ័យ។ លើសពីនេះទៅទៀត បុគ្គលម្នាក់ៗ មានដូចជា អ្នកលក់ អ្នកអនាម័យ និងអ្នកគ្រប់គ្រង គួរត្រូវបានទទួលស្គាល់ដោយសារជារណជន សម្រាប់សកម្មភាពផ្តើមដែលបានធ្វើឡើងក្នុងកំឡុងពេលធ្វើយុទ្ធនាការ។

ខណៈដែលអនុសាសន៍ក្នុងរបាយការណ៍ផ្តោតសំខាន់លើការប្រកួតប្រជែងទ្រង់ទ្រាយធំមួយសម្រាប់ផ្សារទាំងអស់ ជាអនុសាសន៍ គួរធ្វើការអនុវត្តសាកល្បងជាដំបូងទ្រង់ទ្រាយតូចក្នុងផ្សារចំនួន២ និងប្រើប្រាស់លទ្ធផល និងមេរៀនដែលទទួលបានជាគំរូ សម្រាប់ពង្រីកវិសាលភាពទៅផ្សារទាំងអស់។ បន្ទាប់ពីផ្សារទាំង៥ គេដាក់ស្នើឡើងថាផ្សារតូចៗ និងផ្សារទំនើបជាគោលដៅសម្រាប់អនុវត្តបន្ត។

ទិដ្ឋភាពសំខាន់ផ្សេងទៀត គឺការរួមបញ្ចូលការកាត់បន្ថយសំណល់រឹងក្នុងយុទ្ធនាការលើកកម្ពស់ការយល់ដឹង ជាឧទាហរណ៍ ការលើកទឹកចិត្តឲ្យអ្នកដែលទៅផ្សារយកកាបូបដែលអាចប្រើប្រាស់ឡើងវិញមកតាមខ្លួន។

## សំណល់រឹងតាមសាលារៀននិងសំណល់ប្លាស្ទិក

ជម្រើសផ្សេងទៀង គឺការអនុវត្តប្រមូលសំណល់ប្លាស្ទិកតាមសាលារៀន។ រួមជាមួយនឹងផលប៉ះពាល់ដល់បរិស្ថាន វាក៏មានប្រសិទ្ធភាពផងដែរក្នុងការអប់រំកុមារអំពីការយល់ដឹងពីបរិស្ថាន។ ក្រុមហ៊ុនកូកាកូឡា បានធ្វើយ៉ាងជោគជ័យក្នុងខេត្តកំពង់ធំ ក្នុងការផ្តល់ធុងស្តុកសំណល់រឹងធំសម្រាប់ប្រមូលដបប្លាស្ទិកក្នុងទីធ្លាសាលា អមជាមួយនឹងផ្លាកសញ្ញា និងសារអប់រំដែលបានចែករំលែកក្នុងសន្និបាតសាលា។ សិស្សត្រូវបានផ្តល់ព័ត៌មានទាំងនេះ ក្រោយពីការគោរពភ្លេងជាតិនៅពេលព្រឹក និងត្រូវបានរំលឹកដោយគ្រូក្នុងកំឡុងពេលសិក្សា។ បន្ទាប់មកសាលាអាចលក់ដបទៅអេតចាយ និងប្រើប្រាស់ថវិកាបន្តិចបន្តួចនេះសម្រាប់សកម្មភាពផ្សេងៗរបស់សាលា។ ការអនុវត្តសាកល្បងនេះបានពង្រីកទៅកាន់សាលាចំនួន១៧ក្នុងខណ្ឌកំបូល ក្នុងរាជធានីភ្នំពេញក្រោមជំនួយរបស់គណៈកម្មការទីក្រុងស្អាត។ ការយកសកម្មភាពនេះមកធ្វើនៅក្រុងបាត់ដំបងក៏ជាជម្រើសល្អផងដែរ ដោយមានបន្ថែមជាមួយនឹងធុងសំរាម ដាច់ដោយឡែកសម្រាប់ប្រមូលថង់ប្លាស្ទិកឲ្យសហគ្រាសប្លាស្ទិកបាត់ដំបង (BPP)។

## សំណល់រឹងតាមសង្កាត់និងសំណល់ស្ងួត

ក្រោយពីការធ្វើយុទ្ធនាការនៅតាមផ្សារ គេបានផ្តល់អនុសាសន៍ឲ្យផ្តោតសំខាន់លើសង្កាត់កណ្តាល គឺសង្កាត់ស្វាយប៉ោ និងសំណល់ស្ងួត ព្រមទាំងសំណល់ដែលអាចកែច្នៃឡើងវិញបាន។ សង្កាត់នេះជាសង្កាត់ដែលមានប្រជាជន និងភ្ញៀវទេសចរច្រើនជាងគេ ហេតុនេះសង្កាត់នេះបង្កើតសំណល់ក្នុងបរិមាណច្រើនជាងសង្កាត់ផ្សេងទៀត។ ផែនការដែលបានប្រើប្រាស់ក្នុងយុទ្ធនាការតាមផ្សារ គួរត្រូវបានកែសម្រួលដោយយោងតាមតម្រូវការនៃសង្កាត់ និងមេរៀនដែលទទួលបាន។ រីឯទីតាំងនិងតួនាទី អេតចាយក៏គួរត្រូវបានកំណត់ផងដែរ។

## អនុសាសន៍ទី ៤៖ ការបង្កើនចំនួនធុងស្តុកសំណល់រឹងជាសាធារណៈ

ការដែលមានធុងស្តុកសំណល់គ្រប់គ្រាន់សម្រាប់ការញែកសំណល់រឹងនឹងជះឥទ្ធិពលខ្លាំង ដល់ខ្សែសង្វាក់ផលិតកម្មសំណល់។ ការបង្កើនធុងសំរាម គួរត្រូវបានកំណត់ជាដំណាក់កាលតាមយុទ្ធនាការនីមួយៗ និងផ្សារភ្ជាប់ជាមួយនឹងសមត្ថភាពក្នុងការ កែច្នៃសំណល់រឹង និងទាញយកធនធានមកប្រើប្រាស់ឡើងវិញរបស់កន្លែងញែកយកវត្ថុសំណល់រឹង (MRF) និងខំភីដ (COMPED) (សេចក្តីលម្អិតមាននៅផ្នែក VIII យុទ្ធនាការផ្សព្វផ្សាយ ទំព័រ៧៦ ដែលបានរៀបចំនិងត្រូវបានកែសម្រួលនិងអនុវត្តនៅតំបន់ថ្មី)។

អ្នកតំណាងប្រចាំសង្កាត់និងអ្នកគ្រប់គ្រងព្រមទាំងអ្នកអនាម័យផ្សារ គួរកំណត់ទីតាំង សម្រាប់ដាក់ធុងជាំស្ទ័រ ជាមួយនឹងក្រុមហ៊ុន លាក លឹម និង ក្រុមហ៊ុន ស៊ីន ទ្រី ក្រោមការដឹកនាំរបស់សាលាក្រុង។ ធ្វើដូចនេះអាចធានាបានទីតាំងដែលល្អបំផុត។ មិនតែប៉ុណ្ណោះ ការប្រើប្រាស់ និង ការអនុវត្តច្បាប់ ។ល។ ត្រូវបានបង្កើតឡើងថែមទៀត។

### ផ្សារ

ការរៀបចំឲ្យមានតំបន់ប្រមូលឱ្យស្រួលបួលឡើងវិញ ដើម្បីឱ្យអ្នកប្រមូលសំរាមប្រើប្រាស់ធុងដាំស្ទ័រ។ មានការស្នើសុំថា គួរកប់ធុងដាំស្ទ័រពាក់កណ្តាល ឬរៀបជាផ្លូវឡើង ដើម្បីបង្កើនភាពងាយស្រួលក្នុងការប្រើប្រាស់ធុង។ លើសពីនេះទៅទៀត គួរប្រើធុងដាំស្ទ័រប្រភេទម៉្យាងដែលអាចបិទជិតនៅពេលដែលមិនប្រើប្រាស់ (ឧទាហរណ៍ នៅពេលដែលផ្សារបិទ អាចបង្ការប្រជាជនដែលកុំឱ្យយកសំណល់រឹងពីផ្ទះមកចោល ដោយមានដាក់ស្លាកសញ្ញាសមរម្យដើម្បីឱ្យដឹងមុន។ ធុងស្តុកនេះអាចជំនួសធុងស្តុករបស់ក្រុមហ៊ុន ស៊ីន ទ្រី ដែលបានដាក់ឲ្យប្រើប្រាស់ និងអាចប្រើប្រាស់បានជាមួយឡានរបស់ក្រុមហ៊ុនងផងដែរ។

### តំបន់ដែលមិនទទួលបានសេវាកម្មគ្រប់គ្រាន់ក្នុងសង្កាត់

មានតំបន់ដែលគួរឲ្យកត់សម្គាល់ជាច្រើនក្នុងក្រុង ដែលមិនទទួលបានសេវាកម្មគ្រប់គ្រាន់ ដោយសារមូលហេតុជាច្រើនមានជាអាទិ៍ ផ្លូវមានទំហំតូចសម្រាប់ឡានប្រមូលសំរាមចូល ឬតំបន់ដែលក្រីក្រ។ បើទោះបីជាយ៉ាងនេះក៏ដោយ តំបន់ទាំងនោះមិនគួរនៅតែបន្តមិនទទួលបានសេវាកម្មបែបនេះឡើយ ដោយឡែក អ្នកតំណាងប្រចាំសង្កាត់គួរកំណត់ឲ្យបានច្បាស់លាស់នូវតំបន់ទាំងនោះ និងកន្លែងណាដែលគួរឲ្យសាលាក្រុងមកដាក់ធុងសំរាមបន្ថែម ដើម្បីបង្កើនភាពងាយស្រួលនៅក្នុងការប្រមូល។

បញ្ហាមួយដែលពាក់ព័ន្ធ គឺការផ្តល់សេវាកម្មដោយមិនគិតប្រាក់ក្នុងតំបន់ខ្លះ និងគិតប្រាក់ក្នុងតំបន់ផ្សេងទៀត។ គេបានស្នើឡើងថា សង្កាត់គួរគ្រប់គ្រងថ្លៃសេវាប្រមូលពីតំបន់ដែលមានធុងសំរាមសាធារណៈ ដែលនេះនឹងមានពិភាក្សានៅផ្នែកបន្ទាប់។

## អនុសាសន៍ទី ៥៖ ការអប់រំនិងលើកកម្ពស់ការយល់ដឹង

ការគ្រប់គ្រងនៃការផ្លាស់ប្តូរទម្លាប់អនុវត្តតាមផ្ទះ ត្រូវតែជាកម្មវិធីអន្តរាគមន៍រយៈពេលវែង ដែលត្រូវកំណត់ជាជំហានអនុវត្តឱ្យបានច្បាស់លាស់ ស្របជាមួយនឹងការកើនឡើងនៃធុងសំរាមសាធារណៈ ប្រសិនបើមានលទ្ធផលប្រកបដោយចីរភាព។

### ការបណ្តុះបណ្តាលគ្រូ

ធាតុផ្សំនៃអនុសាសន៍នេះ គឺការកសាងសមត្ថភាពឱ្យបានលម្អិត និងច្បាស់លាស់ក្នុងចំណោមអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ មុនពេលចាប់ផ្តើមសកម្មភាពនៅតាមមូលដ្ឋាន។ ក្នុងករណីខ្លះ សកម្មភាពលើកកម្ពស់ការយល់ដឹង ដែលតម្រូវសម្រាប់តែអាជ្ញាធរមូលដ្ឋាន (ក្រុង និងសង្កាត់ / ភូមិ) នឹងអាចបញ្ចុះបញ្ចូលពួកគេឱ្យយល់ដឹងអំពីអត្ថប្រយោជន៍នៃការផ្លាស់ប្តូរអាកប្បកិរិយាបានជាក់ជាពុំខាន។

ប្រធានសង្កាត់គឺជាគោលដៅសំខាន់នៃការបណ្តុះបណ្តាលគ្រូបង្គោល។ ពួកគេមានចិត្តសាទរហើយបានយល់ព្រមជួបជាមួយខាងអេតចាយ និងចេញទៅពិនិត្យមើលតាមផ្ទះក្នុងស្រុក ព្រមទាំងការការពារធុងសំរាម។ ពួកគេបានស្នើសុំឧបករណ៍ និងព័ត៌មានដើម្បីចែករំលែកគំនិត។

### ប្រធានបទនិងសម្ភារៈសម្រាប់យុទ្ធនាការលើកកម្ពស់ការយល់ដឹង

រំលេចយ៉ាងច្បាស់ថាមានប្រធានបទមួយចំនួននៃការគ្រប់គ្រងសំណល់រឹងដែលសាធារណជនទូទៅមានចំណេះដឹងបន្តិចបន្តួច។ ជាពិសេស តម្រូវការនៃសម្ភារៈដែលអាចកែច្នៃឡើងវិញបាននិងមិនអាចកែច្នៃឡើងវិញបាន ព្រមទាំងច្បាប់នៃការគ្រប់គ្រងសំណល់រឹង។ ការផ្សព្វផ្សាយលើចំណុចទាំងអស់នេះ គួរត្រូវធ្វើឡើងដោយប្រើប្រាស់សម្ភារៈ ដែលសាមញ្ញ និងមើលទៅបែបសប្បាយៗ។ ចំណុចគន្លឹះសំខាន់ៗដែលខ្វះចន្លោះ និងតម្រូវឲ្យមានការផ្សព្វផ្សាយទៅកាន់ប្រជាជនមានដូចជា៖

- វិធីក្នុងការបង្កើតសំណល់រឹងតិចជាងមុន(ប្រើប្រាស់កាបូបដែលអាចប្រើប្រាស់ឡើងវិញបានជាដើម)
- ការផាកពិន័យសម្រាប់ការចោលសំរាមពាសវាលពាសកាល និងដុតសំរាម
- កុំប្រាប់ប្រជាជន តែបង្ហាញគាត់ពីវិធីក្នុងការញែកសំណល់រឹង (រវាងសំណល់សរីរាង្គ និងសំណល់រឹងប្រភេទផ្សេងៗទៀត)
- ធ្វើអាទិភាពតាមលំដាប់នៃការគ្រប់គ្រងសំណល់រឹង បង្ការ ប្រើប្រាស់ឡើងវិញ កែច្នៃ ទាញយកជាធនធានប្រើប្រាស់ឡើងវិញ និង ប្រព្រឹត្តិកម្ម

- ផ្តល់ជាបញ្ជីពេញលេញនៃអ្វីដែលអាចកែច្នៃឡើងវិញបាន និងវិធីក្នុងការប្រមូល
- បង្ហាញពីសំណល់រឹងណាដែលងាយនឹងបង្កការយល់ច្រលំ ជាជាងសំណល់រឹងដែលបានស្គាល់ច្បាស់ហើយ (ភាគច្រើនដឹងថា ប្លាស្ទិកនិងកំប៉ុងអសមាសភាពទាំងអស់នេះ គួរត្រូវធ្វើឡើងកែច្នៃឡើងវិញបាន ចុះចំណែក សំបកប្លាស្ទិក និងស្នោវិញ?)
- សារៈសំខាន់នៃការញែកសំណល់រឹង ជាពិសេសចំពោះសុខភាព និងសម្ភារៈផ្ទាល់ខ្លួន
- អាជ្ញាធរមូលដ្ឋាន គាំទ្រ ចូលរួម និងអនុម័តលើសកម្មភាពទាំងនោះយ៉ាងច្បាស់លាស់

លើសពីនេះទៅទៀត សម្រាប់ផ្សារ ឧបករណ៍ត្រូវមានផ្លាំងរូបភាពឲ្យបានជាក់លាក់ ក្នុងការញែកសំណល់រឹងជាពីរប្រភេទ (សំណល់សរីរាង្គ និងអសរីរាង្គ) ដោយបង្ហាញថាសំណល់រឹងប្រភេទណាគួរដាក់ក្នុងធុងណា ហើយបញ្ជាក់ឲ្យច្បាស់ថា អ្វីគួរធ្វើជាមួយនឹងសម្ភារៈដែលមិនសូវបានលើកមកពិភាក្សាដូចជា ថង់ប្លាស្ទិកដែលកខ្វក់ និងប្រអប់ស្នោ។ ជាទូទៅ ការអប់រំគួរត្រូវបង្ហាញថា សម្ភារៈភាគច្រើនអាចទាញយកធនធានបានប្រសិនបើវាស្អាត។ បើទោះបីជាយ៉ាងនេះក៏ដោយ សារដែលផ្សព្វផ្សាយត្រូវកំណត់រឹង តាមមជ្ឈមណ្ឌលកែច្នៃសំណល់រឹងក្នុងមូលដ្ឋាន ឧទាហរណ៍ ប្រសិនបើមានមជ្ឈមណ្ឌលកែច្នៃស្នោ ឲ្យក្លាយទៅជាសម្ភារៈដែលអាចប្រើប្រាស់ឡើងវិញបាន។ សារទាំងនេះត្រូវបានផ្សព្វផ្សាយដោយធ្វើបច្ចុប្បន្នភាពទៅតាមសេវាកម្មដែលមាន។

ធុងដាំស្ទ័រ គួរត្រូវបានតុបតែងឲ្យបានច្បាស់និងដាក់សញ្ញាសម្គាល់ផងដែរ។ ការរៀបចំបែបនេះ គួរត្រូវបង្ហាញយ៉ាងច្បាស់ផងថា អ្វីជាសរីរាង្គ។ ប្រសិនបើមានការភាន់ច្រឡំ សំណល់នោះគួរត្រូវបានដាក់ក្នុងធុងផ្សេងមួយទៀត។ ជារួម ផ្សារយល់ស្របជាមួយចំណុចជាច្រើនដែលបានបង្ហាញ ដូចជា តម្រូវការក្នុងការអប់រំអ្នកលក់ តម្រូវការនៃកាលវិភាគប្រមូលសំណល់រឹងដែលច្បាស់លាស់និងប្រកាន់ខ្ជាប់ តម្រូវការក្នុងការបន្ថែមធុងសំរាម និងតម្រូវការការអប់រំអំពីប្រភេទសំណល់ផ្សេងៗ។ ជាពិសេស មានចំណុចលើកឡើងថា ការដាក់ធុងស្តុកសំណល់ គួរត្រូវបានរួមបញ្ចូលក្នុងកិច្ចសន្យាជាមួយផ្សារ។

## ៣.៤. ការប្រមូល

### អនុសាសន៍ទី ៦៖ ការកៀរគរអ្នករើសសំរាមតាមផ្លូវក្រៅប្រព័ន្ធ ដើម្បីធ្វើឲ្យសេវាកម្មប្រមូលសំរាមកាន់តែល្អប្រសើរជាងមុន

វិស័យក្រៅប្រព័ន្ធមានភាពរឹងមាំណាស់ក្នុងក្រុងបាត់ដំបង និងចូលរួមចំណែកយ៉ាងច្រើនដល់វិស័យកែច្នៃសំណល់ លើសពីនេះទៅទៀត តាមការប៉ាន់ស្មាន មានប្រមាណ៨០%នៃអ្នករើសសំរាមតាមផ្លូវ គឺជាស្ត្រីនិងកុមារ។ បើទោះបីជាយ៉ាងនេះក្តី ពួកគេកម្រនឹងទទួលបានការយកចិត្តទុកដាក់ណាស់ ទាំងនៅពេលរៀបចំផែនការគ្រប់គ្រងសំណល់រឹង និងការធ្វើពិធីអបអរសាទរ ព្រមទាំងលើកទឹកចិត្តថាជាផ្នែកមួយសំខាន់ក្នុងវិស័យសំណល់រឹង។ ការញែកសំណល់រឹងនឹងមានប្រយោជន៍ដល់ពួកគាត់យ៉ាងច្រើន តែយ៉ាងណាក្តីពួកគាត់គួរត្រូវបានបញ្ចូលក្នុងខ្សែសង្វាក់ផលិតកម្មនៃការគ្រប់គ្រងសំណល់រឹងបន្ថែមទៀត។

មានការផ្តល់អនុសាសន៍ ឱ្យធ្វើទំនាក់ទំនងឲ្យបានទៀងទាត់ (យ៉ាងហោចណាស់២ដងក្នុងមួយឆ្នាំ ) ជាមួយអ្នកប្រមូលក្រៅប្រព័ន្ធ នៅទីតាំងដែលបានកត់ចំណាំចំនួន២ និងនៅជិតកន្លែងទិញលក់អេតចាយ។ ចំណុចទី ១ សម្រាប់ការពិភាក្សាគួរកំណត់វិធីសាស្ត្រក្នុងការកែលម្អលទ្ធភាពនៃការទាញយកធនធានពីសំណល់ដែលអាចប្រើប្រាស់ឡើងវិញបាន មានដូចជាការជ្រើសរើសប្រភេទនៃថង់ឲ្យបានជាក់លាក់ (ថង់ថ្លាសម្រាប់សំណល់រឹងដែលអាចកែច្នៃឡើងវិញបាន ហើយថង់ស្រអាប់សម្រាប់សំណល់ចម្រុះ) និងវិធីក្នុងការទុកដាក់សំណល់រឹង (មិនត្រូវទុកថង់ចំហ និងកំពប់ ព្រោះសកម្មភាពបែបនេះនឹងទទួលបានការផាកពិន័យ)។ វគ្គបណ្តុះបណ្តាលផ្សេងៗទៀតដែលគួរដាក់បញ្ចូលមានដូចជា សុខភាពនិងអនាម័យ ច្បាប់និងបទប្បញ្ញត្តិ កាលវិភាគផ្លូវការនៃការប្រមូលសំរាម និងការគ្រប់គ្រងទីលាន (កាត់បន្ថយការដុតដែលមានគ្រោះថ្នាក់ ។ល។)។

សកម្មភាពជាមួយអេតចាយដែលត្រូវបានផ្តល់អនុសាសន៍ មានដូចជា៖

- បណ្តុះបណ្តាលអ្នកអេតចាយម្តងក្នុងមួយឆ្នាំ ជាមួយនឹងការលើកទឹកចិត្តបន្តិចបន្តួច (កាតទូរស័ព្ទ អាវយឺត) លើប្រធានបទដូចជា សុវត្ថិភាពការងារ សុខភាពនិងអនាម័យ

ការគ្រប់គ្រងទីលាន ដំណើរការអាជីវកម្ម ច្បាប់ដែលពាក់ព័ន្ធ និង ជម្រើសក្នុងការទទួលបានការថែទាំសុខភាព ។ល។
- ពិភាក្សាដោយបើកចំហអំពីវិធីជួយពួកគាត់ឲ្យទាញយកធនធានពីសំណល់រឹងដែលអាចកែច្នៃឡើងវិញបានច្រើនជាងមុនដោយមិនធ្វើឲ្យសំរាមខ្ចាត់ខ្ចាយពាសវាលពាសកាល។
- កំណត់វិធីសាស្ត្រក្នុងការទាញយកធនធានពីសំណល់រឹងដែលអាចកែច្នៃឡើងវិញ ឲ្យបានប្រសើរឡើង (មានប្រភេទថង់ ឬធុងសំរាមជាក់លាក់ ដើម្បីបង្ហាញពីវត្តមាននៃសំណល់រឹងដែលអាចកែច្នៃឡើងវិញនិង កាត់បន្ថយការកាយយកសំណល់រឹង)។
- ចែករំលែកព័ត៌មានថ្មីៗពីការប្រជុំប្រចាំត្រីមាស ព្រឹត្តិការណ៍ធុងសំរាម និង ផែនការប្រមូល។
- ចែករំលែកព័តមានពីច្បាប់ និងបទប្បញ្ញត្តិតាមរយៈការប្រើប្រាស់បណ្តាញសង្គមប្រកបដោយភាពច្នៃប្រតិដ្ឋជាមធ្យោបាយ ជាពិសេសលើការចោលសំរាមពាសវាលពាសកាលនិងការពង្រឹងការអនុវត្តច្បាប់
- ពង្រឹងសារៈសំខាន់របស់ពួកគាត់ដោយអបអរសាទរគាត់តាមបណ្តាញសង្គមក្រោយពីវគ្គបណ្តុះបណ្តាល

គេក៏បានដាក់ស្នើផងដែរថាពួកគាត់គួរត្រូវចាត់តាំងតំណាងម្នាក់ចូលរួមសកម្មភាពផ្សេងៗជាមួយនឹងភាគីពាក់ព័ន្ធផ្សេងៗទៀត (ការប្រជុំប្រចាំត្រីមាស យុទ្ធនាការផ្សព្វផ្សាយជាសាធារណៈ ។ល។) និងចែករំលែកព័ត៌មានជាមួយនឹងសហគមន៍ពួកគាត់ទាំងមូល។ វាជារឿងល្អណាស់ក្នុងការលើកទឹកចិត្តពួកគាត់ក្នុងការបង្កើតជាសមាគម ដោយសារវាអាចផ្តល់ផលប្រយោជន៍ឲ្យពួកគាត់ក្នុងរយៈពេលវែង (សូមមើល អនុសាសន៍រយៈពេលវែងអំពីការធ្វើឲ្យអេតចាយមានលក្ខណៈផ្លូវការ ទំព័រទី ១០២)។

## អនុសាសន៍ទី ៧៖ ផែនការលម្អិតនៃការប្រមូលសំរាម

ផែនការនៃការប្រមូលសំរាមមិនត្រូវបានចែករំលែកឲ្យបានទូលំទូលាយជាមួយសហគមន៍ទេ បើទោះបីជាមានកាលវិភាគទូទៅមួយក៏ដោយ។ ទាំងក្រុមហ៊ុន ស៊ីន ទ្រី និង លៀប លឹម ត្រូវបង្កើតផែនទី ជាក់លាក់មួយ ដោយមានបង្ហាញពីកាលវិភាគរបស់ពួកគាត់និងចែករំលែកឲ្យបានទូលំទូលាយតាមរយៈ វិក្កយបត្រ និងអ្នកតំណាងប្រចាំសង្កាត់។

ក្នុងកំឡុងពេលធ្វើយុទ្ធនាការញែកសំណល់រឹង គេបានស្នើឡើងថាកាលវិភាគប្រមូលដែលមានភាពល្អប្រសើរត្រូវបានរៀបចំឡើងដោយមានការព្រមព្រៀងរវាងសាលាក្រុងនិងអ្នកផ្តល់សេវាកម្មប្រមូល។ វាត្រូវរួមបញ្ចូល ការដឹកជញ្ជូនសំណល់រឹងមិនមែនសរីរាង្គទៅមជ្ឈមណ្ឌលញែកសំរាម( MRF) សម្រាប់ញែក និងសំណល់សរីរាង្គទៅអង្គការខមភីដ ( COMPED ) ហេតុដូចនេះភាគីពាក់ព័ន្ធទាំងអស់គួរតែត្រូវបានចូលរួមក្នុងការធ្វើផែនការនិងពិភាក្សា។

ផែនការប្រមូលសំរាមគួរត្រូវធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយជាសាធារណៈម្តងទៀតនៅពេលនោះ។ ប្រសិនបើជោគជ័យ កិច្ចសន្យារវាងសេវាកម្មប្រមូលទាំងពីរគួរត្រូវបានកែសម្រួលជាផ្លូវការដោយរួមបញ្ចូលការកែលម្អ។ កិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាជាមួយភាគីពាក់ព័ន្ធសម្រាប់យុទ្ធនាការនីមួយៗគួរត្រូវបានចាត់ទុកជាគំរូកិច្ចសន្យា តែក៏ត្រូវមានកែសម្រួលដោយយោងតាមមេរៀនដែលទទួលបាន។

ការពិភាក្សានានាអំពីសេវាកម្មប្រមូលផ្លូវការធ្វើការបញ្ចុះតម្លៃដល់ម្ចាស់សំណល់រឹងដែលបានអនុវត្តការញែកសំណល់រឹងរបស់ពួកគាត់អាចត្រូវ ចាប់ផ្តើមអនុវត្ត។ ក៏ប៉ុន្តែ វាក៏បានរំពឹងថានឹងចំណាយពេលយូរក្នុងការទទួលស្គាល់លើប្រាក់សន្សំពីការព្រមព្រៀងលើអត្រាមួយ និងពីសំណល់ដែលបានកែច្នៃ។ ដូចនេះ ប្រធានបទនេះត្រូវបានរៀបរាប់នៅក្នុងផ្នែករងអំពី “អនុសាសន៍រយៈពេលវែង” ដែលនិយាយអំពីការបញ្ចុះតម្លៃ និងការស្តារការទូទាត់ចំណាយលើការគ្រប់គ្រងសំរាមឡើងវិញ នៅទំព័រទី ១០២។

វិសាលភាពការងារដែលបានផ្តល់អនុសាសន៍មានដូចជា៖

- ពិចារណាឡើងវិញនិងលម្អិតអំពីផែនការប្រមូលសំណល់រឹងជាក់ស្តែង ធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លុះបញ្ចាំងពីកំណើននៃធុងសំរាមតាមដំណាក់កាល

- ធ្វើបច្ចុប្បន្នភាពផែនការនៃការប្រមូល យ៉ាងហោចណាស់រៀងរាល់៦ខែ

- ពិភាក្សាជាចំហអំពីការបង្កើនការស្តារឡើងវិញនៃការទូទាត់ការចំណាយលើសេវាកម្ម រួមមានការប្រមូលនិងការបង់ថ្លៃធុងសំរាមសាធារណៈនៅតាមសង្កាត់

## ៣.៥. យុទ្ធនាការផ្សព្វផ្សាយ

ផ្នែករងនេះផ្តល់បទបង្ហាញពីយុទ្ធនាការពីរដំណាក់កាលដំបូងដែលបានស្នើឡើង។ យុទ្ធនាការនីមួយៗចាប់ផ្តើមឡើងដោយបង្ហាញពី ព័ត៌មានទូទៅដែលសំខាន់ៗក្នុងការស្វែងយល់និងការធ្វើផែនការនៅក្នុងតំបន់នីមួយៗ។ ព័ត៌មាននេះនឹងត្រូវចងក្រងសម្រាប់ដំណាក់កាលនាពេលអនាគតដែលមិនបានដាក់បញ្ចូលក្នុងរបាយការណ៍នេះ។

### ៣.៥.១. ដំណាក់កាលទី ១៖ ផ្សារ

រូបភាពទី ២៥ ផ្សារធំៗទាំង ៥ គួរចូលរួមក្នុងការអនុវត្តសាកល្បងមានបង្ហាញជាចំណុចពណ៌ក្រហមក្នុងរូបភាពទី ២៥។

រូបភាពទី ២៥៖ ទីតាំងផ្សារ ផ្សារទំនើប និង ផ្សារតូចៗ



តារាងខាងក្រោមបង្ហាញពីព័ត៌មានទូទៅនៃផ្សារទាំង៥នេះ៖

តារាងទី ៨៖ ព័ត៌មានទូទៅនៃផ្សារទាំង៥

| ឈ្មោះផ្សារ | ផ្សារថ្មី | ផ្សារណាត់ឬផ្សារធំ | ផ្សារភូពុយ | ផ្សារលើ | ផ្សារបឹងឈូក |
|---|---|---|---|---|---|
| ឈ្មោះអ្នកគ្រប់គ្រងផ្សារ | ឈុន សុភាព | សម រី | វ៉ាន់ ចំរើន | សេង សិរីវឌ្ឍនៈ | សៀន ភិរ័ន្ត |
| លេខទំនាក់ទំនង | ០១២ ៩៥៦ ៦២៤ | ០១២ ៥៦៥ ២៣៤ | ០៨៦ ៨៤៧ ៤៧៥ | ០១៧ ៥២៧ ២៨៧ | |
| អាសយដ្ឋាន | ភូមិ ១៣មករា សង្កាត់ ព្រែកព្រះស្តេច | ភូមិ ព្រែកមហាទេព សង្កាត់ស្វាយប៉ោ | ភូមិ អញ្ចាញ សង្កាត់អូរចារ | ភូមិកម្មករ សង្កាត់ស្វាយប៉ោ | ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ |
| លក្ខណៈពិសេសរបស់ផ្សារ | លក់ទំនិញចម្រុះ | លក់ទំនិញចម្រុះ | ផ្សារបោះដុំបន្លែ និងផ្លែឈើ | លក់ទំនិញចម្រុះ | លក់ទំនិញចម្រុះ និងបោះដុំបន្លែ និងផ្លែឈើ |
| ចំនួនតូប | ៦០៦ | ៥២៥ | ៧៣៧ | ២៤៤ | ១០០០ |
| តូបលក់ម្ហូបអាហារ បន្លែ និង សាច់ | ២០០ | ២០២ | ៦០០ | ១៤៨ | ៤០០ |
| តូបលក់គ្រឿងទេស សំលៀកបំពាក់គ្រឿងអលង្ការ ។ល។ | ៤០៦ | ៣២៣ | ១៣៧ | ៩៦ | ៦០០ |
| រយៈពេលបើក | ពីម៉ោង ៤ព្រឹក ដល់ម៉ោង ៦ ៣០ នាទី ល្ងាច | ពីម៉ោង ៥ព្រឹក ដល់ម៉ោង ៦ ៣០ នាទី ល្ងាច | ២៤ម៉ោង | ពីម៉ោង ៦ព្រឹក ដល់ម៉ោង ៦ល្ងាច | ពីម៉ោង ៦ព្រឹក ដល់ម៉ោង ៦ល្ងាច |

## ការបង្កើតសំរាម

យោងតាមការសម្ភាសជាមួយនឹងអ្នកគ្រប់គ្រងផ្សារ អ្នកអនាម័យផ្សារ និង សេវាកម្មប្រមូលសំរាមនៅតាមផ្សារទាំងនោះ យើងអាចប៉ាន់ស្មានបរិមាណសំរាមបានដូចខាងក្រោម៖

| ឈ្មោះផ្សារ | ផ្សារថ្មី | ផ្សារណាត់ ឬផ្សារធំ | ផ្សារភូពុយ | ផ្សារលើ | ផ្សារបឹងឈូក |
|---|---|---|---|---|---|
| បរិមាណសំណល់រឹងសរុប ដែលប៉ាន់ស្មាន (តោន/ថ្ងៃ) | ៤ | ៥,៥ | ៥,៥ | ២ | ៧ |
| សមាសភាពសំណល់ សរីរាង្គដែលប៉ាន់ស្មាន (%) | ៧០% | ៧០% | ៨០% | ៧០% | ៨០% |
| បរិមាណសំណល់សរីរាង្គ ដែលប៉ាន់ស្មាន (តោន/ថ្ងៃ) | ២,៨ | ៣,៨ | ៣,៨ | ១,៤ | ៤,៩ |

បរិមាណសំរាមដែលបង្កើតពីផ្សារទាំង៥នេះមានប្រមាណជិត ១៧តោនក្នុងមួយថ្ងៃដែលបរិមាណនេះលើសពីសមត្ថភាព របស់មជ្ឈមណ្ឌលកែច្នៃជីកំប៉ុសរបស់ខាំផែង ( COMPED ) នាពេលបច្ចុប្បន្ន ដែលមានសមត្ថភាពក្នុងការកែច្នៃត្រឹមតែ ៨តោនក្នុង១ថ្ងៃ ហើយអាចបង្កើនសមត្ថភាពកែច្នៃដល់១០តោន ក្នុងមួយថ្ងៃក្រោមការគាំទ្ររបស់យូនីដូ ( UNIDO ) ។ ហេតុដូចនេះ វាត្រូវបានស្នើឡើងថា គួរមានផែនការក្នុងការពង្រីក មជ្ឈមណ្ឌលខាំផែង ក្នុងឆ្នាំខាងមុខ ។

## សេវាកម្មសម្អាតនៅតាមផ្សារ

តាមរយៈការប្រមូលទិន្នន័យបានបង្ហាញថាជាទូទៅ បុគ្គលិកផ្សារ រួមមានអ្នកអនាម័យ ហើយពួកគាត់មានតួនាទី សំខាន់ពីរគឺ ជូត និង បោស ព្រមទាំងប្រមូលសំរាមពីតាមតូបទាំងអស់ទៅចោល នៅធុងសំរាមនៅខាងក្រៅផ្សារដែលទុកឲ្យសេវាកម្មប្រមូល មកប្រមូល ។ ជាទូទៅ អ្នកលក់បង់ថ្លៃសេវាបន្តិចបន្តួចប្រចាំថ្ងៃ សម្រាប់សេវាកម្មនេះទៅផ្សារ ។ សេចក្ដីលម្អិតនៃសេវាកម្មនេះតាម ផ្សារនីមួយៗមានបង្ហាញក្នុងតារាងទី ៩ ៖

តារាងទី ៩ ៖ លម្អិតនៃសេវាកម្មអនាម័យតាមផ្សារនីមួយៗ[៣៨]

| ឈ្មោះផ្សារ | ផ្សារថ្មី | ផ្សារណាត់ ឬផ្សារធំ | ផ្សារភ្លុយ | ផ្សារលើ | ផ្សារបឹងឈូក |
|---|---|---|---|---|---|
| ចំនួនអ្នកអនាម័យផ្សារ | ២ | ៤ | ១២ | ១ | ៧ |
| ប្រាក់ខែជាមធ្យមសម្រាប់អ្នកអនាម័យម្នាក់ ( ដុល្លារ/ខែ ) | ១២៥ | ២០០ | ១៣០ | ១៥០ | ១៥០ |
| ថ្លៃសេវាអនាម័យដែលអ្នកលក់បង់ក្នុងមួយថ្ងៃ ( ដុល្លារ/ថ្ងៃ ) | ០,១២៥ | ០,០៥ | ០,១២៥ | ០,១២៥ | ពី០,១២៥ ទៅ០,២៥ |
| ថ្លៃសេវាអនាម័យដែលប្រមូលបានក្នុងមួយថ្ងៃ ( ដុល្លារ/ថ្ងៃ ) | ៧៦ | ២៦ | ៩២ | ៣១ | ពី ១២៥ទៅ២៥០ |

## ការស្តុក

មានសម្ភារៈសម្រាប់ស្តុក៣ប្រភេទដែលនិយមប្រើប្រាស់ រួមមាន ធុងសំរាម ធុងដាំស្ល (ជាធម្មតាផ្តល់ឲ្យដោយក្រុមហ៊ុន ស៊ីន ទ្រី ) និង កន្លែងចាក់សំរាមបើកចំហ ។ សម្ភារៈស្តុកដែលប្រើប្រាស់តាមផ្សារនីមួយៗបានបង្ហាញក្នុងតារាងខាងក្រោម ៖

តារាងទី ១០៖ សម្ភារៈស្តុកសំរាមតាមផ្សារនីមួយៗ

| ឈ្មោះផ្សារ | ផ្សារថ្មី | ផ្សារណាត់ ឬផ្សារធំ | ផ្សារភ្លុយ | ផ្សារលើ | ផ្សារបឹងឈូក |
|---|---|---|---|---|---|
| ចំនួនធុងសំរាម | ៨ | ៣ | ១២ | ៨ | ៨ |
| ចំណុះធុងសំរាម ( គីឡូ ) | ៣០ | ៣០ | ១៥ | ១៥ | ១៥ |
| កន្លែងចាក់សំរាមបើកចំហ | ១ | ០ | ១ | ០ | មួយចំនួន |

[៣៨] សោរីនធីប ថានថានី( Sarintip Tantanee ) និងសុធី ហានត្រាកុល ( Suthi Hantrakul ) បញ្ញាប្រឈមក្នុងការគ្រប់គ្រងសំរាមទីក្រុងនៃនគរូបនីយកម្ម៖មេរៀនទទួលបានពី Phitsanulok ប្រទេសថៃ( មករា ២០១៩ )

| ពណ៌នាពីកន្លែងចាក់សំរាមបើកចំហ | ទំហំប្រមាណ ៥មx៦មx០,៨ម ព័ទ្ធដោយជញ្ជាំងបេតុង នៅខាងកើតផ្សារ | មិនមាន | ទី ធ្លាទំនេរ នៅជិតធុងដាំស្ទ័រ | មិនមាន | គំនរសំរាម នៅជុំវិញផ្សារ |
|---|---|---|---|---|---|
| ចំនួនធុងដាំស្ទ័ររបស់ក្រុមហ៊ុន ស៊ីន ទ្រី | ០ | ១ | ២ | ១ | ០ |
| ចំណុះធុងដាំស្ទ័រ (តោន) | ០ | ៤ | ៤ | ៤ | ០ |
| ធុងសំរាមសម្រាប់ញែកសំរាម | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |

## ការប្រមូល

### ការប្រមូលផ្លូវការ

Table ១១ ក្នុងចំណោមផ្សារទាំង៥ ផ្សារបឹងឈូកគឺជាផ្សារតែមួយគត់ដែលធ្វើការប្រមូល និង ដឹកជញ្ជូនសំរាមដោយខ្លួនឯងទៅចាក់នៅទីលាន។ បើទោះបីជាយ៉ាងនេះក្តី ក៏ផ្សារបឹងឈូកត្រូវបង់ថ្លៃទីលានទៅកាន់ក្រុមហ៊ុន ស៊ីន ទ្រីផងដែរ ដែលមានតម្លៃប្រហាក់ប្រហែលទៅនឹងថ្លៃសេវាកម្មប្រមូលនៃផ្សារផ្សេងទៀត។ ការអនុវត្តនៃការប្រមូលនឹងពណ៌នាក្នុងតារាងទី ១១៖

តារាងទី ១១៖ការប្រមូលសំរាមនៅតាមផ្សារ

| ឈ្មោះផ្សារ | ផ្សារថ្មី | ផ្សារណាត់ ឬផ្សារធំ | ផ្សារភូពុយ | ផ្សារលើ | ផ្សារបឹងឈូក |
|---|---|---|---|---|---|
| ក្រុមហ៊ុនផ្តល់សេវាកម្មប្រមូល | ក្រុមហ៊ុន ស៊ីន ទ្រី | ក្រុមហ៊ុន ស៊ីន ទ្រី | ក្រុមហ៊ុន ស៊ីន ទ្រី | ក្រុមហ៊ុន ស៊ីន ទ្រី | ផ្សារផ្ទាល់ |
| ចំនួនឡានសម្រាប់ដំណើរការប្រមូល | ១ | ២ | ១ | ១ | ២ |
| ពណ៌នាពីឡានប្រមូល | ឡានដែលមានប្រព័ន្ធសង្កត់ | - ឡានដែលមានប្រព័ន្ធសង្កត់សម្រាប់សំរាមនៅខាងក្រៅធុងដាំស្ទ័រ<br>- ឡានមកស្ទូចយកធុងដាំស្ទ័រ | ឡានមកស្ទូចយកធុងដាំស្ទ័រ | ឡានមកស្ទូចយកធុងដាំស្ទ័រ | ឡាន១ឬ២តាមបរិមាណសំណល់រឹង |
| បរិមាណសំណល់រឹងដែលប្រមូលចេញពីផ្សារ | ១០០% | ១០០% | ៨៥% | ១០០% | ១០០% |
| បុគ្គលិកប្រមូលសំរាម | ៥ទៅ៦នាក់ | ៦ទៅ៧នាក់ | ម្នាក់ (តែអ្នកបើកឡានប៉ុណ្ណោះ) | ម្នាក់(តែអ្នកបើកឡានប៉ុណ្ណោះ) | ១២ នាក់ |
| ភាពញឹកញាប់នៃការប្រមូល | ម្តងក្នុងមួយថ្ងៃ | ម្តងក្នុងមួយថ្ងៃ | ពីរដងក្នុងមួយថ្ងៃ | ពីរថ្ងៃម្តង | បីដងក្នុង១ថ្ងៃ |
| ម៉ោងប្រមូល | ចន្លោះពីម៉ោង ៣ដល់ម៉ោង ៥ល្ងាច | ចន្លោះពីម៉ោង ៤ដល់ម៉ោង ៧ព្រឹក | ចន្លោះពីម៉ោង ៥ដល់ម៉ោង ១១ព្រឹក | ប្រហែលម៉ោង៥ព្រឹក | ប្រហែលម៉ោង ៥ព្រឹក ម៉ោង ២រសៀល និង ម៉ោង ៥ព្រឹក |

គួរឲ្យកត់សម្គាល់ថាការប្រមូលសំរាមនៅផ្សារភូពុយ និងផ្សារលើត្រូវការតែបុគ្គលិកម្នាក់ប៉ុណ្ណោះដោយសារតែប្រសិទ្ធភាពនៃការប្រមូលដោយប្រើប្រាស់ធុងដាំស្ទ័រ។ ប្រព័ន្ធនេះគួរត្រូវបានដាក់ពង្រាយនៅគ្រប់ផ្សារទាំងអស់។ ដើម្បីជៀសវាង ការចោលសំរាមពាសវាលពាសកាល ធុងដាំស្ទ័រគួរត្រូវដំឡើងឲ្យអ្នកអនាម័យងាយស្រួលក្នុងការប្រើប្រាស់ដូចដែលបានស្នើឡើងក្នុងផ្នែកទី ១។

## ការប្រមូលក្រៅផ្លូវការ

ជាទូទៅ សំណល់រឹងដែលអាចកែច្នៃឡើងវិញបានមានដូចជា កំប៉ុង អាលុយមីញ៉ូម ត្រូវបានប្រមូលដោយអ្នកប្រមូលសំរាមក្រៅប្រព័ន្ធ និងអ្នកអនាម័យផ្សារ។ ជាមធ្យម តាមរយៈការប្រមូលយកទៅលក់អេតចាយនេះ អ្នកអនាម័យម្នាក់អាចរកកម្រៃបានប្រមាណ ២៥ដុល្លារក្នុងមួយខែ។ លើសពីនេះទៅទៀត ផ្សារទាំងនេះគឺជាទីតាំងចម្បងដែលអ្នករើសសំរាមមករើសយកសំណល់រឹងដែលអាចកែច្នៃឡើងវិញបាន ជាពិសេសនៅពេលដែលផ្សារបិទរហូតដល់ពេលល្ងាច។

## អនុសាសន៍សម្រាប់ការអនុវត្តសាកល្បងទ្រង់ទ្រាយតូចនៅតាមផ្សារ

គេបានផ្តល់អនុសាសន៍ឲ្យអនុវត្តសាកល្បងទ្រង់ទ្រាយតូចជាដំបូងនៅផ្សារចំនួន២ ដើម្បីយល់ថាអ្វីដែលដំណើរការបានល្អបំផុត។ បន្ទាប់មកលទ្ធផលដែលទទួលបាននឹងត្រូវបានប្រើប្រាស់ជាគំរូសម្រាប់យុទ្ធនាការផ្សព្វផ្សាយទ្រង់ទ្រាយធំខាងក្រោម។ ដោយសារតែសំណល់សរីរាង្គនៅផ្សារភាគច្រើនត្រូវបានលាយឡំជាមួយសមាសធាតុផ្សេងៗរួមមានដូចជា សាច់សត្វ ឆ្អឹង និងត្រី ដែលមិនអាចមានប្រសិទ្ធភាពក្នុងការកែច្នៃជាជីកំប៉ុសដោយខមភីដ (COMPED) គេបានផ្តល់អនុសាសន៍ ឲ្យផ្តោតសំខាន់ជាដំបូងនៅផ្សារភូពុយ។ ដោយសារតែជាផ្សារបោះដុំផ្លែឈើនិងបន្លែដែលមានទីតាំងនៅជាយសាលាក្រុង វាមានសភាពស្ងប់ស្ងាត់និងងាយស្រួលក្នុងការរៀបចំជាងផ្សារដទៃទៀត។

នៅផ្សារបឹងឈូក ត្រូវបានដាក់ស្នើឲ្យដាក់គោលដៅចំពោះទីតាំងខាងក្នុងផ្សារនិងនៅជុំវិញផ្សារដែលលក់សម្ភារៈស្ងួតជាច្រើនមានដូចជា សំលៀកបំពាក់ ស្បែកជើង តុក្កតា ។ល។ សំណល់រឹងភាគច្រើននឹងជាសំណល់ស្ងួត (ប្លាស្ទិក ក្រដាសកេស ស្នោ ។ល។) និង ដាក់គោលដៅក្នុងការកាត់បន្ថយសំណល់ម្ហូបដែលសល់ពីអាហារថ្ងៃត្រង់ និង អាហារសម្រន់។ ដើម្បីអនុវត្តសាកល្បងឲ្យបានជោគជ័យ វាពិតជាមានសារៈសំខាន់ណាស់ក្នុងការធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងអ្នកប្រមូលដើម្បីជៀសវាងការលាយសំរាមចូលគ្នាក្នុងកំឡុងពេលប្រមូល ដូចដែលបានកើតឡើងពីមុន។

## អនុសាសន៍សម្រាប់ការរៀបចំយុទ្ធនាការសម្រាប់ផ្សារទាំង៥

ការប្តេជ្ញាចិត្តរបស់ផ្សារជាគន្លឹះក្នុងការជំរុញឲ្យការញែកសំណល់រឹងនៅនឹងប្រភពបានជោគជ័យ។ ការរៀបចំផែនការ និងការកំណត់រយៈពេល ៦០ថ្ងៃ[៣៩] លើការធ្វើយុទ្ធនាការ “ការប្រកួតប្រជែងពានរង្វាន់ផ្សារស្អាត” (ដែលមានរៀបរាប់លម្អិតក្នុងតារាងទី ១២) សម្រាប់ផ្សារទាំង៥ អាចចាត់ទុកជាការលើកទឹកចិត្តដោយមិនប្រើប្រាស់ថវិកាក្នុងការជំរុញឲ្យ អ្នកលក់ អ្នកអនាម័យផ្សារ និងអ្នកគ្រប់គ្រងផ្សារអនុវត្តការញែកសំណល់រឹង។ ប្រសិនបើការញែកនៅនឹងប្រភពទទួលបានភាពជោគជ័យ និងផលិតភាពនៃការកែច្នៃជីកំប៉ុសមានការកើនឡើង ការបញ្ចុះតម្លៃលើសេវាកម្មប្រមូលគួរត្រូវធ្វើឡើង។

លំហូរការងារក្នុងការធ្វើយុទ្ធនាការនៅតាមផ្សារ មានបង្ហាញក្នុងរូបភាពទី ២៦ រួមមានទាំងផែនការតាមដំណាក់កាល។ សមិទ្ធផលដែលទទួលបានសំខាន់ៗ មានបង្ហាញក្នុងប្រអប់រូបពេជ្រពណ៌បៃតង និងត្រូវតែធ្វើឲ្យបានមុនពេលបន្តអនុវត្តសកម្មភាពបន្ទាប់។ សកម្មភាពត្រូវបានបង្ហាញក្នុងប្រអប់ការ៉េ ហើយចំណុចចាប់ផ្តើមនិងចំណុចបញ្ចប់ត្រូវបានបង្ហាញក្នុងប្រអប់ពងក្រពើ។

[៣៩] Psychology study from 2009 concluded that it takes on average 60 days to form a habit. Source: How are habits formed: Modelling habit for formation in the real world, Pillippa Lally et all, European Journal of Social Psychology, 16 July 2009.

## រូបភាពទី ២៦៖ លំហូរការងារនៃយុទ្ធនាការទីផ្សារ



### តារាងទី ១២៖ អនុសាសន៍លម្អិតសម្រាប់ការរៀបចំការអនុវត្តសាកល្បងសម្រាប់ផ្សារ

| ល.រ | សកម្មភាពការងារ | ម្ចាស់ការ | លម្អិត |
|---|---|---|---|
| **១** | **សកម្មភាពចាប់ផ្តើម** | **សាលាក្រុង** | **ណែនាំពីពេលវេលានៃយុទ្ធនាការ និង ទំនួលខុសត្រូវនៃភាគីពាក់ព័ន្ធនីមួយៗ ពាក់ព័ន្ធភាគីពាក់ព័ន្ធទាំងអស់ដែលធ្វើការលើការគ្រប់គ្រងសំណល់រឹង** |
| ១.០១ | កំណត់ជនបង្គោលរបស់សាលាក្រុង និងមន្ទីរបរិស្ថានខេត្ត | សាលាក្រុង និងមន្ទីរបរិស្ថាន | គួរជាអ្នកដែលធ្វើការងារច្រើនទាក់ទងនឹងការគ្រប់គ្រងសំណល់រឹង ការិយាល័យសំណល់រឹង និងសោភណភាពក្រុងគឺជាអ្នកដឹកនាំគណៈកម្មការ |
| ១.០២ | កំណត់និងដាក់ចេញសកម្មភាពសម្រាប់អ្នកដឹកនាំជំរុញការញែកសំណល់រឹង | COMPED និងមន្ទីរបរិស្ថាន | មន្ទីរបរិស្ថានជួលបុគ្គលិកម្នាក់<br>COMPED ជួលបុគ្គលិកម្នាក់ (ឬអាចចាត់តាំងបុគ្គលិកញែកម្នាក់ដែលមានស្រាប់ចូលរួមធ្វើយុទ្ធនាការ) បុគ្គលិកពេញម៉ោងទាំងពីរនាក់នេះនឹងធ្វើការពេញម៉ោងរយៈពេល៣ខែ (១ខែមុនពេលចាប់ផ្តើមយុទ្ធនាការរយៈពេល៦០ថ្ងៃ)៖<br>- ចំណាយពេល៩០%ធ្វើការនៅតាមផ្សារ ដោយការផ្សព្វផ្សាយសារវិជ្ជមាន និងជំរុញលើកទឹកចិត្ត អ្នកអនាម័យ អ្នកលក់ និង ប្រជាជនដែលយកសំណល់មកចោលនៅផ្សារឲ្យញែកសំណល់<br>- ផ្តល់របាយការណ៍តាមដានជាសាធារណៈប្រចាំសប្តាហ៍តាមផ្សារនីមួយៗ<br>- ជាបុគ្គលដែលសកម្មក្នុងការជំរុញឲ្យការញែកសំណល់រឹងមានប្រសិទ្ធភាព |
| ១.០៣ | កំណត់អ្នកតំណាងការគ្រប់គ្រងសំណល់រឹងប្រចាំសង្កាត់ សម្រាប់សង្កាត់ទាំង៣ជាទីតាំងផ្សារ | អ្នកតំណាងការគ្រប់គ្រងសំណល់រឹងប្រចាំសង្កាត់ | |
| ១.០៤ | ធ្វើសិក្ខាសាលាដើម្បីរៀបចំផែនការ | អ្នកតំណាងការគ្រប់គ្រងសំណល់រឹងប្រចាំសង្កាត់ | លម្អិតពីតួនាទី និងទំនួលខុសត្រូវកំណត់ការចុះអនុវត្តច្បាប់ |
| M១.១ | **បង្កើតគណៈកម្មការពានរង្វាន់ទីផ្សារស្អាត** | **សាលាក្រុង** | **គណៈកម្មការគ្រប់គ្រង (ជាអ្នកធ្វើការសម្រេចចិត្ត)**<br>**ជនបង្គោលម្នាក់ពីក្រុងបាត់ដំបង (ប្រធាន)**<br>**ជនបង្គោលម្នាក់ពីមន្ទីរបរិស្ថានខេត្តបាត់ដំបង (អនុប្រធាន)**<br>**តំណាងពីសង្កាត់ទាំង៣ (សង្កាត់ ស្វាយប៉ោ អូរចារ និង ព្រែកព្រះស្តេច)**<br>**អ្នកដឹកនាំជំរុញការញែកសំរាមដែលបានជ្រើសរើស**<br>**សមាជិកគណៈកម្មការ (ចូលរួមក្នុងការរៀបចំផែនការផ្សេងៗ)**<br>**តំណាងពីផ្សារទាំង៥**<br>**តំណាងពីខាង COMPED**<br>**អ្នកស្ម័គ្រចិត្តពីក្រុមអ្នកគ្រប់គ្រងសំណល់រឹងផ្សេងៗទៀត** |

| ២ | **សកម្មភាពរបស់គណៈកម្មការ "ពានរង្វាន់ទីផ្សារស្អាត"** | | |
|---|---|---|---|
| ២.០១ | លម្អិតពីសូចនាករសម្រាប់យុទ្ធសាស្ត្រតាមដាន | សាលាក្រុង | លទ្ធផលការត្រួតពិនិត្យប្រចាំសប្តាហ៍តាមផ្សារនីមួយៗពីអ្នកដឹកនាំជំរុញការញែកសំរាមចំនួន២នាក់ លទ្ធផលត្រួតពិនិត្យប្រចាំសប្តាហ៍ពីសំណល់សរីរាង្គដែលទទួលបានពី COMPED លទ្ធផលត្រួតពិនិត្យសំណល់រឹងដែលដឹកទៅមជ្ឈមណ្ឌលញែកសំរាម លទ្ធផលការតាមដានដោយសារជារណៈជន និងអ្នកស្ម័គ្រចិត្តតាមរយៈការប្រើប្រាស់កម្មវិធីទូរស័ព្ទ GoGreen Cambodia |
| ២.០២ | លម្អិតពីផែនការប្រមូលតាមផ្សារជាមួយនឹងក្រុមហ៊ុន ស៊ីន ទ្រី និងក្រុមហ៊ុន លៀប លឹម | មន្ទីរបរិស្ថានខេត្ត | កាលវិភាគប្រមូលសំរាមសម្រាប់ផ្សារនីមួយៗ<br>ក្រុមហ៊ុនស៊ីន ទ្រី ប្រមូលសំណល់សរីរាង្គ (ប្រចាំថ្ងៃ)<br>ក្រុមហ៊ុនលៀប លឹម ប្រមូលសំណល់រឹងផ្សេងទៀតទៅមជ្ឈមណ្ឌលញែកសំរាម (យ៉ាងហោចណាស់៣ដងក្នុងមួយសប្តាហ៍) |
| ២.០៣ | កំណត់ផែនការអនុវត្តច្បាប់ | មន្ទីរបរិស្ថានខេត្ត | ផ្តោតសំខាន់លើការអប់រំជាសាធារណៈអំពីការដាក់ពិន័យក្នុងការដុត និង ការចោលសំរាមពាសវាលពាសកាល និងផ្សព្វផ្សាយពីផែនការដែលនឹងអនុវត្តនាពេលអនាគត |
| M២.១ | **ចុះកិច្ចព្រមព្រៀងសហប្រត្តិបត្តិការ** | **សាលាក្រុង** | **អ្នកគ្រប់គ្រងផ្សារយល់ព្រមចូលរួមយុទ្ធនាការនេះ៖**<br>· **ក្រុមហ៊ុន ស៊ីន ទ្រី យល់ព្រមប្រមូលសំណល់សរីរាង្គពីផ្សារតាមពេលវេលាជាក់លាក់ដែលបានកំណត់**<br>· **ក្រុមហ៊ុន លៀប លឹម យល់ព្រមប្រមូលសំណល់រឹងផ្សេងទៀតទៅមជ្ឈមណ្ឌលញែកសំរាម**<br>· **អ្នកគ្រប់គ្រងផ្សារ ក្រុមហ៊ុន ស៊ីន ទ្រី និង ក្រុមហ៊ុន លៀប លឹម ចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការ** |
| ២.០៤ | រចនាឧបករណ៍ផ្សព្វផ្សាយ និងការតុបតែង | មន្ទីរបរិស្ថានខេត្ត និង ជំនួយការបច្ចេកទេស | ផ្តោតសំខាន់លើការផ្សព្វផ្សាយដែលមិនបង្កើតសំណល់ច្រើន (ដូចជា កាត់បន្ថយការប្រើប្រាស់ខិតបណ្ណ ជាដើម)<br>· បង្កើតជាវីដេអូផ្សព្វផ្សាយ<br>· ប្រើប្រាស់សញ្ញា # លើបណ្តាញសង្គម<br>· ផ្សព្វផ្សាយអប់រំលើសំរាមដែលងាយនឹងបង្កការយល់ច្រលំ(ដូចជាប្លាស្ទិកដែលកខ្វក់ ឬ ស្នោ ជាដើម)<br>· ផ្សព្វផ្សាយអប់រំថាអ្វីខ្លះជាសំណល់សរីរាង្គ និង អ្វីខ្លះមិនមែនជាសំណល់សរីរាង្គ<br>· ផ្សព្វផ្សាយពីសម្ភារៈដែលអាចកែច្នៃឡើងវិញបាន រួមមាន ថង់ប្លាស្ទិក និង ដីកំប៉ុស<br>· លើកទឹកចិត្តក្នុងការប្រមូលយកសំបកដូង និង កាកអំពៅជាដើម ។ល។ |
| M២.២ | **រចនាលើធុងដាំស្ទូរ** | **ក្រុមហ៊ុន លៀប លឹម** | **ប្រសិនបើអាច បោះពុម្ពលើសម្ភារៈដែលអាចកែច្នៃឡើងវិញបាន** |
| ២.០៥ | ជ្រើសរើសទីតាំងដាក់ធុងដាំស្ទូរ | សាលាក្រុង | អ្នកតំណាងការគ្រប់គ្រងសំណល់រឹង និងអ្នកតំណាងផ្សារ ពិភាក្សា និងកំណត់កន្លែងដាក់ និង តម្រូវការនៃធុងដាស្ទូរ |
| ២.០៦ | ជ្រើសរើសទីតាំងដាក់ធុងសំរាម | COMPED | សំភាសអ្នកអនាម័យតាមផ្សារនិងអ្នកគ្រប់គ្រងផ្សារដើម្បីកំណត់ទីតាំងដែលសមស្របដើម្បីដាក់ធុងសំរាមក្នុងផ្សារ |

| | | | |
|---|---|---|---|
| ២.០៧ | ធ្វើការដេញថ្លៃ ទិញធុងដាំស្ល | UNIDO | គួររៀបចំឲ្យបានងាយស្រួលក្នុងការប្រើប្រាស់ |
| ២.០៨ | ធ្វើការដេញថ្លៃ ទិញធុងសំរាម | ក្រុមហ៊ុន លៀប លឹម | សាលាក្រុងត្រូវប្រាកដថា ទីតាំងត្រូវបានកំណត់យោងតាមអ្នកគ្រប់គ្រងផ្សារ |
| ២.០៩ | ផ្តល់វគ្គបណ្តុះបណ្តាល គ្រូបង្គោល (អ្នកដឹកនាំជំរុញការញែកសំណល់ និង អ្នកតំណាងការគ្រប់គ្រងសំណល់រឹង) | សាលាក្រុង មន្ទីរបរិស្ថានខេត្ត និង COMPED | ប្រធានបទដែលត្រូវបញ្ចូលក្នុងវគ្គបណ្តុះបណ្តាលរួមមាន៖<br>- ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ និង ការពង្រឹងការអនុវត្តច្បាប់ ដោយ មន្ទីរបរិស្ថានខេត្ត<br>- ផលប៉ះពាល់ដល់បរិស្ថាន និង សុខភាពសាធារណៈ ដោយមន្ទីរបរិស្ថានខេត្ត<br>- ស្វែងយល់ពីសំណល់សរីរាង្គ និង សារៈសំខាន់នៃជីកំប៉ុស ដោយ COMPED<br>- ស្ថានភាពការគ្រប់គ្រង់សំណល់រឹងជារួមក្នុងក្រុងបាត់ដំបង រួមមាន សារៈសំខាន់នៃអេតចាយ ដោយសាលាក្រុងបាត់ដំបង<br>- ណែនាំ និង ផ្សារភ្ជាប់ទំនាក់ទំនងជិតស្និទ្ធជាមួយនឹងអ្នកគ្រប់គ្រងផ្សារ<br>- ការអប់រំដាក់លាក់ពីសំណល់ដែលជាស្នោ និងប្លាស្ទិក ដោយ Plastic Free Cambodia |
| M២.៣ | **ការដាក់ធុងសំរាម និង ធុងដាំស្ល** | | |
| ២.១០ | ការផ្សព្វផ្សាយយុទ្ធនាការ | សាលាក្រុង | បណ្តាញសង្គម |
| ៣ | **ការចាប់ផ្តើមដំណើរការយុទ្ធនាការ** | | |
| M៣.១ | **ព្រឹត្តិការណ៍ចាប់ផ្តើម យុទ្ធនាការ** | | **ព្រឹត្តិការណ៍មួយថ្ងៃពេញនៅផ្សារទាំង៥ ក្រុមការងារគណៈកម្មការទាំងអស់ត្រូវចំណាយពេលប្រហែលមួយម៉ោងតាមផ្សារនីមួយៗ អ្នកតំណាង អ្នកស្ម័គ្រចិត្ត គណៈកម្មការទាំងមូល បែងចែកកំលាំង និង មានវគ្គមានមុន និងកំឡុងពេល ធ្វើយុទ្ធនាការសម្អាត បុគ្គលសំខាន់ៗក្នុងខេត្តអាចចូលរួមដែរ (ដូចជា គណអភិបាលខេត្ត ចៅសង្កាត់ ជាដើម) ណែនាំឲ្យអ្នកគ្រប់គ្នាស្គាល់អ្នកដឹកនាំជំរុញការញែកសំណល់រឹង សាទរចំពោះអ្នករើសអេតចាយ** |
| ៣.០១ | បណ្តុះបណ្តាល អ្នកអនាម័យនៅផ្សារ (សប្តាហ៍ទី ១ ដល់សប្តាហ៍ទី ២) | អ្នកដឹកនាំជំរុញការញែក សំណល់រឹង និងអ្នកតំណាង ការងារគ្រប់គ្រង សំណល់រឹង ប្រចាំសង្កាត់ | ព្រឹត្តិការណ៍កន្លះថ្ងៃនៅតាមផ្សារទាំង៥<br>- អ្នកដឹកនាំជំរុញការញែកសំរាមផ្តល់វគ្គបណ្តុះបណ្តាល<br>- អ្នកតំណាងការងារការគ្រប់គ្រងសំណល់រឹងត្រូវចូលរួមវគ្គបណ្តុះបណ្តាលនេះដែរ<br>- បោះពុម្ពមួក និង អាវយឺត សម្រាប់អ្នកចូលរួមទាំងអស់<br>- វគ្គបណ្តុះបណ្តាលអំពីប្រធានបទទាំងអស់ដែលរៀបរាប់ក្នុង ២.០៩<br>- ផ្តោតចម្បងលើចំណុចដែលអាចបង្កការភាន់ច្រលំដូចជា សំបកប្លាស្ទិក ស្នោ ជាដើម |
| ៣.០២ | បណ្តុះបណ្តាល អ្នកប្រមូលក្រុមហ៊ុន ស៊ីន ទ្រី និង លៀប លឹម (សប្តាហ៍ទី ៣) | អ្នកដឹកនាំជំរុញ ការញែកសំរាម និងមន្ទីរបរិស្ថាន ខេត្ត | ព្រឹត្តិការណ៍កន្លះថ្ងៃនៅតាមផ្សារទាំង៥<br>- អ្នកដឹកនាំជំរុញការញែកសំរាមផ្តល់វគ្គបណ្តុះបណ្តាល<br>- អ្នកតំណាងការងារការគ្រប់គ្រងសំណល់រឹងត្រូវចូលរួមវគ្គបណ្តុះបណ្តាលនេះដែរ<br>- បោះពុម្ពមួក និង អាវយឺត សម្រាប់អ្នកចូលរួមទាំងអស់<br>- វគ្គបណ្តុះបណ្តាលអំពីប្រធានបទទាំងអស់ដែលរៀបរាប់ក្នុង ២.០៩<br>- ផ្តោតចម្បងលើចំណុចដែលអាចបង្កការភាន់ច្រលំដូចជា សំបកប្លាស្ទិក ស្នោ ជាដើម |

| | | | |
|---|---|---|---|
| ៣.០៣ | បណ្ដុះបណ្ដាលអ្នករើសអេតចាយ (សប្ដាហ៍ទី ៤) | អ្នកដឹកនាំជំរុញការញែកសំរាម និងមន្ទីរបរិស្ថានខេត្ត | ព្រឹត្តិការណ៍កន្លះថ្ងៃនៅតាមផ្សារទាំង៥<br>- អ្នកដឹកនាំជំរុញការញែកសំរាមផ្ដល់វគ្គបណ្ដុះបណ្ដាល<br>- អ្នកតំណាងការងារការគ្រប់គ្រងសំណល់រឹងត្រូវចូលរួមវគ្គបណ្ដុះបណ្ដាលនេះដែរ<br>- បោះពុម្ពម្ហូប និង អាវយឺត សម្រាប់អ្នកចូលរួមទាំងអស់<br>- វគ្គបណ្ដុះបណ្ដាលអំពីប្រធានបទទាំងអស់ដែលរៀបរាប់ក្នុង ២.០៩<br>- ផ្ដោតចម្បងលើចំណុចដែលអាចបង្កការភាន់ច្រលំដូចជា សំបកប្លាស្ទិក ស្នោ ជាដើម |
| M៣.២ | **ព្រឹត្តិការណ៍ពាក់កណ្ដាលយុទ្ធនាការ សំនួរ ចំលើយ និងយុទ្ធនាការសម្អាត** | **សាលាក្រុង** | **រៀបចំដូចគ្នាទៅនឹងព្រឹត្តិការណ៍ចាប់ផ្ដើម ដោយវិលជុំតាមផ្សារទាំង៥**<br>**អបអរសារទរភាពជោគជ័យ**<br>**បុគ្គលសំខាន់ៗចូលរួមក្នុងយុទ្ធនាការសម្អាត**<br>**អនុញ្ញាតឲ្យមានការសួរសំនួរនិងផ្ដល់ចំលើយដើម្បីបំភ្លឺបន្ថែម** |
| ៣.០៤ | ផ្ដោតសំខាន់ជាមួយអ្នកលក់ និងប្រជាជនជិតខាងដែលយកសំរាមមកបោះចោលនៅផ្សារ (សប្ដាហ៍ទី ៤ ដល់សប្ដាហ៍ទី ៨) | អ្នកដឹកនាំជំរុញការញែកសំណល់រឹង | អ្នកដឹកនាំការញែកសំណល់រឹងផ្ដោតលើការពិភាក្សាជាមួយអ្នកលក់<br>ស្វែងយល់ពីបញ្ហាប្រឈមផ្សេងៗ និង ចែករំលែកវាជាមួយគណៈកម្មការ<br>ត្រូវតាមដានមើលអ្នកដែលយកសំរាមមកចោលនៅបរិវេណផ្សារផងដែរ<br>ចុះតាមតូបលក់ និង ជួបអ្នកដែលចោលសំរាមមិនត្រឹមត្រូវដើម្បីពិភាក្សាពីការញែក និងការគ្រប់គ្រងសំណល់រឹង |
| ៣.០៥ | ប្រចាំការនៅតាមផ្សារជាប្រចាំ | អ្នកដឹកនាំជំរុញការញែកសំរាម | អ្នកដឹកនាំជំរុញការញែកសំណល់ត្រូវនៅតាមផ្សារយ៉ាងហោចណាស់ពីរថ្ងៃក្នុងមួយសប្ដាហ៍<br>• ចែករំលែកការពិតផ្សេងៗដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹង<br>• ចូលរួមការសម្អាត<br>• ចាំឆ្លើយសំនួរផ្សេងៗ<br>• ចុះតាមតូបលក់ដើម្បីពិភាក្សាពីការញែកសំណល់រឹង<br>• តាមដានសកម្មភាពញែកសំរាម |
| ៣.០៦ | ចុះតាមដានដោយថែដន្យដោយអាជ្ញាធរមូលដ្ឋាន | សាលាក្រុង និង មន្ទីរបរិស្ថានខេត្ត | សាលាក្រុងនិងមន្ទីរបរិស្ថានខេត្ត ត្រូវចុះត្រួតពិនិត្យតាមផ្សារយ៉ាងហោចណាស់ម្ដងក្នុងមួយសប្ដាហ៍ដើម្បីវាយតម្លៃការញែកសំណល់ |
| ៣.០៧ | ការផ្ដល់ពានរង្វាន់បន្តិចបន្តួចប្រចាំសប្ដាហ៍ | មន្ទីរបរិស្ថានខេត្ត | រៀងរាល់សប្ដាហ៍ ផ្សារមួយនឹងត្រូវបានអបអរសាទរនៅលើហ្វេសប៊ុក (Facebook) ថាជាផ្សារដែលមានការអនុវត្តបានល្អជាងគេដោយយោងតាមសូចនាករតាមដានផ្សេងៗ |
| ៣.០៨ | ការអបអរសាទរប្រចាំសប្ដាហ៍ ផ្សារដែលអនុវត្តបានល្អជាងគេ | អ្នកដឹកនាំជំរុញការញែកសំណល់រឹង និង អ្នកតំណាងការងារគ្រប់គ្រងសំណល់រឹងប្រចាំសង្កាត់ | រៀងរាល់សប្ដាហ៍ បុគ្គល(ដោយមានការសុំអនុញ្ញាតជាមុន) ពីផ្សារនីមួយៗ នឹងត្រូវបានប្រកាសតាមបណ្ដាញសង្គមជាអ្នកដែលបានអនុវត្តបានល្អជាងគេ<br>អាចជារូបថតដែលបង្ហាញពីការអនុវត្តល្អ<br>អាចជា អ្នករើសអេតចាយ អ្នកអនាម័យផ្សារ អ្នកលក់ ឬអ្នកទិញ |
| M៣.៣ | **ព្រឹត្តិការណ៍បញ្ចប់យុទ្ធនាការផ្សព្វផ្សាយ និងវាយតម្លៃផ្សារដែលជាជើងឯក** | **សាលាក្រុង** | **ធ្វើឡើងនៅកណ្ដាលក្រុងបាត់ដំបង**<br>**មានជាស្តង់ និង ធុងសំរាមដាច់ដោយឡែកតាមប្រភេទ សម្រាប់យុទ្ធនាការសម្អាត**<br>**ជ្រើសរើសផ្សារជាជើងឯកយោងតាមសូចនាករដែលបានកំណត់**<br>**ផ្សព្វផ្សាយពីផែនការពង្រីកសកម្មភាពញែកសំរាម** |

## ៣.៤.២. ដំណាក់កាលទី ២៖ សង្កាត់ស្វាយប៉ោ

សង្កាត់ស្វាយប៉ោ (ដូចដែលបានបង្ហាញក្នុងរូបភាពទី ២៧) មានអត្រាទី ប្រជុំជន ១០០% និង ជាសង្កាត់ចម្បងក្នុងក្រុងបាត់ដំបង ដែលមានប្រជាជននិងអាជីវកម្មច្រើនជាងគេ (តារាងទី ៣) ស្ថាប័នសាធារណៈ និង សួនច្បារសាធារណៈ។

### ការបង្កើតសំរាម

ជាមួយនឹងមធ្យមភាគខ្ពស់នៃប្រភពសំណល់រឹងធំៗ (តាមបរិមាណសំណល់រឹងមាន ១៤%មកពីតាមផ្ទះ ៦០% មកពីផ្សារធំៗ ៣៤% មកពីផ្សារផ្សេងទៀត និង ៣៨%ពីសណ្ឋាគារនិងផ្ទះសំណាក់) សង្កាត់ស្វាយប៉ោគឺពិតជាសង្កាត់ដែលបង្កើតសំណល់រឹងក្នុងបរិមាណច្រើនបំផុត (យ៉ាងហោចណាស់ ១៥%នៃសំណល់រឹងក្នុងក្រុងទាំងមូល បើមិនអញ្ចឹងទេអាចច្រើនជាងនេះ)។

### ការស្តុក

ដូចបានរៀបរាប់ក្នុងផ្នែកទី ១ កន្លែងស្តុកសំរាមសាធារណៈមានប្រមាណ១០០ធុងក្នុងក្រុងបាត់ដំបង ដែលក្នុងនោះភាគច្រើនស្ថិតក្នុងសង្កាត់ចម្បងនេះ។ មានធុងដាំស្ទ័រចំណុះ៤តោនចំនួន២ ដែលក្រុមហ៊ុនស៊ីន ទ្រី ដាក់នៅតាមផ្សារ។ បច្ចុប្បន្ននេះ ធុងដាំស្ទ័រមួយនៅខាងក្រៅផ្សារណាត់ និង មួយទៀតនៅខាងក្រៅផ្សារលើ។

### ការប្រមូល

### ការប្រមូលផ្លូវការ

ក្រុមហ៊ុនស៊ីន ទ្រី ទទួលខុសត្រូវក្នុងការប្រមូល និង ដឹកជញ្ជូនក្នុងសង្កាត់នេះ ហើយ កាលវិភាគនៃការប្រមូលមានបង្ហាញនៅក្នុងរូបភាពទី ២៧ ក៏ប៉ុន្តែមិនបានផ្សព្វផ្សាយជាសាធារណៈក្នុងតំបន់សេវាកម្មទេ។ ទាំងការប្រមូលសំរាម និង ថ្លៃសេវាត្រូវបានធ្វើឡើងពីទីតាំងមួយទៅទីតាំងមួយ បុគ្គលិកក្រុមហ៊ុនស៊ីន ទ្រី ចែក និង ប្រមូលវិក្កយបត្រដោយផ្ទាល់ពីអតិថិជន។ គួរឲ្យកត់សម្គាល់ ផ្លូវលេខ១ និង ផ្លូវលេខ៣ ព្រមទាំង សួនច្បារសាធារណៈ សេវាកម្មប្រមូលធ្វើឡើងជារៀងរាល់ថ្ងៃ។ បើទោះបីជាយ៉ាងនេះ មានតំបន់ខ្លះត្រូវបានដាក់កាលវិភាគថានឹងទទួលបានសេវាប្រមូល៣ថ្ងៃក្នុងមួយសប្តាហ៍ ( ច័ន្ទ ពុធ សុក្រ ឬ អង្គារ ព្រហស្បត៍ សៅរ៍) ក៏ប៉ុន្តែជាទូទៅអាចទទួលបានត្រឹមតែម្តង ឬពីរដងប៉ុណ្ណោះក្នុងមួយសប្តាហ៍។ នេះមិនគ្រប់គ្រាន់ដើម្បីធានាឲ្យបានសំណល់សរីរាង្គដែលមានគុណភាពល្អសម្រាប់ខមភីដ ( COMPED ) ឡើយ។

### ការប្រមូលក្រៅផ្លូវការ

ចំនួនអ្នករើសសំរាមក្រៅផ្លូវការនៅទូទាំងក្រុងមិនមានទិន្នន័យច្បាស់លាស់ទេ។ ក៏ប៉ុន្តែតាមរយៈការសំភាសជាមួយនឹងស្តង់ទិញលក់អេតចាយចំនួន៣ ថៅសង្កាត់ទាំង ១០ និង អ្នករើសអេតចាយ១០នាក់ អាចប៉ាន់ស្មានបានថាមានអ្នករើសអេតចាយប្រមាណ១៥០ ទៅ ២០០នាក់នៅទូទាំងក្រុងបាត់ដំបង។ គួរឲ្យកត់សម្គាល់ថា មានទីតាំងពីរក្នុងសង្កាត់ស្វាយប៉ោ ដែលមានក្រុមអ្នករើសអេចាយប្រមាណ ៥០ ទៅ ៦០នាក់ កំពុងតាំងទីរស់នៅមិនស្របច្បាប់នៅទីនោះ។ ទីតាំងទី ១ គឺនៅជិតមន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង ក្នុងភូមិព្រែកមហាទេព និងទីតាំងទី ២ គឺតាមបណ្តោយស្ទឹងសង្កែជិតសួននាគសន្តិភាព និងផ្សាររាត្រី។

### ការចូលរួមពីអាជ្ញាធរមូលដ្ឋាន

សម្រាប់ឆ្នាំ២០១៩ សាលាក្រុងបានចាត់ឲ្យសង្កាត់ស្វាយប៉ោធ្វើការដឹកនាំសកម្មភាពសម្អាត ម្តងក្នុងមួយសប្តាហ៍នៅរៀងរាល់ថ្ងៃសុក្រ ជាពិសេសនៅតាមផ្លូវលេខ១ ផ្លូវលេខ២ និង ផ្លូវលេខ៣ ព្រមទាំងសួនច្បារសាធារណៈ។ សកម្មភាពនេះ បានផ្តល់សារទៅកាន់ប្រជាជនថាការស្តុកសំរាមត្រឹមត្រូវ គឺមានសារៈសំខាន់ណាស់ និងការចោលសំរាមពាសវាលពាសកាលមិនអាចទទួលយកបានឡើយ។ សង្កាត់មិនមាន ទាំងថវិកា ទាំងជនបង្គោលសម្រាប់ការងារគ្រប់គ្រងសំណល់រឹង។

### យុទ្ធនាការអប់រំដែលធ្លាប់ធ្វើពីមុន

កម្មវិធីលើកកម្ពស់ការយល់ដឹងដែលបានធ្វើឡើងក្នុងក្រុងបាត់ដំបងរួមមាន (១) ការចែកខិតបណ្ណ ការប្រកាសជាសំលេង និងការធ្វើសិក្ខាសាលាតាមសហគមន៍។ បើទោះបីជាយ៉ាងនេះក៏ដោយ សកម្មភាពទាំងនេះត្រូវបានធ្វើឡើងត្រឹមរយៈពេលកំណត់មួយប៉ុណ្ណោះនិងមិនមានប្រសិទ្ធភាពរយៈពេលវែងទេ។

## រូបភាពទី ២៧៖ កាលវិភាគប្រមូលសំណល់រឹងក្នុងសង្កាត់ស្វាយប៉ោ



## រូបភាពទី ២៨៖ទីកន្លែងរស់នៅរបស់អ្នករើសសំរាមក្រៅផ្លូវការនៅក្នុងសង្កាត់ស្វាយប៉ោ



## អនុសាសន៍សម្រាប់ការរៀបចំយុទ្ធនាការ សម្រាប់សង្កាត់ស្វាយប៉ោ

ជាទូទៅ ដំណាក់កាលទី ២នៃការអនុវត្តសាកល្បងត្រូវធ្វើតាមគំរូ ដំណាក់កាលទី ១ តែក៏ត្រូវធ្វើតាមសកម្មភាពដែលមានក្នុង ផ្នែកទី ១ផងដែរ ដូចជា ការជ្រើសរើសអ្នកតំណាំងប្រចាំសង្កាត់ ការប្រជុំប្រចាំត្រីមាស និង ការធ្វើលម្អិតនិងបោះពុម្ពកាលវិភាគ ប្រមូលសំរាម។ ការងារបន្ថែមមួយចំនួនបានគូសបញ្ជាក់ក្នុងផ្នែក ខាងក្រោម។

### ការកែសម្រួលទី ១៖ ផ្តោតសំខាន់លើសំរាម ដែលអាចកែច្នៃឡើងវិញបាន

ដំណាក់កាលនៃការអនុវត្តសាកល្បងនេះ គួរត្រូវផ្តោតសំខាន់ លើការធ្វើឲ្យប្រសើរឡើងនៃការញែកសំណល់រឹងដែលអាចកែច្នៃ ឡើងវិញបានសម្រាប់អេតចាយ។ មូលហេតុដោយសារថា សេវាកម្មប្រមូលផ្លូវការ និងក្រៅផ្លូវការ មិនចាំបាច់ត្រូវផ្លាស់ប្តូរទេ តែត្រូវបង្កើនប្រសិទ្ធភាព ហើយមានការបង្ហាញយ៉ាងច្បាស់ដែរ ថាមានតម្រូវការក្នុងការធ្វើឱ្យការចោលសំរាម ការស្តុក និងទីតាំង ប្រមូលសម្រាប់ខ្សែសង្វាក់អេតចាយ ឱ្យកាន់តែល្អប្រសើរឡើង ថែមទៀត។ នេះរួមបញ្ចូលទាំងការប្រមូល និងការញែកដបប្លាស្ទិក និងថង់នៅតាមសាលាដែលបានរៀបរាប់ក្នុងផ្នែកមុនផងដែរ។

ទន្ទឹមនឹងមានតម្រូវការក្នុងការញែកសំណល់រឹងទាំងអស់សម្រាប់ តាមផ្ទះ និងនៅតាមហាងអាជីវកម្ម វាមិនមែនជារឿងងាយស្រួល ទេនៅក្នុងការអនុវត្ត។ នៅក្រុងឡាពីតាណា របស់ប្រទេសឈីលី មានការប៉ាន់ស្មានថា ក្រោយពីយុទ្ធនាការធ្វើឡើងហើយច្រើនឆ្នាំ មានត្រឹមតែ ២៨%ប៉ុណ្ណោះនៃប្រជាជនតាមផ្ទះដែលបានញែក សំណល់រឹងរបស់ពួកគាត់។ លើសពីនេះទៅទៀត ត្បិតការដាក់ គោលដៅនៅតាមទីតាំងអាជីវកម្មដូចជា ភោជនីយដ្ឋាន និង សណ្ឋាគារស្តាប់មើលទៅគួរឲ្យទាក់ទាញ តែវាពិតជាពិបាកណាស់ ក្នុងការរៀបចំផែនការសេវាកម្មដឹកជញ្ជូន ការចរាចរ និង រៀបចំ សេវាកម្មប្រមូលនៅតាមទីតាំងដាក់លាក់ទាំងនេះ ព្រមទាំងដើម្បី ធានាថាកម្មករប្រមូលពិតជាតាមដាន និង ប្រមូលតែពីប្រភពណា ដែលត្រូវបានអនុញ្ញាតមែន។

ខាងក្រោមនេះជាអនុសាសន៍ដែលបានលើកឡើង៖

- ផ្តោតសំខាន់លើការទាញយកធនធានពីសំណល់រឹងដែលអាច កែច្នៃឡើងវិញបានសម្រាប់អេតចាយ
- លើកទឹកចិត្តការធ្វើជីកំប៉ុសតាមផ្ទះពីសំណល់សរីរាង្គ
- រួមបញ្ចូលអេតចាយសម្រាប់យុទ្ធនាការនេះ រួមមានដូចជាការ ពិភាក្សាពីបញ្ហាប្រឈមនិងការចែករំលែកគំនិត ដូចជា៖
    - ចែករំលែកព័ត៌មានថា ការទុកដាក់សំរាមដោយចំហ និង ការទុកសំរាមចោល ពាសវាលពាសកាលអាចនាំទៅរក ការផាកពិន័យ
    - ស្វែងរកដំណោះស្រាយដែលអាចជួយឲ្យសំណល់រឹង ដែលអាចកែច្នៃឡើងវិញងាយស្រួលក្នុងការស្វែង រក។ពិចារណាក្នុងការជំរុញឲ្យមានថង់ពីរប្រភេទ ដោយបង្ហាញពីភាពខុសគ្នា ដូចជា ថង់ដែលថ្លាសម្រាប់ សំណល់រឹងដែលអាចកែច្នៃឡើងវិញបាន។
- ប្រសិនបើចាំបាច់ កំណត់ពេលវេលា និង ចំណុចសម្រាប់ អេតចាយក្នុងការរើសយកសំរាមដែលអាចកែច្នៃឡើងវិញបាន ក្នុងតំបន់ដែលមិនទទួលបានសេវាកម្មគ្រប់គ្រាន់។

### ការកែសម្រួលទី ២៖ ការដាក់ធុងដាំស្វ័រ ក្នុងតំបន់ដែលមិនទទួលបានសេវាកម្មគ្រប់គ្រាន់

ក្នុងកំឡុងពេលសិក្សានេះ មានចំណុចឱ្យកត់សម្គាល់មួយគឺថា មានតំបន់ជាច្រើនក្នុងសង្កាត់ដែលមិនទាន់ទទួលបានសេវា កម្មគ្រប់គ្រាន់។ ចៅសង្កាត់បានយល់ស្របផងដែរថា ធុងសំរាម សាធារណៈនឹងជួយកាត់បន្ថយការចោលសំរាមពាសវាល ពាសកាល និងការដុត។ ខណៈដែលស្នើឡើងឲ្យរក្សាវិធីសាស្ត្រ នៃការប្រមូលដដែលពីទីតាំងមួយទៅទីតាំងមួយ វាក៏ត្រូវបាន ផ្តល់អនុសាសន៍ផងដែរថា យុទ្ធនាការដំណាក់កាលទី ២ នៅសង្កាត់ស្វាយប៉ោ គួររួមបញ្ចូល ការដាក់ធុងដាំស្វ័រនៅទីតាំង ដែលបានជ្រើសរើសដោយចាប់ផ្តើមឡើងពីសាលារៀនទៅមុន គេ។ គោលបំណងនេះដើម្បីធានាថា តំបន់ទាំងអស់ទទួលបាន ផលប្រយោជន៍ពីសេវាកម្មប្រមូលដោយរក្សាការគ្រប់គ្រងធុងដាំស្វ័រ ឲ្យបានល្អ និងមកយកសំរាមឲ្យបានទៀងទាត់ ដើម្បីទប់ស្កាត់នឹង ការចោលសំរាមពាសវាលពាសកាល។

ការស្វែងរកទីតាំងដែលសមស្របអាចជាបញ្ហាប្រឈម ជាពិសេសគឺតំបន់ដែលតូចចង្អៀត។ រូបភាពទី ២៩ បង្ហាញពីទីតាំងដែលត្រូវបានផ្តល់អនុសាសន៍ ដោយសាលាក្រុង បើទោះបីជាអាចមានទីតាំងចាំបាច់ជាងនេះក៏ដោយ។ វាពិតជាមានសារៈសំខាន់ណាស់ដែលសង្កាត់ ធ្វើការពិភាក្សាជាសាធារណៈដើម្បីបញ្ជាក់ពីសារៈសំខាន់នៃការដាក់ធុងសំរាមនៅតាមទីសាធារណៈ និងទាមទារការយល់ព្រមក្នុងការដាក់ធុងជាំស្វ័រតាមទីតាំងទាំងនោះ។ បន្ទាប់មកទៀត សង្កាត់គួរធ្វើការយ៉ាងជិតស្និទ្ធជាមួយសាលាក្រុង និងមន្ទីរបរិស្ថានខេត្តក្នុងការកំណត់ទីតាំងដែលសមស្របសម្រាប់ធុងជាំស្វ័រ ជាពិសេសតំបន់ដែលមិនមានផ្លូវសម្រាប់ចូលប្រមូលបាន។ ជាអនុសាសន៍ គួរកំណត់ឱ្យលើសពី៣ទីតាំង ( លើសពីផ្សារ ) ដែលកន្លែងខ្លះអាចត្រូវការធុងលើសពីអាស្រ័យលើបរិមាណសំណល់រឹងដែលបានបង្កើត។

សម្រាប់ផ្ទះដែលនៅតែចង់លក់សំរាមឲ្យអេតចាយជាជាងចោលសំរាមតាមធម្មតា ធុងសាធារណៈអាចប្រើប្រាស់ក្នុងការចោលសំរាមដែលមានតម្លៃតិច ហើយអាចធ្វើជាចំណុចសាធារណៈសម្រាប់ទិញលក់អេតចាយ ដែលអាចបង្កើតជាឱកាសនាពេលអនាគត ឲ្យពួកគេទទួលទិញសំណល់រឹងដែលអាចកែច្នៃបានជាលក្ខណៈផ្លូវការ ( ដូចជាការបង្កើតជាគំរូធនាគារសំណល់ក្នុងក្រុងសុរ៉ាបាយ៉ា ( Surabaya ) )។

## ការកែសម្រួលទី ៣៖ ការប្រមូលថ្លៃសេវា សម្រាប់ធុងជាំស្វ័រសាធារណៈ

បញ្ហាប្រឈមមួយនៃការដាក់ធុងសាធារណៈគឺការផ្តល់សេវាកម្មដោយមិនគិតប្រាក់ ដែលអាចបង្កជាបញ្ហាតវ៉ាក្នុងសហគមន៍ពីផ្ទះ និងអាជីវកម្មដែលបង់ថ្លៃសេវាកម្ម។ បើទោះជាយ៉ាងនេះ ច្បាប់អនុញ្ញាតឲ្យសាលាក្រុងប្រមូលថ្លៃសេវា និងផ្ទេរភារកិច្ចទៅសង្កាត់។ វាចាំបាច់ក្នុងការបង់ថ្លៃគ្រប់គ្រងសំណល់រឹង។ ធ្វើដូចនេះមិនអាចបង្កឲ្យមានជម្លោះលើបញ្ហាធុងជាំស្វ័រសាធារណៈ ដែលត្រូវបានគេគិតថាប្រើប្រាស់ដោយមិនគិតប្រាក់ បើប្រៀបធៀបទៅនឹងសេវាកម្មប្រមូលពីទីតាំងមួយទៅទីតាំងមួយដែលបង់ប្រាក់។ តម្លៃអាចត្រូវបានកែសម្រួល ( កាត់បន្ថយ ) ចំពោះកន្លែងឬសង្កាត់ដែលទើបតែមានធុងសំរាមសាធារណៈ។ ដោយសារសាលាក្រុងមានបំណងផ្ទេរការងារទៅសង្កាត់ ហើយសង្កាត់ក៏ពេញចិត្តក្នុងការទទួលយកតួនាទី នេះ សង្កាត់គួរមានតួនាទីប្រមូលថ្លៃសេវាពីតាមផ្ទះក្នុងតំបន់ដែលបានប្រើប្រាស់ធុងសាធារណៈ។ សេវាកម្មប្រមូលពីទីតាំងមួយទៅទីតាំងមួយ និងការបង់ថ្លៃសេវាប្រមូលក្នុងតំបន់ផ្សេងទៀត នឹងបន្តធ្វើតាមធម្មតាហើយបញ្ហាដែលមិនបង់ប្រាក់ឲ្យក្រុមហ៊ុនស៊ីន ទ្រីនឹងត្រូវបានកាត់បន្ថយ។

ការព្រមព្រៀងជាផ្លូវការគួរត្រូវបានធ្វើ រវាងសាលាក្រុង សង្កាត់និងសេវាកម្មប្រមូលដើម្បីធានាការអនុវត្តរយៈពេលវែង។ ដូចដែលបានរៀបរាប់ពីមុនក្នុងផ្នែកនេះផងដែរអំពីក្រុមហ៊ុន ស៊ីន ទ្រី កិច្ចសន្យាគួរត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីរួមបញ្ចូលតម្រូវការនៃការធ្វើរបាយការណ៍ និងការតាមដានដើម្បីធានាថាបានទទួលនូវសេវាកម្មដែលបានកែលម្អ។

## ការកែសម្រួលទី ៤៖ ការលើកកម្ពស់ការយល់ដឹង

ជាដំបូង កម្រិតប្រសិទ្ធភាពរួមទាំងរយៈពេលនៃការអនុវត្តត្រូវបានកំណត់សិន មុនពេលសម្រេចប្រើប្រាស់សម្ភារៈដដែលម្តងទៀត។ ការកំណត់ពេលវេលាអាចខ្លីជាងនេះលុះត្រាតែច្បាស់លាស់ថាសហគមន៍ក្នុងមូលដ្ឋាននិងអាជីវកម្មបានចូលរួមក្នុងដំណាក់កាលទីមួយយ៉ាងសស្រាក់សស្រាំ។

ការលើកកម្ពស់ការយល់ដឹងនិងការផ្លាស់ប្តូរឥរិយាបថគួរត្រូវបានផ្តោតលើ ការរៀបចំព្រឹត្តិការណ៍ក្នុងសហគមន៍ ការធ្វើសិក្ខាសាលា និង សកម្មភាពបណ្តុះបណ្តាលទៅកាន់សាធារណជន។ គួរយកចិត្តទុកដាក់លើអេតចាយដែលមានក្នុងតំបន់ និងធ្វើការជិតស្និទ្ធជាមួយពួកគេ ដើម្បីធានានូវការប្រមូលដែលមានភាពល្អប្រសើរជាងនេះ ដោយឲ្យអ្នកដឹកនាំជំរុញការញែកសំណល់រឹង កសាងទំនាក់ទំនងល្អជាមួយពួកគាត់ និងជួយបង្កើតទំនាក់ទំនងល្អរវាងពួកគាត់ជាមួយនឹងអាជ្ញាធរមូលដ្ឋាន។

ផ្ទះគ្រប់ប្រភេទទាំងអស់គួរត្រូវបានកំណត់ជាគោលដៅ។ សកម្មភាពតាមសាលាជាប្រចាំក៏ជាជម្រើសដែលល្អផងដែរសម្រាប់ដំណាក់កាលនេះ និងគួរមានសិក្ខាសាលាដោយសំដៅធ្វើការជាមួយភោជនីយដ្ឋាន និងអាជីវកម្មដោយផ្តល់អនុសាសន៍លើវិធីដែលជួយពួកគាត់អាចសន្សំសំចៃប្រាក់ ឬក៏ធ្វើការញែកសំណល់រឹងបានងាយស្រួលតម្រូវតាមស្ថានភាពពួកគាត់។

## រូបភាពទី ២៩៖ ទីតាំងដាក់ធុងដាំស្ទូវដែលស្នើឡើងក្នុងសង្កាត់ស្វាយប៉ោ



## ៣.៥. អនុសាសន៍រយៈពេលវែង

### បង្កើតប្រព័ន្ធត្រួតពិនិត្យនិងតាមដាន ការប្រមូលសំណល់រឹងដែលបានញែកពីតាមផ្ទះនិងអាជីវកម្ម

ប្រសិនបើការញែកសំណល់រឹងអាចពង្រីកទៅកាន់ផ្ទះនិងអាជីវកម្មទូទាំងក្រុង បញ្ហាប្រឈមមួយគឺការបង្កើតប្រព័ន្ធសម្រាប់ការញែកសំណល់រឹងតាមផ្ទះនិងការអនុវត្តច្បាប់ ព្រមទាំងការបញ្ចុះតម្លៃដែលមានសក្តានុពល។ ខាងសេវាកម្មប្រមូលត្រូវត្រួតពិនិត្យមើលតាមធុងស្តុកថា តើការញែកសំរាមបានត្រឹមត្រូវឬអត់ និង "បិទស្លាក" លើផ្ទះណាដែលមិនគោរពច្បាប់ដែលបានធ្វើឲ្យសេវាកម្មប្រមូលជួបប្រទះការលំបាកនិងចំណាយពេលច្រើនក្នុងដំណើរការសេវាកម្ម។ លើសពីនេះទៅទៀត វគ្គបណ្តុះបណ្តាល និងការត្រួតពិនិត្យគុណភាពមានសារៈសំខាន់ នេះធ្វើឲ្យប្រព័ន្ធដំណើរការពិបាកក្នុងការរៀបចំ និងចំណាយច្រើន។

ជម្រើសដែលល្អគឺការបង្កើតចំណុចវិមជ្ឈការក្នុងសង្កាត់ដើម្បីប្រមូលប្រភេទសំណល់រឹងដាក់លាក់។ ធុងសំរាមអាចដាក់នៅក្នុងតំបន់តាមការពិភាក្សាជាមួយអ្នកតំណាងប្រចាំសង្កាត់ ហើយត្រូវបានចាត់ទុកថាជាចំណុចដែលងាយស្រួលក្នុងការតាមដានឲ្យបានច្បាស់លាស់។ នេះអាចឲ្យប្រជាជនតាមផ្ទះ និងអាជីវកម្មចូលរួមបន្តិចម្តងៗដោយមានការយល់ដឹងជាមុន ក៏ប៉ុន្តែអាចដោះស្រាយបញ្ហាការលាយឡំសំណល់រឹងម្តងទៀតនៅពេលប្រមូល។ លើសពីនេះទៅទៀត ជាមួយនឹងចំណុចទាំងអស់ក្នុងការតាមដានត្រូវមានកិច្ចព្រមព្រៀងដែលពាក់ព័ន្ធអំពីបញ្ហាថា អ្នកណាជាអ្នកតាមដាន អ្វីជាការលើកទឹកចិត្ត និង តើត្រូវធ្វើដូចម្តេចឲ្យមានភាពងាយស្រួល។ សេវាកម្មប្រមូលអាចផ្តល់ឲ្យតាមគោលការណ៍ប្រចាំថ្ងៃ និងបញ្ចុះតម្លៃ ឬលើកទឹកចិត្ត ជាការផ្តល់រង្វាន់ទៅគ្រប់សង្កាត់ទាំងអស់ ឬក៏ទៅដល់ភូមិ។

ជម្រើសដែលស្មុគស្មាញជាងនេះ អាចឲ្យសេវាកម្មប្រមូលបង្កើតជាកូដឃ្យូអ៊ែរ (QR) ឬជាកម្មវិធីដើម្បីបង្ហាញទីតាំងដែលសំរាមផ្ទះនិងអាជីវកម្មត្រូវបានប្រមូលនិងអត្រានៃការញែកសំណល់រឹង។ បើទោះបី ជាយ៉ាងនេះក្តី មានធាតុមួយចំនួនដែលចាំបាច់ក្នុងការដោះស្រាយ ដើម្បីឲ្យប្រព័ន្ធនេះដំណើរការ៖

- បច្ចេកវិទ្យា (កូដ ឬកម្មវិធីឃ្យូអ៊ែរ) ត្រូវការការបង្កើត ការសាកល្បង ការស្វែងរក និងដោះស្រាយកំហុស ព្រមទាំង ធ្វើចេញជាប្រព័ន្ធដើម្បីកំណត់ទីតាំងផ្ទះនិងអាជីវកម្មទូទាំងសាលាក្រុង។ កាន់តែអស្ចារ្យ បើមានប្រព័ន្ធដែលអាចអនុវត្តការបញ្ចុះតម្លៃដោយស្វ័យប្រវត្តិលើវិក្កយបត្រដែលចេញក្នុងខែនីមួយៗ។
- ត្រូវមានប្រព័ន្ធមួយ សម្រាប់អ្នកបង្កើតសំណល់រឹងបង្ហាញពីសំណល់រឹងរបស់ពួកគេដែលបានញែក។ ការរៀបចំដូច្នេះអាចធ្វើទៅបានប្រសិនបើសំរាមដែលអាចកែច្នៃបានដាក់ក្នុងថង់ថ្លា ឬប្រសិនបើធុងប្រភេទដាក់លាក់ត្រូវបានផ្តល់ឲ្យតាមប្រភេទសំណល់រឹង (ឧទាហរណ៍ ធុងសម្រាប់សំរាមស្ងួត ហើយសំរាមប្រភេទផ្សេងទៀតដាក់ក្នុងថង់)។
- តួនាទី ក្នុងការកំណត់សំណល់រឹងដែលបានញែកជាបន្ទុករបស់កម្មករនៃសេវាកម្មប្រមូលផ្លូវការ និង ប្រព័ន្ធមិនអាចដំណើរការបានទេបើគ្មានពួកគាត់។ ហេតុនេះ វគ្គបណ្តុះបណ្តាល និងការលើកទឹកចិត្តពិតជាមានសារៈសំខាន់។
- ឡានប្រមូលអាចត្រូវបានជំនួសដោយឡានដែលមានខណ្ឌចែកតាមប្រភេទសំណល់រឹងដែលបានញែក ឬ បំពាក់ធុងខាងក្រៅសម្រាប់សំណល់ស្ងួត (ដោយហេតុថាសំណល់ភាគច្រើនជាសំណល់សរីរាង្គ)
- ក្រុមហ៊ុនប្រមូលសំរាមផ្លូវការអាចនឹងបង្កើនការចំណាយប្រតិបត្តិការដោយសារតែពេលវេលានៃការប្រមូលត្រូវបានបង្កើន ដែលនេះតម្រូវឲ្យមានថវិកាឧបត្ថម្ភធននិងការលើកទឹកចិត្ត។
- អាជ្ញាធរក្នុងតំបន់ និង/ឬ ម្ចាស់ជំនួយត្រូវផ្តល់ជំនួយលើវគ្គបណ្តុះបណ្តាល ធុងសំរាម ឡានដឹក ។ល។ ដើម្បីធានានិរន្តរភាព អាជ្ញាធរមូលដ្ឋាន និង ក្រុមហ៊ុនប្រមូលផ្លូវការ (ជាជាងម្ចាស់ជំនួយ) ត្រូវព្រមព្រៀងគ្នាលើការបញ្ចុះតម្លៃ ឬការផាកពិន័យដែលប៉ះប៉ូវចំពោះការចំណាយប្រតិបត្តិការដែលបានកើនឡើង និងជាការលើកទឹកចិត្តសម្រាប់កម្មករ (សូមមើលអនុសាសន៍បន្ទាប់ទៀតសម្រាប់ព័ត៌មាននេះ)។

ជម្រើសមួយទៀតអាចប្រមូលសំរាមដែលបានញែកដោយឆ្លាស់ថ្ងៃគ្នា។ បើទោះបីជាយ៉ាងនេះក៏ដោយ មិនគួរអនុវត្តបែបនេះទេ ពីព្រោះថាសេវាកម្មប្រមូលសំរាមក្នុងក្រុងបាត់ដំបង បច្ចុប្បន្នបានធ្វើឡើងយ៉ាងច្រើនត្រឹមតែ៣ថ្ងៃក្នុងមួយសប្តាហ៍ប៉ុណ្ណោះ ដោយ

មានតំបន់ខ្លះទទួលបានត្រឹមតែម្ដងក្នុងមួយសប្ដាហ៍ ឬក៏មិនបានទទួលសោះ។ សម្រាប់ការប្រមូលផ្លាស់ថ្ងៃគ្នា ជាការល្អប្រសើរក្នុងការមានសេវាកម្មប្រមូល ៤ដង ឬច្រើនជាងនេះក្នុងមួយសប្ដាហ៍។

### ផ្ដោតសំខាន់លើការទាញយកសំណល់សរីរាង្គពីតាមផ្ទះនិងអាជីវកម្ម

ដូចដែលបានផ្ដល់អនុសាសន៍ក្នុងការធ្វើយុទ្ធនាការក្នុងសង្កាត់ស្វាយ ប៉ោ លទ្ធផលភ្លាមៗបំផុតដែលអាចធ្វើបាន គឺការលើកទឹកចិត្តការប្រមូលសំរាមដែលអាចកែច្នៃឡើងវិញបានដោយអេតចាយ ដោយសារតែការញែកសំណល់រឹងពីទីតាំងមួយទៅទីតាំងមួយមានភាពស្មុកស្មាញ។ អមជាមួយនឹងការតាមដានដែលបានស្នើឡើងជាមួយនឹងវិមជ្ឈការធុងសំរាម គេបានផ្ដល់អនុសាសន៍ ផងដែរថា ធុងសំរាមទាំងនោះគួរត្រូវប្រើប្រាស់ដើម្បីប្រមូលសំណល់សរីរាង្គ។ ដោយមូលហេតុថា សំណល់ដែលមិនមែនជាសំណល់សរីរាង្គប្រមាណជិត៥០%ត្រូវបានប្រមូលដោយអ្នកប្រមូលក្រៅផ្លូវការក្នុងក្រុង(ដែលអាចស្មើនឹងប្រមាណ១៥%នៃសំណល់ដែលបានបង្កើត) ចំណែកឯសំណល់សរីរាង្គត្រឹមតែ១០%ប៉ុណ្ណោះដែលអាចទាញយកបាន (ដែលស្មើនឹងប្រមាណ៨%នៃសំណល់រឹងសរុប) ដោយសារតែសំណល់សរីរាង្គមានបរិមាណច្រើន (មើលរូបភាពទី ៣០)។ ដូច្នេះ ការទាញយកសំណល់សរីរាង្គ ជាការល្អសម្រាប់ការធ្វើប្រព្រឹត្តិកម្មបន្តទៀតដែលនឹងមានឥទ្ធិពលច្រើនលើប្រព័ន្ធទាញយកធនធានពីសំណល់រឹងទាំងមូល ក្នុងរយៈពេលវែង។

រូបភាពទី ៣០៖ សំណល់ដែលអាចកែច្នៃឡើងវិញជាភាគរយ នៃសំណល់រឹងសរុប សំណល់សរីរាង្គ និងសំណល់អសរីរាង្គ




### ការបង្កើតការលើកទឹកចិត្តនិងការបញ្ចុះតម្លៃលើសេវាកម្មគ្រប់គ្រងសំណល់រឹង

បញ្ហាក្នុងការអនុវត្តការញែកសំរាម គឺការបង្កើតការលើកទឹកចិត្តនិងការបញ្ចុះតម្លៃដែលមានចីរភាព។ ជាមួយនឹងការប្រជុំជាមួយនឹងអ្នកគ្រប់គ្រងផ្សារ វាមិនអាចធ្វើទៅបានទេក្នុងការបញ្ចុះតម្លៃលើថ្លៃសេវាកម្មអនាម័យ ដោយសារតែវាមានតម្លៃទាបរួចហើយ (តម្លៃអតិបរិមាត្រឹម ០.២៥ដុល្លារក្នុងមួយថ្ងៃក្នុងមួយតូប)។ លើសពីនេះទៅទៀត ការផាកពិន័យតាមតូប និងតាមផ្ទះដែលមិនញែកសំណល់ តម្រូវឲ្យមានសកម្មភាពតាមដានដែលលម្អិត និងសមស្រប ដែលនេះទាមទារការខិតខំប្រឹងប្រែងខ្លាំងនិងថវិកាច្រើន (ដូចដែលបានពិភាក្សាក្នុងអនុសាសន៍រយៈពេលវែងមុននេះ)។ វាពិតជាល្អផងដែរ ប្រសិនបើអាជ្ញាធរមូលដ្ឋានគឺជាអ្នកដែលចុះអនុវត្តច្បាប់ ជាជាងទុកឱ្យតែអ្នកផ្សារ និងអ្នកប្រមូលជាអ្នកអនុវត្ត។

ការលើកទឹកចិត្តដែលល្អនិងមានចីរភាពបំផុតគឺការលើកទឹកចិត្តណាដែលបង្កើតឡើងពីកម្រៃដែលសន្សំបានពីការធ្វើប្រព្រឹត្តិកម្មសំណល់រឹង។ នេះតម្រូវឲ្យមានថ្លៃប្រព្រឹត្តិកម្មសំណល់រឹងដែលមិនលាយឡំជាមួយនឹងថ្លៃប្រមូល (ដូចដែលកំពុងអនុវត្ត) និងថវិកាដាក់លាក់សម្រាប់ការគ្រប់គ្រងសំណល់រឹងក្នុងសាលាក្រុង។ នៅក្នុងករណីនេះ វាពិតជាចាំបាច់ក្នុងការពិចារណាថា ការញែកសំណល់រឹងនៅនឹងប្រភព ការទាញយកធនធានពីសំណល់រឹង និងការធ្វើជីកំប៉ុសអាចសន្សំលើថ្លៃចំណាយប្រព្រឹត្តិកម្មដោយសារវាបានកាត់បន្ថយបរិមាណសំណល់រឹងដែលត្រូវកប់។ កម្រៃដែលសន្សំបាននេះអាចដាក់ស្នើជាការបញ្ចុះតម្លៃលើថ្លៃសេវាដែលអ្នកបង្កើតសំណល់រឹងត្រូវបង់ ឬផ្តល់ជាជំនួយលើការលើកទឹកចិត្តផ្សេងៗ (ដូចជាការផ្តល់ជូនជីកំប៉ុសដោយមិនគិតថ្លៃទៅប្រជាជន ដូចឧទាហរណ៍ក្នុងក្រុង ឡាពីតាណា)។ បើទោះបីជាយ៉ាងនេះក៏ដោយមានបញ្ហាប្រឈមមួយចំនួនក្នុងការចរចារនិងការព្រមព្រៀងលើកម្រៃដែលសន្សំបាននេះ។

កម្រៃដែលអាចសន្សំបានដោយសេវាកម្មប្រមូលអាស្រ័យទៅតាមទីតាំងនៃមជ្ឈមណ្ឌលទាញយកធនធានពីសំណល់ ឬកែច្នៃសំណល់ដែលមានលំហូរសំណល់។ ប្រសិនបើមជ្ឈមណ្ឌលទាញយកធនធានពីសំណល់រឹង ឬកែច្នៃសំណល់រឹងមានទីតាំងដដែលនៅទីលាន (ដូចករណីក្រុងបាត់ដំបងសព្វថ្ងៃ) ការចំណាយលើការដឹកជញ្ជូនមិនអាចសន្សំបានទេ។ មានតែផលិតផលជីកំប៉ុសដែលអាចសន្សំបាន បើទោះបីជាយ៉ាងនេះ មជ្ឈមណ្ឌលអាចរកប្រាក់ចំណូលតិចជាងការចំណាយ ហេតុនេះចំណុចប្រសព្វរវាងចំណាយនិងចំណូលត្រូវធ្វើឲ្យបានជាមុនសិន។

ក៏ប៉ុន្តែប្រសិនបើមជ្ឈមណ្ឌលញែកយកធនធានពីសំណល់ ឬកែច្នៃសំណល់នៅជិតសាលាក្រុងជាងទីលាន ជាពិសេសគឺនៅពេលដែលទីលានថ្មីនឹងបង្កើតឡើង ពេលនោះការចំណាយលើការដឹកជញ្ជូននឹងត្រូវបានកាត់បន្ថយ។ ក្នុងករណីនេះ សំណល់រឹងដែលអាចទាញយកធនធានបាន ឬអាចកែច្នៃបាន ត្រូវបញ្ជូនទៅមជ្ឈមណ្ឌលញែកយក ធនធានពីសំណល់ ឬកែច្នៃសំណល់ដែលនៅជិតសាលាក្រុង ដែលអាចសន្សំសំចៃលើការចំណាយក្នុងការធ្វើដំណើរបន្ថែមច្រើនគីឡូម៉ែត្របាន។ សម្រាប់ក្រុងបាត់ដំបង ក្រុមហ៊ុនស៊ីន ទ្រី អាចទទួលបានផលចំណេញដោយការយកសំណល់រឹងឲ្យខមភីដ (COMPED) ពីព្រោះវាមានចម្ងាយជិតជាងទីតាំងទីលានថ្មី (ស្មើនឹងប្រហែលមួយភាគបួននៃចម្ងាយសរុប ដែលបច្ចុប្បន្នការចំណាយលើការដឹកជញ្ជូនស្មើនឹងប្រមាណ ១ដុល្លារ ក្នុងសំណល់រឹង ១ តោន ដែលនឹងកើនឡើង៤ដុល្លារក្នុងមួយតោនសម្រាប់ទីលានថ្មី)។ លើសពីនេះទៅទៀត ប្រសិនបើយុទ្ធនាការញែកបានជោគជ័យ និងមជ្ឈមណ្ឌលញែកសំរាមអាចដំណើរការបាន វានឹងមានសារៈប្រយោជន៍ក្នុងការបំប្លែងសំណល់រឹងព្រមទាំងលើកទឹកចិត្តអ្នករើសអេតចាយក្នុងការប្រមូលដូចដែលបានពិភាក្សាក្នុងផ្នែកមុន។ ហេតុនេះ វាត្រូវបានផ្សព្វផ្សាយផងដែរថាប្រសិនបើសំណល់មិនបានញែក ថ្លៃសេវានៃការប្រមូលរបស់អ្នកនឹងគុណនឹង៤។

ការកំណត់តម្លៃលើកទឹកចិត្តក៏ជាជម្រើសមួយទៀតផងដែរ។ ការកំណត់តម្លៃលើកទឹកចិត្តគឺជាគោលការណ៍មួយដែលការកំណត់តម្លៃអាស្រ័យលើបរិមាណសំណល់ដែលបានបង្កើត។ ហេតុនេះ តាមផ្ទះអាចមានការលើកទឹកចិត្តក្នុងការកាត់បន្ថយបរិមាណសំណល់ដែលបង្កើតដើម្បីកាត់បន្ថយចំណាយ។

បើទោះបីជាយ៉ាងនេះក្តី ការអនុវត្តការកំណត់តម្លៃលើកទឹកចិត្ត (តម្លៃអាស្រ័យលើទម្ងន់)ក្នុងទីក្រុងដែលសេវាកម្មមិនបានគ្របដណ្តប់គ្រប់ទីកន្លែងអាចផ្តល់ផលអវិជ្ជមាន។ តាមផ្ទះអាចត្រូវបានជំរុញឲ្យពួកគាត់កាត់បន្ថយចំណាយដោយចោលសំរាមពាសវាលពាសកាលនិងដុតចោល ដែលនេះនឹងផ្តល់ជាផលអវិជ្ជមាន។ លើសពីនេះទៅទៀត យោងតាមតម្រូវការនៃការរៀបចំ ការអនុវត្តនៃការកំណត់តម្លៃលើកទឹកចិត្តនេះ អាចពិបាកក្នុងការអនុវត្តក្នុងទ្រង់ទ្រាយធំក្នុងទី សាលាក្រុងក្នុងប្រទេសដែលកំពុងអភិវឌ្ឍ។

ក្នុងករណីក្រុងបាត់ដំបង វាគួរឲ្យចាប់អារម្មណ៍ក្នុងការសាកល្បងគំរូនៃការកំណត់តម្លៃលើកទឹកចិត្តនេះនៅកម្រិតសង្កាត់។ ដូច្នេះ ការចំណាយរបស់សាលាក្រុងនៅក្នុងតំបន់នេះ អាចនឹងត្រូវបានកាត់បន្ថយតាមចំនួនដែលបានកំណត់អាស្រ័យលើសមត្ថភាពអាជ្ញាធរមូលដ្ឋានដែលអាចធ្វើទៅបាន។ ការបញ្ចុះតម្លៃនេះ អាចត្រូវបានត្រួតពិនិត្យឡើងវិញរៀងរាល់ឆ្នាំ ដោយគណៈកម្មការញែកសំណល់រឹងនៅនឹងប្រភព (ដែលរួមមាន ប្រតិបត្តិករ អ្នកតំណាងប្រជាជនតាមផ្ទះ និង អាជ្ញាធរសាលាក្រុង)។ ដោយយោងតាមសូចនាករមួយចំនួន (គុណភាពសេវាកម្ម គុណភាពនៃការញែក បរិមាណនៃសំណល់រឹងដែលបានបង្កើតក្នុងមនុស្សម្នាក់ ។ល។) ឱ្យធ្វើឱ្យទំហំថវិកាឧបត្ថម្ភធន ត្រូវបាន

ផ្លាស់ប្តូរ។ អត្ថប្រយោជន៍នៃគណៈកម្មការនេះ គឺបង្ហាញការវាយតម្លៃលើការអនុវត្ត និងលើកទឹកចិត្តប្រជាជនតាមផ្ទះឱ្យប្រឹងអនុវត្តឱ្យបានល្អជាងមុន ជាការថ្នូរនឹងការកាត់បន្ថយតម្លៃបន្ថែមទៀត។

## ការធ្វើឲ្យប្រសើរឡើងការស្តារឡើងវិញនៃការចំណាយលើការគ្រប់គ្រងសំណល់រឹង

តាមការប៉ាន់ស្មាន មានតែត្រឹមមួយភាគបួននៃអតិថិជនតាមផ្ទះប៉ុណ្ណោះ ដែលបានបង់ថ្លៃសេវាគ្រប់គ្រងសំណល់រឹង ដែលនេះបង្ហាញថាមានអត្រាវិក្កយបត្រដែលមិនបានបង់ក្នុងកម្រិតខ្ពស់។ វាអាចបណ្តាលមកពីរង្វង់កង្វះខាតនៅត្រង់ចំណុចនេះ ដោយហេតុថា សេវាកម្មមានគុណភាពមិនល្អ ហេតុនេះប្រជាជនមិនបង់ថ្លៃសេវា សេវាកម្មក៏ត្រូវបានថមថយ និង មានប្រជាជនតិចតួចដែលបន្តបង់ប្រាក់។ ដើម្បីលុបបំបាត់កង្វះខាតនេះ យន្តការអនុវត្តច្បាប់ត្រូវតែធ្វើឡើងដោយមានការផ្លាស់ប្តូរគុណភាពសេវាកម្ម បើមិនចឹងទេពួកគាត់នឹងទទួលបរាជ័យ។ នេះជាមូលហេតុដែលចាំបាច់ត្រូវបង្កើត និង ផ្សព្វផ្សាយជាដំបូងផ្លូវប្រមូលសំរាមព្រមទាំងប្រព័ន្ធតាមដានសំលេង (បុគ្គលិកមន្ទីរបរិស្ថានខេត្តដែលបានចាត់តាំង) ដើម្បីធានាថាសេវាកម្មប្រមូលត្រូវបានប្រកាន់ខ្ជាប់។

នៅដែលប្រព័ន្ធទាំងពីរនេះ ត្រូវបានបង្កើតឡើង (ដែលត្រូវការពេលច្រើន) សេវាកម្មប្រមូលផ្លូវការនិងអាជ្ញាធរមូលដ្ឋានអាចធ្វើសាររួមថាការបង់ថ្លៃសេវាកម្មត្រូវតែធ្វើ បើមិនដូច្នេះទេ នឹងមានការផាកពិន័យចំពោះអ្នកដែលមិនបង់ថ្លៃសេវា (ដែលមានចែងក្នុងអនុក្រឹត្យ ១១៣)។ សារទាំងនេះគួរបង្ហាញតាមរយៈយុទ្ធនាការផ្សព្វផ្សាយ ជាសាធារណៈ (តាមទូរទស្សន៍ វិទ្យុ ការផ្សព្វផ្សាយជាសំលេងជាសាធារណៈ ។ល។) ផ្ទាំងផ្សព្វផ្សាយ បណ្តាញសង្គមជាដើម។

ជម្រើសមួយទៀត គឺធ្វើឲ្យសង្កាត់យកកម្រៃដែលប្រមូលបានទៅផ្តល់ជាជំនួយឲ្យក្រុមហ៊ុន ស៊ីន ទ្រី សម្រាប់ធុងសំរាមសហគមន៍ជំនួសឲ្យប្រជាពលរដ្ឋ ដូចដែលបានស្នើឡើងក្នុងដំណាក់កាលនៃការធ្វើយុទ្ធនាការក្នុងសង្កាត់។ ថ្លៃសេវាដែលបានបង់គួរផ្អែកតាមតារាងដែលបានកំណត់ដោយច្បាប់ (មើលឧបសម្ព័ន្ធទី ៤)។

## ការធ្វើផែនការសម្រាប់ទីលាននាពេលអនាគត

មានការរំពឹងទុកថា ក្នុងប៉ុន្មានឆ្នាំខាងមុខនេះ ទីលាននាពេលបច្ចុប្បន្ននឹងបិទ និងផ្លាស់ប្តូរទៅទីតាំងថ្មី។ នេះនឹងផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងដល់សកម្មភាពរបស់ខមភីដ និង ក្រុមហ៊ុន ស៊ីន ទ្រី ព្រមទាំងខ្សែសង្វាក់សំណល់រឹងទាំងមូល។

នៅទីលានថ្មី គេរំពឹងថានឹងមានជញ្ជីងសម្រាប់ថ្លឹងទម្ងន់។ ថែមពីលើនេះ ទីតាំងនឹងត្រូវបានគ្រប់គ្រងតាមគោលការណ៍តម្លៃក្នុងមួយតោននៃសំរាមដែលដឹកចូល។ ហេតុដូចនេះ វាពិតជាគួរឲ្យចាប់អារម្មណ៍ណាស់ក្នុងការរៀបចំ យុទ្ធនាការបញ្ច្រាបការយល់ដឹងលើការកែច្នៃជាជីកំប៉ុសជំនួសឲ្យការបញ្ជូនសំរាមទៅទីលាន។ គោលបំណងគឺការលើកកម្ពស់ការយល់ដឹងថាអាជ្ញាធរមូលដ្ឋានត្រូវវិនិយោគវិញទាំងអស់ ឬដោយផ្នែកពីប្រាក់សន្សំដែលទទួលបានតាមរយៈការកាត់បន្ថយបរិមាណសំរាមដែលបានបំប្លែងទៅជាជីកំប៉ុស ដោយផ្តល់ជាថវិកាឧបត្ថម្ភធនទៅខមភីដ (COMPED) ផ្អែកតាមបរិមាណសំណល់រឹងដែលបានកែច្នៃជំនួសឲ្យថ្លៃទីលាន។

ជាចុងបញ្ចប់ វាពិតជាមានសារៈសំខាន់ណាស់ដែលត្រូវគិតគូរដល់អ្នករើសអេតចាយផងដែរនៅពេលដែលមានការផ្លាស់ប្តូរទីលាន។ វាអាចជាឱកាសមួយក្នុងការធ្វើឲ្យសេវាកម្មរបស់ពួកគមានលក្ខណៈផ្លូវការដោយជួលពួកគេឲ្យធ្វើការនៅខមភីដ ឬនៅមជ្ឈមណ្ឌលញែកសំរាម (MRF)។ ធ្វើបែបនេះ ក៏អាចជំរុញឲ្យមជ្ឈមណ្ឌលអប់រំរបស់ COMPED នៅអាចដំណើរការបានផងដែរ។

## ទទួលស្គាល់និងធ្វើឲ្យអេតចាយមានលក្ខណៈផ្លូវការ

ជាចុងក្រោយ ការរួមបញ្ចូលអ្នករើសអេតចាយទៅជាអ្នកផ្តល់សេវាកម្មផ្លូវការជាងនេះ ឱ្យច្រើនទៅៗ ជាដំណើរការដែលអាចធ្វើទៅរួច។ ជម្រើសមួយគឺអាចផ្តល់ជាអាជ្ញាបណ្ណសម្រាប់ពួកគាត់ក្នុងការគ្រប់គ្រងសេវាកម្មរបស់ពួកគាត់ និងលើកទឹកចិត្តឱ្យមានការរៀបចំបែបនេះ។ ប្រសិនបើពួកគាត់ត្រូវបានចងក្រង(ឬចូលរួម) ជាសមាគម វានឹងផ្តល់ផលប្រយោជន៍ឲ្យពួកគាត់ក្នុងរយៈពេលវែង

(ដូចជាករណី សហគមន៍អ្នករើសអេតចាយដែលទទួលបានការឧបត្ថម្ភរបស់អាជ្ញាធរមូលដ្ឋានក្នុងប្រទេស La Pintana, អាមេរិចខាងត្បូង)។ ប្រយោជន៍សម្រាប់សមាគម គឺបេឡាជាតិរបបសន្តិសុខសង្គមដែលបច្ចុប្បន្នកំពុងធ្វើការទទួលស្គាល់អ្នកដែលប្រកបរបរដោយខ្លួនឯង និងអាចឧបត្ថម្ភជាផលប្រយោជន៍ផ្សេងៗ (ការថែទាំសុខភាព និងគ្រោះថ្នាក់ការងារ) សម្រាប់សមាគមដែលត្រូវបានទទួលស្គាល់ ក្នុងកំឡុងពេល២ទៅ៣ឆ្នាំខាងមុខ។ ដូចដែលបានដឹង កម្មករដែលបម្រើការដោយខ្លួនឯងមិនត្រូវបានទទួលស្គាល់ឡើយ ក៏ប៉ុន្តែអ្នកមានកាន់បណ្ណគ្រួសារក្រីក្រអាចចុះឈ្មោះបាននៅបេឡាជាតិរបបសន្តិសុខសង្គម។ គេបានផ្តល់អនុសាសន៍ថា រដ្ឋាភិបាលត្រូវគាំទ្រសេវានេះឲ្យបានទូលំទូលាយ ពីព្រោះអ្នករើសសំរាមតាមផ្លូវ និងនៅទីលានភាគច្រើនជា ស្ត្រី និងកុមារ ក៏ប៉ុន្តែសមាគមគួរត្រូវបានបង្កើតតាមទម្រង់ធម្មជាតិ។

ដើម្បីពង្រឹងសមាគមក្នុងក្រុងបាត់ដំបង នៅក្នុងវិស័យនៃការប្រមូលសំរាមក្រៅផ្លូវការ វាអាចមានប្រយោជន៍ក្នុងការអញ្ជើញ សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (អាយឌៀ IDEA) ដើម្បីណែនាំ និងជួបជាមួយអ្នករើសអេតចាយកំឡុងពេលផ្តល់វគ្គបណ្តុះបណ្តាល។ អាយឌៀ គឺជាសមាគមដែលបានចុះឈ្មោះនៅក្រសួងមហាផ្ទៃ ដែលត្រូវបានអញ្ជើញជាផ្លូវការដោយនាយករដ្ឋមន្ត្រីក្នុងការសហការជាមួយរដ្ឋាភិបាលលើសិទ្ធិអ្នកធ្វើការក្រៅប្រព័ន្ធ រួមមានអ្នករើសសំរាមតាមផ្លូវជាដើម។

សមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) ទំនាក់ទំនង៖ លោក កៅ គឿន អគ្គលេខាធិការរង
វែបសាយ៖ http://ideacambodia.org

## ការសិក្សាវិភាគលក្ខណៈសំណល់រឹង

ការសិក្សាវិភាគសំណល់រឹងដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយមានភាពចាំបាច់ណាស់ក្នុងការកំណត់សមាសភាពពិតប្រាកដនៃសំណល់រឹងដែលបានបង្កើត។ អ្វីដែលចំណេញបំផុតពីការសិក្សានេះ គឺអាចបង្កើនការយល់ដឹងពីលទ្ធភាពជាក់ស្តែងនៃអេតចាយ ដែលធ្វើឲ្យការចងក្រងជាលក្ខណៈផ្លូវការ និងការគ្រប់គ្រងអាចធ្វើទៅបានប្រសិនបើចាំបាច់។ ការសិក្សានេះក៏អាចជួយឲ្យមានការស្វែងយល់ប្រសើរឡើងនៃវិស័យកែច្នៃសំណល់រឹង និងអនុញ្ញាតឲ្យមានការអភិវឌ្ឍបន្តទៀត ដូចជា ការធ្វើពិពិធកម្មមជ្ឈមណ្ឌលប្រព្រឹត្តិកម្មសំណល់ (មជ្ឈមណ្ឌលជីកំប៉ុស ថ្មី ឡជីវៈឧស្ម័ន ។ល។) និងការលើកទឹកចិត្តក្នុងការបន្តការទាញយកធនធានពីសំណល់ក្នុងរយៈពេលវែង។



# ៤. ការធ្វើឲ្យប្រសើរឡើង ធុរកិច្ចកែច្នៃ សំណល់រឹងក្នុងក្រុងបាត់ដំបង

## ៤.១. ខមភីដ (COMPED)[៤០]

### *៤.១.១ ការវិភាគទីផ្សារ*

ដើម្បីទទួលបានអត្រាផលិតកម្មខ្ពស់ ការវិភាគផ្នែកហិរញ្ញវត្ថុ បង្ហាញថាការញែកសំណល់រឹងជាកត្តាគន្លឹះ បើទោះបីជាការបង្កើនធាតុចូលដែលជាសំណល់សរីរាង្គដែលសំបូរទៅដោយកាបូន និងផលិតភាព ដើម្បីធ្វើឲ្យប្រសើរឡើងគំរូធុរកិច្ច។

វាត្រូវបានបង្ហាញយ៉ាងច្បាស់ថា សំណល់សរីរាង្គដែលស្ងួតអាចពិបាកក្នុងការរក តាមរយៈការសម្ភាសន៍ជាមួយភាគីមួយចំនួន បង្ហាញថា សំណល់សរីរាង្គស្ងួតមានតម្រូវការខ្ពស់សម្រាប់ការដុត។ មានករណីអង្កាមជាឧទាហរណ៍ ដែលត្រូវបានទិញដោយកន្លែងផលិតឥដ្ឋក្នុងតម្លៃប្រកួតប្រជែងមួយ។ ក្រោយពីបានទទួលម៉ាស៊ីនបំបែកពីយូនីដូ សំណល់សរីរាង្គដែលសំបូរកាបូនធំៗ ងាយនឹងបំបែកទៅជាសំណល់រឹងតូចៗដើម្បីងាយស្រួលក្នុងការយកមកធ្វើជីកំប៉ុស។ ទោះបីជាយ៉ាងនេះក្តី ចំណុចកង្វះខាតនេះ អាចកែលម្អបានតាមរយៈការយកមែកឈើពីឲ្យក្រុមហ៊ុន លៀប លឹម ដែលធ្វើសេវាកម្មរក្សាសោភ័ណភាពសាលាក្រុង ដែលអាចផ្គត់ផ្គង់បានរហូតដល់ ១០តោនក្នុងមួយខែឯណោះ។ លើសពីនេះទៅទៀត មានឱកាសមួយចំនួនក្នុងការទាញយកសំណល់សរីរាង្គស្ងួតពីទីផ្សារដូចជា កាកអំពៅ ឬ សំបកដូង។ សំណល់រឹងទាំងនេះគួរត្រូវបានលើកទឹកចិត្តឲ្យប្រមូលក្នុងកំឡុងពេលធ្វើយុទ្ធនាការផ្សព្វផ្សាយ។

ក៏គួរឲ្យកត់សម្គាល់ផងដែរថា ប្រសិនបើការញែកសំណល់រឹងមានភាពប្រសើរឡើង សមត្ថភាពមជ្ឈមណ្ឌលកែច្នៃកំប៉ុសខមភីដ (COMPED) នឹងដល់ចំណុចកំណត់ដែលគ្របដណ្តប់លើផ្ទៃក្រឡាទំហំ៦០០ម៉ែត្រការ៉េ និងការវិភាគផ្នែកហិរញ្ញវត្ថុបង្ហាញថាធុរកិច្ចទាំងមូលមានភាពប្រសើរឡើង។ យ៉ាងហោចណាស់ទំហំនេះត្រូវតែពង្រីកទ្វេដងក្នុងកំឡុងពេល មួយឆ្នាំ ឬពីរឆ្នាំ (ឲ្យបាន១២០០ ម៉ែត្រការ៉េ) ដើម្បីអាចទទួលបានពី ២០ទៅ ២៤ តោនក្នុងមួយថ្ងៃ និងពង្រីកទៅពេលអនាគតឲ្យបានទំហំយ៉ាងហោចណាស់ ២៥០០ម៉ែត្រការ៉េដើម្បីអាចកែច្នៃសំណល់បានពី ៤០ ទៅ ៥០ តោនក្នុងមួយថ្ងៃ។ ទាំងយូនីដូ និងសាលាក្រុងគួរស្វែងរកជីសម្រាប់ឧបត្ថម្ភបន្ថែមទៀតសម្រាប់គោលបំណងនេះនាពេលអនាគត។

តាមការសិក្សាទីផ្សារដែលបានធ្វើឡើងក្នុងគម្រោងនេះ វាបង្ហាញយ៉ាងច្បាស់ថា មានអ្នកចាប់អារម្មណ៍លើផលិតផលជីកំប៉ុស តែអ្នកទិញចង់ឲ្យគុណភាពជីកំប៉ុសនេះ មានការធ្វើទីផ្សារឲ្យបានច្បាស់ ហើយប្រសិនបើធ្វើបាន នោះនឹងមានការបញ្ជាទិញក្នុងបរិមាណដ៏ច្រើន។

[៤០] គំរូហិរញ្ញវត្ថុរបស់អាជីវកម្មត្រូវបានដកចេញ (រាប់បញ្ចូលក្នុងឧបសម្ព័ន្ធ) សម្រាប់ហេតុផលរក្សាការសម្ងាត់

បច្ចុប្បន្ននេះ ដីកំប៉ុសត្រូវបានវេចខ្ចប់ដោយមិនមានលក្ខណៈផ្លូវការទេ។ នេះអាចជាបញ្ហាប្រឈមមួយជាពិសេសសម្រាប់អ្នកទិញរាយិសេសាបញ្ហាប្រឈមមួយសម្រាប់អ្នកទិញ។ បរិមាណដ៏ច្រើនលើផលិតផលដីកំប៉ុស តែងអ្នកទិញចង់ឲ្យគុណភាពដីកំប៉ុសត្រូវបានធ្វើទីផ្សារឲ្យបាន។ ការវេចខ្ចប់ដែលត្រឹមត្រូវអាចបង្កើនទំនុកចិត្តរបស់អតិថិជនលើផលិតផល និងប្រកបដោយវិជ្ជាជីវៈ។ ប្រសិនបើខមភីដ (COMPED) ចង់ធ្វើការប្រកួតប្រជែងទីផ្សារ គេបានផ្តល់អនុសាសន៍ ថាគាត់ត្រូវធ្វើស្លាកយីហោ និង ធ្វើយុទ្ធសាស្ត្រទីផ្សារផលិតផលរបស់ពួកគាត់ដើម្បីបំពេញស្តង់ដាក្នុងស្រុកដែលអ្នកទិញត្រូវការ និងមានទំនុកចិត្តលើគុណភាពផលិតផល (ដោយមានផ្លាកសញ្ញាច្បាស់លាស់មានវេចខ្ចប់ និង មានបង្ហាញគុណភាពផលិតផលជាដើម)។ ការបង្កើតខិតបណ្ណ ក៏មានប្រយោជន៍ច្រើនដែរ ព្រោះអ្នកទិញអាចប្រៀបធៀបដីកំប៉ុសរបស់ពួកគាត់ទៅនឹងដីដែលមានលក់លើទីផ្សារបច្ចុប្បន្ន និងការកែប្រែគុណភាពដី ឬកំណត់មធ្យោបាយធ្វើទីផ្សារដែលគួរឲ្យទាក់ទាញ។

ខមភីដ (COMPED) មិនមានយុទ្ធសាស្ត្រទីផ្សារច្បាស់លាស់ក្នុងការផ្សព្វផ្សាយផលិតផលរបស់ពួកគាត់ទេ។ ជាមួយដឹងចំណេះដឹងនៃតម្រូវការ វាក៏ធ្វើបានផងដែរក្នុងការកែសម្រួល និងធ្វើពិពិធកម្មផលិតផល (ដូចជាការលាយដីកំប៉ុសជាមួយនឹងដីគីមីជាឧទាហរណ៍)។ សមាសធាតុមួយនៃការធ្វើយុទ្ធសាស្ត្រទីផ្សារនេះគឺការធ្វើតេស្តជាប្រចាំនិងការធ្វើទីផ្សារលើលទ្ធផល (រួមមានសមាសភាពលោហៈធ្ងន់ដែលមានក្នុងដី)ដើម្បីធានាគុណភាពផលិតផល។ ទិន្នន័យដែលបានផ្តល់ឲ្យដោយ ខមភីដ (COMPED) កំឡុងពេលសិក្សា (មានក្នុងតារាងទី ១៩) បង្ហាញថាគុណភាពអាចប្រកួតប្រជែងក្នុងទីផ្សារសាលាក្រុងស្រុក។

យោងតាមទីផ្សារនៃដីកំប៉ុស អ្នកតំណាងពីហ្វាស់ស្មែខ (FASMEC) បានបញ្ជាក់យ៉ាងច្បាស់ថា មានចម្ការចេកនិងស្វាយដែលត្រូវការដីកំប៉ុសក្នុងបរិមាណច្រើន (ចម្ការចេកមានទីតាំងនៅខេត្តកំពង់ចាមមានតម្រូវការប្រមាណ១០០តោនក្នុងមួយខែក្នុងដើមឆ្នាំ២០១៩)។ ចម្ការមួយចំនួនក្នុងខេត្តបាត់ដំបងនិងប៉ៃលិនក៏ត្រូវការដីកំប៉ុសដែរ។ បើទោះបីជាយ៉ាងនេះក៏ដោយការសម្ភាសជាមួយខូរ៉ា ( COrAA ) (ដែលមានសមាជិកភាគច្រើនជាម្ចាស់ចម្ការម្រេចក្នុងខេត្តកំពត) បានបង្ហាញថា មានចម្ការខ្លះគាត់ផលិតដីកំប៉ុសដោយខ្លួនឯង។ លើសពីនេះទៅទៀតមានការប្រកួតប្រជែងខ្លាំងជាមួយដីគីមី (តារាងទី ២០) និងជាមួយដីកំប៉ុសនាំចូលពីក្រៅប្រទេស។ ព័ត៌មានទាំងនេះ បង្ហាញយ៉ាងច្បាស់ថា ការបង្កើនសម្ភារៈផ្សព្វផ្សាយនិងទំនាក់ទំនងជាក់លាក់ជាមួយចម្ការ ទំនងជានាំផលប្រយោជន៍ច្រើនដល់ខមភីដ (COMPED) ។

យោងតាមការសង្កេតលើទីផ្សារដីកំប៉ុសនៅកម្ពុជា ក្រុមហ៊ុនធ្វីនអាហ្គ្រីតិច (TWIN Agri Tech) ក្នុងរាជធានីភ្នំពេញក៏ផលិតកំប៉ុសនិងលក់ក្នុងតម្លៃប្រហាក់ប្រហែលគ្នានឹងខមភីដ (COMPED) ដែរ (សូមមើលតារាងទី ១៩)។ បើទោះបីជាយ៉ាងនេះក៏ដោយផលិតផលរបស់ខមភីដ (COMPED) មានគុណភាពខ្ពស់ជាង។ ម្យាងវិញទៀត ក្រុមហ៊ុនធ្វីនអាហ្គ្រីតិច (TWIN Agri Tech) ក៏ផលិតដីកំប៉ុសជន្លេនផងដែរ ដែលមានគុណភាពល្អជាងហេតុនេះអាចជាទីចង់ប្រើប្រាស់ជាង។ ខមភីដ (COMPED) គួរដាក់បញ្ចូលការធ្វើដីកំប៉ុសប្រភេទនេះបន្ថែមទៀតក្នុងមជ្ឈមណ្ឌលរបស់ខ្លួន ដើម្បីបង្កើនលទ្ធភាពប្រកួតប្រជែងលើទីផ្សារ។ ភាពខុសគ្នាចម្បងរវាង ក្រុមហ៊ុនធ្វីនអាហ្គ្រីតិច (TWIN Agri Tech) និង ខមភីដ (COMPED) គឺការប្រមូលសំណល់ពីហាង និង ភោជនីយដ្ឋានដោយបង់ប្រាក់ និងមានសមត្ថភាពក្នុងការផលិតក្នុងបរិមាណច្រើន (អាច៤០០ទៅ៨០០តោនក្នុងមួយខែ)។ បើទោះបី ខមភីដ (COMPED) អាចបង្កើនសមត្ថភាពតាមរយៈការពង្រីកទំហំមជ្ឈមណ្ឌល (សូមមើលអនុសាសន៍ទៅ៤) វាពិតជាមានបញ្ហាប្រឈមក្នុងការចុះប្រមូលដោយសារតែមានទ្រង់ទ្រាយតូច (ស្ថានភាពសេដ្ឋកិច្ច) ដែលអាចបង្កឲ្យការចំណាយខ្ពស់លើប្រតិបត្តិការដោយបន្ថែមសកម្មភាពចុះប្រមូល។ បើទោះបីជាយ៉ាងនេះ ខមភីដ (COMPED) អាចពិចារណាលើការធ្វើពិពិធកម្មដីកំប៉ុសជន្លេន ដើម្បីធ្វើឲ្យផលិតផលរបស់គាត់កាន់តែមានការប្រកួតប្រជែងនិងអាចលក់ក្នុងតម្លៃខ្ពស់លើទីផ្សារនេះអាចធ្វើឲ្យពួកគាត់អាចប្រកួតប្រជែងបានច្រើនជាងមុន។

តារាងទី ១៣៖ ការប្រៀបធៀបខមភីដ (COMPED) និងអ្នកផ្គត់ផ្គង់ជីសរីរាង្គផ្សេងទៀតនៅកម្ពុជា

| សូចនាករ | COMPED | TWIN Agri Tech Co., LTD | MSG (Maly San Group Co., Ltd) | Ex-M-Cambodia Co., Ltd |
|---|---|---|---|---|
| អាសយដ្ឋាន | សង្កាត់ចម្ការសំរោង ក្រុងបាត់ដំបង | ផ្លូវលេខ ១៣១ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ភ្នំពេញ | អគារ MSG ផ្លូវលេខ ១៤៦ សង្កាត់ទឹកល្អក់ទី ២ ខណ្ឌទួលគោក ភ្នំពេញ | ផ្លូវលេខ ៩៦E0 ផ្លូវលេខ ២១៥ សង្កាត់វាលវង់ ខណ្ឌ៧មករា |
| ផលិតផល | ក្នុងស្រុក | ក្នុងស្រុក | នាំចូលពីប្រទេសថៃ | នាំចូលពីប្រទេសបែលហ្សិក |
| **តម្លៃ** | | | | |
| ដុល្លារ/៤០គីឡូ | ៦.២៥ | ៨ | ១៣ | ១៥ |
| ដុល្លារ/តោន | ១៣០ | ១២៥ | ៣២៥ | ៣៣០ |
| ថ្លៃដឹកជញ្ជូន | មិនគិតប្រាក់ | មិនគិតប្រាក់ ក្នុងសាលាក្រុងភ្នំពេញ | មិនគិតប្រាក់ | មិនគិតប្រាក់ |
| **សារធាតុចិញ្ចឹម** | | | | |
| N | ២.២៦ | ១.៨ | ១.៣ | ៤ |
| P | ២.២៦ | ១.៥១ | ១.៥៩ | ៣ |
| K | ៣.៥៤ | ២.០១ | ១.១១ | ៣ |

### តារាងទី ១៤៖ ការប្រៀបធៀបជីសរីរាង្គរបស់ខមភីដ ( COMPED ) ជាមួយនឹងជីគីមី ពីប្រទេសវៀតណាម និងជីសរីរាង្គពីប្រទេសថៃ

| ជីសរីរាង្គរបស់ COMPED | ជីគីមីពីវៀតណាម | ជីសរីរាង្គពីប្រទេសថៃ |
|---|---|---|
| ជីកំប៉ុស<br><br>ជីកំប៉ុស( ២.២៦:២.២៦:៣.៥៤[៤១] )៖ ១៣០ដុល្លារ/តោន | ( ១ ) ក្រុមហ៊ុនជីត្រីកោណ<br>- UREA ( ៤៦:0:0 )៖ ៣៤0ដុល្លារ/តោន<br>- DAP ( ១៨:៤៦:0 )៖ ៤៥0ដុល្លារ/តោន<br>- Kali ( 0:0:៦0 )៖ ៣៦0ដុល្លារ/តោន | ( ១ ) ក្រុមហ៊ុនជីក្របីក្រហម<br><br>ជីកំប៉ុស ( ៦:៣:៣ )៖<br>៣២0ដុល្លារ-៣៦0 ដុល្លារ/តោន |
| | ( ២ ) Cheam Tech Co., Ltd<br>- UREA ( ៤៦:0:0 )៖ ៣៤0 ដុល្លារ/តោន<br>- DAP ( ១៨:៤៦:0 )៖ ៤៤0ដុល្លារ/តោន<br>- Kali ( 0:0:៦0 )៖ ៣៧0ដុល្លារ/តោន | ( ២ ) MSG (Maly San Group Co., Ltd<br><br>Compost ( ១.៣:១.៥៩:១.១១ )៖<br>៣២៥ ដុល្លារ/តោន |
| | ( ៣ ) Bind Dien Fertilizer Co., Ltd<br>- UREA ( ៤៦:0:0 )៖ ៣៨៦ដុល្លារ/តោន<br>- DAP ( ១៨:៤៦:0 )៖ ៥៥៦ដុល្លារ/តោន<br>- Kali ( 0:0:៦0 )៖ ៤២0ដុល្លារ/តោន | |

មានចំណុចមួយដែលនៅមិនទាន់ច្បាស់ ថាតើតម្រូវការជីកំប៉ុសពីសំណល់ទីប្រជុំជននឹងបង្កើតជាផលវិបាកក្នុងការលក់ ដែរឬទេ ដោយសារជួនការវាមានកេរ្ត៍ឈ្មោះមិនល្អ និងមានប្រសិទ្ធភាពទាបប្រើប្រៀបធៀបទៅនឹងជីកំប៉ុសពីកសិកម្ម។ ការសិក្សាក្នុងគម្រោងនេះមិនមានបញ្ជាក់ពីចំណុចប្រឆាំងនឹងជីកំប៉ុសដែលផលិតចេញពីសំណល់ទីប្រជុំជនទេ តែបើទោះបីជាយ៉ាងនេះការសិក្សាស៊ីជម្រៅគួរត្រូវធ្វើឡើងដើម្បីកំណត់ថាតើវាអាចប៉ះពាល់ដល់ប្រសិទ្ធភាពផលិតផលដែរឬទេ។ ការសិក្សាទីផ្សារ គួរត្រូវបានគិតពិចារណាពីតម្រូវការដាក់លាក់សម្រាប់ជីកំប៉ុសត្រូវការក្នុងការផលិតពីសំណល់ទីប្រជុំជន និង កំណត់បញ្ហាជាក់លាក់ដែលពាក់ព័ន្ធគ្នា។

- ជីកំប៉ុសដែលផលិតចេញពីសំណល់ទី ប្រជុំជន/ទីផ្សារ អាចត្រូវបានបំពុលដោយសំណល់មានគ្រោះថ្នាក់ ( ថ្មពិល សារធាតុគីមីដែលបានប្រើប្រាស់សម្រាប់គោលបំណងផ្សេងៗ ជាដើម ) នៅពេលដែលទុកចោលនៅផ្ទះ ឬកំឡុងពេលដឹកជញ្ជូន។
- ប្រសិនបើដំណើរការនៃការញែកមិនពេញលេញ ជីកំប៉ុសអាចមានផ្ទុក កំទេចប្លាស្ទិក អំបែងកែវ និងឧបករណ៍មុតស្រួចផ្សេងៗទៀត។

[៤១] (2.26:2.26:3.54) បង្ហាញពីឧទាហរណ៍នៃសារធាតុចិញ្ចឹម (N:P:K) ក្នុងជី

- ជីកំប៉ុសដែលផលិតចេញពី សំណល់រឹងតាមផ្ទះ/ផ្សារ អាចមិនសូវមានជីជាតិដូចជីកំប៉ុសដែលផលិតចេញពីលាមកសត្វ។

ការសិក្សាទីផ្សារកំប៉ុសគួរត្រូវបញ្ចូលពេលសិក្សាដោយមានការចុះសម្ភាសន៍ជាមួយកសិដ្ឋានដើម្បីកំណត់ឲ្យបានច្បាស់ពីទីផ្សារសម្រាប់ជីកំប៉ុស និងរួមបញ្ចូលការវិភាគ ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និង ការគំរាមកំហែង (SWOT) នៃការប្រកួតប្រជែង ដូចជាជីកំប៉ុសដែលផលិតចេញពីលាមកសត្វ ជីគីមី ជីកំប៉ុសជន្លេនជាដើម។ នេះអាចជួយក្នុងការកំណត់ទំហំវិនិយោគលើកន្លែងកែច្នៃនាពេលអនាគត។ គួរកត់សម្គាល់ផងដែរថា ទីប្រឹក្សាកំពុងធ្វើការសិក្សាគម្រោង២ផ្សេងទៀតដែលពាក់ព័ន្ធនឹងគម្រោងនេះ មួយនៅខេត្តសៀមរាបអំពីផលិតផលជីកំប៉ុស និងមួយទៀតនៅរាជធានីភ្នំពេញពីផលិតផលពីភក់បង្គន់ក្នុងកំឡុងពេលប៉ុន្មានខែខាងមុខនេះ។

### ៤.១.២. អនុសាសន៍

#### អនុសាសន៍ទី ១៖ ធ្វើឲ្យប្រសើរឡើងគុណភាពសំណល់សរីរាង្គ

វានឹងមានផលប្រយោជន៍ដល់ខមភីដ (COMPED) ក្នុងការធ្វើការជិតស្និទ្ធជាមួយនឹងអ្នកគ្រប់គ្រងផ្សារ អ្នកអនាម័យផ្សារ និងសេវាកម្មប្រមូល ស៊ីន ទ្រី ក្នុងការធ្វើការញែកសំណល់រឹង។ លើសពីនេះទៅទៀត ខមភីដក៏នឹងទទួលបានផលប្រយោជន៍ច្រើនផងដែរ ក្នុងការប្រមូលសំណល់រឹងពីផ្សារ ៤ ផ្សេងទៀត ដោយសារផ្សារទាំងនោះមានផលិតផលប្រភេទផ្សេងទៀត។ នេះអាចជួយឲ្យទទួលបានសំណល់សរីរាង្គស្ងួត ដូចជាសំបកដូង និងកាកអំពៅ ដែលអាចជួយបង្កើនទិន្នផលកំប៉ុសនិងជួយធ្វើឲ្យមានតុល្យភាពផលធៀបកាបូននិងអាសូត។

មធ្យោបាយកាន់តែល្អក្នុងការទទួលបានសំណល់សរីរាង្គនិងស្រស់នោះគឺខមភីដ ចូលរួមការប្រមូលដោយផ្ទាល់នៅតាមផ្សារ ដោយសារតែ ក្រុមហ៊ុន ស៊ីន ទ្រី នឹងមិនទទួលបានការលើកទឹកចិត្តអ្វីឡើយក្នុងការបង្កើនប្រសិទ្ធភាពការញែកសំណល់នៅពេលនេះ។ ប្រសិនបើខមភីដ ប្រមូលសំរាមដោយខ្លួនឯង នោះនឹងអនុញ្ញាតឲ្យខមភីដ បានមើលដោយផ្ទាល់ពីគុណភាពនៃផលិតផល លើកកម្ពស់ការយល់ដឹងរបស់អ្នកលក់និងអ្នកអនាម័យផ្សារ ព្រមទាំងអាចធ្វើពិពិធកម្មប្រាក់ចំណូលរបស់គាត់ទៀតផង។

បើទោះបីជាយ៉ាងនេះក៏ដោយ  ដោយសារតែសមត្ថភាពទីលានបច្ចុប្បន្នជិតពេញ វានឹងមានផលប្រយោជន៍ដល់ក្រុមហ៊ុន ស៊ីន ទ្រី ក្នុងការប្រមូលសំរាមតាមប្រភេទផ្សេងគ្នា ដោយសារទីតាំងមជ្ឈមណ្ឌលកែច្នៃរបស់ខមភីដ មានទីតាំងជិតជាងទីតាំងទីលានថ្មីដែលស្នើឡើង។ ចំណុចនេះត្រូវបង្ហាញនិងពិភាក្សាជាមុនជាមួយក្រុមហ៊ុន ស៊ីន ទ្រី ជាមុនដើម្បីជានាកិច្ចសហប្រតិបត្តិការ។

| សកម្មភាពដែលបានណែនាំ | ភាគីពាក់ព័ន្ធដែលចូលរួម |
|---|---|
| ទំនាក់ទំនងជាប្រចាំជាមួយអ្នកគ្រប់គ្រងផ្សារនិងអ្នកអនាម័យផ្សារ ដោយចាប់ផ្តើមឡើងនៅផ្សារ ភូពុយ | អ្នកគ្រប់គ្រងផ្សារនិងអ្នកអនាម័យផ្សារ |
| ពិពិធកម្មការប្រមូលតាមផ្សារទៅផ្សារទាំងបួនផ្សេងទៀត ផ្សារដំបូងអាចជាផ្សារណាត់និងផ្សារបឹងឈូក ហើយបន្តទៅផ្សារផ្សេងទៀត | សាលាក្រុង<br>អ្នកគ្រប់គ្រងផ្សារ |
| សាលាក្រុងបានចាត់តាំងក្រុមហ៊ុន លៀប លឹម ឲ្យយកមែកឈើដែលកាប់បានពីសេវាកម្មរបស់គាត់ទៅឲ្យខមភីដ ឲ្យបានច្រើនជាងមុន | សាលាក្រុង<br>ក្រុមហ៊ុន លៀប លឹម |
| ធ្វើការដេញថ្លៃ ឡានសម្រាប់ប្រមូលសំណល់សរីរាង្គដោយផ្ទាល់និងគិតកម្រៃបន្តិចបន្តួច (លុះត្រាតែក្រុមហ៊ុនបានបញ្ចុះតម្លៃឲ្យផ្សារលើសេវាកម្មប្រមូល) | ខមភីដ |

## អនុសាសន៍ទី ២៖ ធ្វើម៉ាកផលិតជីកំប៉ុស និងកំណត់យុទ្ធសាស្រ្តទីផ្សារ

តាមរយៈការសិក្សាទីផ្សារដែលធ្វើឡើងក្នុងគម្រោងនេះ បង្ហាញយ៉ាងច្បាស់ថាមានចំណាប់អារម្មណ៍លើផលិតផលជីកំប៉ុស តែអ្នកទិញចង់ឲ្យគុណភាពត្រូវបានធ្វើទីផ្សារនិងប្រសិនបើអាច ការទិញស្ថិតក្នុងបរិមាណដែលច្រើន។

វាអាចមានសារៈសំខាន់ផងដែរថាក្នុងការសិក្សាទីផ្សារជីកំប៉ុសឲ្យបានស៊ីជម្រៅដើម្បីធ្វើទីផ្សារផលិតផលបានច្បាស់លាស់។ វាអាចរួមបញ្ចូលការធ្វើការវិភាគ ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង នៃការប្រកួតប្រជែងជាមួយផលិតផលផ្សេងទៀត ដូចជា ជីកំប៉ុសដែលផលិតពីលាមកសត្វ ជីគីមី ជីកំប៉ុសជន្លេនជាដើម។ នេះអាចជួយក្នុងការកំណត់ទំហំវិនិយោគលើកន្លែងកែច្នៃនាពេលអនាគត។

ទោះបីជាយ៉ាងនេះក៏ដោយខមភីដ គួរបង្កើតការវេចខ្ចប់ដែលទាក់ទាញ និង ធ្វើម៉ាកផលិតផលដោយមានព័ត៌មានគុណភាព ដើម្បីធ្វើឲ្យអតិថិជនមានទំនុកចិត្ត។ វាក៏មានសារៈសំខាន់ផងដែរក្នុងការបង្កើតខិត្តបណ្ណដើម្បីប្រៀបធៀបកំប៉ុសរបស់គាត់នឹងជីដែលមានលក់លើទីផ្សារទូទៅ ឬកំណត់សម្ភារៈទីផ្សារផ្សេងទៀតដែលមានភាពទាក់ទាញ។ ឧទាហរណ៍ ខមភីដ បង្កើតការធ្វើតេស្តនៅខាងក្រៅសម្រាប់ជីកំប៉ុសរបស់គាត់ និងផ្តល់វគ្គបណ្តុះបណ្តាលលើវិធីនៃការប្រើប្រាស់និងហេតុអ្វីត្រូវប្រើប្រាស់ជីកំប៉ុស។

| សកម្មភាពដែលបានណែនាំ | ភាគីពាក់ព័ន្ធដែលចូលរួម |
|---|---|
| ធ្វើការសិក្សាទីផ្សារកំប៉ុសស៊ីជម្រៅ | ជំនួយការបច្ចេកទេស |
| បង្កើតការវេចខ្ចប់និងម៉ាកកំប៉ុស ដោយមានផ្លាកសញ្ញានិងព័ត៌មានអំពីគុណភាពកំប៉ុស(NPK) | AMK, AIMS |
| បង្កើតខិតបណ្ណដោយប្រៀបធៀបផលប្រយោជន៍នៃជីកំប៉ុសនិងជីប្រភេទផ្សេងទៀត | COMPED |
| ធ្វើតេស្តផលិតផលជាប្រចាំដើម្បីបង្ហាញពីប្រសិទ្ធភាព និងធ្វើការទំនាក់ទំនងជាមួយដៃគូដែលមានសក្តានុពលផ្សេងទៀត (ដូចជាកាវ៉ាក់ (CAVAC) និងគម្រោងកសិកម្មហ្គ្រេថ (Gret) នៅខេត្តសៀមរាប) | មន្ទីរពិសោធន៍ឯករាជ្យ |
| ទំនាក់ទំនងជាមួយមីក្រូហិរញ្ញវត្ថុអេអឹមខេ (AMK) ដើម្បីអាចធ្វើការផុសផលិតផលជីកំប៉ុសក្នុងកម្មវិធីទន្លេសាប ដែលជាការធ្វើទីផ្សារឌីជីថលដើម្បីមានទំនាក់ទំនងជាមួយកសិករ។ | COMPED |
| ចូលរួមជាមួយគម្រោងអេអាយអឹមអែស (AIMS) ដើម្បីបានជួបកសិករក្នុងខេត្តបាត់ដំបងតាមរយៈព្រឹត្តិការណ៍ផ្សេងៗ ដើម្បីអាចផ្សព្វផ្សាយពីការប្រើប្រាស់ជីកំប៉ុស | COMPED |

## អនុសាសន៍ទី ៣៖ ពិពិធកម្មផលិតផល

មានលទ្ធភាពច្រើនដើម្បីធ្វើពិពិធកម្មផលិតផល ឬសេវាកម្មដើម្បីបង្កើនចំណូល ឬភាពទាក់ទាញ។ មធ្យោបាយមួយនោះគឺការចាប់ផ្តើមសេវាកម្មប្រមូលសំណល់រឹងនិងធ្វើប្រព្រឹត្តិកម្ម។ ដោយសារវាជាបំណងរបស់ខមភីដ (COMPED) ក្នុងការទទួលបានសំណល់រឹងស្អាត ការផ្ទេរការគ្រប់គ្រងសំណល់រឹងផ្សារទៅខមភីដនឹងទទួលបានផលប្រយោជន៍ច្រើន។ នេះតម្រូវឲ្យមានឡានសម្រាប់ប្រមូលសំណល់និងអាចជាប្រភពប្រាក់ចំណូលបន្ថែមជាពិសេសជាងគេនោះគឺអាចធ្វើឲ្យស្ថានភាពអាជីវកម្មមានភាពប្រសើរឡើង។ តែបើទោះបីជាយ៉ាងនេះក៏ដោយ ដូចជាមិនចាំបាច់ធ្វើបែបនេះនោះទេ នៅពេលដែលទីលានថ្មីត្រូវបានបើនៅទីតាំងដែលឆ្ងាយ ព្រោះវានឹងក្លាយទៅជាចំណាប់អារម្មណ៍របស់ក្រុមហ៊ុនស៊ីន ទ្រីក្នុងការប្រមូលសំណល់ជាច់ដោយឡែកសម្រាប់ខមភីដ

ដោយសារតែវាអាចជួយកាត់បន្ថយការចំណាយ។ ទោះជាយ៉ាងនេះក្ដី វាអាចវាអាចបង្កឲ្យមានការប្រកួតប្រជែងរវាងសេវាកម្មរបស់ខមភីដ និង សេវាកម្មរបស់ក្រុមហ៊ុន ស៊ីន ទ្រី។

ដោយផ្អែកលើភាពជាក់លាក់នៃតម្រូវការ យើងគួរពិចារណាលើចំណុចខាងក្រោម៖

- ការធ្វើកំប៉ុសជន្លេន
  - តម្រូវឲ្យមានការកែសម្រួលមជ្ឈមណ្ឌលកែច្នៃជីកំប៉ុសបច្ចុប្បន្ន
  - ជីកំប៉ុសជន្លេនមានគុណភាពខ្ពស់ជាង និងភាពទាក់ទាញនៃផលិតផលប្រភេទនេះអាចខ្លាំងជាង =អាចបន្ថែមតម្លៃជាងមុន +ចំណូលបន្ថែមពីការលក់ជន្លេន(ជាអាហារសម្រាប់កសិដ្ឋានចិញ្ចឹមត្រីឬបង្កង) http://earthwormvietnam.com/
- ជីកំប៉ុសលាយជាមួយជីគីមី
  - អាចមានផលប៉ះពាល់រយៈពេលខ្លី និងរយៈពេលវែង (តែអាចប្រើប្រាស់បាន ឬទេសម្រាប់អាហារសរីរាង្គនៃកសិអាជីវកម្ម?)
  - អាចបង្កើនតម្លៃបន្ថែម

| សកម្មភាពដែលបានណែនាំ | ភាគីពាក់ព័ន្ធដែលចូលរួម |
|---|---|
| ផ្ដល់សេវាកម្មប្រមូល ជាពិសេសតាមផ្សារ | ផ្សារ |
| ពិពិធកម្មផលិតផល៖ ជីកំប៉ុសជន្លេន ជីកំប៉ុសលាយជាមួយជីគីមី ជាដើម។ល។ | COMPED |
| **កម្មវិធីអេផផទន្លេសាប** (Tonle Sap App) ត្រូវបានបង្កើតឡើងដោយមីក្រូហិរញ្ញវត្ថុអេអឹមខេ (AMK) ក្រោមកិច្ចសហការជាមួយម្ចាស់ជំនួយមួយចំនួននិងបានដាក់ឲ្យដំណើរការនៅដើមឆ្នាំ ២០១៩។ វាជាបណ្ដាញឌីជីថលមួយដែលអាចធ្វើការទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងកសិករ រួមមានព័ត៌មានដូចជា៖<br><br>- ធាតុផ្សំកសិកម្មដូចជាជី ថ្នាំសំលាប់សត្វល្អិត ជំរប្លាស្ទិកឧបករណ៍ដំណាក់ទឹកនិងវត្ថុផ្សេងៗទៀត<br>- លក់រាយ និង លក់ដុំ ធាតុផ្សំកសិកម្ម<br>- ជំនាញសម្រាប់ដោះស្រាយបញ្ហាកសិកម្ម<br>- កម្ចីសម្រាប់ធ្វើដើមទុន និង វិនិយោគ<br>- បច្ចុប្បន្នភាពព័ត៌មានទាក់ទងនឹងកសិកម្ម<br><br>ទំនាក់ទនង៖ លោកស្រី គឹម ដាវីន<br>អ៊ីម៉ែល: davin.kim@amkcambodia.com | **អេអាយអឹមអេស** (AIMS) **“គម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច”** គឺជាគម្រោងរយៈពេល៦ឆ្នាំ ក្រោយ ក្រោមការផ្តល់ហិរញ្ញប្បទានពីមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍន៍កសិកម្ម (IFAD) និងអនុវត្តដោយក្រសួងពាណិជ្ជកម្ម ដើម្បីលើកកម្ពស់វិបុលភាពរបស់កសិករខ្នាតតូចនៅកម្ពុជា តាមរយៈកំណើននៃចំណេញដោយផ្សារភ្ជាប់កសិអាជីវកម្មទៅនឹងទីផ្សារកសិកម្ម រហូតដល់ឆ្នាំ២០២៣។ ខេត្តបាត់ដំបងគឺជាខេត្តមួយក៏ជាខេត្តដែលអនុវត្តគម្រោងនេះផងដែរ។<br><br>ទំនាក់ទនង៖ លោក គឹម ហួត<br>ប្រធានគម្រោងប្រចាំខេត្តបាត់ដំបង<br>អ៊ីម៉ែល៖ huort៧៧@yahoo.com |

## អនុសាសន៍ទី ៤៖ ពង្រីកទំហំមជ្ឈមណ្ឌលកែច្នៃជីកំប៉ុស

ដូចបានពិភាក្សានៅផ្នែកមុន ប្រសិនបើមានការញែកសំណល់បានត្រឹមត្រូវ សមត្ថភាពក្នុងការកែច្នៃជីកំប៉ុសរបស់មជ្ឈមណ្ឌលរបស់ខមភីដ នឹងដល់ចំណុចកំណត់យោងតាមផ្ទៃក្រឡាដែលគ្របដណ្ដប់នាពេលបច្ចុប្បន្ន។ យ៉ាងហោចណាស់ មជ្ឈមណ្ឌលគួរត្រូវពង្រីកទំហំទ្វេដង ក្នុងរយៈពេល ១ឆ្នាំ ឬ២ឆ្នាំ ខាងមុខ

(រហូតដល់ទំហំ១២០០ម៉ែត្រការ៉េ)ដើម្បីអាចទទួលសំណល់រឹងបាន ២០ទៅ២៤តោនក្នុងមួយថ្ងៃ ដែលអាចបម្លែងសំណល់រឹងសរីរាង្គប្រមាណ ២៥%និងមួយភាគ៦នៃសំណល់រឹងក្នុងក្រុងបាត់ដំបង។ វាអាចមានលទ្ធភាពក្នុងការពង្រីកលើទីតាំងបច្ចុប្បន្ន ប្រសិនបើមានការធ្វើផែនការច្បាស់លាស់ ដោយសារវាមានទំហំផ្ទៃដីសរុបប្រមាណ ១ហិចតា។ ក្នុងរយៈពេលវែង គេផ្តល់អនុសាសន៍ថា វាពិតជាចាំបាច់ក្នុងការពង្រីកកន្លែងផលិតជីខមភីដឲ្យបានផ្ទៃក្រឡាយ៉ាងហោចណាស់ ២៥០០ម៉ែត្រការ៉េ ដើម្បីកែច្នៃសំណល់រឹង ពី៤០ទៅ៥០តោនក្នុងមួយថ្ងៃ នេះអនុញ្ញាតក្នុងការបំប្លែងសំណល់រឹងប្រមាណ៤០%នៃសំណល់រឹងទាំងអស់ក្នុងសាលាក្រុង និង ប្រហែលជាអាចពង្រីកលើសនេះទៀតនាពេលអនាគត។ ទាំងយូនីដូ ទាំងសាលាក្រុង គួរស្វែងរកដីជាជំនួយឧបត្ថម្ភក្នុងរយៈពេលវែង។

ជាចំណុចពិសេស តំបន់ដែលមានពណ៌ក្រហមនៃមជ្ឈមណ្ឌលខមភីដ ក្នុងរូបភាពទី ៣១ អាចប្រើប្រាស់បានសម្រាប់ការពង្រីក។ គេផ្តល់អនុសាសន៍ថា យូនីដូ ឬក៏ម្ចាស់ជំនួយផ្សេងទៀតគួរផ្តល់ជំនួយបន្ថែមក្នុងការពង្រីកទៅតំបន់នេះផងដែរ។ បើទោះបីជាយ៉ាងនេះក៏ដោយ ការពង្រីកសមត្ថភាពផលិតគួរត្រូវបានពិចារណាលុះត្រាណាមានការ បញ្ជាក់ថាមានលទ្ធភាពក្នុងការលក់ជីកំប៉ុសដែលបានផលិតក្នុងតម្លៃសមរម្យ។

រូបភាពទី ៣១៖ ទិដ្ឋភាពទូទៅនកន្លែងផលិតជីកំប៉ុសខមភីដ COMPED និង មជ្ឈមណ្ឌលញែកសំរាម MRF (ប្រភព: រូបភាពពី Google)



| សកម្មភាពដែលបានណែនាំ | ភាគីពាក់ព័ន្ធដែលចូលរួម |
|---|---|
| ពង្រីកទ្វេដងកន្លែងធ្វើជីកំប៉ុសក្នុងឆ្នាំ បន្ទាប់ឲ្យបានទំហំ ១២០០ ម៉ែត្រការ៉េ (មិនមានតម្រូវការដីបន្ថែម ប្រសិនបើមានការធ្វើផែនការច្បាស់លាស់) | ជំនួយការបច្ចេកទេស និង COMPED |
| ពង្រីកកន្លែងកែច្នៃជីកំប៉ុសឲ្យបានទំហំ ២៥០០ម៉ែត្រការ៉េ ក្នុងរយៈពេលមធ្យម និងរយៈពេលវែង (៣ទៅ៥ឆ្នាំ ខាងមុខ) | សាលាក្រុង COMPED និង ជំនួយការបច្ចេកទេស |

## អនុសាសន៍ទី ៥៖ សិក្សាសមិទ្ធិលទ្ធភាពក្នុងការចុះឈ្មោះ និងទទួលបានផលប្រយោជន៍ពីទីផ្សារកាបូន

ប្រភពចំណូលមួយទៀតដែលមានសក្តានុពលសម្រាប់មជ្ឈមណ្ឌលកែច្នៃជីកំប៉ុសគឺទីផ្សារកាបូន។ ការធ្វើជីកំប៉ុសអាចបង្ការការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ហេតុដូចនេះមជ្ឈមណ្ឌលកែច្នៃជីកំប៉ុសជាច្រើនអាចមានសិទ្ធិទទួលបានផលចំណេញពីទីផ្សារកាបូន។

ការបំបែកសមាសជាតុសរីរាង្គពីសំណល់រឹងតាមផ្ទះដោយមិនមានត្រួតពិនិត្យច្បាស់លាស់ បង្កើតមេតាន (ដែលជាឧស្ម័នផ្ទះកញ្ចក់ដែលមានឥទ្ធិពល២១ដងខ្លាំងជាងឧស្ម័នកាបូនិច)។ ការធ្វើជីកំប៉ុសពីសំណល់តាមផ្ទះ អាចកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់យ៉ាងច្រើន ដែលអាចឲ្យមជ្ឈមណ្ឌលកែច្នៃជីកំប៉ុសអាចទទួលបានផលប្រយោជន៍ពីទីផ្សារកាបូន (លក់ដោយស្ម័គ្រចិត្តនៅលើទីផ្សារ)។ ការទទួលបានផលប្រយោជន៍ពីទីផ្សារកាបូនតម្រូវឲ្យមានការចុះឈ្មោះលើបណ្តាញឯកទេសមួយ និងមានវិញ្ញាបនបត្រដែលមានភាពស្មុគស្មាញ និងមានតម្លៃថ្លៃ។ អ្នកកាន់គម្រោងត្រូវតែអាចបង្ហាញថា កន្លែងរបស់គាត់អាចកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ បើប្រៀបធៀបទៅនឹងស្ថានភាពដែលគ្មានកន្លែងនោះ។ ឯកសារនេះជាធម្មតាចាំបាច់ត្រូវមានការអនុម័តដោយអង្គភាពឯករាជ ដែលបន្ទាប់មកអនុញ្ញាតឱ្យគម្រោងនេះត្រូវបានចុះឈ្មោះនៅលើទីផ្សារថាជាអ្នកលក់កាបូន។ ការតាមដានត្រូវតែបានបង្កើតឡើងដោយគម្រោងដើម្បីកំណត់បរិមាណឧស្ម័នផ្ទះកញ្ចក់ដែលត្រូវជៀសវាង ហើយរបាយការណ៍តាមដានត្រូវតែត្រូវបានផ្ទៀងផ្ទាត់ដោយអង្គភាពឯករាជ។

ជាឧទាហរណ៍ ហ្គាវ៉ាល័រ (Gavalor) (អង្គការក្រៅរដ្ឋាភិបាលដែលបានចូលរួមជាមួយហ្គ្រេថ (Gret) នៅក្នុងឆ្នាំ២០១៨) បានប៉ាន់ស្មានថា នៅសាលាក្រុង មហាជង្គៈ (Mahajanga) ប្រទេស ម៉ាដាហ្គាស្ការ៍ (Madagascar) មជ្ឈមណ្ឌលធ្វើជីកំប៉ុសពីសំណល់សរីរាង្គបាន ១០០០ តោនក្នុងមួយឆ្នាំ អាចបញ្ចៀសការបញ្ចេញឧស្ម័នកាបូនិចស្មើនឹង ១៥,៩៥៤ តោនក្នុងរយៈពេល១០ឆ្នាំ។ ជាមួយនឹងតម្លៃ ២០ដុល្លារ/តោន នៃសមមូលឧស្ម័នកាបូនិច មជ្ឈមណ្ឌលធ្វើជីកំប៉ុសរំពឹងថានឹងអាចទទួលបានប្រាក់ចំណូលប្រមាណ ៣២០.០០០ ដុល្លារ ក្នុងកំឡុងពេល ១០ឆ្នាំ នេះ។

| សកម្មភាពដែលបានណែនាំ | ភាគីពាក់ព័ន្ធដែលចូលរួម |
|---|---|
| ទីផ្សារកាបូន | COMPED |

### ៤.១.៣. ការសន្និដ្ឋាន

ការសិក្សាបង្ហាញយ៉ាងច្បាស់ថា ការធ្វើឲ្យប្រសើរឡើងការញែកសំណល់រឹង ក្នុងក្រុងបាត់ដំបង ដោយផ្តោតសំខាន់លើការស្តារឡើងវិញសំណល់សរីរាង្គ និងជាពិសេសសំណល់សរីរាង្គដែលសំបូរទៅដោយសារជាតុកាបូន អាចជួយធ្វើឲ្យករណីអាជីវកម្មរបស់អង្គការខមភីដ (COMPED) មានភាពប្រសើរឡើងយ៉ាងខ្លាំង។ ដោយមិនមានការញែកសំណល់រឹង មជ្ឈមណ្ឌលត្រូវការថវិកាឧបត្ថម្ភយ៉ាងច្រើន។ ក្នុងការសិក្សានេះ មានការផ្តល់អនុសាសន៍ថា អ្នកដែលធ្វើការក្នុងការគ្រប់គ្រងសំណល់រឹងទាំងអស់ត្រូវចូលរួមក្នុងសកម្មភាពដែលបានលើកឡើងដើម្បីធ្វើឲ្យសកម្មភាពគ្រប់គ្រងសំណល់រឹងមានភាពប្រសើរឡើងក្នុងក្រុងបាត់ដំបងដូចដែលបានលើកឡើងក្នុងផ្នែកមុននៃរបាយការណ៍នេះ។ ក្រៅពីនេះ ជំនួយការបច្ចេកទេសនឹងត្រូវផ្តល់ជូនដើម្បីធានាថាសកម្មភាពទាំងអស់នឹងត្រូវបានអនុវត្តដោយហ្មត់ចត់។

ជាមួយនឹងការកែលម្អការធ្វើទីផ្សារ ការត្រួតពិនិត្យគុណភាព (ការធ្វើតេស្ត) និងកំណើនក្នុងការផលិត ទំនងមានស្ថានភាពវិជ្ជមានសម្រាប់ការលក់ជីកំប៉ុស។ ការសិក្សាស៊ីជម្រៅ ត្រូវបានផ្តល់អនុសាសន៍ដើម្បីវិភាគទីផ្សារសម្រាប់ប្រភេទផលិតផលផ្សេងៗនាពេលខាងមុខ។ ចំណុចខ្លះនឹងត្រូវបានសិក្សាដោយគម្រោងពាក់ព័ន្ធផ្សេងទៀត នាពេលអនាគត។ លើសពីនេះទៅទៀត គេផ្តល់អនុសាសន៍ដោយសង្កត់ធ្ងន់ថា ទំហំកន្លែងកែច្នៃជីកំប៉ុសនៅមជ្ឈមណ្ឌល ត្រូវតែពង្រីកឲ្យបានទំហំ ១២០០ម៉ែត្រការ៉េក្នុងរយៈពេលខ្លីខាងមុខនេះ ដើម្បីសម្របសម្រួលសមត្ថភាពក្នុងការផលិតបរិមាណជីកំប៉ុសឲ្យបានច្រើនជាងមុន និង ប្រសិនបើអាចខំភីដ (COMPED) ត្រូវទទួលការចុះឈ្មោះក្នុងការទទួលបានអត្ថប្រយោជន៍ពីកម្មវិធីទីផ្សារកាបូន។

## ៤.២. សហគ្រាសប្លាស្ទិកបាត់ដំបង[៤២]

### ៤.២.១. ការវិភាគទីផ្សារ

ការផលិតផលិតផលប្លាស្ទិកនៅក្នុងប្រទេសកម្ពុជាមានកម្រិតតិចតួចណាស់ ដោយផលិតផលប្លាស្ទិកភាគច្រើន (អាចកែច្នៃឡើងវិញបាន និងគ្រាប់ប្លាស្ទិក) ត្រូវបាននាំចេញទៅប្រទេសវៀតណាម និងថៃ និងប្រទេសមួយចំនួនទៀត។

សម្រាប់អ្នកដែលកំពុងកែច្នៃនៅកម្ពុជាបច្ចុប្បន្ននេះ (ដូចជាក្រុមហ៊ុនជប៉ុន ហ្គោមី រីសាយខ្លីង ១១០ Gomi Recycling ១១០) មានតម្រូវការប្រភពផលិតផលដែលមានគុណភាពខ្ពស់ (គ្រាប់ប្លាស្ទិក)។

ភ្នំពេញមានទីតាំងស្ថិតនៅឆ្ងាយជាងនៅថៃបន្តិចចំពោះទីផ្សារ ប៉ុន្តែអាចផ្តល់ឱកាសបន្ថែមទៀត។ តារាងទី ២៦ មានរាយបញ្ជីពេងចក្រមួយចំនួន ដែលបានចាប់អារម្មណ៍ក្នុងការទិញគ្រាប់ប្លាស្ទិកកែច្នៃហើយដែលផលិតក្នុងស្រុក ប៉ុន្តែពួកគេនៅស្ទាក់ស្ទើរមិនដាក់ចិត្តថានឹងទិញទេ លុះណាតែបានពិនិត្យនូវសំណាកគ្រាប់ប្លាស្ទិកដើម្បីពិនិត្យគុណភាពជាមុនសិន។ លើសពីនេះទៅទៀត ទំនងជាមានអ្នកផលិតថង់ប្លាស្ទិក នៅបាត់ដំបង ប៉ុន្តែមិនមានគ្រាប់ប្លាស្ទិកដែលមានគុណភាពខ្ពស់ដាក់លក់នៅទីនោះទេ។ ទោះយ៉ាងណាព័ត៌មានសម្រាប់ទំនាក់ទំនងមិនត្រូវបានបង្ហាញទេ។ គួរឱ្យសោកស្តាយដែលគ្មានរូបភាពច្បាស់បង្ហាញពីគុណភាពចុងក្រោយរបស់ផលិតផល ដូចនេះការវិភាគទីផ្សារកាន់តែពិបាកបញ្ជាក់។ ខាងក្រោមនេះជាបញ្ជីអ្នកទិញដែលបង្ហាញការចាប់អារម្មណ៍ ប្រសិនបើផលិតផលបំពេញតាមស្តង់ដារដែលគេចង់បាន ដូច្នេះ សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង គួរតែផ្តល់ធ្វើទីផ្សារដល់ពួកគេជាមុន បន្ទាប់ពីចាប់ផ្តើមប្រតិបត្តិការជាមួយការដំឡើងសមត្ថភាពដែលផ្តល់ដោយយូនីដូ។

តារាងទី ១៥៖ បញ្ជីទីផ្សារដែលមានសក្តានុពលក្នុងរាជធានីភ្នំពេញសម្រាប់សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង

| ល.រ | ក្រុមហ៊ុន | អាសយដ្ឋាន | ទំនាក់ទំនង | អ្នកផ្គត់ផ្គង់បច្ចុប្បន្ន |
|---|---|---|---|---|
| ១ | VSY Plastic factory | មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា រាជធានីភ្នំពេញ | ០៧០ ៦៦៩ ៤៦៤,០៩៥ ៦៦៥ ៤៦៤ | ប្រទេសចិន និងថៃ |
| ២ | Modern Plastic & Packaging (Cambodia) Co., Ltd. | ផ្លូវលេខ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ | ០២៣ ៤២៥ ២៣៥, ០២៣ ៤២៥ ២៣៥ | ប្រទេសថៃ |
| ៣ | UST Crafts | ផ្លូវលំ ភូមិព្រៃកតាពៅ សង្កាត់តាមប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ | ០៩៧ ៩៧ ០៧ ៥៧៣, ០១១ ៧៤ ៧០ ៧១ | ប្រទេសចិន |
| ៤ | SHPP | ផ្ទះលេខ ៣២៩ ផ្លូវលេខ ២៤៥ មហាវិថីម៉ៅសេទុង សង្កាត់ផ្សារដេប៉ូ១ រាជធានីភ្នំពេញ | ០៧៨ ៧៨៦ ៦៦៧ | វៀតណាម |

ហានិភ័យធំបំផុតចំពោះទីផ្សារ គឺការអនុវត្តអនុក្រឹត្យស្ដីពីថង់ប្លាស្ទិក ដែលនឹងជះឥទ្ធិពលយ៉ាងខ្លាំងដល់សកម្មភាពរបស់សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង។ ទោះយ៉ាងណាការកែសម្រួលទាក់ទងនឹងការរឹតត្បិតការទិញឥវ៉ាន់នៅក្នុងប្រទេសថៃ (ដូចជាការហាមឃាត់ការនាំចូលកាកសំណល់ប្លាស្ទិក ដែលក៏ដូចទៅនឹងករណីរបស់ប្រទេសចិន និងវៀតណាម) នឹងផ្ដល់ផលប្រយោជន៍ដល់ក្រុមហ៊ុន ហើយអាចទាក់ទងដល់កែសម្រួលមួយដែលផ្ទុយទៅនឹងការអនុវត្តច្បាប់នៅកម្ពុជា។ ដូច្នេះការគាំទ្រគួរតែត្រូវបានផ្ដល់ដល់ក្រុមហ៊ុននេះ ដើម្បីធ្វើពិពិធកម្មផលិតកម្មរបស់ខ្លួនទៅជាផលិតផល អិលឌីភីអ៊ី (LDPE) ឬអេចឌីភីអ៊ី (HDPE) ជាដើម។ លើសពីនេះទៀតការប្រែប្រួលបែបនេះ មានន័យថាស្ដង់អេតចាយនឹងត្រូវធ្វើសកម្មភាពមុនកែច្នៃខ្លះលើទំនិញរបស់ពួកគេជាមុន ប្រសិនបើពួកគេចង់បន្តលក់វាទៅឱ្យប្រទេសថៃ ឬប្រទេសក្រៅផ្សេងទៀត ដែលធ្វើឱ្យសិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង ក្លាយជាអតិថិជនដែលគេចង់បាន។ នេះក៏បង្កើតឱកាសសម្រាប់ទីផ្សារផលិតកម្មកម្ពុជាដើម្បីកែច្នៃឡើងវិញនៅក្នុងរង្វង់ប្រទេស។

### ៤.២.២. អនុសាសន៍

ការកែលម្អល្អបំផុតមួយដែលអាចធ្វើទៅបានសម្រាប់សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង គឺជំរុញការកែច្នៃថង់ប្លាស្ទិកនៅក្នុងក្រុង។ អ្នករើសអេតចាយ និងប្រជាជនភាគច្រើននៅទីក្រុង មិនដឹងថាសំរាមថង់ប្លាស្ទិកមានតម្លៃទីផ្សារទេ ហើយម្ចាស់សំរាមជាច្រើនទៀតក៏មិនដឹងអំពីរឿងនេះដែរ។ ខណៈពេលដែលវាអាចជាបញ្ហាប្រឈមក្នុងការប្រមូល និងរក្សាទុកថង់ប្លាស្ទិក បើធៀបទៅនឹងអត្រាចំណូលដែលទទួលបានពីសំណល់ប្លាស្ទិកប្រភេទនេះ ការលើកកម្ពស់ការផ្សព្វផ្សាយពីទីតាំងនេះ នឹងបង្កើនការយល់ដឹង ហើយក៏ទំនងជាបង្កើនសមត្ថភាពរបស់សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបងក្នុងការប្រមូលសម្ភារៈក្នុងស្រុកដែរ។ លើសពីនេះ ការអប់រំអំពីការទិញនូវសំរាមស្អាតក្នុងតម្លៃខ្ពស់ អាចបង្កើនការទាញយកធនធាន។

ឧបករណ៍សំខាន់ពីរសម្រាប់លើកកម្ពស់អាជីវកម្ម គឺអាចជាការទទួលបានវិញ្ញាបនបត្រពីក្រសួងទាំង ២។ ទីមួយនោះ គឺតាមរយៈមន្ទីរបរិស្ថានខេត្តដែលមានសិទ្ធិក្នុងការចេញវិញ្ញាបនបត្រដល់អង្គភាពដែលមិនប៉ះពាល់ដល់បរិស្ថាន។ ការសន្ទនារវាងភាគីទាំងពីរគួរតែធ្វើឱ្យប្រសើរឡើង ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការកែច្នៃប្លាស្ទិកនៅក្រុងបាត់ដំបង ក៏ដូចជាការកសាងសមត្ថភាពទាំងមន្ទីរបរិស្ថានខេត្ត និងសិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង ដើម្បីលើកកម្ពស់ការគ្រប់គ្រងផ្នែកសុខភាព និងអនាម័យក្នុងការកែច្នៃនេះ។ ជម្រើសមួយក្នុងការជួយក្នុងរឿងនេះ គឺការបណ្ដុះបណ្ដាលពីបញ្ហាសុខភាព និងអនាម័យ (ដូចដែលនឹងត្រូវផ្ដល់ជូនអេតចាយ) ដល់បុគ្គលិករបស់សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង។

លើសពីនេះទៀតក្រសួងឧស្សាហកម្ម និងសិប្បកម្ម (MIH) ដែលត្រួតពិនិត្យលើប្រតិបត្តិការ និងវិញ្ញាបនបត្រ ជាអ្នកផ្ដល់វិញ្ញាបនបត្រប្រតិបត្តិការសម្រាប់ស្ដការបំពេញតាមស្ដង់ដារ។ ស្ដង់ដារទាំងនេះ គឺភាពច្បាស់លាស់សម្រាប់ទីតាំងផលិតជាទូទៅ ដូចជារោងចក្រកាត់ដេរ ប៉ុន្តែប្រហែលជាមិនមានភាពច្បាស់លាស់សម្រាប់អង្គភាពមួយចំនួន ដូចជាសិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបងនោះទេ។ ទោះយ៉ាងណា សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបងគួរតែចូលរួមជាមួយក្រសួង ដើម្បីស្វែងយល់ពីជំហានដែលត្រូវធ្វើដើម្បីទទួលបានវិញ្ញាបនបត្រ។

[៩២] គំរូអាជីវកម្មហិរញ្ញត្រូវបានដកចេញ (រាប់បញ្ចូលក្នុងឧបសម្ព័ន្ធ) សម្រាប់ហេតុផលរក្សាការសម្ងាត់

| សកម្មភាពដែលបានណែនាំ | ការចូលរួមរបស់ភាគីពាក់ព័ន្ធ |
|---|---|
| ផ្សព្វផ្សាយពីតម្រូវការថង់ប្លាស្ទិកដល់ប្រជាជន និងអ្នករើសអេតចាយក្នុងក្រុងសម្រាប់កែច្នៃឡើងវិញ រួមមានរបៀបសម្អាតសម្ភារៈទាំងនោះ ជាពិសេសតម្លៃថង់ដែលស្អាត | សាលាក្រុង<br>សង្កាត់/ស្រុក<br>មន្ទីរបរិស្ថានខេត្ត |
| រៀបចំសិក្ខាសាលាដើម្បីលើកកម្ពស់ការកែច្នៃនៅខេត្តបាត់ដំបងជាមួយអាជ្ញាធរមូលដ្ឋានស្តង់អេតចាយ អ្នករើសអេតចាយ និងប្រតិបត្តិករពាក់ព័ន្ធនឹងវិស័យកែច្នៃ | សាលាក្រុង<br>មន្ទីរបរិស្ថានខេត្ត |
| ស្វែងរកការទទួលបាននូវញ្ញាបនបត្រការអនុវត្តបរិស្ថានពីមន្ទីរបរិស្ថានខេត្ត | មន្ទីរបរិស្ថានខេត្ត<br>សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង |
| បណ្តុះបណ្តាលបុគ្គលិកឱ្យប្រតិបត្តិការអនុវត្តអនាម័យល្អនៅកន្លែងធ្វើការ | សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង |

## អនុសាសន៍ទី ២៖ ការទិញប្លាស្ទិកពីស្តង់អេតចាយ

វិធីមួយ ដើម្បីធ្វើឱ្យប្រសើរឡើងនូវទីផ្សាររបស់សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង គឺត្រូវចូលរួម និងទិញសំរាមស្អាតដោយផ្ទាល់ពីស្តង់អេតចាយ ចៀសជាងប្រជែងទិញពីអេតចាយជាមួយពួកគេ។ ខណៈពេលដែលសំណល់ប្លាស្ទិកពីទីលានចាក់សំរាមមានតម្លៃថោក វាកាន់តែតែគ្រិចជាដែរ ដូច្នេះវាត្រូវការពេលវេលា និងថវិកាកាន់តែច្រើនដើម្បីញែក និងលាងសម្អាត នាំឱ្យចំណាយថវិកាដដែល។ ថ្លៃសមាមាត្រនៃសំរាមដុល ស្អាត និងបានញែក ហើយមានតម្លៃទាបជាង។ សំណល់ប្លាស្ទិកពីស្តង់អេតចាយមានតម្លៃថ្លៃជាងមែន តែត្រូវបានញែក និងស្អាត ដែលធ្វើឱ្យតម្លៃកើនឡើងពី ២០០ ទៅ ៥០០ រៀល/គីឡូក្រាម ប៉ុន្តែបានជួយកាត់បន្ថយថ្លៃដើម ហើយជាមួយនឹងការដំឡើងសមត្ថភាពរបស់យូនីដូក្នុងការផលិតគ្រាប់ប្លាស្ទិកដែលមានគុណភាពខ្ពស់ ក៏ជួយឱ្យរកប្រាក់ចំណូលកាន់តែច្រើន ពីការលក់ផលិតក្នុងតម្លៃខ្ពស់វិញដែរ។

វាក៏នឹងផ្តល់នូវសំរាមដែលយកចូលមានសភាពស្អាតជាងមុន ដែលមិនត្រឹមតែជួយកាត់បន្ថយថ្លៃដើមរបស់ សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង ប៉ុន្តែក៏ជួយបន្ថយចំណាយលើឈ្មួញកណ្តាលដែរ។ ដោយសារតែកង្វះចំណេះដឹង និងធន្ទះរបស់ស្តង់អេតចាយ ក្នុងការចែករំលែកព័ត៌មានដល់ភាគីពាក់ព័ន្ធ គេបានណែនាំឱ្យធ្វើឱ្យកែលម្អវិញនូវទំនាក់ទំនងរវាងសិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង និងស្តង់អេតចាយ ដោយចាត់ទុកសិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបងជាអង្គភាពមួយដែលផ្តល់នូវគុណតម្លៃបន្ថែម ដោយកាត់បន្ថយតម្រូវការឈ្មួញកណ្តាល ក្នុងកំឡុងពេលលក់ទៅឱ្យអង្គភាពក្នុងស្រុក ឬទៅក្រៅប្រទេស។

| សកម្មភាពដែលបានណែនាំ | ការចូលរួមរបស់ភាគីពាក់ព័ន្ធ |
|---|---|
| សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង ធ្វើការទាក់ទង និងលើកទឹកចិត្តដល់ស្តង់អេតចាយឱ្យលក់ថង់ប្លាស្ទិកមកខ្លួនដោយបញ្ជូនឡានដឹកទំនិញទៅប្រមូលទិញថង់ប្លាស្ទិក | សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង ស្តង់អេតចាយ<br>អ្នករើសអេតចាយ |
| ធ្វើការជាមួយស្តង់អេតចាយដើម្បីរកប្រភពប្លាស្ទិកផ្សេងទៀតសម្រាប់កែច្នៃបន្ទាប់មកដាក់លក់ទៅប្រទេសថៃ | សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង |
| លើកសំណើសេវាកម្មដល់ស្តង់អេតចាយ ដើម្បីបង្កើនតម្លៃបន្ថែមក្នុងសកម្មភាពរបស់ពួកគេ (ការបង្រួម កាត់ ។ល។) | សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង |

## អនុសាសន៍ទី ៣៖ លក់ទៅឲ្យផលិតករក្នុងស្រុក

ដូចដែលបានរៀបរាប់នៅក្នុងផ្នែកវិភាគទីផ្សារ ការធ្វើដំឡើងសមត្ថភាពរបស់យូនីដូ នឹងអនុញ្ញាតឱ្យសិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង អាចលក់ទៅឱ្យក្រុមហ៊ុនផលិតក្នុងស្រុក។ នៅពេលណាផលិតផលិតផលថ្មីបាន សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង គួរតែទាក់ទងក្រុមហ៊ុនផលិត ហើយយកសំណាកគំរូទៅពួកគេ។ ពួកគេបានបញ្ជាក់យ៉ាងច្បាស់ថា ពួកគេចាប់អារម្មណ៍ចង់ទិញផលិតផលក្នុងស្រុកប៉ុន្តែទាមទារត្រូវដឹងឱ្យច្បាស់អំពីគុណភាពនៃផលិតផលដែលផ្តល់ដោយសិប្បកម្ម។ ការចំណាយលើការដឹកជញ្ជូនត្រូវតែគិតគូរ ព្រោះថាក្រុមហ៊ុនផលិតភាគច្រើនមានទីតាំងនៅភ្នំពេញ។ និយាយជារួម ដោយភាពស្រពិចស្រពិលនៃការនាំចេញប្លាស្ទិកនាពេលអនាគត ជាប្រយោជន៍ធំរបស់សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង ក្នុងការដែលបង្កើតទំនាក់ទំនងជាមួយក្រុមហ៊ុនផលិតយ៉ាងហោចណាស់មួយនៅក្នុងប្រទេសកម្ពុជា ក្នុងករណីមានការប្រែប្រួលជាសកលភ្លាមៗណាមួយកើតឡើង។

| សកម្មភាពដែលបានណែនាំ | ការចូលរួមរបស់ភាគីពាក់ព័ន្ធ |
|---|---|
| បញ្ជូនសំណាកគំរូទៅក្រុមហ៊ុនផលិតនានានៅប្រទេសកម្ពុជា (បន្ទាប់ពីការដំឡើងសមត្ថភាពរបស់យូនីដូ បានអនុវត្ត។ | សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង |
| បង្កើតទំនាក់ទំនងជាមួយអ្នកទិញយ៉ាងហោចណាស់ម្នាក់ក្នុងករណីមានការប្រែប្រួលភ្លាមៗក្នុងការនាំចេញប្លាស្ទិកទៅអន្តរជាតិ | សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង |

## អនុសាសន៍ទី ៤៖ គាំទ្រសិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង ដើម្បីអនុវត្តតាមបទដ្ឋានគតិយុត្តស្តីពីការកែច្នៃ និងការការពារបរិស្ថាន

ទន្ទឹមនឹងសិប្បកម្មនេះ ផ្តល់នូវសកម្មភាពកែច្នៃដ៏សំខាន់ វាក៏មានភាពចាំបាច់ត្រូវយកចិត្តទុកដាក់លើបរិមាណទឹកកខ្វក់ដ៏ច្រើនដែលបានបង្កើតដោយសិប្បកម្មនេះផងដែរ ដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាន។

| សកម្មភាពដែលបានណែនាំ | ការចូលរួមរបស់ភាគីពាក់ព័ន្ធ |
|---|---|
| ជួលទីប្រឹក្សាបច្ចេកទេស និងមន្ទីរពិសោធន៍ឯករាជ ដើម្បីធ្វើការសិក្សាវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និងសង្គម | សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង |
| អនុវត្តការអនុសាសន៍ណែនាំ ដើម្បីអនុវត្តតាមស្តង់ដារដែលមានស្រាប់ | សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង |

## អនុសាសន៍ទី ៥៖ ការសិក្សាសមិទ្ធិលទ្ធភាពដើម្បីធ្វើពិពិធកម្មផលិតកម្ម

ផ្អែកលើការសិក្សាសមិទ្ធិលទ្ធភាព សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង អាចពិចារណាក្នុងការធ្វើពិពិធកម្មផលិតកម្មរបស់ខ្លួនដោយផលិតប្លាស្ទិករឹង និង/ឬ កែច្នៃសំណល់ដែលមិនអាចកែច្នៃឡើងវិញបាន ដូចជាប្រអប់ស្នោជាដើម។ សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង អាចពិចារណាលើការអភិវឌ្ឍសកម្មភាពកែច្នៃសាកល្បងមួយចំនួន (ពីរ៉ូលីសក្នុងប្លាស្ទិក (pyrolysis of plastic), ផលិតកម្មអេសអ៊ែរអែហ្វ (production of SRF), ។ល។) ដើម្បីបង្កើនបរិមាណវត្ថុធាតុដើមដែលត្រូវបង្វែរទៅទីលានចាក់សំរាម។

### ៤.២.៣. សេចក្តីសន្និដ្ឋាន

មានការបញ្ជាក់ច្បាស់ណាស់ថា មានករណីអាជីវកម្មសម្រាប់សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង ដែលការផ្សព្វផ្សាយសេវាកម្មទាំងក្នុងស្រុក ដើម្បីធ្វើឱ្យប្រសើរឡើងនូវវត្ថុដែលប្រមូលចូល (ប្លាស្ទិកស្អាត) និងហើយការបង្កើនការធ្វើទីផ្សារផលិតផលរបស់សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបងនៅកម្ពុជា គឺពិតជាចាំបាច់។ រឿងនេះនឹងក្លាយជាការពិត ប្រសិនបើទីផ្សារអន្តរជាតិកាន់តែរឹតត្បិត ដែលជាការផ្តល់ឱកាសដល់ប្រទេសកម្ពុជា។ គម្រោងគ្រប់គ្រងសំណល់រឹងផ្សេងៗ គួរតែផ្តោតលើការកែច្នៃ និងការទាញយកយកធនធានពីសំណល់ប្លាស្ទិកនៅក្នុងប្រទេសដើម្បីបិទវដ្តនៃការកែច្នៃសំណល់។

## ៤.៣. មជ្ឈមណ្ឌលញែកសំរាម

ដោយសារវិស័យក្រៅផ្លូវការរស់រើកនៅក្នុងខេត្តបាត់ដំបង និងបរិមាណដ៏ច្រើននៃកាកសំណល់សរីរាង្គ មជ្ឈមណ្ឌលញែកសំណល់រឹងបានផ្តល់នូវតម្លៃបន្ថែមតិចតួចបំផុត ដល់ការទាញយកធនធានពីផលិតផលដែលអាចកែច្នៃបានដែលស្ងួត។ ទោះយ៉ាងណាក៏ដោយ មជ្ឈមណ្ឌលញែកសំណលដែលជាខ្សែសង្វាក់ញែកសំរាម អាចទាញយកធនធានពីវត្ថុធាតុដែលអាចកែច្នៃដែលមានតម្លៃទាប ហើយរួមចំណែកដល់ការបង្វែរបរិមាណវត្ថុធាតុចេញពីទីលានចាក់សំរាម។ ខាងក្រោមនេះ គឺជាការណែនាំសម្រាប់ការធ្វើឱ្យមុខងាររបស់មជ្ឈមណ្ឌលកាន់តែមានដំណើរការប្រសើរឡើង ក្នុងរយៈពេលវែង។

ដោយមិនគិតពីជម្រើសដែលបានទទួលនៅកន្លែងទាញយកធនធាន សកម្មភាពដំបូងគឺត្រូវបង្កើតកិច្ចព្រមព្រៀងផ្លូវការជាមួយអ្នកម៉ៅការបន្ត ដើម្បីដំណើរការកន្លែងទាញយកធនធាន។ បើគ្មានវាទេ នោះការអនុវត្តនឹងនៅទ្រឹង ហើយតួនាទី និងការទទួលខុសត្រូវក៏គ្មានភាពច្បាស់លាស់។ កិច្ចព្រមព្រៀងនេះគួរតែចង្អុលបង្ហាញយ៉ាងច្បាស់ថា អ្នកណាជាអ្នកមានភារៈនឹងដំណើរការទីតាំង និងពង្រាងអំពីផែនការសកម្មភាពលម្អិត។

### ៤.៣.១. ជម្រើសទី ១៖ ចាប់ផ្តើមប្រតិបត្តិការឱ្យបានឆាប់ៗ

អាស្រ័យតាមការរចនារបស់វា សមត្ថភាពរបស់មជ្ឈមណ្ឌលញែកសំរាម ត្រូវទទួលបានសំណល់ស្ងួតចំនួន ៨ តោនក្នុងមួយថ្ងៃ ដោយមានអ្នកញែកចំនួន ៨នាក់ ធ្វើការតាមកាលវិភាគការងារធម្មតា ៨ម៉ោង ក្នុងមួយសប្តាហ៍ ៦ថ្ងៃ។ ដូច្នេះនេះ តម្រូវឱ្យមានអ្នកញែកម្នាក់សម្រាប់មួយតោនក្នុងមួយថ្ងៃ។ មកដល់ពេលនេះ អេតចាយមិនចាប់អារម្មណ៍មកធ្វើការនៅកន្លែងនេះទេ ព្រោះពួកគេរកលុយបានច្រើនជាងពីការប្រមូលសំរាម។ ទោះយ៉ាងណាក៏ដោយ ជាមួយនឹងការអនុវត្តយុទ្ធនាការទីផ្សារ វាចាំបាច់ត្រូវមានកន្លែងដែលមានមុខងារសម្រាប់ញែកសំណល់មិនមែនសរីរាង្គ។

វាត្រូវបានគេផ្តល់យោបល់ឱ្យមានអ្នកញែកពីរនាក់ធ្វើការពេញម៉ោង ដោយផ្តល់ប្រាក់ខែមធ្យមប្រហាក់ប្រហែលនឹងប្រាក់ចំណូលប្រចាំខែជាមធ្យមរបស់អ្នករើសអេតចាយ។ នៅពេលបរិមាណសំណល់រឹងកើនឡើងពេលយុទ្ធនាការចាប់ផ្តើមនោះ ចំនួនបុគ្គលិកគួរតែកើនឡើងស្របតាមចំនួនសំណល់រឹង (កម្មករម្នាក់ក្នុងមួយតោនក្នុងមួយថ្ងៃ)។ នេះក៏អាចផ្តល់ឱកាសដល់អេតចាយនៅទីលានចាក់សំរាមមានការងារធ្វើ នៅពេលដែលទីលានចាក់សំរាមថ្មីដំណើរការ។ ដើម្បីសម្រួលដល់ការប្រែប្រួលនេះ ការបិទ និងការផ្លាស់ប្តូរទីតាំងទី លាណសំរាមត្រូវតែទាក់ទងទៅអេតចាយ។

ដោយសារ ៨០% នៃអ្នករើសអេតចាយគឺជាស្ត្រី ការជួលពួកគាត់ផ្តល់នូវឱកាសដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅសម្រាប់ស្ត្រីឱ្យបានកាន់តែប្រសើរ។

វាពិតជាពិបាកក្នុងការវាយតម្លៃយ៉ាងច្បាស់ ថាតើថវិកាប៉ុន្មានដែលអាចទាញយកពីកន្លែងទាញយកធនធាន ពីការប្រមូល និងលក់ទៅស្តង់អេតចាយ ពីព្រោះវាមិនច្បាស់ថាតើសំណល់រឹងដែលអាចកែច្នៃប៉ុន្មានមាននៅក្នុងធុងសំរាម។ ដោយមានការប្រែប្រួលនិងភាពមិនច្បាស់ច្រើន ដូច្នេះគេមិនអាចមានហេតុផលដើម្បីកំណត់ចំណុចប្រសព្វចំណាយ-ចំណេញបានទេ។ ទោះយ៉ាងណា វាជាយោបល់របស់ទីប្រឹក្សាបច្ចេកទេសដែលធ្វើការអរគុណដល់សកម្មភាពរបស់អ្នករើសអេតចាយក្នុងប្រតិបត្តិការនៅក្នុងទីក្រុងដែលនាំឱ្យមានតែវត្ថុធាតុអាចកែច្នៃដែលមានតម្លៃថោក ក្នុងចំនួនតិចតួចប៉ុណ្ណោះទៅដល់ទីលានចាក់សំរាម។ ហេតុដូច្នេះ ត្បិតថា

ការបង្វែរវត្ថុធាតុអាចកែច្នៃបានដែលមានតម្លៃទាប មុននឹងវាអាចទៅដល់ទីលានចាក់សំរាមបាន ជាអ្វីដែលយើងអាចធ្វើបាន តែវាហាក់ដូចជាមានភាពស្មុគស្មាញណាស់ (ឬមិនអាចទៅរួចទេ) ដើម្បីរក្សាលំនឹងថវិកាបេស់កន្លែងទាញយកធនធានតែជាមួយប្រាក់ចំណូលពីវត្ថុធាតុអាចកែច្នៃបាន ហើយទំនងជាប្រតិបត្តិការកន្លែងទាញយកធនធាន ត្រូវការការឧបត្ថម្ភធនក្នុងរយៈពេលវែងថែមទៀតផង។ ដើម្បីវិភាគឱ្យបានពេញលេញ ថាតើការងារនេះត្រូវការប្រាក់ឧបត្ថម្ភធនចាំបាច់ប៉ុន្មាននោះ យុទ្ធនាការកំណត់លក្ខណៈត្រូវធ្វើនៅកម្រិតគ្រួសារ និងទីលានចាក់សំរាម ដើម្បីកំណត់ប្រសិទ្ធភាពនៃការប្រមូលដោយអ្នករើសអេតចាយ និងតម្លៃនវត្ថុធាតុ អាចកែច្នៃបានដែលសេសសល់។

### ៤.៣.២. ជម្រើសទី ២៖ ដើរតួជាស្តង់អេតចាយ

មានឱកាសសម្រាប់មជ្ឈមណ្ឌលញែកសំរាមដើរតួជាស្តង់អេតចាយ។ ដើម្បីធ្វើដូច្នេះបាន វាចាំបាច់ត្រូវបំពាក់ដោយគ្រឿងម៉ាស៊ីនសមស្រប ដូចជាម៉ាស៊ីនបង្រួម និងស្វែងរកទីផ្សារដើម្បីនាំចេញដោយផ្ទាល់ទៅប្រទេសថៃ ឬប្រទេសវៀតណាម។

ដើម្បីធ្វើដូចនេះ កន្លែងទាញយកធនធាន នឹងត្រូវចាប់ផ្តើមទិញសំណល់រឹងពីអ្នករើសអេតចាយ។ ប្រាកដច្បាស់នោះ គឺវាជសមបំផុតដែលត្រូវទិញពីអ្នកលក់រើសអេតចាយនៅទីលានចាក់សំរាម ទោះយ៉ាងណាក៏ដោយវាមានបញ្ហាប្រឈមមួយដែលបច្ចុប្បន្នពួកគេមានតម្រូវឱ្យលក់ទៅស្តង់អេតចាយមួយចំនួន ដូច្នេះការដោះដូរនេះទាមទារនូវកិច្ចព្រមព្រៀងរវាងសាលាក្រុង ក្រុមហ៊ុនលៀប លឹម និងក្រុមហ៊ុនស៊ីន ទ្រី។

### ៤.៣.៣. ជម្រើសទី ៣៖ លក់ថង់ប្លាស្ទិកស្អាតសម្រាប់សិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង

ជម្រើសមួយទៀត គឺត្រូវទិញ សម្អាត និងលក់ថង់ប្លាស្ទិកទៅឱ្យសិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង។ បន្ទាប់ពីការប្តូរទីតាំងសិប្បកម្មនាពេលថ្មីៗនេះ ផលិតផលប្លាស្ទិកខេត្តបាត់ដំបងអាចជួយសម្រួលដល់ការបន្ថែមតម្លៃពីព្រោះកន្លែងទាញយកធនធានស្ថិតនៅក្នុងក្រុង។ សិប្បកម្មផលិតផលប្លាស្ទិកខេត្តបាត់ដំបងនឹងទទួលបានអត្ថប្រយោជន៍ពីការមានសំណល់រឹងស្អាតជាងមុន ហើយកន្លែងទាញយកធនធាន នឹងទទួលបានអត្ថប្រយោជន៍ដោយទទួលបានប្រាក់ចំណូលពីផលិតផលដែលជាងស្អាត។

ការណ៍នេះ តម្រូវឱ្យមានគ្រឿងម៉ាស៊ីន និងការដំឡើងសមត្ថភាពទីតាំងពីម្ចាស់ជំនួយ។ គួរកត់សម្គាល់ថា ដើម្បីអនុវត្តសកម្មភាពនេះ ត្រូវការប្រភពទឹកជាចាំបាច់។

មានគុណវិបត្តិដ៏មួយគឺថាសិប្បកម្មផលិតផលប្លាស្ទិកខេត្តបាត់ដំបងជាញឹកញយ ប្រមូលយកថង់ប្លាស្ទិកពីទីលានចាក់សំរាម។ វាមិនច្បាស់ទេថា តើអនុសាសន៍នេះគ្រាន់តែជាការនាំឱ្យកន្លែងទាញយកធនធានដើរតួជាឈ្មួញកណ្តាលដែលធ្វើឱ្យតម្លៃកើនឡើង។ យ៉ាងណាៗកិច្ចការនេះ អាស្រ័យលើការទាញយកធនធានពីថង់ប្លាស្ទិកជារួម ស្របជាមួយនឹងការធ្វើយុទ្ធនាការ។

### ៤.៣.៤. ជម្រើសទី ៤៖ ការកែច្នៃស្មៅ

ការធ្វើឱ្យប្រសើរដែលល្អឡើងជាងនេះទៀតនោះគឺកន្លែងទាញយកធនធាន បំពេញនូវចន្លោះខ្វះខាតហើយកែច្នៃសំរាមស្មៅ។ ចំនួននៃការធ្វើឱ្យប្រសើរគួរឱ្យកត់សម្គាល់មួយចំនួនគឺចាំបាច់រួមទាំងតម្រូវទីធ្លាបន្ថែមទៀត។ ខាងក្រោមនេះ គឺជាជម្រើសដែលអាចធ្វើបានដើម្បីការកែច្នៃស្មោះ៖

- **ការទាញយកធនធាន៖** នេះគឺជាជម្រើសបំប្លែងពីសំណល់ទៅថាមពល។ ស្មៅអាចត្រូវបានកំទេច និងលក់ជាទំរង់ប្រេងឥន្ធនៈ ដែលជាវិធីសាមញ្ញបំផុតក្នុងការកែច្នៃស្មៅ។
- **ការកែច្នៃឡើងវិញ៖** ការធ្វើឱ្យប្រសើរឡើងប្រភេទនេះតម្រូវឱ្យមានការកំទេច ការរំលាយ កំណាក និងការហូតវត្ថុ។
- **ការកែច្នៃឡើងវិញ៖** ការកែច្នៃមួយទៀតគឺគ្រាន់តែទាក់ទងនឹងការកំទេច ការរំលាយ កំណាក និងការដកហូតយកវត្ថុអ្វីមួយ។

បញ្ហាលំបាកជាមួយស្មោនោះ គឺវាមានដង់ស៊ីតេទាប ដូច្នេះការដឹកជញ្ជូនសម្រាប់ការកែច្នៃគឺថ្លៃណាស់។ ការនេះជាធម្មតាធ្វើឱ្យមានការលំបាកក្នុងការកំណត់គំរូអាជីវកម្មដែលល្អមួយ។ ទោះជាយ៉ាងណាក៏ដោយជាមួយនឹងទីលានចាក់សំរាមនៅជិត និងសមត្ថភាពក្នុងការញែកសំណល់រឹង នេះអាចជាជម្រើសមួយដែលគេចង់បាន។ លើសពីនេះទៀត វាមិនច្បាស់ទេថាតើទីតាំងទីលានចាក់សំរាមនៅកាន់តែឆ្ងាយ អាចធ្វើឱ្យមានករណីធ្វើអាជីវកម្មសម្រាប់ជម្រើសនេះ ឬយ៉ាងណា ប៉ុន្តែវាច្បាស់ណាស់ថាវានឹងពិបាកប្រសិនបើគ្មានការញែកវត្ថុធាតុនោះទេ។

## ៤.៣.៥. ជម្រើសទី ៥៖ ដំឡើងទៅជាកន្លែងកែច្នៃមួយកម្រិតទៀត ឬខ្សែសង្វាក់ញែកពេញលេញ

ជម្រើសមួយទៀតអាចដំឡើងទីតាំងញែកដើម្បីទាញយកធនធានឱ្យជាទៅខ្សែសង្វាក់ផ្គត់ផ្គង់ ដែលមានភាពល្អប្រសើរឡើង ដើម្បីសម្រួលដល់ដំណើរការញែក។ ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចនេះ ទីប្រឹក្សាបច្ចេកទេស បានកត់សម្គាល់ថាកន្លែងនោះមិនត្រូវបានបំពាក់ឧបករណ៍ ដើម្បីញែកសំណល់ប្រកបដោយប្រសិទ្ធភាពទេ (មានតែម៉ាស៊ីនគៀបមួយ ម៉ាស៊ីនកិនកែវមួយ ម៉ាស៊ីនភ្លើងមួយ និងឧបករណ៍ផ្ទុកមួយប៉ុណ្ណោះ)។ ដើម្បីបង្កើនប្រសិទ្ធភាពនៃការញែក ជាចាំបាច់ត្រូវវិនិយោគលើម៉ាស៊ីនញែក ឧបករណ៍បញ្ជូន តុសម្រាប់ដាក់សម្ភារៈញែក និងម៉ាស៊ីនរុញបញ្ជូន។ នេះនឹងអនុញ្ញាតឱ្យមានការញែកសំរាមមុនពេលយកទៅចាក់នៅទីលានចាក់សំរាម។ សេណារីយ៉ូនេះទាមទារការគាំទ្រពីម្ចាស់ជំនួយសម្រាប់ការវិនិយោគ ហើយក៏ទំនងជាត្រូវការការគាំទ្រពីអាជ្ញាធរមូលដ្ឋាន ដើម្បីឧបត្ថម្ភធនថ្លៃប្រតិបត្តិការផងដែរ។ វាអាចងាយស្រួលជាងមុន ក្នុងការតស៊ូមតិសុំការគាំទ្រដល់សេណារីយ៉ូនេះ នៅពេលដែលទីលានចាក់សំរាមថ្មីបើកដំណើរ ដែលការចំណាយលើការសម្អាតនឹងកើនឡើង។

ជម្រើសចុងក្រោយ គឺត្រូវផ្លាស់ប្តូរទាំងស្រុងឱ្យទៅជាប្រភេទកន្លែងមួយផ្សេងទៀតដែលបិទរង្វង់ផលិតកម្ម។ ជាជម្រើសមួយដែរនោះគឺផលិតផលិតផលប្លាស្ទិកដែលទិញពីសិប្បកម្មផលិតប្លាស្ទិកខេត្តបាត់ដំបង។ ទោះយ៉ាងណាក៏ដោយ អាចនឹងមិនមានកន្លែងគ្រប់គ្រាន់សម្រាប់សកម្មភាពបែបនេះទេ ហើយឧបត្ថម្ភធនខ្ពស់នឹងត្រូវការចាំបាច់ដើម្បីទិញឧបករណ៍បំពាក់ចំបាច់។

ម្យ៉ាងវិញទៀត កន្លែងសម្រាប់រៀបចំនេះអាចត្រូវបានធ្វើឡើងជាផ្នែកមួយរបស់អង្គការខមភីដ ( COMPED ) ឬកន្លែងកែច្នៃសំណល់សរីរាង្គជាច់ដោយឡែកមួយ ដែលអាចប្រើជាកន្លែងមួយសម្រាប់ធ្វើជីកំប៉ុស ដូចជាការធ្វើជីកំប៉ុសដោយប្រើជន្លេនជាដើម។ ជាថ្មីម្តងទៀត ជម្រើសនេះនឹងតម្រូវឱ្យមានឧបត្ថម្ភធនខ្ពស់ ទោះបីជាមានបរិមាណសំណល់សរីរាង្គដ៏ច្រើនដែលបង្កើតដោយក្រុងក៏ដោយ ព្រោះថាបើត្រូវការញែកសំរាមទាំងនោះទៀត ច្បាស់ជានឹងនាំឱ្យមានតម្រូវការកន្លែងកែច្នៃថែមទៀត ជាក់ជាពុំខាន ។



# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១៖ ឯកសារយោង


១៧ Triggers, Reducing Plastic Bag Waste in Major Cities of Cambodia Behavior Change Communication Campaign Market Research Report November ២០១៥

ADB Project Admin Manual, Kingdom of Cambodia: Greater Mekong Sub-Region Southern Economic Corridor Towns Development Project, November ២០១២

Allen, Cecilia, La Pintana, Chile: Prioritizing the Recovery of Vegetable Waste, June ២០១២

CDIA TA-៨៥៥៦: Pre-feasibility Studies for Second Tonle Sap Integrated Urban Management Project (៤៧២៨៥-០០១), ២០១៧

CDIA, Urban Environmental Infrastructure Improvement Project Report, August ២០១០

Climate and Clean Air Coalition Municipal Solid Waste Initiative, Solid waste management City Profile: Phitsanulok Municipality, Thailand, ២០១៤

Gokaldas, Virali, Mumbai, India: Waste Picker-Run Biogas Plants as a Decentralized Solution, June ២០១២

IGES, Participatory Waste Management Approach for Climate Change Mitigation: The Case of Battambang City, June ២០១៨

IGES/COMPED, Work Plan for Mitigating Short-Lived Climate Pollutants (SLCPs) from Landfills and Municipal Solid Waste - Cities Reducing Emissions Through Improved Waste Management in Battambang, Cambodia; IGES, Municipality of Battambang, and COMPED, February ២០១៧

IGES and UNEP, Planning and Implementation of Integrated Solid waste management Strategies at Local Level: The Case of Surabaya City, May ២០១៧

KAS, Deika on Solid waste management: A Case of Participatory Legislative Drafting at the Commune Level, ២០១៧

Lally, Pillippa et al, How are habits formed: Modelling habit for formation in the real world, European Journal of Social Psychology, ១៦ July ២០០៩

Sarintip Tantanee and Suthi Hantrakul, Municipal Waste Management Challenges of Urbanization: Lesson Learned from Phitsanulok, Thailand, January ២០១៩

SCE/Gret/Group Huit, ADB Tonle Sap Basin Feasibility Study, March ២០១៨

UNESCAP/Waste Concern, Valuing Waste, Transforming Cities, ២០១៥

## ឧបសម្ព័ន្ធទី ២៖ ការប្រជុំជាមួយភាគីពាក់ព័ន្ធ

| ស្ថាប័ន | បុគ្គល | កាលបរិច្ឆេទ | ប្រធានបទដែលពិភាក្សា |
|---|---|---|---|
| Green Move Consulting | នន់ សុផាន់ណា | ១០-ធ្នូ-១៨ | ការទាញយកធនធានពីសំណល់រឹង និង សហគ្រាសធុនតូចនិងមធ្យមនៅខេត្តបាត់ដំបង |
| COMPED ការិយាល័យភ្នំពេញ | សំ ផល្លា | ១១-ធ្នូ-១៨ | មជ្ឈមណ្ឌលកែច្នៃជីកំប៉ុស COMPED |
| BPP | ឆេង គឹមឆេង | ១២-ធ្នូ-១៨ | ដំណើរការមជ្ឈមណ្ឌលកែច្នៃថង់ប្លាស្ទិក និងទស្សនកិច្ចជុំវិញទីតាំង |
| ក្រុងបាត់ដំបង ក្រុមហ៊ុន លៀប លឹម ក្រុមហ៊ុន ស៊ីន ទ្រី និង មន្ទីរបរិស្ថានខេត្ត | ផ្សេងៗ | ១៣-ធ្នូ-១៨ | ណែនាំពីគម្រោង ដំណើរការរបស់ក្រុមហ៊ុន ស៊ីន ទ្រី និង លៀប លឹម ព្រមទាំងអនុសាសន៍សម្រាប់គម្រោង |
| មជ្ឈមណ្ឌលញែកសំរាម ( MRF ) | លៀប លឹម | ១៣-ធ្នូ-១៨ | ដំណើរការមជ្ឈមណ្ឌលញែកសំរាម និងទស្សនកិច្ចជុំវិញទីតាំង |
| ស្តង់អេតចាយតូចក្នុងខេត្តបាត់ដំបង | មិនមាន | ១៣-ធ្នូ-១៨ | តម្លៃនៃការចំណាយទៅលើអេតចាយ ការសម្ភាសន៍ជាមួយអេតចាយពីតំបន់ក្បែរៗនោះ |
| COMPED ខេត្តបាត់ដំបង | ចន ចេក | ១៣-ធ្នូ-១៨ | ដំណើរការមជ្ឈមណ្ឌលកែច្នៃជីកំប៉ុស និង ទស្សនកិច្ចជុំវិញទីតាំង |
| Plastic Free ប្រចាំខេត្តបាត់ដំបង | Kim Knoaa | ១៤-ធ្នូ-១៨ | ការអង្កេតនានាលើសេវាកម្មប្រមូលសំរាម អនុសាសន៍សម្រាប់ការប្រមូលទិន្នន័យ |
| ក្រុងបាត់ដំបង | ណយ ចេក | ១៤-ធ្នូ១៨ | ព័ត៌មានពីកិច្ចសន្យាក្រុមហ៊ុន លៀប លឹម និង ក្រុមហ៊ុន ស៊ីន ទ្រី |
| COrAA (Cambodian Organic Agriculture Association) | Chihoko SUZUSHIMA | ៩-មករា-១៩ | ស្វែងយល់ពី ការចុះឈ្មោះសមាជិកកសិកម្មសរីរាង្គ និង អំពីទីផ្សារជីកំប៉ុស |
| ក្រសួង កសិកម្ម | ផាន់ ប្រុស | ១១-មករា-១៩ | ស្វែងយល់ពីអ្នកធ្វើកសិកម្មសរីរាង្គនៅកម្ពុជា |
| ក្រសួង បរិស្ថាន | ដែក វិមានរស្មី | ១៤-មករា-១៩ | ស្វែងយល់ពីអនុវត្តច្បាប់នាពេលអនាគតលើអនុក្រឹតស្តីពីថង់ប្លាស្ទិក |
| FASMEC (Federation of SMEs) | លេស៊ីន រិទ្ធី<br>លី វិសាល<br>សូក ម៉ាន់នី | ១៤-មករា-១៩ | ស្វែងយល់ពីសហគ្រាសធុនតូច និង មធ្យម សម្រាប់ទីផ្សារជីកំប៉ុសនិងការកែច្នៃប្លាស្ទិក |
| KAS | Rober Hor | ១៦-មករា-១៩ | ស្វែងយល់ពីការរៀបចំធ្វើជីកា ( ច្បាប់កម្រិតសង្កាត់ ) ដោយ KASក្នុងក្រុងបាត់ដំបង |

| ស្ថាប័ន | បុគ្គល | កាលបរិច្ឆេទ | ប្រធានបទដែលពិភាក្សា |
|---|---|---|---|
| ADB | សន រដ្ឋា | Email អ៊ីម៉ែល | សមិទ្ធិលទ្ធភាពនៃ មជ្ឈមណ្ឌលញែកសំរាម និង ការរៀបចំ |
| UNIDO GGGI និង ក្រសួងបរិស្ថាន (នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់) | ផ្សេងៗ | ១៣-កុម្ភៈ-១៩ | ការរៀបចម្ការអនុវត្តសាកល្បង |
| AIMS – ខេត្តបាត់ដំបង | គឹម ហួត<br>អ៊ាង បញ្ញាភារៈ លុយ សុភា | ២១-កុម្ភៈ-១៩ | ស្វែងយល់ពី ទីផ្សារដឹកពុំសក្នុងខេត្តបាត់ដំបង តសាកល្បង្ញើដឹកា (ច្បាប់កំរិតសង្កាត់) ដោយលប៉ុសនិងការកែច្នៃប្លាស្ទិច |
| ក្រុមហ៊ុន ស៊ីន ទ្រី សាខាខេត្តបាត់ដំបង | ឡុង ភីឌីអូន | ២២-កុម្ភៈ-១៩ | ស្វែងយល់ពីសេវាកម្មប្រមូលសំរាមក្នុងសាលាក្រុង នាពេលបច្ចុប្បន្ន |
| ក្រសួងបរិស្ថាន (នាយកដ្ឋានអប់រំបរិស្ថាន) | ផ្សេងៗ | ១-កុម្ភៈ-១៩ | ស្វែងយល់ពីការរៀបចំ យុទ្ធនាការផ្សព្វផ្សាយ និងផែនការសម្រាប់ក្រុងបាត់ដំបង |
| GoGreen Cambodia | Natalya Rodionova | ១-មីនា-១៩ | ស្វែងយល់ពីកម្មវិធី GoGreen Cambodia និងផែនការនាពេលអនាគត |
| សភាពាណិជ្ជកម្មកម្ពុជា | មិនអាចទាក់ទងបាន តែបានប្រើប្រាស់វេបសាយ សម្រាប់ជាឯកសារយោង https://www.ccc.org.kh/ | | ស្វែងយល់ពីទីផ្សារសក្តានុពលសម្រាប់គ្រាប់ជ័រដែលបានកែច្នៃពីថង់ប្លាស្ទិក |

## ឧបសម្ព័នទី ៣៖ សកម្មភាពដែលបានធ្វើកំឡុងពេលដើរប្រមូលទិន្នន័យ

| ល.រ | ប្រភពទិន្នន័យ | វិធីសាស្ត្រ | ចំនួនសំណាក |
|---|---|---|---|
| I. | **អាជ្ញាធរមូលដ្ឋាន** | | |
| | ចៅសង្កាត់ | ការសម្ភាស | ១០ |
| II. | **ផ្សារទាំង៥ (ផ្សារបឹងឈូក ផ្សារភូពុយ ផ្សារណាត់ ផ្សារលើ និង ផ្សារថ្មី)** | | |
| | អ្នកគ្រប់គ្រងផ្សារ | ការសម្ភាស | ៥ |
| | អ្នកអនាម័យផ្សារ | ការសម្ភាស | ៥ |
| | សេវាកម្មប្រមូលសំរាមផ្សារ | ការសម្ភាស | ៤ |

| | | | |
|---|---|---|---|
| III. | **មជ្ឈមណ្ឌលកែច្នៃសំណល់រឹង** | | |
| | សហគ្រាសកែច្នៃថង់ប្លាស្ទិក | ការប្រជុំ | ១ |
| IV. | **អ្នករើសអេតចាយ** | | |
| | អ្នករើសអេតចាយនៅទីលាន (អញ្ជើញអ្នកចូលរួម៨នាក់) | ការពិភាក្សាជាក្រុម | ១ |
| | អ្នករើសអេតចាយនៅទីលាន | ការសម្ភាស | ៨ |
| | អ្នករើសអេតចាយនៅជុំវិញសាលាក្រុង | ការសម្ភាស | ១០ |
| V. | **ស្តង់ទិញលក់អេតចាយ** | | |
| | ស្តង់ធំដែលនាំចេញទៅក្រៅប្រទេស | ការសម្ភាស | ១ |
| | ស្តង់ទំហំមធ្យម | ការសម្ភាស | ១ |
| | ស្តង់ទំហំតូច | ការសម្ភាស | ២ |
| VI. | **ភាគីពាក់ព័ន្ធផ្សេងទៀត** | | |
| | អង្គការ Bareebo និង Kleine Hilfsaktion- អ្នកបង្កើតកសិដ្ឋានសរីរាង្គនៅក្បែរសាលាក្រុង | តេទូរស័ព្ទ | ១ |
| | Plastic Free ប្រចាំខេត្តបាត់ដំបង | ការប្រជុំ | ១ |
| | មន្ទីរកសិកម្មខេត្ត | ការប្រជុំ | ១ |
| | បណ្តាញយុវជនប្រចាំខេត្តបាត់ដំបង (អញ្ជើញអ្នកចូលរួម៤នាក់) | ការពិភាក្សាជាក្រុម | ១ |
| | ក្រុមស្រ្តី (អញ្ជើញអ្នកចូលរួម៧នាក់ពីបណ្តាញអង្គការបន្ទាយស្រី) | ការពិភាក្សាជាក្រុម | ១ |
| VII. | **ការធ្វើផែនទី ធុងសំរាមសាធារណៈ** | ការកំណត់ទីតាំង GPS | ១ |

## ឧបសម្ព័ន្ធទី ៤៖ ថ្លៃសេវាប្រមូលសំរាម[៤៣]

| ល.រ | ពណ៌នា | តម្លៃ |
|---|---|---|
| **ក. ផ្ទះល្វែង** | | |
| ១ | ផ្ទះល្វែងក្រោម (EO) | ១.0 ដុល្លារ |
| ២ | ផ្ទះល្វែងលើ ចាប់ពីជាន់ទី ១ឡើង | 0.៥ ដុល្លារ |
| **ខ. ផ្ទះប្រកបអាជីវកម្ម** | | |
| ៣ | ផ្ទះល្វែងក្រោមប្រកបអាជីវកម្ម (EO) | ២.0 ដុល្លារ |
| ៤ | ផ្ទះល្វែងក្រោមប្រកបអាជីវកម្ម ចាប់ពី ២ល្វែងឡើង | ៥.0 ដុល្លារ |
| ៥ | ផ្ទះលើកស្លាកក្រុមហ៊ុន | ១0.0 ដុល្លារ |
| ៦ | ភូមិគ្រឹះ | ៥.0 ដុល្លារ |
| ៧ | ភូមិគ្រឹះជួលឱ្យបរទេស | ១0.0 ដុល្លារ |
| **គ. ភោជនីយដ្ឋាន** | | |
| ៨ | ភោជនីយដ្ឋាន | ២0.0 ដុល្លារ |
| ៩ | ខារ៉ាអូខេ | ២0.0 ដុល្លារ |
| ១0 | អាហារដ្ឋាន | ១0.0 ដុល្លារ |
| ១១ | រោងភាពយន្ត | ១0.0 ដុល្លារ |
| ១២ | សិប្បកម្ម | ១0.0 ដុល្លារ |
| ១៣ | ស្ថានីយ៍ប្រេងឥន្ធនៈ | ១0.0 ដុល្លារ |
| ១៤ | កន្លែងលាងរថយន្ត និង ម៉ូតូ | ១0.0 ដុល្លារ |
| ១៥ | កន្លែងលាងម៉ូតូ | ៥.0 ដុល្លារ |
| ១៦ | ចំណតរថយន្ត | ២0.0 ដុល្លារ |
| ១៧ | ចំណតរថយន្តក្រុមហ៊ុន | ២0.0 ដុល្លារ |

[៤៣] ថ្លៃសេវាប្រមូលនិងដឹកជញ្ជូនប្រចាំខែចេញនៅខែមករាឆ្នាំ២00៧ ដោយអភិបាលខេត្ត និងក្រុង

| ឃ. សណ្ឋាគារ | | |
|---|---|---|
| ១៨ | សណ្ឋាគារចាប់ពី ៣០ បន្ទប់ចុះ | ២០.០ ដុល្លារ |
| ១៩ | សណ្ឋាគារចាប់ពី ៣០ បន្ទប់ឡើង | ៥០.០ ដុល្លារ |
| ២០ | ផ្ទះសំណាក់ចាប់ពី ២០ បន្ទប់ចុះ | ១០.០ ដុល្លារ |
| ២១ | ផ្ទះសំណាក់ចាប់ពី ២០ បន្ទប់ឡើង | ២០.០ ដុល្លារ |
| ២២ | គ្រឹះស្ថានរដ្ឋបាល | ១.០ ដុល្លារ |
| ២៣ | សាលារៀនរដ្ឋ | ១.០ ដុល្លារ |
| ២៤ | សាលារៀនឯកជន | ១០.០ ដុល្លារ |
| ២៥ | គ្លីនីកឯកជន | ១០.០ ដុល្លារ |
| ២៦ | ធនាគារឯកជន | ១០.០ ដុល្លារ |
| ២៧ | ធនាគារជាតិ | ១.០ ដុល្លារ |
| ២៨ | ផ្សព្វផ្សាយពាណិជ្ជកម្មក្រុមហ៊ុន (មួយយប់) | ៣០.០ ដុល្លារ |
| ង. ផ្សារ | | |
| ២៩ | ចាបពី ២០០រៀលប្រចាំថ្ងៃក្នុងមុខរបរនីមួយៗ និងអ្នកលក់តាមទីសាធារណៈ | |

| I.៤ | បុគ្គលិកផ្នែកប្រតិបត្តិការ | ១៣ | រួមមាន អ្នកបើកបរ និង ជាង ជាដើម |
|---|---|---|---|
| I.៥ | កម្មករបោស | ១៣ | បោសនិងប្រមូលសំរាមនៅតាមសួនសាធារណៈ |
| I.៦ | កម្មករកើប | ២៩ | មកជាមួយនឹងឡានប្រមូល ដើម្បីចូកសំរាមដាក់ក្នុងឡាន |
| II. | **រថយន្ត** | | |
| II.១ | រថយន្ត ១១ តោន | ២ | ប្រមូល និង ដឹកជញ្ជូនសំរាម |
| II.២ | រថយន្ត ៥ តោន | ១០ | ប្រមូល និង ដឹកជញ្ជូនសំរាម |
| II.៣ | រថយន្ត ១.៥ តោន | ១ | ដឹកប្រេងទៅទីលាន |

| | | | |
|---|---|---|---|
| II.៤ | រថយន្ត ១៦ តោន | ១ | ដឹកដីទៅទីលាន |
| II.៥ | Bulldozer- D៣០ | ១ | ប្រតិបត្តិការនៅទីលាន |
| II.៦ | Bulldozer- D៥០ | ១ | ប្រតិបត្តិការនៅទីលាន |
| **III.** | **ផ្សេងៗ** | | |
| III.១ | រទេះអូស | ៣ | បោស និង ប្រមូល សំណល់រឹង |
| III.២ | ធុងកម្មករបោស | ១៥ | បោស និង ប្រមូល សំណល់រឹង |

## ឧបសម្ព័ន្ធទី ៥៖ បញ្ជីវត្តមាន នៅថ្ងៃសិក្ខាសាលាជាមួយភាគីពាក់ព័ន្ធក្នុង ខែឧសភា ឆ្នាំ ២០១៩

Global Green Growth Institute

សិក្ខាសាលា៖ គំរូអាជីវកម្ម សម្រាប់ខ្សែសង្វាក់ផលិតកម្មកែច្នៃសំណល់រឹងប្រកបដោយចីរភាព
ដោយផ្តោតសំខាន់លើ សំណល់ប្លាស្ទិកនិងសំណល់សរីរាង្គ

បញ្ជីវត្តមាន
ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩
ទីកន្លែង៖ សណ្ឋាគារខេមរាបាត់ដំបង១

| ល.រ | ឈ្មោះ | តួនាទី | ស្ថាប័ន |
|---|---|---|---|
| ១ | Thin Phalla | ទីប្រឹក្សា | សង្កាត់រតនៈ |
| ២ | Ear Kim Cheng | អនុប្រធានមន្ទីរ | មន្ទីរបរិស្ថានខេត្ត |
| ៣ | Moeun Vibol | ជំទប់ទី មួយ | សង្កាត់អូរចារ |
| ៤ | Che Chhorn | ជំទប់ទី ពីរ | សង្កាត់ទួលតាឯក |
| ៥ | Phoung Samoeun | មន្ត្រី | ក្រសួងមហាផ្ទៃ |
| ៦ | Hok Kimseng | មន្ត្រី | ក្រសួងមហាផ្ទៃ |
| ៧ | Aing Kimseang | មន្ត្រីទិន្នន័យ | GRET |

| | | | |
|---|---|---|---|
| ៨ | Et Sothea | ភាស៊ី | ផ្សារណាត់ |
| ៩ | Nim Sour | អ្នកសម្របសម្រួល | GIZ/DAR |
| ១០ | Soeung LyLy | មន្ត្រី | DGE/GSSD |
| ១១ | Oeurn Phanavit | មន្ត្រីរដ្ឋបាល | DGE/GSSD |
| ១២ | Teang Sovoeung | ទីប្រឹក្សា | សង្កាត់ស្លាកែត |
| ១៣ | Khorm Sakhorn | អ្នកបកប្រែ | Big taxt |
| ១៤ | Phon Theoun | ជំនួយការអ្នកបកប្រែ | Big taxt |
| ១៥ | E Vuthy | DSG | NCSO |
| ១៦ | Sout Samdy | មន្ត្រី | GGGI |
| ១៧ | Delasal | ប្រធាន | SAMATOA |
| ១៨ | Kim KNORR | BTB Kad | PFC |
| ១៩ | MARCUSWOLL | ប្រធាន | NEARADEI NGO |
| ២០ | Tith Rotha | ជំនួយការ | សាលាក្រុង |
| ២១ | Beu Sok Thoeut | ទីប្រឹក្សា | សង្កាត់វត្តគរ |
| ២២ | Oeun Panhaneat | អនុប្រធាននាយកដ្ឋាន | GSSD |
| ២៣ | Nout Nivann | ប្រធាន | មន្ទីរកសិកម្មបាត់ដំបង |
| ២៤ | Long Pidi oun | ប្រធានសាខា | ក្រុមហ៊ុន ស៊ីន ទ្រី |
| ២៥ | Peng Sopheap | ទីប្រឹក្សា | |
| ២៦ | Karolien Casaer | តំណាងប្រចាំប្រទេស | GGGI |
| ២៧ | Soeun Chamrong | ការិយាល័យសោភ័ណភាពក្រុងនិងគ្រប់គ្រងសំណល់រឹង | សាលាក្រុង |
| ២៨ | Dek Vimeanreaksmey | អនុប្រធាននាយកដ្ឋាន | ក្រសួងបរិស្ថាន |
| ២៩ | Chin Somaly | ទីប្រឹក្សា | សង្កាត់ព្រែកព្រះស្តេច |
| ៣០ | Sary Mithuna | សិស្ស | បណ្ណញយុវជនខេត្តបាត់ដំបង |
| ៣១ | Mey Phavorn | សិស្ស | បណ្ណញយុវជនខេត្តបាត់ដំបង |
| ៣២ | Sou Ara H’vatt | អភិបាលខេត្ត | |

| | | | |
|---|---|---|---|
| ៣៣ | Noy Chek | ប្រធានការិយាល័យ | សាលាក្រុង |
| ៣៤ | Sean Bophaphal | ជំនួយការ | Comped |
| ៣៥ | Prak Monita | រដ្ឋបាល | GRET |
| ៣៦ | Em Oeurn | ទីប្រឹក្សា | សង្កាត់ស្វាយប៉ោ |
| ៣៧ | Erm Si Yoeun | ជំទប់ទី ១ | សង្កាត់ក្តុលដុលទាវ |
| ៣៨ | Yart Pok | ទីប្រឹក្សា | សង្កាត់អូម៉ាល់ |
| ៣៩ | Seng Siri ratanak | ប្រធាន | ផ្សារលើ |
| ៤០ | Leap Lim | ប្រធាន | ក្រុមហ៊ុន លៀប លឹម |
| ៤១ | Touch Sokharith | ប្រធានគម្រោង | GRET ខេត្តសៀមរាប |
| ៤២ | Terra Michaels | ជំនួយការបច្ចេកទេស | GRET |
| ៤៣ | Sean Phivan | ប្រធាន | ផ្សារបឹងឈូក |
| ៤៤ | Hoeun Deou | អភិបាលរង | សាលាក្រុងបាត់ដំបង |
| ៤៥ | Som Rie | ប្រធាន | ផ្សារណាត់ |
| ៤៦ | Thit Metchorra | ប្រធាននាយកដ្ឋាន | UNIDO |
| ៤៧ | Tem Sokchan | រដ្ឋបាល | |



Supported by

GGGI

Follow our activities
On Facebook and Twitter

www.gggi.org